ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

# ព្រះពុទ្ធសាសនា ឆ្លើយតបអំពើហិង្សាលើកុមារ



សម្រាប់
ពុទ្ធិកសិក្សាថ្នាក់បរិញ្ញាបត្រ

ពិនិត្យដោយ
ក្រសួងធម្មការ និងសាសនា និង អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

ព.ស. ២៥៦១ រក្សាសិទ្ធិ គ.ស. ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការ និងសាសនា

# ព្រះពុទ្ធសាសនា ឆ្លើយតបអំពើហិង្សាលើកុមារ

សម្រាប់

ពុទ្ធិកសិក្សាថ្នាក់បរិញ្ញាបត្រ

ពិនិត្យដោយ

ក្រសួងធម្មការ និងសាសនា និង អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

# អារម្ភកថា

*អំពើហិង្សាលើកុមារ ជាបញ្ហាដ៏ធំមួយក្នុងចំណោមបញ្ហាដ៏ធំដទៃទៀត ដែលបានកើតឡើងនៅលើពិភពលោក និងព្រះរាជាណាចក្រកម្ពុជាទាំងមូល។*

*និយាយជារួម នៅលើពិភពលោកនេះ គ្មានប្រទេសណាមួយអាចចៀសផុតពីអំពើហិង្សាលើកុមារឡើយ គ្រាន់តែតិចហើយនិងច្រើន។ ប្រទេសខ្លះមានអត្រាតិច ឯប្រទេសខ្លះទៀតមានចំនួនច្រើន។ កុមារជាង២លាននាក់ស្លាប់អំឡុងពេល១០ឆ្នាំចុងក្រោយដោយសារសង្គ្រាម។ កុមារ១០លាននាក់លើពិភពលោក មានបញ្ហាផ្លូវចិត្ត ដ៏ធ្ងន់ធ្ងរជាលទ្ធផលនៃសង្គ្រាម ហើយកុមារ ៣០លាននាក់រស់នៅក្នុងតំបន់សង្គ្រាម។ ក្រៅពីនេះ កុមារអាយុក្រោម១៥ឆ្នាំ ត្រូវបានគេជួលឱ្យធ្វើទាហាននៅក្នុងប្រទេស២៦ ក្នុងចំណោមប្រទេសជាសមាជិកអង្គការសហប្រជាជាតិ។*

*ដោយឡែក ព្រះរាជាណាចក្រកម្ពុជាក៏កំពុងតែប្រឈមនូវបញ្ហាទាំងនេះយ៉ាង ធ្ងន់ធ្ងរផងដែរ។ កុមារី៤២% នៅក្នុងប្រទេសកម្ពុជា ជួបប្រទះនូវអំពើហិង្សាក្នុងវ័យកំពុង លូតលាស់ តាមប្រភេទនៃអំពើហិង្សា។ ៥០% ជួបប្រទះហិង្សាផ្លូវកាយ, ២០% ជួបប្រទះហិង្សាផ្លូវចិត្ត, ៤% ជួបប្រទះហិង្សាផ្លូវភេទ និង១៦% ជួបប្រទះហិង្សាលើសមួយទម្រង់។ ចំណែកឯកុមារាវិញ ៤១% ជួបប្រទះហិង្សាក្នុងវ័យកំពុងលូតលាស់ តាមប្រភេទនៃអំពើហិង្សា, ៥០% ជួបប្រទះហិង្សាផ្លូវកាយ, ២៥% ជួបប្រទះហិង្សាផ្លូវចិត្ត, ៦% ជួបប្រទះហិង្សាភេទ និង២០% ជួបប្រទះហិង្សាលើសមួយទម្រង់។ ក្រៅពីនោះ កុមារត្រូវបានគេប្រើប្រាស់ និងកេងប្រវ័ញ្ចអស់ជាច្រើនសតវត្សមកហើយ។ បទពិសោធន៍បង្ហាញឱ្យឃើញថា កុមារជួបប្រទះក្តីអស់សង្ឃឹម ប្រឈមនឹងស្ថានភាពដ៏គ្រោះថ្នាក់ (**ទុក្ខសច្ច**)។*

*បញ្ហាទាំងនេះ កើតឡើងដោយមានមូលហេតុជាច្រើនដែលហៅថា **សមុទយសច្ចៈ**។ ហេតុនាំឱ្យមានអំពើហិង្សាកុមារនេះដោយរួមមានៈ កង្វះការអប់រំ កង្វះមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម និងអកុសលមូលទាំងបីគឺ លោភៈ ទោសៈ និងមោហៈ ស្ថិតក្នុងផ្នត់គំនិតរបស់មនុស្សមួយចំនួនទាំងអាណាព្យាបាល ទាំងមនុស្សទូទៅ។*

*អ្វីដែលយើងចង់បាន គឺចង់ឃើញកុមារទូទាំងពិភពលោកទាំងមូល រួមទាំងកុមារកម្ពុជាផងរួចចាកអំពើហិង្សា។ ការមិនមានអំពើហិង្សាលើកុមារជាប្រភពនៃការរីកចម្រើនលើស្មារតី និងវិចារណញ្ញាណរបស់មនុស្សជាតិ និងជាប្រភពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ (**និរោធសច្ច**)។*

ដើម្បីទទួលបានសមិទ្ធផលទាំងនេះ ទាមទារឱ្យមានយន្តការចូលរួមជាពហុវិស័យ ជាពិសេស ការអប់រំតាមបែបព្រះពុទ្ធសាសនានិងការអនុវត្តច្បាប់ ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ(**មគ្គសច្ច**)។

ក្នុងន័យនេះ អត្ថបទស្ដីពីព្រះពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារ ដែលបានបញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររួចហើយនេះ ពិតជារួមវិភាគក្នុងជ្រុងណាមួយ សម្រាប់បង្ការ ទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារជាក់ជាមិនខាន។

ខ្ញុំព្រះករុណា អាត្មាភាព សង្ឃឹមថា សាស្ត្រាចារ្យគ្រប់រូបដែលមានចំណេះដឹង បទពិសោធន៍ និងទេពកោសល្យគ្រប់គ្រាន់ទាំងខាងពុទ្ធចក្រនិងអាណាចក្រ នឹងផ្ទេរចំណេះដឹងនិងទស្សនាទាន នៃអត្ថបទស្ដីពីព្រះពុទ្ធសាសនាឆ្លើយតបអំពើហិង្សា លើកុមារដល់សមណនិស្សិត និស្សិតប្រកបដោយជោគជ័យ។ ចំណែកឯសមណនិស្សិត និស្សិតដែលបានទទួលចំណេះដឹងស្ដីពីការឆ្លើយតបអំពើហិង្សាលើកុមារហើយ នឹងធ្វើជាគំរូនិងផ្សព្វ ផ្សាយដល់ពុទ្ធបរិស័ទ និងឥរិយាបថសង្គមឱ្យផ្លាស់ប្តូរពីឥរិយាបថ អវិជ្ជមានទៅរកឥរិយាបថវិជ្ជមាន ពោលគឺមិនប្រព្រឹត្តអំពើហិង្សាលើកុមារ។ សូមថ្លែងអំណរគុណដល់អង្គការ UNICEF ដែលបានជួយទាំងថវិកា និងបច្ចេកទេស ក្នុងការនិពន្ធសៀវភៅនេះឱ្យចេញជារូបរាងឡើង។

សូមឱ្យកុមារខ្មែរ និងកុមារនៅលើពិភពលោក រួចផុតពីអំពើហិង្សា។

សូមឱ្យសុខសន្តិភាព ប្រតិស្ឋានក្នុងសង្គមខ្មែរ និងលើពិភពលោកទាំងមូល។

ព្រះសុមេធវង្ស បណ្ឌិត **សុខ ប៊ុនធឿន**

ព្រះប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា

នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្រសួងធម្មការ និងសាសនា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការ និង សាសនា
អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
លេខ : ១៣៩៥/១៧ អ.ព.ស.ជ

## និវេទនកថា

និយាយជារួម ព្រះពុទ្ធសាសនា ជាសាសនាមួយបានលើកកម្ពស់យ៉ាងខ្លាំងដល់កាតព្វកិច្ចលើកុមារដែលមានបញ្ជាក់ក្នុងសង្គហធម៌របស់មាតាបិតាចំពោះបុត្រ និងព្រហ្មវិហារធម៌ទាំងបួនជាដើម។ និយាយដោយឡែក អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិកុមារ បានសហការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដោយបានបង្កើតកម្មវិធីសិក្សាបញ្ចូលមេរៀនព្រះពុទ្ធសាសនាដើម្បីផ្តល់ចំណេះដឹង និងផ្ទេរចំណេះដឹងដល់សមណនិស្សិត និស្សិត និងពុទ្ធបរិស័ទក្នុងការលើកកម្ពស់ការយកចិត្តទុកដាក់ខ្ពស់ពីមាតាបិតា ក្រុមគ្រួសារ សហគមន៍និងសង្គមចំពោះកុមារកម្ពុជាទាំងមូល។

សៀវភៅស្តីពី «ពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារ» គឺជាឧបករណ៍និងឯកសារដ៏មានតម្លៃសម្រាប់ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារធ្វើយ៉ាងណាឱ្យកុមារកម្ពុជាជៀសផុតពីអំពើហិង្សា។ មេរៀននេះ ពិតជាមេរៀនដែលបង្កើតឡើងដោយមានខ្លឹមសារចម្រុះរវាងទ្រឹស្តីព្រះពុទ្ធសាសនា ច្បាប់ជាតិនិងច្បាប់អន្តរជាតិក្នុងការធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិកុមារ។

កុមារ គឺជាទំពាំងស្នងឬស្សីមិនអាចខ្វះបានសម្រាប់គ្រួសារ ព្រះពុទ្ធសាសនា និងសង្គមជាតិ។ កុមារ ត្រូវតែមានសុខភាពល្អ៤ប្រការគឺ សុខភាពផ្លូវកាយ សុខភាពខួរក្បាល សុខភាពស្មារតី និងសុខភាពផ្លូវចិត្ត។ ដើម្បីសម្រេចតាមវត្ថុបំណងទាំងនេះ កុមារត្រូវតែជៀសផុតពីអំពើហិង្សា។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិជឿជាក់ថា មេរៀននេះ ពិតជារួមចំណែកយ៉ាងធំធេងក្នុងការបញ្ជ្រាបចំណេះដឹងនិងអនុវត្តបានទូលំទូលាយក្នុងការឆ្លើយហិង្សាលើកុមារនៅកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃ ។ ឆ្នាំរកា..នព្វស័ក ព.ស.២៥៦១

ត្រូវនឹងថ្ងៃទី០៦...ខែតុលា.....ឆ្នាំ២០១៧

**អគ្គាធិការពុទ្ធិកសិក្សា**
**អគ្គាធិការរង**

សាស្ត្រាចារ្យ ទំ .ឈឹមហេង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការ និង សាសនា**
**លេខ** ៦៦/១៧ **ក.ធ.ស**/ប្រ.ក

រាជធានីភ្នំពេញថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៧

## ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សៀវភៅ
## ពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារក្នុងកម្មវិធីពុទ្ធិកសិក្សាថ្នាក់បរិញ្ញាបត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/១៩ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- យោងអនុក្រឹត្យលេខ ១៥៤អនក្រ.បក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងប្រកាសលេខ ៦៤៩/១១ ក.ធ.ស.ប្រក.ចុះថ្ងៃទី២០ ខែកញ្ញាឆ្នាំ២០១១ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធរបស់ការិយាល័យថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងចំណុះផ្នែកនានាក្រោមឱវាទ អង្គភាពអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា
- យោងប្រកាសលេខ ០៨៧/១៥ ក.ធ.ស.ប្រក ចុះថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការរៀបចំមេរៀនការទប់ស្កាត់អំពើហិង្សាលើកុមារក្នុងកម្មវិធីសិក្សាទាំងបីកំរិត
- យោងប្រកាសលេខ ៣៦/១៦ក.ធ.ស.ប្រក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីពុទ្ធិកសិក្សាថ្នាក់បរិញ្ញាបត្រ

## សម្រេច

**ប្រការ១** ដាក់ឱ្យប្រើប្រាស់ **សៀវភៅពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារ** ក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រនៅគ្រប់គ្រឹះស្ថានពុទ្ធិកឧត្តមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២** ខុទ្ទកាល័យ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានកិច្ចការសាសនា ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិឧត្តមសិក្សា គ្រឹះស្ថានពុទ្ធិកឧត្តមសិក្សានិងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៣** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន-ជូន**
-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- គណៈសង្ឃនាយក
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  ដើម្បីថ្វាយ-ជូនជ្រាប
- ពុទ្ធិកសាកលវិទ្យាល័យ
- ដើម្បីអនុវត្ត
-ឯកសារ កាលប្បវត្តិ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

**ហ៊ឹម ឆែម**


# 393, តិរវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីមែល : ministry religion@yahoo.com Web site : www.mocar.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ០៤០៧/១៥ ក.ធ.ស/ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំមេរៀន ការទប់ស្កាត់អំពើហិង្សាលើកុមារ ក្នុងកម្មវិធីពុទ្ធិកសិក្សាទាំង៣កម្រិត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- យោងអនុក្រឹត្យលេខ១៥៤ អនក្រ បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

**សម្រេច**

**ប្រការ ១** : បង្កើតគណៈកម្មការរៀបចំមេរៀន ( ការទប់ស្កាត់អំពើហិង្សាលើកុមារ )ក្នុងកម្មវិធីពុទ្ធិកសិក្សាទាំង៣កម្រិត ដែលមានសមាសភាព ដូចខាងក្រោម៖

I- **គណៈកម្មការកណ្តាល**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមបណ្ឌិត មិន ឃិន | រដ្ឋមន្ត្រី | ប្រធាន |
| ២- | សម្តេចព្រះមហាសុមេធាធិបតីនន្ទ ង៉ែត | ព្រះអគ្គាធិការ | អនុប្រធាន |
| ៣- | សម្តេចព្រះពោធិវង្ស អ៊ំ លឹមហេង | ព្រះអគ្គាធិការរង | អនុប្រធាន |
| ៤- | ព្រះសំវរៈវិជ្ជា សុខ ប៊ុនធឿន | ប្រធានផ្នែក | សមាជិកអចិន្ត្រៃយ៍ |
| ៥- | ព្រះញាណវិជ្ជា ជួន សាវឿន | សាកលវិទ្យាធិការរង | សមាជិក |
| ៦- | ព្រះសិរីសម្មតិវង្ស លន់ សុគន្ធា | ប្រធានផ្នែក | សមាជិក |
| ៧- | ព្រះឃោសធម្ម រៀម សុភ័ក្រ | ប្រធានផ្នែក | សមាជិក |
| ៨ | តំណាងក្រសួងអប់រំយុវជននិងកីឡា | | សមាជិក |
| ៩- | តំណាងអង្គការយូនីសេហ្វ | | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចកោះប្រជុំគ្រប់គណៈកម្មការ ដែលនាំការរៀបចំមេរៀន ដោះស្រាយតម្រូវការនានារបស់គណៈកម្មការនីមួយៗ ពិនិត្យនិងសម្រេចដាក់ឱ្យប្រើប្រាស់។

II- **គណៈកម្មការនិពន្ធកម្រិតឧត្តមសិក្សា**

| | | |
|---|---|---|
| ១- លោក ហ៊ឹង ហ៊ាន | សាកលវិទ្យាធិការរង | ប្រធាន |
| ២- ព្រះឧត្តមភិក្ខុ [illegible] | សាកលវិទ្យាធិការ | អនុប្រធាន |
| ៣- លោកស្រី [illegible] | សាកលវិទ្យាធិការរង | សមាជិក |
| ៤- លោក [illegible] | គ្រូបង្រៀន | សមាជិក |
| ៥- ព្រះវិន័យធរ [illegible] | អនុប្រធានផ្នែក | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការស្រាវជ្រាវសរសេរ រៀបចំមាតិកាមេរៀន [illegible] កម្រិតឧត្តម។

III- **គណៈកម្មការនិពន្ធកម្រិតមធ្យមសិក្សា**

**ក. កម្រិតមធ្យមសិក្សាទុតិយភូមិ**

| | | |
|---|---|---|
| ១- [illegible] | គ្រូបង្រៀន | ប្រធាន |
| ២- លោក [illegible] | គ្រូបង្រៀន | អនុប្រធាន |
| ៣- លោក [illegible] | អនុប្រធានផ្នែក | សមាជិក |
| ៤- ព្រះមហា [illegible] | ប្រធានការិយាល័យ | សមាជិក |
| ៥- លោកស្រី [illegible] | ប្រធានការិយាល័យ | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការស្រាវជ្រាវសរសេរ រៀបចំមាតិកាមេរៀន [illegible] កម្រិតមធ្យមសិក្សាទុតិយភូមិ។

**ខ. កម្រិតមធ្យមសិក្សាបឋមភូមិ**

| | | |
|---|---|---|
| ១- ព្រះសិរីមុនី [illegible] | [illegible] | ប្រធាន |
| ២- [illegible] | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៣- លោក [illegible] | គ្រូបង្រៀន | សមាជិក |
| ៤- លោក [illegible] | អនុប្រធានផ្នែក | សមាជិក |
| ៥- ព្រះមហា [illegible] | អនុប្រធានការិយាល័យ | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការស្រាវជ្រាវសរសេរ រៀបចំមាតិកាមេរៀន [illegible] កម្រិតមធ្យមសិក្សាបឋមភូមិ។

IV- **គណៈកម្មការនិពន្ធកម្រិតបឋមសិក្សា**

| | | |
|---|---|---|
| ១- លោក [illegible] | អនុប្រធានផ្នែក | ប្រធាន |
| ២- ព្រះមហា [illegible] | អនុប្រធានផ្នែក | អនុប្រធាន |
| ៣- លោក [illegible] | អនុប្រធានផ្នែក | សមាជិក |
| ៤- លោក [illegible] | គ្រូ | សមាជិក |
| ៥- លោក [illegible] | គ្រូ | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការស្រាវជ្រាវសរសេរ រៀបចំជាក្រងមេរៀន ការទប់ស្កាត់អំពើហិង្សាលើកុមារ ចូលក្នុងកម្មវិធីពុទ្ធិកសិក្សាកម្រិតបឋមសិក្សា។

V- **គណៈកម្មការត្រួតពិនិត្យ**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមបណ្ឌិត មិន ឃិន | រដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តមបណ្ឌិត សេង សុមុនី | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ព្រះសំរេះវិជ្ជា សុខ ប៊ុនធឿន | ប្រធានផ្នែក | អនុប្រធាន |
| ៤- | ព្រះសិរិនិតបញ្ញា យឹម ចំរើន | អនុប្រធានផ្នែក | អនុប្រធាន |
| ៥- | លោកជំទាវ មិន ចញ្ជីណែត | អគ្គនាយិកា | សមាជិកា |
| ៦- | លោកជំទាវ កែវ សុធារី | អគ្គនាយិកា | សមាជិកា |
| ៧- | លោក កែវ ខន្តីយុធា | ប្រធាននាយកដ្ឋាន | សមាជិក |
| ៨- | តំណាងអង្គការយូនីសេហ្វ | | សមាជិក |
| ៩- | លោកស្រី ជា ប៊ុនយឹន | អនុប្រធាននាយកដ្ឋាន | សមាជិកា |
| ១០- | លោកស្រី ហោ ផល្លីន | ប្រធានការិយាល័យ | សមាជិកា |
| ១១ | លោក ស្រី សុវណ្ណមុនី | មន្ត្រី | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចត្រួតពិនិត្យ វាយតម្លៃអត្ថបទ ដែលគណៈកម្មការនីមួយៗ និពន្ធចងក្រងជាសព្វគ្រប់តាមនីតិវិធី។

**ប្រការ ២** : គណៈកម្មការនីមួយៗ ត្រូវធ្វើកិច្ចប្រជុំ បែងចែកភារកិច្ចដល់សមាជិក ដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់។

**ប្រការ ៣** : សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

រដ្ឋមន្ត្រី

មិន ឃិន

**កន្លែងទទួល:**

- គណៈសង្ឃនាយក
- អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- គ្រប់សាកលវិទ្យាល័យ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- គ្រប់អង្គភាពចំណុះក្រសួងធម្មការនិងសាសនា «ដើម្បីជ្រាប ជូនជ្រាប»
- ដូចប្រការ៣ «ដើម្បីអនុវត្តន៍»
- ឯកសារ-កាលប្បវត្តិ

# មាតិកាអត្ថបទ

**ទំព័រ**

ជំពូក១៖ ការការពារកុមារ ........ ១

គោលបំណង ........ ១

សេចក្តីផ្តើម ........ ១

១.១- និយមន័យ ........ ៣

១.១.១- ព្រះពុទ្ធសាសនា ........ ៣

១.១.២- អំពើហិង្សា ........ ៤

១.១.៣- អំពើហិង្សាក្នុងគ្រួសារ ........ ៤

១.១.៤- កុមារ និងអំពើហិង្សាលើកុមារ ........ ៤

១.១.៥- ការការពារកុមារ ........ ៥

ក- សូចនាករ (កត្តាចង្អុលបង្ហាញ) ........ ៧

ខ- បញ្ហាសំខាន់ៗដែលទាក់ទង នឹងការរំលោភបំពានកុមារនៅកម្ពុជា ........ ៨

១.២- ពុទ្ធសាសនាឆ្លើយតបនឹងអំពើហិង្សាលើកុមារ ........ ៩

១.៣- ទស្សនវិជ្ជាពុទ្ធសាសនា ........ ១០

១.៣.១- កាលាមសូត្រ ........ ១០

១.៣.២- សិង្គាលសូត្រ ........ ១៣

១.៤- អំពើហិង្សាលើកុមារនៅកម្ពុជា ........ ១៤

១.៥- បទដ្ឋានគតិយុត្តនានាស្តីពីកុមារ ........ ១៧

១.៥.១- ច្បាប់អន្តរជាតិ ............ ១៧

១.៥.២- ច្បាប់ជាតិ ............ ១៨

ក- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ............ ១៨

ខ- ទេសចរណ៍ផ្លូវភេទលើកុមារ ............ ១៩

គ- ពេស្យាកម្ម ............ ១៩

ឃ- ការរំលោភបំពានផ្លូវភេទ និង ការបៀតបៀនផ្លូវភេទកុមារ ............ ១៩

ង- ការផលិតចែកចាយរូបភាពអាសអាភាសកុមារ ............ ២០

ច- ការជួញដូរកុមារសម្រាប់គោលបំណងផ្លូវភេទ ............ ២០

ឆ- ពលកម្មកុមារ ............ ២០

ជ- អំពើហិង្សាក្នុងគ្រួសារ ............ ២១

ឈ- ការសុំកូនអន្តរប្រទេស ............ ២១

ញ- ការមិនអើពើ ............ ២២

ដ- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ............ ២២

១.៦- សង្ខេបមេរៀន ............ ២២

១.៧- សំណួរត្រិះរិះ ............ ២៣

ជំពូក២៖ អំពើហិង្សាលើកុមារ ............ ២៤

គោលបំណង ............ ២៤

សេចក្តីផ្តើម ............ ២៤

២.១- ជំនឿ និងការពិតនៃអំពើហិង្សាលើកុមារ ............ ២៤

២.១.១- ការរស់នៅរបស់កុមារជាមួយអំពើហិង្សា ........ ២៨
២.១.២- ករណីសិក្សា «សាមណេរ សុខា» ........ ៣២
២.២- ប្រភេទនៃអំពើហិង្សាលើកុមារ ........ ៣៣
២.២.១- អំពើហិង្សាផ្លូវកាយ ........ ៣៤
ក- ការដាក់ទណ្ឌកម្មលើរាងកាយ (Corporal punishment) ........ ៣៥
ខ- ការរុកកួនធាតៅ (Bullying) ........ ៣៥
២.២.២- អំពើហិង្សាផ្លូវភេទ ........ ៣៥
២.២.៣- អំពើហិង្សាផ្លូវចិត្ត ........ ៣៧
២.២.៤- ការមិនអើពើ (Neglect) ........ ៣៧
២.៣- សូចនាករ នៃអំពើហិង្សាលើកុមារ ........ ៣៨
២.៣.១- ការសិក្សាសៀវភៅរឿង «សាមណេរសុខា» ........ ៣៩
២.៣.២- សារដែលទទួលបានតាមរយៈរឿងសាមណេរសុខា ........ ៤០
២.៤- ផលប៉ះពាល់ នៃអំពើហិង្សាលើកុមារ ........ ៤១
២.៤.១- ផលប៉ះពាល់លើកុមារផ្ទាល់ និងគ្រួសារ ........ ៤១
២.៤.២- ផលប៉ះពាល់លើសង្គម ........ ៤២
២.៥- អំពើហិង្សាលើកុមារមិនអាចទទួលយកបានឡើយ ........ ៤៣
២.៥.១- ការទទួលខុសត្រូវខាងពុទ្ធវិន័យ ឬ សីលធម៌ (Moral Responsibility) ........ ៤៣
២.៥.២- ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ........ ៤៤
៥.២.៣- យន្តការរាយការណ៍ចំពោះអំពើហិង្សា ........ ៤៥

២.៦- សង្ខេបមេរៀន ................................................................................................ ៤៧

២.៧- សំណួរត្រិះរិះ ................................................................................................ ៤៩

ជំពូក៣៖ ការចិញ្ចឹមកុមារ ឬកូនបែបវិជ្ជមាន ................................................................ ៥១

គោលបំណង ................................................................................................ ៥១

សេចក្តីផ្តើម ................................................................................................ ៥១

៣.១- ការអភិវឌ្ឍកុមារ ................................................................................................ ៥១

៣.១.១- តើអ្វីទៅជាការអភិវឌ្ឍកុមារ? ................................................................ ៥២

៣.១.២- ដំណាក់កាលនៃការអភិវឌ្ឍកុមារ ................................................................ ៥២

៣.២- ការចិញ្ចឹមកូនបែបវិជ្ជមាន ................................................................................ ៥៣

៣.២.១- ការដាក់ពិន័យបែបវិជ្ជមាន (Positive Discipline) ........................................ ៥៧

៣.២.២- សិទ្ធិ និងតម្រូវការ ................................................................................ ៦០

៣.២.៣- ចិត្តវិទ្យាកុមារ ................................................................................ ៦១

៣.២.៤- ឥរិយាបថរបស់អាណាព្យាបាល និងកុមារ ................................................ ៦២

ក- ពាក្យសញ្ញានិងទំនាក់ទំនងអាកប្បកិរិយា ធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្ត....... ៦៣

ខ- ការជួយដោះស្រាយកុមារ ................................................................ ៦៣

គ- ផលប៉ះពាល់នៃការចិញ្ចឹមកូន ឬកុមារតាមជំនឿបុរាណ ................................ ៦៤

៣.៣- សារៈសំខាន់នៃការថែរក្សាកុមារតាមគ្រួសារ និងសហគមន៍ ................................ ៦៤

៣.៣.១- កុមារ និងគ្រួសារ នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីកុមារ ................................ ៦៨

៣.៣.២- គោលនយោបាយស្តីពីការថែទាំកុមាររបស់រដ្ឋាភិបាល ................................ ៦៨

៣.៤- សង្ខេបមេរៀន ..................................................... ៦៩

៣.៥- សំណួរត្រិះរិះ ..................................................... ៧០

ជំពូក ៤៖ ព្រះពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារ..................................... ៧១

គោលបំណង ..................................................... ៧១

សេចក្តីផ្តើម ..................................................... ៧១

៤.១- ទ្រឹស្តីពុទ្ធសាសនា និងអហិង្សាធម៌..................................... ៧២

៤.១.១- អហិង្សាធម៌ក្នុងឱវាទបាដិមោក្ខ..................................... ៧៥

៤.១.២- ទ្រឹស្តីនានាទាក់ទងនិងអហិង្សាធម៌ ..................................... ៧៩

ក- ការគិតពីមនុស្សតាមរយៈពុទ្ធសាសនា..................................... ៧៩

ខ- ការគិតពីកុមារតាមរយៈពុទ្ធសាសនា ..................................... ៨០

គ- តើកុមារគួរមានសិទ្ធិ និងទទួលបានសិទ្ធិអ្វីខ្លះ? ..................................... ៨១

ឃ- តើអ្វីជាការបំពានលើកុមារ? ..................................... ៨២

ង- ការដាក់ទោសទណ្ឌលើអ្នកបំពាន «កុមារ» តាមរយៈបរាភវសូត្រ ............. ៨៣

៤.១.៣-ការទុះបញ្ចាំង និងឆ្លើយតបអំពើហិង្សាលើកុមារ តាមរយៈពុទ្ធសាសនា.... ៨៦

ក- វត្តអារាម ជាមជ្ឈមណ្ឌលពហុវិស័យ ..................................... ៨៦

ខ- ប្រព័ន្ធវិស័យពុទ្ធិកអប់រំ..................................... ៨៧

គ- ប្រព័ន្ធពាក់ព័ន្ធនានា..................................... ៨៧

៤.២- ទស្សនាទានពុទ្ធសាសនាស្តីពីអហិង្សាធម៌ ..................................... ៨៧

៤.២.១- អត្តសម្មាបណិធិ..................................... ៩២

៤.២.២- អដ្ឋង្គិកមគ្គ (ផ្លូវប្រកបដោយអង្គ ៨ប្រការ)........................................... ៩៥
ក- សម្មាទិដ្ឋិ (Right Vision) គំនិតយល់ឃើញត្រូវ........................................... ៩៦
ខ- សម្មាសង្កប្បៈ (Right Thought) ការត្រិះរិះត្រូវ........................................... ៩៧
គ- សម្មាវាចា (Right Speech) សម្ដីត្រូវ........................................... ៩៨
ឃ- សម្មាកម្មន្ត (Right Actions) ការងារត្រូវ........................................... ១០០
ង- សម្មាអាជីវៈ (Right Livelihood) ការចិញ្ចឹមជីវិតត្រូវ........................................... ១០០
ច- សម្មាវាយាម (Right Efforts) ការព្យាយាមត្រូវ........................................... ១០២
ឆ- សម្មាសតិ (Right Mindfulness) ការរលឹកត្រូវ........................................... ១០២
ជ- សម្មាសមាធិ(Right Meditation) ការតម្កល់ចិត្តត្រូវ........................................... ១០៣
៤.២.៣- អកុសលមូលទាំង៣........................................... ១០៤
៤.២.៤- ការធ្វើបញ្ហាំង និងការឆ្លើយតប........................................... ១០៨
៤.៣- ការចូលរួមរបស់សាមណេរ និងយុវជន........................................... ១១០
៤.៣.១- ឥរិយាបថប្រកបដោយហានិភ័យរបស់វ័យជំទង់ (Adolescence)........................................... ១១២
៤.៣.២- ផលប៉ះពាល់នៃអំពើហិង្សាលើសុខភាព........................................... ១១៤
៤.៣.៣- ឥរិយាបថប្រកបដោយហានិភ័យ........................................... ១១៦
ក- ឥរិយាបថពាក់ព័ន្ធនឹងការប្រើប្រាស់ជាតិស្រវឹង........................................... ១១៦
ខ- ឥរិយាបថពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់........................................... ១១៧
គ- ឥរិយាបថផ្លូវភេទ........................................... ១១៧
៤.៣.៤- តើសាមណេរ និងក្មេងជំទង់អាចធ្វើអ្វីខ្លះ?........................................... ១១៨

៨.៤- សង្ខេបមេរៀន ........ ១១៩

៨.៥- សំណួរត្រិះរិះ ........ ១១៩

ជំពូក៩៖ វិធីសាស្ត្រផ្សព្វផ្សាយ ........ ១២០

គោលបំណង ........ ១២០

សេចក្តីផ្តើម ........ ១២០

៩.១- វិធីសាស្ត្រផ្សព្វផ្សាយ ........ ១២១

៩.១.១- ការលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារ ........ ១២១

៩.១.២- ធម្មទេសនា ពីទម្រង់នៃអហិង្សាជម៌ក្នុងការបង្រៀនប្រដៅ និងអប់រំកុមារ... ១២១

៩.១.៣- ការជំរុញ ឬបង្កើតឱ្យមានបរិយាកាសសុវត្ថិភាព ........ ១២៤

៩.១.៤- ការចលនាសហគមន៍ ឱ្យហ៊ាននិយាយ និងធ្វើសកម្មភាព ........ ១២៤

៩.១.៥- ការពន្យល់ពីទង្វើបែបហិង្សាលើកុមារមួយចំនួនដែលគួរចៀសវាង ........ ១២៥

៩.១.៦- ភាពជាគំរូ ........ ១២៦

៩.១.៧- មិត្តអប់រំមិត្ត ........ ១២៦

៩.១.៨- វត្តអារាម និងសហគមន៍ ........ ១២៧

៩.១.៩- ការប្រជុំជាមួយមាតាបិតាសិស្ស ........ ១២៩

៩.១.១០- សកម្មភាពផ្សេងៗទៀត អំពីការចូលរួមរបស់ព្រះសង្ឃ ........ ១២៩

៩.១.១១- អ្នកកៀរគរសហគមន៍ ........ ១៣៩

៩.២- សង្ខេបមេរៀន ........ ១៤១

៩.៣- សំណួរត្រិះរិះ ........ ១៤២

ឯកសារយោង..........................................................................................................១៤៣

# ជំពូក១៖ ការការពារកុមារ

## គោលបំណង

*ក្រោយពីសិក្សាជំពូកនេះ សមណនិស្សិត និស្សិតនឹងទទួលបាន៖*

- *ការយល់ដឹងអំពី អត្ថិភាពនៃអំពើហិង្សាលើកុមារនៅកម្ពុជា*
- *ការយល់ដឹងពី វាក្យសព្ទ ពាក់ព័ន្ធនិងការការពារកុមារ*
- *ការយល់ដឹងពីអារម្មណ៍របស់កុមារដែលរស់នៅក្នុងអំពើហិង្សា តាមរយៈសូចនាកររាស់វែង*
- *ការយល់ដឹងអំពី ការការពារកុមារតាមរយៈ ធម៌វិន័យ (ច្បាប់ពុទ្ធសាសនា) ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ ។*

## សេចក្ដីផ្ដើម

*ទំពាំងស្នងឫស្សី ជាសុភាសិតដែលខ្មែរច្រើនជំនាន់សម្រាប់ទូន្មានកូនចៅ។ ទំពាំងជាពន្លកដំបូងនៃពូជឫស្សី ប្រដូចទៅនឹងកុមារដែលមានវ័យក្មេង ហើយត្រូវលូតលាស់ក្លាយជាយុវជន ឬមនុស្សចាស់ដែលមានន័យស្មើនឹងដើមឫស្សី។ ទំពាំងដុះលូតលាស់ល្អនឹងនាំឱ្យបានជាឫស្សីល្អដែរ។ ចំណែកឯកុមារ ដែលទទួលបានការថែទាំ បណ្ដុះបណ្ដាលបានល្អ នឹងនាំឱ្យក្លាយជាធនធានមនុស្សដ៏សំខាន់សម្រាប់ការកសាង និង អភិវឌ្ឍប្រទេសជាតិ។ អនាគតរបស់កុមារម្នាក់ៗ យើងពិតជាមិនអាចទស្សន៍ទាយបានទេ ទោះជាកុមារនោះស្ថិតក្នុងឋានៈ ឬស្ថានភាពគ្រួសារបែបណាក៏ដោយ។ ដូច្នេះ យើងជាមនុស្សដែលទទួលបាននូវការអប់រំ ដឹងខុសដឹងត្រូវ គួរតែគិតរកវិធីសាស្ត្រសាងអនាគតដ៏ល្អប្រសើរមួយសម្រាប់កុមារជំនាន់ក្រោយ។ ម្យ៉ាងវិញទៀត យើងក៏គួរតែហ៊ានផ្លាស់ប្ដូរជំនឿ ឬទម្លាប់អាក្រក់មួយចំនួនដែលមានផលជាអវិជ្ជមាន សម្រាប់អនាគតកុមាររបស់យើងដែរ។*

តាមបទពិសោធន៍ ប្រទេសកម្ពុជាបានឆ្លងកាត់នូវភ្លើងសង្គ្រាមឈ្មានពាន សង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំ។ ការណ៍នេះ ជាហេតុធ្វើឱ្យប្រទេសស្ថិតក្នុងហានិភ័យទ្រព្យសម្បត្តិ ធនធានមនុស្ស តម្លៃគុណធម៌ អារ្យធម៌ និងភាពស៊ីវិល័យរបស់មនុស្សជាតិទៀតផង។ សង្គ្រាម និងភាពក្រីក្របានបន្សល់ទុកនូវទម្លាប់នៃការប្រើប្រាស់ អំពើហិង្សា ការបែកបាក់គ្រួសារ ជាស្នាមរបួសសង្គមដែលចាំបាច់ទាមទារការយកចិត្តទុកដាក់មើលថែព្យាបាលឱ្យបានទាន់ពេលវេលា។ បញ្ហាប្រឈមចំពោះមុខនេះ គឺយើងត្រូវតែនាំគ្នាអប់រំមនុស្សធំដែលមានតួនាទីជាអាណាព្យាបាលកុមារ ឱ្យផ្លាស់ប្តូរ នូវទម្លាប់មិនល្អ និងបង្ហាញនូវទម្លាប់ដែលល្អដើម្បីអនាគតរបស់កុមារ។ កុមារនឹងក្លាយ ជាសសរទ្រូងដឹកនាំ និងអភិវឌ្ឍប្រទេសជាតិនាពេលអនាគត ដែលជាក្តីសង្ឃឹម របស់យើងទាំងអស់គ្នា។ ការអប់រំតាមប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការពង្រឹងនីតិរដ្ឋ គឺជាផ្នែកដ៏សំខាន់សម្រាប់អប់រំទប់ស្កាត់ នូវទម្រង់នៃអំពើហិង្សា លើកុមារគ្រប់ប្រភេទ តែយើងក៏មិនអាចបំភ្លេចនូវប្រព័ន្ធអប់រំរបស់ព្រះពុទ្ធសាសនា ដែលនៅតែមានឥទ្ធិពលយ៉ាងសំខាន់ក្នុងសង្គម។ ប្រទេសកម្ពុជា បានលើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយប្រជាជនជាង៩៥% គោរពប្រណិប័តន៍ ព្រះពុទ្ធសាសនា។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាជាសាសនាសន្តិភាព មិនប្រើប្រាស់អំពើហិង្សាពប់ចាប់ពីបុគ្គលសន្តិភាព គ្រួសារសន្តិភាព និងសហគមន៍សន្តិភាព។ល។ តើព្រះពុទ្ធសាសនាពិតជាមានឥទ្ធិពល សម្រាប់ឆ្លើយតបអំពើហិង្សាលើកុមារមែនឬ? តើត្រូវដោះស្រាយបញ្ហាទាំងនេះដោយវិធីសាស្ត្រណា?

ដើម្បីឆ្លើយនិងសំណួរខាងលើ ក្រុមស្រាវជ្រាវរបស់សាលាពុទ្ធិកឧត្តមសិក្សាបានរៀបចំសរសេរនូវសៀវភៅនេះ ដោយបានបែងចែកជាប្រាំជំពូកសំខាន់ៗ។ ជំពូក១ និយាយអំពីសញ្ញាណទូទៅ ជំពូក២ និយាយអំពីប្រភេទនិងផលប៉ះពាល់នៃអំពើហិង្សាលើកុមារ ជំពូក៣ និយាយអំពីឧត្តមប្រយោជន៍កុមារ ជំពូក៤ និយាយពីការឆ្លើយតបអំពើហិង្សាលើកុមារតាមរយៈពុទ្ធសាសនា និងជំពូក៥ និយាយអំពីពិធីសាស្ត្រផ្សព្វផ្សាយ និងចិត្តសាស្ត្រកុមារ។

## ១.១- និយមន័យ

*មុននឹងយល់ពីវិធីសាស្ត្រ និងយន្តការសម្រាប់ឆ្លើយតបអំពើហិង្សាលើកុមារ គប្បីយល់ពីនិយមន័យនៃបច្ចេកសព្ទសំខាន់ៗមួយចំនួនដែលមានក្នុងអត្ថបទនេះជាមុនសិន។*

### ១.១.១- *ព្រះពុទ្ធសាសនា*

*ពាក្យថា «ព្រះពុទ្ធសាសនា» (ពុទ្ធ = អ្នកត្រាស់ដឹង + សាសនា= ពាក្យប្រៀនប្រដៅ ពាក្យទូន្មាន...)។ ពាក្យប្រៀនប្រដៅរបស់ព្រះ<u>សម្មាសម្ពុទ្ធ</u> ហៅថាព្រះពុទ្ធសាសនា។* ***ព្រះពុទ្ធសាសនា*** *បានក្តោបយកន័យទាំងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងពាក្យអប់រំ ពាក្យទូន្មាន ពាក្យប្រដៅរបស់ព្រះសង្ឃជាអង្គសាវ័ករួមហៅថា ព្រះរតនត្រ័យ ។* ***ព្រះពុទ្ធ-សាសនា*** *មិនមែនជា <u>លទ្ធិ</u>សាសនា ឬពាហិរសាសនា*(Religion) *តាមអត្ថន័យនៃពាក្យ ដូចអ្នកផងធ្លាប់យល់មកនោះទេ ពីព្រោះព្រះពុទ្ធសាសនាមិនមែនជាប្រព័ន្ធ*(Système) *នៃជំនឿឥតហេតុផល*(Croyance ) *និងការបូជា*(Culte) *នោះឡើយ ។*

***«ព្រះពុទ្ធសាសនា»*** *មានអត្ថន័យថា «ជាពុទ្ធវចនៈ ដែលស្តីពីជីវិតចូលទៅដល់ក្នុងជីវិតតាមយថាភូតញាណទស្សនៈ ពុំមែនគិតសើៗតែសំបកក្រៅនោះទេ តែជា ពុទ្ធវចនៈស្តីពីដំបូន្មានផ្តល់ឱ្យមនុស្សចេះប្រតិបត្តិ ចេះដើរខ្លួនឯងទៅតាមគន្លងដំបូន្មាន ល្អិតសុខុមត្រឹមត្រូវវិសេស ជាពុទ្ធវចនៈស្តីពីដំបូន្មានបង្រៀនមនុស្សឱ្យមានក្តីសង្ឃឹម តស៊ូយកឈ្នះខ្លួនឯង ចេះរស់ក្នុងជីវិត ចេះតស៊ូចំពោះសេចក្តីស្លាប់មិនរួញរា មិនថ្លូរ មិនញញើតដោយខន្តីធម៌ ជាពុទ្ធវចនៈបណ្តុះបណ្តាលពុទ្ធិ គុណធម៌ ក្តីល្អ ក្តីរីករាយ ឱ្យកើតដល់ខ្លួនឯង និងដល់ជនដទៃទូទៅ»។ ពុទ្ធសាសនាមិនប្រដៅពុទ្ធសាសនិកជន ឱ្យមានជំនឿឥតហេតុផលទាល់សោះឡើយ។ ជំនឿឥតហេតុផលនេះ ពុំមាននៅក្នុងពុទ្ធសាសនាទេ។ ពុទ្ធសាសនិកជនប្រើជំនឿដែរ តែជាជំនឿមួយបែប គឺជំនឿហេតុផល ជំនឿជាទីទុកចិត្ត*(Confidence ) *ហើយមាន <u>ប្រាជ្ញា</u> ប្រកបផងដែលនៅក្នុងភាសា <u>បាលី</u> លោកហៅថា <u>សទ្ធា</u> (ជំនឿ <u>ហេតុផល</u> ប្រកបដោយ <u>បញ្ញា</u> )។*

### ១.១.២- អំពើហិង្សា

*ហិង្សា [ហិង-សា] ហឹសា (សំ.,បា.) (ហឹសា) ការបៀតបៀន ការពាធា ការធ្វើអាក្រក់រកគ្នា ការធ្វើទុក្ខគ្នា : មនុស្សត្រូវកុំឱ្យមានហិង្សារកគ្នា[១] ។*

### ១.១.៣- អំពើហិង្សាក្នុងគ្រួសារ

*សំដៅលើអំពើហិង្សាដែលកើតមាន នឹងអាចកើតមានទៅលើប្តី ឬប្រពន្ធ កូនក្នុងបន្ទុក និងជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។ ភាគច្រើននៃជនរងគ្រោះអំពើហិង្សាក្នុងគ្រួសារ គឺជាស្ត្រីនិងកុមារដែលជាជនទន់ខ្សោយងាយរងគ្រោះ។ ស្ត្រីរងគ្រោះភាគច្រើនទាល់តែមានការលំបាកយ៉ាងខ្លាំង ទើបសម្រេចចិត្ត ទម្លាយបញ្ហាទុក្ខសោក ឬការធ្វើបាបពីស្វាមីឱ្យទៅអ្នកខាងក្រៅបានដឹង ដើម្បីស្វែងរក ជំនួយ។*

*សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត (រួមមាន ការប្រមាថ មាក់ងាយ ការគំរាមកំហែង និងការដាក់ឱ្យនៅឯកោម្នាក់ឯង) និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលត្រូវបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាទៅលើមនុស្សផ្សេងៗទៀតដែលកំពុងរស់នៅក្នុងគ្រួសារនោះ។*

### ១.១.៤- កុមារ និងអំពើហិង្សាលើកុមារ

*មានន័យថា ជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។ កុមារត្រូវទទួលបានការប្រព្រឹត្តដោយមិនមានការរើសអើង ទោះក្នុងទម្រង់ណាមួយក៏ដោយ។ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការ នយោបាយ ឬគំនិតផ្សេងគ្នា ជាតិសាសន៍ ជនជាតិដើម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាព កំណើត ឬ*

---

[១] ជួន ណាត : ***វចនានុក្រមខ្មែរភាគ១-២*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ភ្នំពេញ ឆ្នាំ១៩៦៨។

ឋានៈផ្សេងៗឡើយ (ការការពារកុមារ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ មាន៥៤មាត្រា)។

ម្យ៉ាងទៀត បើយោងតាមអ្នកប្រាជ្ញព្រះពុទ្ធសាសនាសម្គាល់កុមារដោយវិគ្គហៈថាៈ **កុំ ភូមឹ កពោតីតិ = កុមាពោ** អ្នកណាលេងនូវផែនដីជាប្រក្រតី អ្នកនោះឈ្មោះថាកុមារ។ កុមារនេះបានដល់ក្មេងតូចទាំងប្រុសទាំងស្រី ដែលចូលចិត្តលេងដី មានដីខ្សាច់ជាដើម។

អំពើហិង្សាលើកុមារជាសកម្មភាពទាំងឡាយណា (កាយកម្ម វចីកម្ម និងមនោកម្ម) ដែលធ្វើឱ្យកុមារឈឺចាប់។

## ១.១.៥- ការការពារកុមារ

ការការពារកុមារ គឺជាការទប់ស្កាត់ និងឆ្លើយតបទៅនិងគ្រោះថ្នាក់ដែលកើតឡើងដោយចេតនា និងអចេតនាចំពោះកុមារ។ គោលបំណងនៃការការពារកុមារ គឺដើម្បីលើកកម្ពស់ការការពារ និងបំពេញសិទ្ធិកុមារនៅក្នុងការការពារពីការរំលោភបំពាន ការមិនអើពើ ការកេងប្រវ័ញ្ច និងអំពើហិង្សាគ្រប់ទម្រង់។

ព្រះពុទ្ធជាម្ចាស់ទ្រង់យកព្រះទ័យទុកដាក់ខ្ពស់ចំពោះកុមារ ទ្រង់ចាត់ទុកកុមារជាពន្លកត្រួយដែលត្រូវតែគាំពារ និងសម្រិតសម្រាំងទុកជាកម្លាំងចលករសំខាន់បំផុតសម្រាប់បន្តវេនទ្រទ្រង់ព្រះពុទ្ធសាសនា ក៏ដូចជាធនធានអភិវឌ្ឍន៍ប្រទេសនីមួយៗ។ ព្រះអង្គទ្រង់ដាស់តឿនឱ្យពុទ្ធបរិស័ទ យកព្រះទ័យទុកដាក់ថែទាំកុមារតូច មានការទំនុកបម្រុងចំណីអាហារ សំលៀកបំពាក់ទីសេនាសនៈ និងភាពកក់ក្តៅដល់កុមារក្នុងពុទ្ធសាសនា។ ក្នុងពុទ្ធសម័យមានកុមារឈ្មោះ កុមារកស្សប ជាកូនរបស់ភិក្ខុនីម្នាក់ ដែលមានផ្ទៃពោះ តាំងពីមុនពេលចូលមកបួសហើយក៏គ្រប់ខែ និងប្រសូតក្រោមការមើលការខុសត្រូវពីសំណាក់ឧបាសិកា វិសាខា។ ក្រោយមកព្រះបាទបសេនទិកោសល យកធ្វើជាកូនចិញ្ចឹម។ ព្រះពុទ្ធអង្គទ្រង់ផ្តាំឱ្យភិក្ខុទាំងឡាយឧស្សាហ៍ឱ្យនំចំណីដល់កុមារនោះ រហូតដល់ធំពេញវ័យក៏ចូលបួសជាសាមណេរ និងភិក្ខុជាបន្តបន្ទាប់រហូតបានសម្រេចជាព្រះអរហន្តមួយអង្គក្នុងព្រះពុទ្ធសាសនា ។

កិច្ចការពារកុមារ កើតមាននៅគ្រប់ពេល ទាំងកុមារក្នុងស្ថានភាពងាយរងគ្រោះ ឬរស់នៅក្នុងស្ថានភាពហិង្សា។ ក្នុងកាលៈទេសៈនេះ កិច្ចការពារកុមារ គឺជាការងារដ៏សំខាន់ ដែលយើងត្រូវយល់ដឹងព្រោះ៖

- កុមារទទួលរងគ្រោះផ្នែកផ្លូវចិត្ត នៅពេលដែលកុមារមើលឃើញមនុស្សពីរនាក់ ដែលពួកគេស្រឡាញ់វាយតប់គ្នា។ ឧទាហរណ៍ កុមារមានអារម្មណ៍ភ័យខ្លាច ងាយរងគ្រោះ និងគ្មានអំណាច។
- ការសិក្សាស្រាវជ្រាវបានបង្ហាញថា ការដាក់កុមារឱ្យនៅក្នុងបរិយាកាសដែលមានអំពើហិង្សា អាចប៉ះពាល់ការអភិវឌ្ឍខួរក្បាលរបស់កុមារ។
- អំពើហិង្សាអាចជះឥទ្ធិពលដល់កុមារ បើទោះជាកុមារមិនបានឃើញអំពើនោះក៏ដោយ។ ឧទាហរណ៍ នៅពេលដែលកុមារស្ដាប់ឮសូរសកម្មភាពហិង្សា ឬមើលឃើញផលប៉ះពាល់របស់វាទៅលើជនរងគ្រោះ ធ្វើឱ្យកុមារមានភាពភ័យខ្លាច បាត់បង់ភាពកក់ក្ដៅ និងមានស្នាមទុយ៌សក្នុងចិត្ត។
- បញ្ហាដទៃទៀតទាក់ទងនឹងកុមារ ដូចជាការរំលោភបំពានផ្លូវកាយ និងផ្លូវភេទ ទំនងជាអាចកើតឡើងច្រើន នៅពេលដែលមានអំពើហិង្សាក្នុងគ្រួសារកើតមានឡើង។
- កុមារស្ថិតក្នុងការប្រឈមនិងការរងរបួស ជាពិសេសប្រសិនបើកុមារចូលធ្វើអន្តរាគមន៍នៅក្នុងអំពើហិង្សា ដែលពួកគេធ្វើដើម្បីការពារជនរងគ្រោះ។
- នៅពេលដែលឪពុក ឬម្ដាយ ឬក៏អ្នកថែរក្សាណាម្នាក់ ត្រូវគេរំលោភបំពាន (ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ) នោះនាំឱ្យសមត្ថភាពរបស់ពួកគេក្នុងការការពារកុមារត្រូវថយចុះយ៉ាងខ្លាំង។
- កុមារដែលស្ថិតក្នុងបរិយាកាសនៃអំពើហិង្សា គឺស្ថិតក្នុងការប្រឈមនិងការប្រើអំពើហិង្សា នៅក្នុងទំនាក់ទំនងរបស់ពួកគេផ្ទាល់ទាំងក្នុងស្ថានភាពជាកុមារ និង ជាមនុស្សពេញវ័យ។

- វាជាប្រការសំខាន់ណាស់ដែលស្ថាប័ននីមួយៗ រួមទាំងវត្តអារាមផងដែរត្រូវបង្កើតគោលការណ៍ការពារ និងគាំទ្រកុមារ។ គោលបំណងក្នុងការបង្កើតគោលការណ៍ការពារ និងគាំទ្រកុមារគឺៈ
- ដើម្បីបញ្ចៀសកុមារ ឱ្យចាកផុតពីការធ្វើទុក្ខទោសដោយចេតនាក្តី និងដោយអចេតនាក្តី ទៅលើការរំលោភបំពានទាំងផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនយកចិត្តទុកដាក់។
- ជាកន្លែងដែលកុមារយល់ថាមានសុវត្ថិភាព ភាពកក់ក្តៅ ទំនុកចិត្តអាចបញ្ចេញគំនិតយោបល់ និងជាកន្លែងដែលកុមារត្រូវបានគេគោរព ឱ្យតម្លៃ និងផ្តល់អំណាច[២]។

## ក- សូចនាករ (កត្តាចង្អុលបង្ហាញ)

ខាងក្រោមនេះ ជាសូចនាករទូទៅនៃអាកប្បកិរិយាមួយចំនួនរបស់កុមារ ដែលរស់នៅក្នុងបរិយាកាសនៃអំពើហិង្សា មានលក្ខណៈស្រដៀងគ្នាទៅនឹងសូចនាករទម្រង់ ផ្សេងទៀតនៃការរំលោភបំពានផងដែរ។ សូចនាករទាំងនេះរួមមានៈ

- គេងមិនលក់ ខ្លាចមិនហ៊ានចូលគេង យល់សប្តិអាក្រក់ យល់សប្តិឃើញមានគ្រោះថ្នាក់។
- ពេតសញ្ញាផ្នែករាងកាយ ដូចជា ឈឺក្បាល ឬឈឺពោះ។
- ប្រុងប្រយ័ត្នជ្រុលចំពោះគ្រោះថ្នាក់ ឬការធ្វើបាបពីអ្នកដទៃ។
- វាយតប់ជាមួយអ្នកដទៃ បង្កការឈឺចាប់ដល់កុមារដទៃ ឬសត្វ។
- ខឹងច្រឡោត ឬមានអាកប្បកិរិយារឹងរូស។
- ដកខ្លួនពីគេឯង ឬពីសកម្មភាពទូទៅ។
- មានសភាពប្រងើយកន្តើយ ធ្លាក់ទឹកចិត្ត កម្លាំងតិចតួច។

---

[២] អង្គការអាដហុក ស្ថានភាពអំពើហិង្សាលើស្ត្រី និងកុមារ ឆ្នាំ២០១១ បោះពុម្ព ២០១២

- អារម្មណ៍ឯកោ និងដាច់ឆ្ងាយពីគេឯង។
- សេពគ្រឿងញៀនពេលកំពុងមានបញ្ហា ឬក្រោយពីពេលនោះមក។
- ប៉ុនប៉ងសម្លាប់ខ្លួន ឬចូលទៅពាក់ព័ន្ធនិងអាកប្បកិរិយា ដែលប្រកបដោយគ្រោះថ្នាក់។
- ការចងចាំខ្សោយ។
- ពិបាកក្នុងការផ្ទង់អារម្មណ៍ និងផ្តោតអារម្មណ៍។
- មានអារម្មណ៍ថា អ្វីដែលខ្លួនបានប្រឹងប្រែងអស់សមត្ថភាពនៅតែមិនទាន់ល្អគ្រប់គ្រាន់។
- មានការព្រួយបារម្ភខ្លាំងជ្រុល។
- ធ្វើដូច ឬធ្វើតាមអាកប្បកិរិយារបស់ជនរំលោភបំពាន។

## ខ- បញ្ហាសំខាន់ៗដែលទាក់ទងនឹងការរំលោភបំពានកុមារនៅកម្ពុជា

ប្រទេសកម្ពុជាជាប្រទេសបានឆ្លងកាត់សង្គ្រាម ប្រកបដោយភាពហិង្សាអស់រយៈពេលជាច្រើនឆ្នាំ ហើយបានបន្សល់ទុកនូវប្រជាជន ដែលមានការប៉ះទង្គិចយ៉ាងខ្លាំង និងមានបញ្ហាជាប់មកជាមួយ។ ភាពក្រីក្របានធ្វើឱ្យមានអត្រាមរណភាពទារក និងកុមារមានចំនួនខ្ពស់ អនក្ខរជនមានចំនួនច្រើន និង ប្រាក់ចំណូលមានចំនួនទាប។ កុមារធ្វើអ្វីទៅតាមអ្វីដែលគេមើលឃើញ។ ផលប៉ះពាល់នេះ បានប៉ះពាល់ខ្លាំងទៅលើកុមារកម្ពុ-ជា។ ប្រសិនបើកុមារមើលឃើញ ឬទទួលបទពិសោធន៍ពីអំពើហិង្សាពួកគេនឹងក្លាយជាអ្នកប្រព្រឹត្តអំពើហិង្សា។

កុមារត្រូវបានទទួលរងគ្រោះជារៀងរាល់ថ្ងៃ ដោយការបាត់បង់ឱកាសចូលរៀន មរណភាព ការរំលោភការងារ គ្រោះថ្នាក់ ពេស្យាចារ និងការជួញដូរ។ ការដាក់ទណ្ឌកម្មលើរាងកាយ ក្នុងទម្រង់នៃការវាយធ្វើបាប វាយតប់ ក្តិចមួល មួលត្រចៀក។ល។ ពីដើមមកត្រូវបានគេចាត់ទុកថា ជាទម្លាប់ចាំបាច់ដើម្បីប្រដៅកុមារ ដោយមិនបានយល់ដឹងពីផលប៉ះពាល់លើកុមារ ក៏ដូចជាការបង្រៀនកុមារឱ្យប្រព្រឹត្តហិង្សាតាមខ្លួន ទាំងមិនដឹងខ្លួន ហើយដែលបានក្លាយជាក្រុមសង្គម ដែលបន្តឱ្យមានអំពើហិង្សាលើកុមារ។

*ផលប៉ះពាល់នៃការរំលោភបំពានផ្លូវភេទលើកុមារ ជះឥទ្ធិពលកាន់តែធ្ងន់ធ្ងរជាង ការប្រព្រឹត្តអំពើហិង្សាទៅទៀត។ កុមារីត្រូវទទួលរងនូវការរំលោភបំពាន ម្តងហើយ ម្តងទៀត ពួកគេតែងតែទទួលរងនូវការរំលោភបំពានផ្លូវចិត្ត ដោយសារតែភាពអាម៉ាស់ និងទទួលរងនូវការស្តីបន្ទោសសម្រាប់ការរំលោភបំពានផ្លូវភេទ។ ចំណែកកុមារាមិនត្រូវ បានគេជឿថា ទទួលរងការរំលោភបំពានផ្លូវភេទនោះទេពីព្រោះបញ្ហានេះថ្មីសម្រាប់កម្ពុ-ជា និងដោយសារតែគេរំពឹងថា ក្មេងប្រុសៗអាចតទល់ដោយខ្លួនឯងបាន។ កុមារាត្រូវការទទួលបានការជឿជាក់ពីអ្នកដទៃថា រឿងនោះកើតឡើងចំពោះពួកគេមែន។*

*ទស្សនៈដែលថា សេចក្តីអាម៉ាស់ដែលពាក់ព័ន្ធ និងការដែលប្រពន្ធចាកចេញពីប្តីដែលប្រើអំពើហិង្សា វាធ្ងន់ជាងការព្រួយបារម្ភអំពីសុវត្ថិភាពរបស់កូន ទោះបីកូនត្រូវបានទទួលគ្រោះថ្នាក់ធ្ងន់ធ្ងររួចហើយក៏ដោយ។*

*និទណ្ឌភាព និងអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ ដែលមានន័យថា ច្បាប់មិនអាចលើកកម្ពស់សិទ្ធិរបស់កុមារឱ្យបានសមស្រប រួមជាមួយនិងការខ្វះខាត ព័ត៌មានដែលអាចទុកចិត្ត និងខ្វះការស្រាវជ្រាវសមស្រប។ ដូច្នេះទំហំនៃអំពើហិង្សានេះ មិនត្រូវគេយល់ដឹងពេញលេញឡើយ។*

**១.២- ពុទ្ធសាសនាឆ្លើយតបនឹងអំពើហិង្សាលើកុមារ**

*ព្រះពុទ្ធសាសនា បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការថែទាំ គាំពារទារក ឬកុមារ។ ក្នុងព្រះវិន័យព្រះពុទ្ធសាសនា ត្រង់មនុស្សវិគ្គហ(ការសម្លាប់មនុស្ស) ជាសិក្ខាបទទីមួយក្នុងចំណោមសិក្ខាបទទាំងបួននៃបរាជិករបស់ពួកភិក្ខុ ដែលជាសិក្ខាបទមានទោសធ្ងន់ជាងគេ ក្នុងចំណោមសិក្ខាបទទាំង២២៧។ ពុទ្ធវិន័យបានហាមមិនឱ្យដាក់ថ្នាំទម្លាក់គភ៌ទារកក្នុងផ្ទៃមាតារាប់ចាប់តាំងពីដឹងថាទារកមកចាប់ផ្ទៃ រហូតដល់ថ្ងៃប្រសូត។ ដំណើរវិវត្តរបស់ទារកក្នុងផ្ទៃត្រូវបានកំណត់ជា៥ដំណាក់កាលសំខាន់ៗដូចខាងក្រោម៖*

*១. **កលល:** សណ្ឋានរូបដូចជាភក់ ឬដូចសប្បិទន់*

*២. **អព្វុទ:** សណ្ឋានដូចជាទឹកលាងសាច់*

*៣. **បេសិ** សណ្ឋានដូចជាដុំសាច់ ឬដូចដុំសំណ*

*៤. **ឃន:** សណ្ឋានរូបដូចសាច់ពងមាន់នៅក្នុងស្រោមសំបក*

*៩. **បញ្ចសាខា** សណ្ឋានដង់ខ្លួន មានពកប្រាំ មានក្បាល១ ដៃ២ ជើង២។*

*ក្នុងដំណាក់កាលទាំងប្រាំនេះ ទោះជាក្នុងដំណាក់កាលណាក៏ដោយ បើភិក្ខុ ក្នុងព្រះពុទ្ធសាសនា ធ្វើឱ្យគភ៌នោះរអិលធ្លាក់ចាកផ្ទៃនៃមាតា ភិក្ខុនោះត្រូវ អាបត្តិបារាជិក។*

*ក្នុងសិក្ខាបទនិច្ចសីល(សីល៥) សិក្ខាបទទី១ បានហាមប្រាមមិនឱ្យបៀតបៀន ឬសម្លាប់សត្វ។ សត្វក្នុងទីនេះសំដៅដល់សត្វដែលមានជីវិតទាំងអស់ រួមទាំងមនុស្សផង ដែរ។ ត្រង់នេះបញ្ជាក់ថា ពុទ្ធសាសនាបានយកចិត្តទុក្ខដាក់ដល់សិទ្ធិរស់រានមានជីវិត របស់មនុស្សសត្វ។ ជាពិសេសកុមារដែលជាទំពាំងស្នងឫស្សីនេះផងដែរ។*

*ជាងនេះទៅទៀត ថ្វីត្បិតតែពុទ្ធសាសនាពុំបាននិយាយចំៗចំពោះកុមារមែន តែព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ជារួមសម្រាប់មនុស្សទូទៅ ជាពិសេសគោលការណ៍របស់ពុទ្ធសាសនា គោរពការរស់រានមានជីវិតរបស់មនុស្ស សត្វ រុក្ខជាតិ និងធម្មជាតិជុំវិញការរស់នៅរបស់មនុស្សនោះថែមទៀតផង។*

**១.៣-ទស្សនវិជ្ជាពុទ្ធសាសនា**

*ព្រះពុទ្ធសាសនា ត្រូវបានគេចាត់ទុកថាជាបណ្តុំនៃទស្សនវិជ្ជា។ ទស្សនវិជ្ជាទាំងនោះទាក់ទងនូវរាល់វិស័យទាំងអស់ក្នុងជីវិត ជាពិសេសទាក់ទងនិងសីលធម៌ ចរិយាធម៌ សតិអារម្មណ៍ និងតួនាទីរបស់មនុស្ស ឬសង្គហធម៌។*

*១.៣.១- កាលាមសូត្រ*

*សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ស្តេចទៅកាន់ចារិក ក្នុងកោសលជនបទ ជាមួយនិងភិក្ខុសង្ឃច្រើនអង្គ ក៏បានទៅដល់និគមឈ្មោះកេសបុត្រ របស់ពួកក្សត្រិយ៍ឈ្មោះកាលមៈ។ ពួកកាលាមក្សត្រិយ៍នៅក្នុងកេសបុត្រនិគម។ បានឮដំណឹងហើយ ប្រកាសប្រាប់គ្នាថា ម្នាលគ្នាយើងដ៏ចម្រើនបានឮថា ព្រះសមណគោតមជាសក្យបុត្រ ចេញពីសក្យត្រកូលបួស ហើយបានមកដល់កេសបុត្រនិគម កិត្តិសព្ទសរសើរ ព្រះគោតមដ៏ចម្រើននោះឯង ពីរោះល្បីខ្ចរខ្ចាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្តទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរជាងសត្វលោក ទ្រង់ ទូ*

ឆ្នានទូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត។ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ធ្វើឱ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយព្រះអង្គឯង នូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វព្រមទាំងពួកសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និង មនុស្សដ៏វិសេស ហើយអាចប្រកាសបាន ព្រះអង្គទ្រង់សម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង។ ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់។ ក៏ការណ៍ដែលបានឃើញបានជួបនិងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។

លំដាប់នោះ ពួកកាលាមក្សត្រិយ៍នៅក្នុងកេសបុត្រនិគម បានចូលទៅគាល់ព្រះដ៏មានព្រះភាគ។ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ ពួកខ្លះក៏ធ្វើសេចក្តីរីករាយ ជាមួយព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគអង្គុយក្នុងទីសមគួរ ពួកខ្លះប្រកាសនាម និងគោត្តអង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីសមគួរ។ លុះពួកកាលាមក្សត្រិយ៍ ក្នុងកេសបុត្រនិគម អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា «បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍មួយពួកមកកាន់កេសបុត្រនិគម សមណព្រាហ្មណ៍ទាំងនោះ សម្តែងប្រកាសនូវវាទៈ គឺលទ្ធិរបស់ខ្លួនឯង បៀតបៀនមើលងាយបង្អាប់បង្អោនលើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃ។ បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ដទៃមួយពួកទៀត មកកាន់កេសបុត្រនិគម សមណព្រាហ្មណ៍ទាំងនោះ ក៏សម្តែងប្រកាសនូវវាទៈរបស់ខ្លួនឯង បៀតបៀនមើលងាយ បង្អាប់បង្អោនលើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃដែរ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមានសេចក្តីងឿងឆ្ងល់សង្ស័យពេកណាស់ ចុះបណ្តាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ អ្នកនិយាយពិត អ្នកណានិយាយកុហក ម្នាលកាលាមក្សត្រិយ៍។ "អ្នកទាំងឡាយ ងឿងឆ្ងល់

ដែរ គួរសង្ស័យដែរ ព្រោះការងឿងឆ្ងល់ និងការសង្ស័យកើតឡើងដល់អ្នកទាំងឡាយក្នុងទីនេះហើយ" ។

ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់តម្រុយផ្សេងៗ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យ សមនិងសេចក្ដី យល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈ(នេះ) ជាគ្រូរបស់យើង។ ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះបុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះ អ្នកទាំងឡាយត្រូវលះបង់ចោលចេញ ។ (កាលាមសូត្រ ទំព័រទី ២១៨)

ទ្រឹស្ដីក្នុងកាលាមសូត្រ ជាទស្សនវិជ្ជាមួយដែលបង្រៀនឱ្យយើងចេះប្រើគំនិត មុននឹងកាន់ជឿលើអ្វីមួយ។ ទស្សនៈនេះមានសារៈសំខាន់ណាស់ សម្រាប់ពុទ្ធសាសនិករបស់ពុទ្ធសាសនា ក៏ដូចជាអ្នករៀនសូត្រទូទៅ ជាពិសេសសម្រាប់អាណាព្យាបាល របស់បុត្រធីតាទាំងឡាយក្នុងការប្រៀនប្រដៅ ចិញ្ចឹមបីបាច់ថែរក្សាកូនចៅរបស់ខ្លួន ដើម្បីចៀសនូវជំនឿគ្មានហេតុផលផ្សេងៗ។ ប្រទេសកម្ពុជា ពិតជាមានមនុស្សជាច្រើន បានប្រកាសខ្លួនជាពុទ្ធសាសនិក តែមានករណីជាច្រើនដែលអាណាព្យាបាលមួយចំនួនចិញ្ចឹមនិងបង្រៀនកូនមិនទាន់ពេញបរិបូរណ៍ ស្របតាមពុទ្ធវចនៈ។ មិនចាំបាច់និយាយដល់មាតាបិតា ដែលមិនបានសិក្សារៀនសូត្រនោះទេ សូម្បីតែព្រះសង្ឃ ភាគច្រើនពីអតីតកាលបានបង្រៀនសិស្សគណខ្លួនតាមបែបហិង្សាដែរ។ យើងធ្លាប់បានឮតៗគ្នាមកពីជំនាន់មុន បើសាមណេរ ឬសិស្សលោករៀនមិនចេះ ត្រូវទទួលទណ្ឌកម្មនិងរំពាត់ ឬលុតជង្គង់លើសំបកខ្នុរជាដើម។ នៅមានករណី នៃអំពើហិង្សាជាច្រើនប្រភេទទៀត ដែល

យើងធ្លាប់បានឮ និងជួបប្រទះ តែបទពិសោធន៍ទាំងនេះមិនមែនជាមធ្យោបាយល្អសម្រាប់សម័យទំនើបនេះឡើយ។

ដូច្នេះរាល់ជំនឿ និងទម្លាប់អាក្រក់ទាំងឡាយ គួរតែត្រូវបានកែប្រែ ដើម្បីឱ្យសង្គមជាតិមួយមានទម្លាប់ល្អ។ ជាពិសេស ការសិក្សាអំពីកាលាមសូត្រ នឹងធ្វើឱ្យអាណាព្យាបាលទាំងអស់ចេះគិតពិចារណា នឹងសម្លឹងទៅទិសដៅនៃអនាគតដ៏វែងឆ្ងាយ របស់បុត្រធីតាយើងគ្រប់គ្នា។

## ១.៣.២- សិង្គាលសូត្រ

សិង្គាលសូត្រ[៣] ជាសូត្រមួយដែលសម្តែងបញ្ជាក់ពីការរស់នៅរបស់សង្គមមនុស្ស និងការគ្រប់គ្រងសង្គមមនុស្សឱ្យទទួលបានសេចក្តីសុខនិងសេចក្តីចម្រើន។ ព្រះសម្មាសម្ពុទ្ធសម្តែងព្រះសូត្រនេះចំពោះសិង្គាលមាណព។ ពេលដែលបិតារបស់មាណពនេះហៀបនឹងធ្វើមរណកាល ក៏បានផ្តាំកូនឱ្យគោរពថ្វាយបង្គំទិសទាំងប្រាំមួយសព្វកាល។ បន្ទាប់ពីផ្តាំមាណពរួចមក បិតាក៏មរណកាលទៅ។ មាណពក៏យកសពបិតាទៅបូជាតាមសមគួរ។ ជារៀងរាល់ព្រឹក មាណពតែងធ្វើដំណើរទៅថ្វាយបង្គំទិសទាំងប្រាំមួយតាមបណ្តាំរបស់បិតា ។

ព្រះសម្មាសម្ពុទ្ធ បានប្រមើលមើលឃើញឧបនិស្ស័យរបស់មាណពនោះ ព្រះអង្គក៏ទៅប្រោស។ ព្រះពុទ្ធអង្គក៏យាងទៅគង់នៅក្រោមម្ចប់ឈើមួយដើម នៅទីជិតទឹកទន្លេងបូជាបិតារបស់មាណព។ ពេលព្រឹកឡើង មាណពក៏ធ្វើដំណើរទៅថ្វាយបង្គំ ទិសខាងកើត ទិសខាងត្បូង ទិសខាងលិច ទិសខាងជើង ទិសខាងលើ ទិសខាងក្រោម ដូចសព្វដង ប៉ុន្តែមិនយល់អត្ថន័យនៃទិសទាំងនោះទេ។ បន្ទាប់ពីថ្វាយបង្គំទិសទាំងនោះរួច មាណពក៏ឃើញព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្រោមដើមឈើនៅទីជិតនោះ ប្រកបដោយព្រះឥរិយាបថស្រគត់ស្រគំគួរជាទីជ្រះថ្លាក្រៃលែង។ ខណៈនោះ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកា

[៣] ព្រះសូត្រនេះមានសម្តែងក្នុងទីឃនិកាយ

*ទៅមាណពនោះដោយព្រះវាចាដ៏ពីរោះ រួចក៏ទ្រង់ត្រាស់សួរមាណពនោះថា **«តើអ្នកមកទីនេះ ដើម្បីប្រយោជន៍អ្វី?»**។ មាណពនោះឆ្លើយថា **«ខ្ញុំព្រះអង្គមកទីនេះ ដើម្បីថ្វាយបង្គំទិសទាំងប្រាំមួយតាមបណ្តាំរបស់លោកឪពុករបស់ខ្ញុំព្រះអង្គ»**។ ព្រះសម្មាសម្ពុទ្ធត្រាស់សួរបន្តថា ក្នុងសាសនារបស់តថាគតក៏មានសម្តែងពីទិសទាំងប្រាំមួយហ្នឹងដែរ **តើអ្នកចង់យល់ពីអត្ថន័យ នៃទិសទាំងប្រាំមួយនោះទេ?»**។ មាណពឆ្លើយថា**«បពិត្រព្រះអង្គ ខ្ញុំព្រះអង្គចង់ដឹង ចង់យល់ណាស់»**។ បើអ្នកចង់ដឹងចង់យល់ចូរអង្គុយមក តថាគតនឹងពន្យល់ឱ្យអ្នកយល់។ មាណពនោះ ក៏អង្គុយចុះដើម្បីត្រងត្រាប់ព្រះពុទ្ធដីកា។ ព្រះពុទ្ធអង្គ ទ្រង់សម្តែងបញ្ជាក់ពីការរស់នៅក្នុងសង្គម ពីកិច្ចដែលពុទ្ធសាសនិកទាំងឡាយគប្បី វៀរចាកអំពើអាក្រក់[៤] វៀរបង់អំពើដែលនាំឱ្យខាតបង់ទ្រព្យសម្បត្តិ[៥] និងសង្គហធម៌របស់មនុស្សដែលត្រូវសង្គ្រោះគ្នាទៅវិញទៅមក (មាតាបិតាចំពោះបុត្រៗចំពោះមាតាបិតា គ្រូចំពោះសិស្សៗចំពោះគ្រូ ស្វាមីចំពោះភរិយាៗចំពោះស្វាមី គ្រូចំពោះសិស្សៗចំពោះគ្រូ)។ បន្ទាប់ពីសិង្គាលមាណពបានស្តាប់រួចមក ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធដីកាយ៉ាងខ្លាំង។ គាត់ក៏បានថ្វាយខ្លួនជាឧបាសកយកព្រះរតនត្រៃជាទីពឹង ទីរលឹកស្មើដោយជីវិតចាប់ពីពេលនោះមក។*

**១.៤-អំពើហិង្សាលើកុមារនៅកម្ពុជា**

*តាមការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានកុមារកម្ពុជាជាងពាក់កណ្តាលធ្លាប់ទទួលរងយ៉ាងហោចណាស់មួយទម្រង់នៃអំពើហិង្សានៅមុនអាយុ១៨ឆ្នាំ។ មានកុមារកម្ពុជាប្រមាណជាមួយភាគបួនទទួលរងការរំលោភបំពានផ្លូវចិត្ត និង៥% ទទួលរងការរំលោភបំពានផ្លូវភេទមុនអាយុ១៨ឆ្នាំ។ ការអង្កេតលើអំពើហិង្សាលើកុមារនៅកម្ពុជាបានបង្ហាញថា ជាធម្មតាកុមារទទួលរងការរំលោភបំពានលើផ្លូវកាយពីមនុស្ស*

*[៤] កម្មកិលេស(អំពើនាំឱ្យសៅហ្មង) ៤យ៉ាងគឺ ១-វៀរចាកការសម្លាប់ ២-វៀរចាកលួចទ្រព្យសម្បត្តិអ្នកដទៃ ៣-វៀរចាកប្រព្រឹត្តចំពោះកូន ប្តី ប្រពន្ធអ្នកដទៃ ៤-វៀរចាកពោលពាក្យកុហក។*

*[៥] សំដៅដល់អបាយមុខ៦យ៉ាងគឺ ១-វៀរចាកផឹកទឹកស្រវឹង ២-វៀរចាកការដើរលេងយប់ ៣-វៀរចាកមើលល្បែង ៤-វៀរចាកល្បែងភ្នាល់ ៥-វៀរចាកយកមនុស្សអាក្រក់ជាគៀន ៦-វៀរចាកការខ្ជិលច្រអូស។*

ដែលពួកគេស្គាល់ និងជឿទុកចិត្ត ពោលគឺឪពុកម្តាយ (ជាពិសេសម្តាយ) និងគ្រូបង្រៀន (ជាពិសេសគ្រូប្រុស)តែម្តង។ អ្នកជិតខាង មិត្តភក្តិ គូកំណាន់ និងសមាជិកគ្រួសារ ត្រូវបានរកឃើញថា ជាអ្នកដែលប្រព្រឹត្តការរំលោភបំពានផ្លូវភេទញឹកញាប់ជាងគេលើកុមារ ពោលគឺមិនមែនជាជនចម្លែក[៦]ដែលកុមារមិនស្គាល់នោះទេ។ ចំពោះកុមារដែលទទួលរងអំពើហិង្សា ការអង្កេតនេះគូសបញ្ជាក់យ៉ាងច្បាស់លាស់ពីទំនាក់ទំនងរវាងអំពើហិង្សា និងផលវិបាកសុខភាពរយៈពេលខ្លី និងឥរិយាបថប្រថុយប្រថានសំខាន់ៗជាច្រើន ដោយអ្នកដែលទទួលរងអំពើហិង្សាច្រើននិយាយថា ពួកគេមានបញ្ហាផ្លូវចិត្តកម្រិតមធ្យម ជំងឺកាមរោគ ការបង្កគ្រោះថ្នាក់ ចំពោះខ្លួនឯង និងការគិតចង់ធ្វើអត្តឃាត។ ផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្ត អាចអូសបន្លាយពេលយូរ ក្រោយពេលដែលអំពើហិង្សាបានបញ្ចប់។

អំពើហិង្សាលើកុមារ គឺជាក្តីបារម្ភយ៉ាងធំធេងរបស់ប្រទេសកម្ពុជា។ អ្នកដែលពាក់ព័ន្ធក្នុងកិច្ចការដោះស្រាយនូវបញ្ហានេះ រួមមានសង្គមស៊ីវិលដែលធ្វើការទាក់ទងនិងអំពើហិង្សាលើកុមារ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវតែបន្តអនុវត្តន៍ឱ្យបានម៉ឺងម៉ាត់ និងរួមគ្នាចាត់វិធានការឱ្យបានតឹងរ៉ឹងបំផុត សំដៅលុបបំបាត់រហូតដល់កម្រិតអប្បបរមា នូវអំពើហិង្សា និងការរំលោភបំពានលើកុមារឱ្យបានទាន់ពេលវេលា និងបានល្អប្រសើរ។ ក្រសួងស្ថាប័នពាក់ព័ន្ធទាំងនោះរួមមាន ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការងារ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារផងដែរ។ ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើកុមារត្រូវតែជាសូចនាករស្នូលមួយ នៃការលើកកម្ពស់សេវាសង្គមរបស់ជាតិ។ សូចនាករនេះ គួរតែជាព័ត៌មានយោងសម្រាប់គ្រប់វិស័យទាំងអស់របស់រាជរដ្ឋាភិបាល សម្រាប់ការរៀបចំថវិកាផងនិងយន្តការសម្របសម្រួលដែលពាក់ព័ន្ធ ដោយមានការដាក់ចេញនូវផែនការពិនិត្យតាម

[៦] របបគំហើញនៃការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារឆ្នាំ២០១៣

ដាន និងវាយតម្លៃច្បាស់លាស់ដើម្បីវាយតម្លៃវឌ្ឍនភាព និងរក្សានូវជោគជ័យដែលសម្រេចបានកន្លងមក។

មានយុទ្ធសាស្ត្រចំនួន៦ ដែលមានសារៈសំខាន់សម្រាប់ធ្វើការលុបបំបាត់អំពើហិង្សាលើកុមារដូចជា ៖

១- គាំទ្រឪពុកម្ដាយ អ្នកផ្ដល់សេវា ថែទាំ និងគ្រួសារ។

២- ជួយកុមារ និងក្មេងជំទង់គ្រប់គ្រងហានិភ័យ និងបញ្ហាប្រឈម។

៣- ផ្លាស់ប្ដូរឥរិយាបថ និងបទដ្ឋានសង្គមដែលលើកទឹកចិត្តឱ្យមានអំពើហិង្សា។

៤- លើកកម្ពស់ និងផ្ដល់សេវាគាំទ្រដល់កុមារ។

៥- អនុវត្តច្បាប់ និងគោលនយោបាយដែលការពារកុមារ។

៦- កសាង ឬអភិវឌ្ឍប្រព័ន្ធទិន្នន័យរឹងមាំ និងភ័ស្ដុតាងច្បាស់លាស់សម្រាប់ទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។

អំពើហិង្សាលើកុមារ មិនត្រឹមតែមានផលប៉ះពាល់លើកុមារជាជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យខាតបង់ដ៏ច្រើនលើសលប់ ដល់សង្គមទៀតផង។ អំពើហិង្សាលើកុមារកំពុងបង្វែរប្រាក់រាប់ពាន់លានដុល្លារពីការចំណាយលើបុព្វហេតុសង្គម ហើយកត្តានេះធ្វើឱ្យល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច ថយចុះធ្វើឱ្យបាត់បង់ធនធានមនុស្ស និងសង្គម។ ការស្រាវជ្រាវបង្ហាញថា ក្នុងឆ្នាំ២០១៣ យ៉ាងហោចណាស់កម្ពុជាខាតបង់ថវិកាចំនួន១៦៨លានដុល្លារ ដោយសារតែផលវិបាកផ្នែកសុខភាព មួយចំនួនបង្កដោយអំពើហិង្សាលើកុមារ។ អំពើហិង្សាកាលពីកុមារភាពបាន បណ្ដាលឱ្យខាតបង់ផលិតភាពគិតជាសាច់ប្រាក់ចំនួន ៨៣.៣ លានដុល្លារ[៧]។

ផលចំណេញផ្នែកសេដ្ឋកិច្ច ដែលទទួលបានពីការវិនិយោគលើការអភិវឌ្ឍ កុមារតូច បច្ចុប្បន្ននេះត្រូវបានគេដឹងយ៉ាងច្បាស់ ប៉ុន្តែអំពើហិង្សាបានបង្អាក់យ៉ាងធ្ងន់ធ្ងរដល់

---

[7] ក្រសួងកិច្ចការនារីៈ បន្ទុកសេដ្ឋកិច្ចចំពោះផលវិបាកផ្នែកសុខភាព នៃអំពើហិង្សាលើកុមារ ក្នុងប្រទេសកម្ពុជា បោះពុម្ពឆ្នាំ២០១៥

*កុមារក្នុងការសម្រេចសក្តានុពលពេញលេញរបស់ពួកគេ ដែលនាំឱ្យមានការខាតបង់យ៉ាងសម្បើមដល់សង្គមជាតិ។ ការបញ្ឈប់អំពើហិង្សាលើកុមារ គឺជាលក្ខខណ្ឌក្រមសីលធម៌ចាំបាច់ ហើយក៏ផ្តល់ប្រយោជន៍សេដ្ឋកិច្ចផងដែរ ដូចដែលតួលេខបានបង្ហាញ។*

**១.៥-បទដ្ឋានគតិយុត្តនានាស្តីពីកុមារ**

*បទដ្ឋានគតិយុត្តនានាស្តីពីកុមារ សំដៅដល់ច្បាប់ វិធាន និង បទបញ្ញាទាំងឡាយស្តីពីកុមារដែលបានបង្កើតឡើងដោយរដ្ឋ ដែលមានឥទ្ធិពលក្នុងការអនុវត្តទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើស ឬរំលោភបំពានទៅលើកុមារ។ ប្រទេសកម្ពុជាបានទទួលយកច្បាប់អន្តរជាតិ និងច្បាប់ជាតិមកអនុវត្ត។*

***១.៥.១- ច្បាប់អន្តរជាតិ***

*កម្ពុជាបានផ្តល់សច្ចាប័នច្បាប់អន្តរជាតិដែលពាក់ព័ន្ធមួយចំនួនដល់កុមារដូចខាងក្រោម៖*

- *អនុសញ្ញាស្តីពីសិទ្ធិកុមារ*
- *ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ*
- *ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ*
- *អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងពិធីសារបន្ថែម*
- *ពិធីសារចំពោះការទប់ស្កាត់បង្ក្រាប និងដាក់ទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមទៅលើអង្គការសហប្រជាជាតិ*
- *សន្ធិសញ្ញា ILO លេខ១៨២ ស្តីពីការហាមឃាត់ពលកម្មកុមារ និងវិធានការបន្ទាន់សម្រាប់ លុបបំបាត់ រាល់ទម្រង់អាក្រក់បំផុតនានា នៃពលកម្មកុមារ។*

### ១.៥.២- ច្បាប់ជាតិ

ច្បាប់ក្នុងប្រទេសកម្ពុជាថ្មីៗនេះ មិនមានច្បាប់ការពារកុមារ ដាច់ដោយឡែកមួយឡើយ។ ច្បាប់នានាពីការការពារកុមារ ដែលបានប្រើក្នុងប្រទេស គឺមានទ្រង់ទ្រាយតូចបំផុត ប៉ុន្តែស្មុគស្មាញ និងកប់នៅក្នុងច្បាប់ផ្សេងៗជាច្រើនទៀត ទាំងច្បាប់ជាតិ និងអន្តរជាតិ។ ច្បាប់ផ្សេងៗគ្របដណ្តប់ត្រឹមតែផ្នែកមួយចំនួន នៃការការពារកុមារប៉ុណ្ណោះ។ ផ្នែកទាំងនេះរួមមានៈ

#### ក- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បន្ថែមលើច្បាប់នានាខាងលើ រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល នៃប្រទេសកម្ពុជាបានចែងក្នុងមាត្រាមួយចំនួនដូចខាងក្រោមដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ ៖

- រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំង នឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយ ដល់សុខភាព ឬសុខុមាលភាពរបស់កុមារ (មាត្រា៤៨)។
- រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ (មាត្រា៤៦)។
- មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ (មាត្រា៤៧)។
- រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង (មាត្រា៧៣)។

## ខ- ទេសចរណ៍ផ្លូវភេទលើកុមារ

ប្រទេសកម្ពុជា មិនមានច្បាប់ដែលដាក់ទោសចំពោះករណីទេសចរណ៍ផ្លូវភេទលើកុមារទេ។ ប៉ុន្តែមានមាត្រាមួយចំនួន នៅក្នុងច្បាប់ពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ អាចនឹងត្រូវប្រើដើម្បីនាំជនល្មើសអំពើផ្លូវភេទ កុមារ និងអ្នកសមគំនិត ក្នុងករណីទេសចរណ៍ផ្លូវភេទកុមារមកកាត់ទោស។ ឧទាហរណ៍ ដូចជា មាត្រា២៨ ៣៤ ៣៦-៣៧ ជាដើម។

## គ- ពេស្យាកម្ម

ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ដាក់ទោសទណ្ឌមួយចំនួនទាក់ទងនិងករណីពេស្យាកម្មអនីតិជន (ក្រោមអាយុ១៨ឆ្នាំ)។ វាជាការណ៍មួយដែលមានទោសក្នុងការដែលៈ

- ផ្តល់ពេស្យាកម្មកុមារដល់នរណាម្នាក់ ទិញពេស្យាកម្មកុមារ (មាត្រា២៨, ៣៣-៣៧)

-ផ្តល់ពេស្យាកម្មដោយការធ្វើទារុណកម្ម(មានការធ្វើទារុណកម្ម បើមិនព្រមទទួលភ្ញៀវ) មាត្រា២៩

-គ្រប់គ្រងពេស្យាកម្មកុមារ ឬគ្រប់គ្រងផ្ទះបនសម្រាប់ពេស្យាកម្មកុមារ ឬផ្តល់ទីតាំងសម្រាប់កុមារពេស្យាកម្មកុមារ ហៅភ្ញៀវឱ្យមកទិញពេស្យាកម្មកុមារ (មាត្រា៣០-៣២) ។

## ឃ- ការរំលោភបំពានផ្លូវភេទ និង ការបៀតបៀនផ្លូវភេទកុមារ

ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ចែងថា នឹងមានទោសក្នុងការៈ

- សេពសន្ថវៈជាមួយនឹងអនីតិជនក្រោម១៥ឆ្នាំ (មាត្រា៣៣-៣៧)។
- ប្រព្រឹត្តអំពើអាសទៅលើអនីតិជនក្រោម១៥ឆ្នាំ (មាត្រា៤២-៤៣)។ ច្បាប់នេះ ក៏បានកំណត់និយមន័យ អំពើអាស ថា ជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរ-

ភេទ ឬផ្នែកភេទផ្សេងទៀត របស់ជនដទៃ ឬការឱ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬតតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬរីករាយ ដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

### ង- ការផលិតចែកចាយរូបភាពអាសអាភាសកុមារ

ច្បាប់ពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ដាក់ទោសទណ្ឌមួយចំនួន ទាក់ទងនិងករណីផលិតចែកចាយរូបភាពអាសអាភាសអនីតិជនដែលរាប់បញ្ចូលសកម្មភាពដូចខាងក្រោម (មាត្រា៣៨-៤១)៖

- ចែកចាយ ដឹកជញ្ជូន លក់ ជួល បង្ហាញ បញ្ចាំងរូបភាពអាសអាភាសកុមារនៅតាមទីសាធារណៈ
- មានជាកម្មសិទ្ធិ ដឹកជញ្ជូន នាំចូល ឬនាំចេញរូបភាពអាសអាភាសកុមារដើម្បីប្រើក្នុងការប្រព្រឹត្តបទល្មើសខាងលើ
- ផលិតរូបភាពអាសអាភាសកុមារដើម្បីប្រើក្នុងការប្រព្រឹត្តបទល្មើសខាងលើ
- ផលិតរូបភាពអាសអាភាសកុមារ។

### ច- ការជួញដូរកុមារសម្រាប់គោលបំណងផ្លូវភេទ

ច្បាប់ពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ដាក់ទោសទណ្ឌមួយចំនួនទាក់ទងនឹងករណីជួញដូរមនុស្ស។ អ្នកប្រព្រឹត្ត និងអ្នកសមគំនិតទទួលទោសកម្រិតដូចគ្នា។ បើជនរងគ្រោះជាអនីតិជន គឺត្រូវជាប់ពន្ធនាគារពី១៥ឆ្នាំ ទៅ២០ឆ្នាំ។ (សូមអានមាត្រា២៣-៣៧)

### ឆ- ពលកម្មកុមារ

ច្បាប់ការងាររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៧ មានជំពូកផ្សេងៗគ្នាទាក់ទងនឹងពលកម្មកុមារ (សូមអានមាត្រាពាក់ព័ន្ធមួយចំនួន ១៧៣ ១៧៥ ១៧៧-១៨០ ១៨៤ ១៨៦ ៣៦៨)៖

- អាយុដែលអាចធ្វើការងារបានយ៉ាងតិចណាស់ក៏១៥ឆ្នាំ ប៉ុន្តែកុមារអាយុចន្លោះពី១២ ទៅ ១៥ឆ្នាំ អាចធ្វើការងារស្រាលៗបានដែលមិនគ្រោះថ្នាក់ (មិនមានការកំណត់ច្បាស់លាស់អំពីពាក្យគ្រោះថ្នាក់នៅក្នុងច្បាប់នេះទេ) និងដែលមិនប៉ះពាល់ដល់វត្តមាននៅសាលា ឬ កម្មវិធីបណ្តុះបណ្តាលផ្សេងៗ។
- បញ្ជីឈ្មោះកុមារធ្វើការក្រោមអាយុ១៨ឆ្នាំ ត្រូវតែទុកដោយនិយោជក និងប្រគល់ឱ្យអធិការដ្ឋានការងារ។ កុមារទាំងនេះត្រូវតែមានការយល់ព្រមពីអាណាព្យាបាលរបស់ពួកគេក្នុងការធ្វើការងារនេះ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលខុសត្រូវក្នុងការពង្រឹងកុមារ នៃច្បាប់ការងាររបស់កម្ពុជា។ ប៉ុន្តែច្បាប់ការងារអនុវត្តបានត្រឹមតែទំនាក់ទំនងផ្លូវការ រវាងនិយោជិក និងនិយោជកប៉ុណ្ណោះ វាមិនបានគ្របដណ្តប់ផ្នែកជាច្រើនទៀត នៃការងារមិនផ្លូវការ ដូចជាក្នុងរបររកស៊ីក្នុងគ្រួសារ ការដាំដុះក្នុងគ្រួសារ ការសុំទាន ការដើររើសអេតចាយ ការអូសរទេះ និងការធ្វើការងារនៅពេលថ្ងៃដែលបញ្ហាពលកម្មកុមារធ្ងន់ធ្ងរបំផុតកើតមាន។

## ជ- អំពើហិង្សាក្នុងគ្រួសារ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ អនុវត្តចំពោះអំពើហិង្សារវាងសមាជិកក្នុងរង្វង់គ្រួសារ និង អំពើហិង្សា ចំពោះកុមារ នៅក្នុងរង្វង់គ្រួសារនោះផងដែរ។ វាអនុវត្តចំពោះការរំលោភបំពានផ្លូវកាយ អារម្មណ៍ សេដ្ឋកិច្ច និងផ្លូវភេទរួមទាំងការបង្ខិតបង្ខំ ការបៀតបៀន និងការធ្មក់ចាប់។ វាក៏គ្របដណ្តប់ការបម្រើការងារនៅតាមផ្ទះផងដែរ។

## ឈ- ការសុំកូនអន្តរប្រទេស

ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវបានអនុម័តនៅឆ្នាំ២០០៩។ ច្បាប់នេះមានគោលបំណងធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលជាកម្មវត្ថុនៃការសុំកូនអន្តរប្រទេស។ ច្បាប់នេះកំណត់អាយុកុមារ ដែលអាចសុំបានត្រូវមានអាយុក្រោម៨ឆ្នាំ។ កុមារអាយុក្រោម១៨ឆ្នាំអាចសុំបាន នៅក្នុងករណីកុមារត្រូវការថែទាំ

ពិសេស ឬមានបងប្អូនបង្កើតច្រើននាក់ដែលម្នាក់មានអាយុក្រោម៨ឆ្នាំ ឬអ្នកសុំជាសាច់ញាតិដែលជាពូ មីង តា យាយ ឬចាស់ព្រឹទ្ធាចារ្យរបស់កុមារ។ ច្បាប់នេះក៏បានហាម ការធ្វើអាជីវកម្ម ឬធ្វើសកម្មភាពយកកម្រៃពីការសុំកូនអន្តរប្រទេស។

ញ- ការមិនអើពើ

នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា១០៤៨ ស្តីពីការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា បានចែងថា បើឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬបើបានធ្វេសប្រហែសក្នុងការបំពេញករណីកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬ ដកហូតអំណាច មេបាតាមការទាមទាររបស់ញាតិក្នុង៤ថ្នាក់របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន។

ដ- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់នេះផ្តោតសំខាន់ទៅលើយុត្តិធម៌អនីតិជនប្រព្រឹត្តបទល្មើស(មាត្រា៣) កំណត់គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជនប្រព្រឹត្តបទល្មើស (មាត្រា៥ និង ៦) ណែនាំអាជ្ញាធរពាក់ព័ន្ធឱ្យប្រើប្រាស់ជម្រើសផ្សេង ក្រៅពីការចាប់ និងឃុំខ្លួន (មាត្រា ១៣-១៤ ២៧-២៨ ៣៨-៣៩ ៤១ ៤៩ ៥២ និងជំពូកទី១០ជាដើម)។

**១.៦-សង្ខេបមេរៀន**

កុមារគឺជាក្តីសង្ឃឹមរបស់យើងគ្រប់គ្នាសម្រាប់បន្តវេន សម្រាប់គ្រួសារ ព្រះពុទ្ធសាសនា សង្គម និងជាអ្នកបន្តពូជមនុស្សនៅលើផែនដី[៨]។ ប៉ុន្តែដើម្បីបានអ្នកបន្តវេន ក្តីសង្ឃឹម និងជាគ្រាប់ពូជដ៏ល្អនោះ លុះត្រាតែអាណាព្យាបាល មាតាបិតា សង្គមធ្វើជាគំរូដ៏ល្អរបស់ពួកគេ។ ការធ្វើជាគំរូពុំមែនជាការងាយស្រួលនោះឡើយ គឺទាមទារឱ្យអាណា

[៨] ខ្លឹមសាររបស់ព្រះសុមេធវង្ស បណ្ឌិត សុខ ប៊ុនធឿន ថ្ងៃក្នុងសន្និសីទអន្តរជាតិស្តីពី ជំងឺអេដស៍និងសិទ្ធិកុមារឆ្នាំ២០០៨។

ព្យាបាលចំណាយពេលវេលា ស្វែងយល់នូវវិធីសាស្ត្រ នៃការចិញ្ចឹមក្មេងតាមបែបវិជ្ជមាន និងលះបង់នូវទម្លាប់អាក្រក់នានាហើយដែលទម្លាប់ខ្លះនោះ បានកប់ជ្រៅទៅក្នុងសន្តានចិត្ត ឬក្លាយជាទំនៀមទម្លាប់សម្រាប់បង្រៀនកុមារឱ្យធ្វើអាក្រក់ ដោយពុំដឹងខ្លួនទៀត ផង។ ការចិញ្ចឹមកូនមិនបានល្អអាចនឹងក្លាយជាផលវិបាកដ៏ធំ សម្រាប់អនាគតកូន ក៏ដូចជាគ្រួសារសង្គមជាតិទាំងមូលផងដែរ។

ដើម្បីចិញ្ចឹមកូនបានល្អ អាណាព្យាបាលត្រូវស្វែងយល់ពីខ្លួនឯង សិក្សាពីគំនិតល្អៗពីអ្នកដទៃ ជឿនូវរបៀបមើលថែកូនដែលគួរជឿ ដោយស្វែងយល់ពីហេតុផល ឱ្យបានច្បាស់លាស់។ ច្បាប់ជាតិ ច្បាប់អន្តរជាតិនានា ក៏ជាប្រភពដែលផ្តល់គំនិត និងជាឧបករណ៍សម្រាប់វាស់វែងការគាំពារក្នុងកិច្ចបីបាច់ថែរក្សាការពារដល់សិទ្ធិសេរីភាពរបស់កុមារឱ្យរួចពីការរំលោភបំពាននានា។ ម្យ៉ាងទៀតប្រជាជនភាគច្រើនបានគោរពព្រះពុទ្ធសាសនា ហើយក្នុងព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅដ៏ល្អៗជាច្រើន ដែលប្រកបដោយទស្សនៈនៃការអប់រំដល់ជីវភាពរស់នៅល្អរបស់មនុស្ស សត្វ រុក្ខជាតិ ជាពិសេស សម្រាប់កុមារតែម្តង។

កុមារប្រៀបដូចជាការវស់មួយដែលសស្អាត ប្រសិនបើផ្តិតនូវពណ៌អ្វីភ្ជាប់ទៅហើយ ពណ៌នោះនឹងជាប់ជាមួយកុមារនោះហើយ។ យើងពិតជាចង់ឱ្យកុមារនាបច្ចុប្បន្ននេះ ក្លាយជាមនុស្សសំខាន់សម្រាប់សម័យកាលក្រោយ ហើយប្រាថ្នាឱ្យពួកគេក្លាយជាមនុស្ស ដែលចេះទទួលខុសត្រូវខ្ពស់ និងដោះស្រាយបញ្ហាអ្វីៗ ទាំងបញ្ហាផ្ទាល់ខ្លួន និងបញ្ហាជាតិនានាប្រកបដោយបញ្ញាញាណ មេត្តា និងអហិង្សា។

**១.៧-សំណួរត្រិះរិះ**

១. ហេតុដូចម្តេចបានជាបុរាណប្រៀបធៀបកុមារជាទំពាំងស្នងឬស្សី? ចូរពន្យល់!

២. តើកុមារ មានន័យថាដូចម្តេច?

៣. ដូចម្តេចដែលហៅថាអំពើហិង្សាលើកុមារ?

៤. តើការការពារកុមារមានន័យដូចម្តេច?

៥. តើពុទ្ធសាសនាបាននិយាយអំពីការទប់ស្កាត់ហិង្សាលើកុមារដែរឬទេ? ចូរបង្ហាញ!

៦. តើមានច្បាប់ណាខ្លះដែរ និយាយដល់ការការពារដែលត្រូវបានគេរំលោភបំពាន?

# ជំពូក២៖ អំពើហិង្សាលើកុមារ

## គោលបំណង

*ក្រោយពីសិក្សានូវជំពូកនេះ សមណ និស្សិត និស្សិតនឹងទទួលបាន៖*

- *ការយល់ដឹងបានច្បាស់អំពីប្រភេទនិងផលប៉ះពាល់នៃអំពើហិង្សាលើកុមារ*
- *ការយល់ដឹងពីជំនឿគ្មានហេតុផល ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកុមារ*
- *ការយល់ដឹងពីរបៀបនៃការបញ្ចៀស និងទប់ស្កាត់អំពើហិង្សាលើកុមារ*
- *ការយកទ្រឹស្តីទាំងនេះ ធ្វើបញ្ចាំងសកម្មភាពជាក់ស្តែងនៅតាមសហគមន៍*

## សេចក្តីផ្តើម

*អំពើហិង្សាកំពុងជាក្តីបារម្ភសម្រាប់ពិភពលោកទាំងមូល។ ដោយឡែកកម្ពុជា ជាប្រទេសមួយ ក្នុងចំណោមបណ្តាប្រទេសហត្ថលេខីទាំងឡាយនៅលើពិភពលោកនៃអនុសញ្ញាស្តីពីកុមារឆ្នាំ១៩៨៩។ កម្ពុជាមានកាតព្វកិច្ចក្នុងការអនុវត្តដើម្បីឆ្លើយតប ដោះស្រាយបញ្ហាកុមារស្របតាមអនុសញ្ញាស្តីពីកុមារនេះ។ ការស្វែងយល់នូវឫសគល់ នៃបញ្ហា ទាមទារឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងនោះក្រសួងធម្មការ និងសាសនា និងគណៈសង្ឃនាយក បានរួមចំណែកយ៉ាងសកម្មក្នុងការបង្ការ ទប់ស្កាត់អំពើហិង្សាលើកុមារ។*

## ២.១- ជំនឿ និងការពិតនៃអំពើហិង្សាលើកុមារ

*ក្នុងបរិយាកាសនៃអំពើហិង្សា មានករណីខ្លះបណ្តាលមកពីជំនឿក្នុងទម្លាប់ និងអាកប្បកិរិយា ប្រកបដោយភាពអវិជ្ជមាន និងភាពរើសអើងហួសហេតុ មិនគួររក្សាទុក តទៅទៀត ។ ជាឧទាហរណ៍៖*

- *ការប្រើទឹកក្រូចឆ្មាដាក់លើភ្នែកទារក*
- *ការដាក់កាំបិតមុតស្រួច លើក្បាលដំណេកកុមារ*

- ការកាត់រោមភ្នែកទារក ដើម្បីឱ្យទារកមានរោម ភ្នែកវែង
- នៅពេលទារកគេងលក់ មានការញញឹមក៏ស្រែកដាក់ទារក
- ការបិទសម្បុកឆ្កែញាំង សម្បុកពីងពាង លើផ្ចិតទារក
- ការជួសពិសអាចម៍កុក ដើម្បីកម្ចាត់មេរោគក្នុងពោះ
- ការកោសខ្យល់ដោយប្រើប្រេងកាត ម្ទូ ប្រេងកូឡា ប្រេងដូង ដើម្បីកម្ចាត់ជំងឺ ផ្តាសាយ គ្រុន ឈឺក្បាល...
- ការមិនឱ្យកូនបៅទឹកដោះព្រៃ (ទឹកដោះដំបូង)
- ការចេញដើរនៃទារកមុនខួប (អាយុមួយឆ្នាំ) មិនល្អ
- ការផឹកថ្នាំខ្មែរ ឬផឹកស្រាថ្នាំ ដើម្បីឱ្យងាយស្រួលក្នុងការសម្រាលបុត្រ
- ការនិយាយពាក្យសរសើរកូនក្នុងផ្ទៃ នៅពេលម្តាយកំពុងមានផ្ទៃពោះ
- ពេលស្ត្រីមានផ្ទៃពោះទិញអីវ៉ាន់ ត្រូវជុតក្រដាសបណ្តេញចង្រៃ ឧបទ្រពទាំងពួង
- កូនប្រុសត្រូវតែមិនស្រក់ទឹកភ្នែក
- ពេលមានឧបសគ្គក្នុងគ្រួសារចោទថា «មកពីកូនចង្រៃ មកចាប់កំណើត»
- ការលេងប្រដាប់ភេទកុមារថា «ជាសញ្ញានៃការស្រឡាញ់»
- ការបន្ទាចក្មេង ក្នុងបំណងមិនឱ្យធ្វើអ្វីមួយ
- មិនឱ្យក្មេងទទួលយកការបរាជ័យ
- ការមិនហ៊ានសរសើរទារកថា «កូនឆ្លាត កូនល្អ កូនសំណាង»
- ការទប់ស្កាត់ហាមឃាត់ មិនឱ្យកូនធ្វើអ្វីមួយដែលខ្លួនមិនពេញចិត្ត ដោយពុំបានបញ្ជាក់ពីដែនកំណត់
- ក្មេងខូច ត្រូវប្រើធម៌ក្តៅ ឬប្រើហិង្សា
- ការវាយ ស្តី ការជេរ ការបន្ទោស ដើម្បីឱ្យកុមារល្អ

- ក្មេងត្រូវស្ដាប់ចាស់ ធ្វើតាមចាស់ ទើបល្អ
- ក្មេងពុំគួរឆ្ងល់ ឬសួរច្រើនពេកទេ កុំចង់ដឹងច្រើន
- ក្មេងគិតមិនបានជ្រៅដូចចាស់ៗទេ កុំឱ្យវាដឹង
- កុំសរសើរក្មេង នាំឱ្យវាបានចិត្ត
- ចូរនិយាយឱ្យកុមារឈឺចាប់ ទើបវាក្លាយជាមនុស្សល្អ
- បើកុមារជួបការលំបាក កុំជួយវា
- ការខោកក្បាល ទាត់ ញ៉ឹងស្ទីកត្រចៀក ការបង្អត់បាយ បង្អត់ទឹក ការដាក់ទោស ឱ្យស្រមោចក្ងើងខាំ ឱ្យឈរកណ្ដាលថ្ងៃក្ដៅ ឬលុតជង្គង់អង្វរសុំទោស នៅពេល កុមារមានកំហុសតិចតួច
- ការជៀលដល់ពូជ ត្រកូល ម៉ែឪ
- ការប្រើឱ្យកុមារចេះសង់សឹក ចំពោះកុមារដូចគ្នា
- ការឱ្យកូនខ្លួន យកឈ្នះលើគេគ្រប់ជំហាន
- ការមិនឱ្យក្មេង និយាយពាក្យអាក្រក់ពីចាស់ៗ
- ការឱ្យក្មេងស៊ីចុងអំពៅ ឆាប់ចេះហែលទឹក
- ការមិនឱ្យក្មេងៗចូលរួម ក្នុងពេលសម្រាលបុត្រ

ប្រការខាងលើនេះ គឺជាទម្លាប់ដែលសង្គមខ្មែរធ្លាប់ប្រើកន្លងមកចំពោះកុមារ ដោយពុំបានគិតថាវាជាការបំពាន និងជាអំពើហិង្សាចំពោះកុមារទេៗ ការពិតរឿងរ៉ាវទាំងអស់នេះវាពុំមែនជាមាគ៌ា ឬគន្លងប្រកបដោយក្ដីស្រឡាញ់កុមារ ឬការគាំទ្រផ្លូវចិត្តកុមារទេៗ តាមទ្រឹស្ដីពុទ្ធសាសនា ការជឿត្រូវឈរលើលក្ខណៈវិនិច្ឆ័យ វិចារវិទ្យា ទស្សនវិជ្ជា ចិត្តវិទ្យា និងបដិច្ចសមុប្បាទធម៌ៗ ការនិយាយស្ដី ការធ្វើការអនុវត្ត និងការគិតត្រូវតែមានការសង្កេត ទៅតាមហេតុផលរបស់វាៗ ការប្រើខុស ការពោលខុស ការគិតខុស ជា

ទោសនៃអវិជ្ជមាន ឬភាពល្ងង់ខ្លៅ។ បុគ្គលជាបណ្ឌិតបើមុននឹងធ្វើអ្វីមួយមានការពិសោធន៍ តាមប្រព័ន្ធវិទ្យាសាស្ត្រប្រកបដោយកោសល្យវិច្ច័យពិតៗ ។

ដើម្បីទប់ស្កាត់ការយល់ខុស ការធ្វើខុស ការពោលខុស យើងគប្បីស្វែងរក ឬទៅជួបកវីបណ្ឌិត ដែលមានជំនាញឱ្យជួយផ្តល់ការប្រឹក្សា ឬផ្តល់អនុសាសន៍ ឱ្យបានមុនជាដាច់ខាត។ ការយល់ខុស ការគិតខុស ការពោលខុស ការព្យាយាមខុសនាំឱ្យមានទស្សនៈខុស អារម្មណ៍មិនច្បាស់ សតិមិនល្អចំពោះខ្លួនឯងហើយក៏អាចឱ្យបុគ្គលដទៃយល់ដូចខ្លួន បណ្តាលឱ្យធ្លាក់ដល់ការអន្តរាយខ្លួន និងអ្នកដទៃទៀតផង។ រាល់គំរូអាក្រក់ ទោះប្រកបដោយចេតនាក្តី អចេតនាក្តី គឺវិនាសអន្តរាយដូចៗគ្នា មានទោសដូចៗគ្នា ។

ចំពោះជំនឿ ឬសច្ចធម៌នេះ ក្នុងទ្រឹស្តីពុទ្ធសាសនាបានពន្យល់យ៉ាងច្បាស់លាស់ ដែលនឹងបង្ហាញនៅក្នុងជំពូកក្រោយៗទៀត (ជំពូក២) នៃមេរៀន ។

យើងជាអ្នកកង្វល់អំពីការប្រើការរំលោភបំពានដោយហិង្សាលើកុមារ គប្បីបញ្ចៀសអ្វីនៅក្នុងភាពស្រពិចស្រពិល ភាពផ្សងព្រេងដែលនាំឱ្យខាតប្រយោជន៍ដល់កុមារ។ ឧទាហរណ៍ ទឹកក្រូចមានសារជាតិកាត់សាច់ទៅ ឱ្យទៅជាសាច់ធ្មិនបានគេហៅថា «ជាតិអាស៊ីត»។ អាស៊ីដ អាចកាត់ដែក សាច់ ហើយនាំឱ្យខូចដល់ប្រព័ន្ធក្អែក។

អាស្រ័យហេតុនេះ ការជឿត្រូវមានសច្ចធម៌ ត្រូវមាននិយាមព័ត៌មានពិតប្រកបដោយមូលដ្ឋានច្បាស់លាស់ បើពុំដូច្នោះយើងក៏មានបាប អ្នកទទួលរងគ្រោះក៏ខូចតម្លៃជីវិតជារៀងរហូត ។

### ២.១.១- ការរស់នៅរបស់កុមារជាមួយអំពើហិង្សា

អំពើហិង្សា បានដល់សកម្មភាព អំពើ ការងារ ដែលធ្វើឱ្យមានការរំលោភបំពាន និងការធ្វើឱ្យមានផលប៉ះពាល់ដល់កុមារ ទោះបីស្ថិតនៅទម្រង់ណាមួយក៏ដោយ ឱ្យតែសកម្មភាពនោះ ប៉ះពាល់ដល់ផលប្រយោជន៍របស់កុមារ ។

តាមការបង្ហាញរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលអ្នកពិគ្រោះបញ្ហា និងបុគ្គលិកសង្គមកិច្ចបានឱ្យដឹងថា កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ ទទួលរងការរំលោភបំពាន ទាំងផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត ផ្លូវភេទ ផ្លូវអារម្មណ៍ ការរើសអើង និងការស្អប់ខ្ពើមជាដើម។ អំពើនោះ បានបង្ហាញឱ្យឃើញតាមទិដ្ឋភាពនានាដូចជា

- ការប្រមាថមាក់ងាយដល់កុមារ
- ការគំរាមកំហែងដល់កុមារ
- ការដាក់ឱ្យបិតនៅក្នុងភាពឯកោអនាថា
- ការធ្វើឱ្យកុមារបាត់បង់ឥស្សរភាព និងសិទ្ធិក្នុងការរស់នៅ
- ការធ្វើឱ្យកុមារបាត់បង់ជីវភាព សេដ្ឋកិច្ច សុខាភិបាល សុខភាព ការសិក្សា និងការទទួលបាននូវសេវាកម្មផ្សេងៗ ក្នុងលក្ខណៈប្រយោល ឬផ្ទាល់ពីគ្រួសារ។

អំពើហិង្សានេះ ផ្តល់ផលប៉ះពាល់ដល់កិច្ចការពារកុមារទាំងស្រុង ព្រោះកុមារត្រូវទទួលបាននូវៈ

- ការគាំទ្រផ្លូវចិត្ត ក្នុងទង្វើណាមួយជាវិជ្ជមាន ដូចជាពេលកុមារកំពុងមានការភ័យខ្លាច កំពុងឯកោ កំពុងមានទុក្ខព្រួយ
- ការអភិវឌ្ឍខួរក្បាល បញ្ញាញាណ គំនិតអភិវឌ្ឍ និងស្ថិតនៅក្នុងបរិយាកាសដ៏ល្អ មិនប៉ះពាល់ហិង្សានានា

- ការទប់ស្កាត់នូវពល់សកម្មភាព សំឡេង ព្រឹត្តិការណ៍ ឬឧបទ្ទវហេតុដែលនាំឱ្យរំខានដល់ផ្លូវចិត្តរបស់កុមារ
- ការគេចផុតពីអំពើហិង្សានានា ដែលកើតមានក្នុងគ្រួសារ ឬសង្គម
- ការបិទបាំងបរិយាកាស ដែលមានអ្នកចិញ្ចឹម ឬអាណាព្យាបាល មានលេចចេញអំពើ ឬទម្រង់ណាមួយក្នុងរង្វង់គ្រួសារ ឬអ្នកជិតខាង។

ប្រវត្តិរបស់ប្រទេសកម្ពុជាមានចំណុចសំខាន់ៗ ទាក់ទងដល់ការរំលោភបំពានហិង្សាលើកុមារដូចតទៅៈ

- ក្រោយពីសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម កុមារភាគច្រើន ក្លាយជាកុមារកំព្រាឪពុកឬម្តាយ ឬក៏កំព្រាទាំងឪពុកម្តាយ រហូតកុមារខ្លះគ្មានទីពឹងពុំនាក់ទៀតផង។ ពេលនោះ កុមារខ្លះក្លាយជាកុមារអនាថាគួរឱ្យអនិច្ចា ។
- ប្រជាជនភាគច្រើន ទទួលរងទុក្ខពីការព្រាត់ប្រាស់ ការបាក់បែកប្រពន្ធប្តី ឬបង ប្អូន។ ក្រោយពីបញ្ចប់សង្គ្រាម ភាពក្រីក្រកើតឡើងដោយពុំមានផ្ទះសម្បែង ទ្រព្យសម្បត្តិ ដីធ្លី មុខរបរ សត្វ ពាហនៈ ពូជធារ និងមធ្យោបាយអាជីវកម្មផ្សេងៗ។ កង្វះខាតនេះ ក៏ជាហេតុមួយបណ្តាលឱ្យមានបញ្ហាកង្វះខាតក្នុងការការពារ និងការចិញ្ចឹមកុមារផងដែរ។ម្យ៉ាងវិញទៀត ប្រព័ន្ធនិងវិស័យនានា ក៏ពុំទាន់មាន ដំណើរការរៀបរយស្រួលបួល ម្ល៉ោះហើយសាលារៀន មន្ទីរពេទ្យ អាគារសិក្សា សម្ភារៈឧបករណ៍ធនធាន ផ្តល់ការអប់រំក៏ពុំមានគុណសម្បត្តិ គ្រប់គ្រាន់ដែរ ដូចជាគ្រូ សាស្ត្រាចារ្យ បច្ចេកទេស គរុកោសល្យ គោលការណ៍អប់រំ យុទ្ធសាស្ត្រអប់រំ ស្តង់ដារសិក្សា គម្រោងបង្រៀន ចិត្តគរុកោសល្យក៏ពុំទាន់ឆ្លើយតបផងដែរ ។
- ទម្លាប់ចាស់ វប្បធម៌ចាស់ នៅបន្តអនុវត្តក្នុងការចិញ្ចឹមកុមារ

- ការរងនូវគត្តាសេដ្ឋកិច្ច និងបញ្ហាផ្សេងៗ រួមចំណែកឱ្យមានការលក់កូន ការលក់កុមារ ការលក់ក្រមុំព្រហ្មចារីយ៍ ការចាញ់ឧបាយកលជនទុច្ចរិត និងការកេងប្រវ័ញ្ច ឬបោកប្រាស់ស្ត្រីៗពេញជំទង់ និងពេញវ័យឱ្យទៅបម្រើសេវាកម្មផ្លូវភេទជាដើមៗ
- ប្រព័ន្ធនីត្យានុកូលភាពផ្នែកតុលាការយុត្តិធម៌ កិច្ចការសង្គម ការអប់រំ កិច្ចការពារកុមារនៅមានកម្រិតៗ
- វប្បធម៌ជាតិធ្លាក់ចុះ វប្បធម៌បរទេសហូរមកលាយឡំ ពិសេសការផ្សព្វផ្សាយតាមសារព័ត៌មាននានា ដែលបង្ហាញនូវហិង្សាជាច្រើន ដូចជាការសម្តែង ជាលក្ខណៈហិង្សា ជាងការបង្ហាញដំណោះស្រាយប្រកបដោយភាពវិជ្ជមានៗ
- កម្មវិធីអប់រំតាមទូរទស្សន៍ មានតិចតួចបំផុតបើប្រៀបធៀបនឹងកម្មវិធីកម្សាន្តសប្បាយដែលខ្វះការអប់រំ
- ការវិវឌ្ឍនៃសង្គមវិទ្យាសាស្ត្រលឿនពេក ទាំងកុមារនិងឪពុកម្តាយ ដើរមិនទាន់ម៉្លោះហើយផលលំបាកនានាបានធ្លាក់លើកុមារ ដូចជាការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអាំងទែណែត(Internet)ជាដើមៗ
- បញ្ហាពហុវិស័យ ចោទជុំវិញសង្គមគ្រួសារ វើខ្លួនមិនរួចដូចជា ការចំណាយជីវភាពក្នុងគ្រួសារ ការចំណាយមិនចាំបាច់ដូចជា ចំណាយលើទឹកស្រវឹង ឬរបស់មិនទាំងនាំនូវការរីកចម្រើនៗ
- បញ្ហាសំខាន់នាពេលបច្ចុប្បន្នគឺ មានការធ្លាក់ចុះនូវសីលធម៌ដូចជា ឪពុកម្តាយមិនយកចិត្តទុកដាក់ចំពោះកូន គំលាតរវាងកូន និងឪពុកម្តាយ កូនមិនស្តាប់ ឪពុកម្តាយ សិស្សមិនស្តាប់គ្រូ នេនមិនស្តាប់ភិក្ខុ សង្ឃមិនស្តាប់ចៅអធិការ គ្រូសូត្រយាយជីមិនស្តាប់អាចារ្យៗ

ការកាត់បន្ថយអំពើហិង្សាលើកុមារ ទាមទារឱ្យមានបរិយាកាសការពារកុមារ (Protective Environment) ពិសេសមានការគាំទ្រពីច្បាប់ និងប្រព័ន្ធការពារកុមារ យន្តការ ការពង្រឹងការអនុវត្តច្បាប់ ព្រមទាំងមានការចូលរួមគ្រប់ពហុវិស័យ ។

ព្រះពុទ្ធសាសនា ដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមបង្កើតនូវបរិយាកាសការពារកុមារ។ សៀវភៅរឿងដែលផលិតដោយក្រសួងធម្មការ និងសាសនា ក្រោមការឧបត្ថម្ភពីអង្គការយូនីសេហ្វ មានចំណងជើងថា «សាមណេរសុខា» ផលិតនៅឆ្នាំ ២០១៦ បានបង្ហាញពីការចូលរួមរបស់ព្រះសង្ឃ ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ និងធ្វើជាគំរូដល់ឧបាសក ឧបាសិកាចំណុះជើងវត្ត។ ការបួសរបស់សាមណេរសុខា គឺបានទទួលសរណគមន៍ ការបូជាជីវិត គោរពជឿជាក់ និងស្មោះត្រង់ចំពោះពុទ្ធសាសនា។ បន្ទាប់មកសាមណេរមានការប្រតិបត្តិយ៉ាងត្រឹមត្រូវ តាមអង្គសីលសិក្ខាបទ ដែលមានទណ្ឌកម្ម១០ នាសនង្គ:១០ ព្រមទាំងការប្រព្រឹត្តតាមសេក្ខិយវត្ត ឬអភិសមាចារិកវត្តទៀតផង។ ពិសេសសាមណេរ សុខា បានរស់នៅក្នុងទិដ្ឋភាពថ្មី សង្គមថ្មី ក្រឹត្យក្រមថ្មី ចរិយាធម៌ថ្មី សូម្បីកាយ វាចា ចិត្ត ក៏ប្រកបដោយគុណធម៌ ឬស្ថិតក្នុងតម្លៃព្រះធម៌ ដែលមានសច្ចធម៌ និងបញ្ចសីល (មានពន្យល់ក្នុងមេរៀនក្រោយទៀត) ។

ហេតុនេះ គំហើញជាគោលការណ៍ ឬជាយុទ្ធសាស្ត្រក្នុងការឆ្លើយតប ការទប់ស្កាត់អំពើហិង្សាតាមរយៈពុទ្ធសាសនាយើងនឹងទទួលបាន ៖

១. ការវៀរចាកការរំលោភសិទ្ធិមនុស្សទូទៅ

២. ការវៀរចាកមិច្ឆាជីវៈ ដែលច្បាប់ហាមឃាត់

៣. ការគេចផុតពីការរួមភេទខុសក្រមសីលធម៌ និងការជួញដូរផ្លូវភេទ

៤. ការវៀរចាកពីការកុហក បោកប្រាស់ ភរភូត

៥. ការមិនប្រើប្រាស់ទឹកស្រវឹង និងគ្រឿងញៀន

### ២.១.២-ករណីសិក្សា «សាមណេរសុខា»

សង្ខេបរឿងសាមណេរ សុខា ជារឿងខ្លីមួយនិយាយអំពីកុមារម្នាក់ឈ្មោះសុខា រង នូវអំពើហិង្សាក្នុងគ្រួសារ ហើយវត្តនិងព្រះសង្ឃបានជួយកែប្រែជីវិតកុមារ និងគ្រួសារ កុមារជួបនូវសុភមង្គល។ រឿងនេះបានបង្ហាញនូវការចូលរួមរបស់ពុទ្ធសាសនា ក្នុងការក សាងសហគមន៍មួយ ប្រកបដោយអហិង្សាធម៌។ សូមរកសៀវភៅសាមណេរ សុខា តាមប ណ្ណាល័យពុទ្ធិកសិក្សានានា ដើម្បីជាឯកសារយោង។ តាមរយៈសកម្មភាពនៃសាមណេរ សុខា យើងអាចទាញចេញនូវខ្លឹមសារ និងអត្ថន័យមកបង្ហាញ ដើម្បីពន្យេចេញឱ្យ ឃើញនូវតម្លៃ និងសក្តានុពលក្នុងការបញ្ចៀស និងការទប់ស្កាត់ ការរំលោភបំពាន ហិង្សាលើកុមារបាន។

- ភេទសាមណេររបស់សុខា គឺជាភេទអ្នកបួស។ ជាបញ្ញត្តិបូជនីយបុគ្គល និង បូជនី យដ្ឋាននៃសង្គម ពាក្យ ឬបរិបទពាក្យ សាមណេរក្តី ព្រះសង្ឃក្តី វត្តអារាមក្តី ពុទ្ធិក អប់រំក្តី វាមានន័យដូចជាការអភិវឌ្ឍមនុស្ស បុគ្គលរួចទៅហើយៗអ្នកទៅនៅវត្ត ប្រាកដជាមានសន្តាន អាកប្បកិរិយា សីលធម៌ ចរិយាធម៌ ឬបុគ្គលិកលក្ខណៈគួរ ជាទីគោរពបូជាទៅហើយ សូម្បីការគ្រងស្បង់ក៏ប្រកបដោយសោភ័ណភាព ការ និយាយស្តី ឬវោហាសាស្ត្រក៏ប្លែកពីកាលមិនទាន់មកបួសជា «សាមណេរ»។
- លក្ខណៈពិសេសមួយទៀត សាមណេរ សុខា បានទទួលការអប់រំបន្ថែមទៀត ពី សំណាក់វត្តអារាម ពីសង្គមសង្ឃ ពីពុទ្ធិកសិក្សា ពីកម្មវិធីពហុវិស័យក្នុងប្រពៃណី ពុទ្ធសាសនា និងទំនៀមទម្លាប់ខ្មែរ។ លោកមានឱកាសស្រាវជ្រាវ អនុវត្តការចូល

រួម ការសម្តែង និងការផ្តល់ប្រឹក្សាជាមួយមនុស្សទូទៅ និងតម្លៃមួយទៀតត្រង់ការស្ថិតនៅក្នុងភេទជាអ្នកបួសនេះ មានការគោរពពីមនុស្សទូទៅ ដែលជាតម្លៃផ្តល់ឱ្យតាមបែបវប្បធម៌ និង ប្រពៃណី ដែលសង្គមខ្មែរទាំងមូលបានស្តាប់និងធ្វើតាមក្នុងនាមជាពុទ្ធសាសនិក ។

ហេតុនេះ ទាំងភេទ ទាំងមណ្ឌលអប់រំ ទាំងពន្លឺព្រះធម៌ ទាំងប្រជាប្រិយភាព រួមទាំងចំណេះដឹងថ្មី ប្រកបដោយបញ្ញាឆ្លាតវៃផងនោះ សាមណេរ សុខា បានក្លាយជាបុគ្គលគំរូមួយដ៏ល្អសម្រាប់មនុស្សទាំងឡាយ។ រួមជាមួយគ្នានេះ ដោយសារតែភាពជាគំរូព្រះអង្គក៏មានប្រជាប្រិយភាពក្នុងចំណោមពុទ្ធបរិស័ទ អាចចូលរួមអន្តរាគមន៍ ដោះស្រាយ និងទំនាក់ទំនងល្អជាមួយគ្រប់បណ្តាញអង្គភាព ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២.២- ប្រភេទ នៃអំពើហិង្សាលើកុមារ

ប្រភេទអំពើហិង្សាលើកុមារកើតមាន នៅពេលដែលបុគ្គលណាម្នាក់មានចេតនាធ្វើបាបកុមារទោះជាលើរាងកាយឬផ្លូវអារម្មណ៍ក្តី។ អំពើហិង្សារួមមានទាំងការប្រើកម្លាំងឬបំពានអំណាចតាមរយៈតំណែងរបស់ខ្លួន ការគំរាមកំហែងថានឹងប្រើហិង្សា ដែលអាចបង្កគ្រោះថ្នាក់ បើទោះបីជាសកម្មភាពហ្នឹងមិនទាន់កើតឡើងក៏ដោយ។ អំពើហិង្សាចំពោះកុមារអាចកើតមានឡើងនៅតាមផ្ទះ សាលារៀន និងសហគមន៍ ហើយជារឿយៗ ច្រើនតែពាក់ព័ន្ធនឹងអ្នកដែលទទួលខុសត្រូវផ្ទាល់ ឬអ្នកដែលកុមារទុកចិត្តមានដូចជា ឪពុកម្តាយ និងគ្រូបង្រៀន រួមទាំងបងប្អូនបង្កើតមិត្តរួមថ្នាក់ ឬសង្សារ។ អំពើហិង្សាលើកុមារអាចស្តែងចេញជាទម្រង់ ឬប្រភេទច្រើនយ៉ាង តាមរយៈធន្ទៈផង និងអធន្ទៈផង តាមកត្តាផ្ទាល់ផង និងតាមកត្តាប្រយោលផង។ អំពើហិង្សាលើកុមារយ៉ាងហោចណាស់ក៏មាន៤ទម្រង់ធំៗ ដូចជា អំពើហិង្សាផ្លូវកាយ ផ្លូវចិត្តឬអារម្មណ៍ ផ្លូវភេទ និងការមិន អើពើ។

### ២.២.១- អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយរួមមាន ការទះកំផ្លៀង ការច្រាន ការដាល់ ការទាត់ធាក់ ការវាយនឹងរំពាត់ ឬការវាយដោយប្រើវត្ថុរឹង ការខ្ទប់ដង្ហើម ការច្របាច់ក ការធ្វើឱ្យលង់ទឹក ការធ្វើឱ្យរលាកដោយចេតនា ឬការប្រើប្រាស់ ឬគំរាមដោយអាវុធ ដូចជាកាំបិត ឬអាវុធដទៃទៀត។

ក- ការដាក់ទណ្ឌកម្មលើរាងកាយ (Corporal punishment)

ការដាក់ទណ្ឌកម្មលើរាងកាយ ឬការគំរាមកំហែងថា នឹងដាក់ទណ្ឌកម្មបែបនេះ កើតឡើងនៅពេលឪពុកម្ដាយឬគ្រូបង្រៀនមានចេតនាបង្កការឈឺចាប់ ឬការលំបាកដល់អ្នកណាម្នាក់ ដែលជាទូទៅធ្វើឡើង ដើម្បីប្រដៅកែតម្រូវដាក់ទណ្ឌកម្ម ឬរារាំងកុំឱ្យធ្វើសកម្មភាពដដែរទៀត ។

ការដាក់ទណ្ឌកម្មលើរាងកាយ រួមមានការទះកំផ្លៀង ការវាយនិងដៃ ឬឧបករណ៍អ្វីមួយ ការដាល់ ការទាត់ធាក់ រុញច្រាន សំពង ក្តិច ខាំ បោចសក់ ទាញស្លឹកត្រចៀក បង្ខំអ្នកណាម្នាក់ឱ្យឈរ ឬប្រកាន់ជំហរមិនស្រួល ការដុត រលាក ស្រោច ឬជះទឹកក្តៅ ឬការបញ្ច្រុក ញាំអ្វីមួយដោយបង្ខំ។ ការដាក់ទណ្ឌកម្មលើរាងកាយ ក៏រួមបញ្ចូលទាំងការដាក់ទណ្ឌកម្ម ដែលមិនប៉ះពាល់ផ្ទាល់ដល់រាងកាយដូចជា ការបង្អាប់បំបាក់មុខ គំរាមកំហែង បន្ទាច ឬសើចចំអកកុមារ ឬយុវជនយុវតីជាដើម។ល។ ពេលខ្លះ កុមារក៏អាចស្លាប់ បន្ទាប់ពីទទួលរងការរំលោភបំពានផ្លូវកាយផងដែរ។

មនុស្សពេញវ័យមួយចំនួនជឿថា «ការវាយ»ឬ«ការទះកំផ្លៀង» ជារឿងធម្មតានៅពេលប្រើសម្រាប់អប់រំអ្នកណាម្នាក់។ ប៉ុន្តែនេះជាអំពើខុសឆ្គងពីព្រោះគេមិនត្រូវប្រើប្រាស់អំពើហិង្សា ដើម្បីអប់រំអ្នកណាម្នាក់ឡើយដោយសារវាបណ្តាលឱ្យមានគ្រោះថ្នាក់។ ការដាក់ទណ្ឌកម្មលើរាងកាយ គឺជាវិធានការ «រហ័ស» ដែលតាមជាក់ស្តែង បង្កតែភាពភ័យខ្លាច និងបង្រៀនកុមារឱ្យយកហិង្សាមកដោះស្រាយតែប៉ុណ្ណោះ។ មាតាបិតា និងគ្រូត្រូវអប់រំ និងពន្យល់ឱ្យបានច្បាស់លាស់ និងផ្តល់ដំបូន្មានបែបស្ថាបនាអំពីថា តើកុមារត្រូវ

ផ្លាស់ប្តូរ ឬមានអាកប្បកិរិយាល្អនាពេលអនាគត។ នេះជាមធ្យោបាយតែមួយគត់ ដែលធ្វើឱ្យអ្នកណាម្នាក់ចេះមានវិន័យខ្លួនឯងត្រឹមត្រូវ។

ខ- ការរុកកួនធាតៅ

ទង្វើនេះ អាចពាក់ព័ន្ធទៅនិងអំពើហិង្សាលើផ្លូវកាយ ឬផ្លូវចិត្តដែលប្រព្រឹត្តពីកុមារដូចគ្នាផ្សេងទៀត។ អ្នកដែលដើររុកកួនធាតៅគេគិតថាខ្លួនឯងសម្បើម និងខ្លាំងជាងគេ និងព្យាយាមបន្ទុះបង្អាប់ ឬរំលោភបំពានលើផ្លូវកាយអ្នកដទៃ។ អ្នកដែលដើររុកកួនគេបែបនេះ ដោយសារតែពួកគេមិនអាចរាប់អានមិត្តភក្តិ តាមបែបផែន ដែលសង្គមអាចទទួលយកបាន។ តាមការពិតទៅការរុកកួនធាតៅគេ ជាសញ្ញាបង្ហាញពីចំណុចខ្សោយទៅវិញទេ។ មនុស្សធំអាចធ្វើការត្រួតពិនិត្យមើលក្មេងៗ ដើម្បីចៀសវាងការរុកកួនធាតៅ ហើយក្មេងៗចាំបាច់ គួរតែប្រាប់សកម្មភាពរុកកួនទៅកាន់មនុស្សធំដែលគេទុកចិត្ត។ ឧទាហរណ៍ ក្មេងប្រុសម្នាក់ នៅក្នុងសាលាត្រូវបានគេរុកកួនធាតៅដោយសារតែគេមិនសូវចេះលេងកីឡា ឬក្មេងស្រីម្នាក់ត្រូវបានគេសើចចំអកដោយសារតែនាងមានបញ្ហាក្នុងការអាន។ សិស្សទាំងនេះមានអារម្មណ៍ពិបាកចិត្ត និង កណ្តោច កណ្តែងមែនទែន។ ការរុកកួនធាតៅអាចមាន៖

- ការវាយ ឬយាយីលើផ្លូវកាយ
- ហៅឈ្មោះបែបរហ័សនាមលេងសើចចំអក
- ការគំរាមកំហែង និងបំភិតបំភ័យ
- បង្ខំអ្នកណាម្នាក់ប្រគល់ប្រាក់កាស និងរបស់របរផ្សេងៗ

## ២.២.២- អំពើហិង្សាផ្លូវភេទ

អំពើហិង្សាផ្លូវភេទ ត្រូវបានកំណត់រាប់បញ្ចូលរាល់ទម្រង់នៃការរំលោភបំពាន ផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទរបស់កុមារ។ អំពើហិង្សាផ្លូវភេទគ្របដណ្តប់ទៅលើ កម្រងនៃបទល្មើស ដែលរួមមានជាអាទិ៍ សកម្មភាពរួមភេទបានសម្រេចដោយគ្មានការយល់ព្រម (ឧទាហរណ៍ ការរំលោភសេពសន្ថវៈ) ការប៉ុនប៉ងធ្វើសកម្មភាពរួមភេទ ដោយគ្មានការយល់ព្រម ការប៉ះពាល់ផ្លូវភេទដោយរំលោភបំពាន (ឧ. ការប៉ះពាល់ ដែលគេមិនចង់

ឱ្យប៉ះ) និងការរំលោភបំពានផ្លូវភេទដោយគ្មានការប៉ះពាល់ (ឧ. គំរាម ប្រើអំពើហិង្សាផ្លូវភេទ ការបង្ហាញកេរភេទ ការបៀតបៀនផ្លូវភេទដោយពាក្យសម្ដី)។ អំពើហិង្សាផ្លូវភេទក៏រាប់បញ្ចូលផងដែរ នូវការលួងលោម ឬការបង្ខិតបង្ខំកុមារម្នាក់ ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទណាមួយដោយខុសច្បាប់ ឬសកម្មភាពផ្លូវភេទណាមួយ ដែលគ្រោះថ្នាក់ដល់សតិអារម្មណ៍របស់កុមារ ការកេងប្រវ័ញ្ចកុមារ នៅក្នុងពេស្យាចារ ឬ ការអនុវត្តន៍ផ្លូវភេទដែលខុសច្បាប់ដទៃទៀត និងការកេងប្រវ័ញ្ចកុមារនៅក្នុងការសម្ដែង និងសម្ភារៈអាសអាភាស។

ពេលខ្លះ កុមារទទួលរងការបៀតបៀនប៉ះស្ទាប ដែលធ្វើឱ្យពួកគេមានអារម្មណ៍ពិបាក ឬពេលខ្លះត្រូវបានគេបង្ខំ ឬលួងលោមឱ្យរួមភេទ។ ករណីនេះកើតឡើង នៅពេលមានអ្នកណាម្នាក់ និយាយរឿងភេទប្រាប់អ្នកឱ្យអ្នកមើលវីដេអូសិច ឬ មើលរូបភាពអាសអាភាស ឬប្រព្រឹត្តអំពើអាសនៅចំពោះមុខអ្នក។ ជារឿយៗ ទង្វើបែបនេះ ត្រូវបានប្រព្រឹត្តដោយបុរស ឬក្មេងប្រុសនៅក្នុងគ្រួសាររបស់ពួកគេ ឬដោយសារមិត្តភក្តិរបស់ពួកគេ (ដូចជា មិត្តប្រុស និងមិត្តស្រី ជាដើម)។ ក្មេងស្រី និងក្មេងប្រុសតែងទទួលរងការបៀតបៀនផ្លូវភេទនៅផ្ទះ និងពេលខ្លះនៅសាលារៀន។

អំពើហិង្សាផ្លូវភេទ ដែលកើតឡើងចំពោះមនុស្សច្រើនស្រទាប់ ទោះបីជាអ្នកមាន ឬក្រក្ដី ក្មេងប្រុសឬក្មេងស្រីក្ដី មានអាយុប៉ុន្មានក៏ដោយ។ ជនល្មើសអាចជាអ្នកដទៃ ប៉ុន្តែភាគច្រើនកុមារត្រូវបានបៀតបៀនផ្លូវភេទ ដោយអ្នកគេបានស្គាល់និងជឿទុកចិត្ត ដូចជាសាច់ញាតិ អ្នកជិតខាង មិត្តប្រុសឬមិត្តស្រីក្ដី។ អំពើហិង្សាផ្លូវភេទ ជាញឹកញាប់ កើតឡើងនៅផ្ទះឬនៅសាលា។ អំពើហិង្សាផ្លូវភេទអាចកើតឡើងនៅពេលយប់ ប៉ុន្តែ ក៏អាចកើតឡើងនៅពេលថ្ងៃដែរ។ ឧទាហរណ៍ក្មេងប្រុសនិយាយពីរឿងរួមភេទដល់មិត្តស្រីរបស់គាត់ ហើយលួងលោមនាងឱ្យរួមភេទជាមួយខ្លួន ដោយការគំរាមកំហែងនាងថាបែកគ្នាប្រសិនបើនាងមិនយល់ព្រម។

### ២.២.៣- ***អំពើហិង្សាផ្លូវចិត្ត***

*ការប្រមាថ ការហៅឈ្មោះបែបចំអក ការគំរាមកំហែង ការដាក់ឱ្យនៅតែម្នាក់ឯង ឬមិនរាប់រកអ្នកណាម្នាក់ គឺជាឧទាហរណ៍នៃអំពើហិង្សាលើផ្លូវចិត្ត ហើយជារឿយៗ ត្រូវបាន ប្រើប្រាស់ដាក់ទណ្ឌកម្មដើម្បីធ្វើឱ្យនរណាម្នាក់ឈឺចាប់។ ការរំលោភបំពាន ផ្លូវចិត្តកើតមាននៅពេលដែលឪពុកម្តាយ ឬអ្នកថែរក្សា បង្កើតនូវបរិយាកាស ផ្នែកអារម្មណ៍ដោយមានគោលបំណង ឬដោយការធ្វេសប្រហែស ដែលធ្វើឱ្យខូចខាត តួនាទីផ្នែកអាកប្បកិរិយា ផ្នែកផ្លូវចិត្ត ផ្នែកបញ្ញា ស្មារតី ឬផ្នែករាងកាយរបស់កុមារ។ អំពើហិង្សាលើផ្លូវចិត្តអាចរួមមាន៖*

- *ថាឱ្យអ្នកណាម្នាក់ថាជាមនុស្សគ្មានបានការ មិនគួរឱ្យគេចូលចិត្ត ឬមនុស្សមិនល្អគ្រប់ជប់*
- *មិនអនុញ្ញាតឱ្យអ្នកណាម្នាក់មានឱកាសបញ្ចេញមតិ ដោយធ្វើឱ្យគេស្ងាត់មាត់ ឬ «សើចចំអក» អំពីរបៀបដែលគេនិយាយ*
- *បន្ទាប ឬគំរាមកំហែងអ្នកណាម្នាក់*
- *ការរិះគន់ដែលកើតមានម្តងហើយម្តងទៀត*
- *ការបង្អត់អាហារ ឬ ការបំបិទសិទ្ធិ*
- *ការព្រងើយកន្តើយ។*

### ២.២.៤- ***ការមិនអើពើ*** (Neglect)

*ការមិនអើពើ គឺជាកង្វះភាពស្និទ្ធស្នាល ភាពចុះសម្រុងគ្នា ការអត់ឱនគ្នា និងកង្វះភាពរីករាយក្នុងគ្រួសារដែលជាហេតុធ្វើឱ្យកុមារទទួលរងនូវសម្ពាធខាងផ្លូវចិត្ត*[៩]*។ ការមិនអើពើនេះ ជាប្រភពនៃសេចក្តីទុក្ខគ្រប់យ៉ាង។ ឯការអើពើគ្នា ការយកចិត្តទុកដាក់ដល់គ្នានិងគ្នា ការព្រមព្រៀងគ្នាជាប្រភពនាំមកនូវសេចក្តីសុខ។ ក្នុងន័យនេះ ព្រះពុទ្ធដីកាបញ្ជាក់ថា សុខា សង្ឃស្ស សមគ្គី សមគ្គានំ តបោ សុខោ ការព្រមគ្នារបស់សង្ឃ*(សង្គម)

[៩] *សុខ ប៊ុនធឿន : វិធីកាត់បន្ថយស្ត្រេស ភ្នំពេញ បោះពុម្ព ព.ស.២៥៥៣ ទំព័រ៧៥*

រមែងនាំមកនូវសេចក្តីសុខ។ ជាងនេះទៀត វាជាការខកខានមិនបានផ្តល់នូវតម្រូវការមូលដ្ឋានផ្នែករាងកាយ និងផ្នែកផ្លូវចិត្តដល់កុមារ។ ការទុកកុមារចោលមិនអើពើ ដោយខកខានមិនបានបំពេញភារកិច្ចខ្លួន ដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ។ ការមិនអើពើ ជាអំពើដែលអាណាព្យាបាល ឪពុកម្តាយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីឱ្យកុមារធំដឹងក្តីមានសុវត្ថិភាព និងសុខភាពល្អដូចជាកូនគ្មានសំបុត្រកំណើត មិនបានទៅសាលា ឬមិនបានទៅឱ្យពេទ្យពិនិត្យពេលកូនឈឺឬក៏មិនការពារកូនៗពីគ្រោះថ្នាក់ផ្សេងៗ ដែលអាចនឹងកើតឡើង។ ពេលខ្លះធ្វើដោយចេតនា ដោយសារតែឪពុកម្តាយមិនមានធនធានគ្រប់គ្រាន់ ដូចជា គ្មានថវិកាការអប់រំឬរស់នៅតំបន់ដាច់ស្រយាល។ ប៉ុន្តែក៏មានករណីទុកកុមារចោល កើតឡើងនៅពេលដែលឪពុកម្តាយ និងអាណាព្យាបាលមានប្រាក់កាសចំណេះដឹង និងមានលទ្ធភាពថែរក្សាកូនឱ្យបានល្អដែរ ប៉ុន្តែបែរជាមិនបានធ្វើដើម្បីកូនរបស់ខ្លួន។

ឧទាហរណ៍៖ ឪពុកម្តាយដែលចំណាយប្រាក់ទៅលើការស៊ីផឹក ជក់បារី និងលេងល្បែង តែមិនបានផ្តល់អាហារ ឬ សម្ភារៈសិក្សាឱ្យកូនៗរបស់ពួកគេ ឬឪពុកម្តាយ ដែលទុកកូនដែលមានជំងឺ ឬរងរបួសចោលដោយមិនយកចិត្តទុកដាក់។

## ២.៣-សូចនាករ នៃអំពើហិង្សាលើកុមារ

មានសូចនាករខ្លះៗ ដែលបង្ហាញពីអំពើហិង្សាដូចតទៅ ៖

- មានការគេងមិនលក់ ការខ្លាចមិនហ៊ានចូលគេង ខ្លាចសុបិន្តអាក្រក់
- មានរោគសញ្ញាតាមផ្លូវកាយ ដូចជាឈឺក្បាល ឈឺពោះ ...
- មានបម្រុងប្រយ័ត្នខ្ពស់ ចំពោះគ្រោះថ្នាក់ ឬការរងផ្លូវចិត្តពីអ្នកដទៃ
- មានការប្រើឥរិយាបថមិនគួរគប្បី លើកុមារដទៃទៀត
- មានចរិតច្រឡោតតោតតូង ឆាប់ខឹងអ្នកដទៃ
- មានការដកខ្លួន គេចចេញពីសកម្មភាពទូទៅ
- មានការព្រងើយកន្តើយរបស់កុមារ ក្នុងសកម្មភាពចូលរួម

- មានការធ្លាក់ទឹកចិត្ត ធ្វើព្រងើយកន្តើយ ហើយអារម្មណ៍កុមារហាក់ដូចជា ឯកោនិយម
- មានការចូលចិត្តប្រព្រឹត្តគ្រឿងញៀន ក្រោយពេលមានបណ្តាញណាមួយ
- មានការបង្ហាញទឹកមុខញូញ ស្មុក ហាក់ចង់ធ្វើអត្តឃាត
- មានការភ្លេចភ្លាំង បាត់បង់ការចងចាំច្រើន
- ពុំមានចំណង់ផ្តោត ឬចាប់អារម្មណ៍លើការងារទាំងពួង
- មានអារម្មណ៍ច្រើនព្រួយ ចំពោះអ្វីដែលខ្លួនច្រើនធ្វើ
- មានឥរិយាបថច្រងើងច្រងាង ដូចជាជនរំលោភបំពាន
- ក្រៅពីនេះ នៅមានទម្រង់ ឬប្រភេទផ្សេងៗទៀត ដូចជា ស្ថានភាពសេដ្ឋកិច្ច អនាម័យ សុខភាព ស្មេកស្មាំង បាត់បង់ការសិក្សា មានការគេចវេះទៅប្រើគ្រឿងញៀនតាមការអូសទាញពីអ្នកដទៃ ។

## ២.៣.១- ការសិក្សាសៀវភៅរឿង «សាមណេរសុខា»

រឿងសាមណេរសុខាបង្ហាញពីតួនាទីវត្តអារាម និងព្រះសង្ឃដែលជួយកែប្រែជីវិតកុមារ និងគ្រួសារឱ្យជួបនូវសុភមង្គល។ រឿងនេះបានបង្ហាញផងដែរនូវការចូលរួមរបស់ពុទ្ធសាសនា ក្នុងការកសាងសហគមន៍មួយប្រកបដោយធម៌អហិង្សា។

### សង្ខេបរឿង

កុមារឈ្មោះសុខា រស់នៅជាមួយឪពុកម្តាយ ហើយទទួលរងនូវអំពើហិង្សា ជារៀងរាល់ថ្ងៃ។ ដោយទ្រាំលែងបាន សុខាក៏ទៅពឹងព្រះចៅអធិការឱ្យជួយដោះស្រាយ។ ក្រោយមកគ្រួសារសុខាវិលត្រឡប់មករកសុភមង្គលវិញ ហើយសុខាក៏សម្រេចចិត្តបួស ជាសាម

ណោរ។ ដោយក្តីស្វាធ្យាយ សាមណោរសុខាបានជួយអប់រំដល់គ្រួសារជាច្រើន ឱ្យចៀស ផុតពីអំពើហិង្សានានាក្នុងសង្គម[១០]។

### ២.៣.២- សារដែលទទួលបានតាមរយៈរឿងសាមណោរសុខា

- តាមរយៈអត្ថបទនៃខ្សែជីវិតសាមណោរ សុខា យើងទទួលបាននូវសារៈសំខាន់ៗ នៃការចូលរួម ក្នុងការទប់ស្កាត់ការរំលោភបំពានហិង្សាលើកុមារដូចតទៅៈ
- ការចូលរួមអប់រំក្នុងសកម្មភាពមហាជន រួមទាំងកុមារ
- តាមចុះអន្តរាគមន៍តាមគ្រួសារ និងអង្គភាពសង្គម
- ការសង្គ្រោះកុមារឱ្យស្រឡាញ់វត្ត ចូលចិត្តមកវត្ត
- ការផ្តល់លទ្ធភាព និងសង្គហសង្គ្រោះពីព្រះសង្ឃ
- ការពន្យល់កុមារឱ្យស្រឡាញ់អំពើល្អ
- អាចធ្វើឱ្យកុមារ ឬសង្គមពុទ្ធបរិស័ទផ្លាស់ប្តូរជំនឿបាន
- ការចូលរួមលើកតម្លៃជីវិត និងសិទ្ធិកុមារតាមសីលធម៌
- ការបង្រៀនពីរបៀបកែប្រែឥរិយាបថ មកជាមនុស្សល្អ
- កុមារល្អ យុវជនល្អ តាមរយៈព្រះអង្គ និងតាមរយៈទ្រឹស្តីអប់រំពុទ្ធសាសនា
- ការចូលរួមជួយផ្សព្វផ្សាយអប់រំ តាមប្រព័ន្ធសេវាផ្សេងៗ ប្រកបដោយចលនា ជាប់ មិនដាច់ និងមានប្រសិទ្ធភាព
- ការធ្វើយ៉ាងណាឱ្យវត្តក្លាយជាកន្លែងមានសុវត្ថិភាពសម្រាប់កុមារ ផ្តល់ជំនួយដល់ កុមារ ក៏ដូចជាកសាងនូវធនធានមនុស្សប្រកបដោយ អហិង្សាធម៌

---

[១០] សូមស្វែងរកសៀវភៅរឿងសាមណោរសុខា មាននៅតាមបណ្ណាល័យរបស់សាលាពុទ្ធិកសិក្សា។

ការចូលរួមជុំវិញ និងបង្កើតឱ្យមានបរិយាកាសប្រកបដោយសុវត្ថិភាពក្រៅពីនេះ នៅមានឱកាសច្រើនទៀត ដែលសាមណេរ សុខា អាចចូលរួម អប់រំទេសនា សម្ភាសន៍ ក្នុងឱកាសបុណ្យតាមវត្ត និងតាមភូមិនានា ក្នុងចំណុះវត្តបាន។ ព្រះសង្ឃអាចចូលរួម អន្តរាគមន៍ និងផ្តល់ប្រឹក្សាដល់ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានតាមការគួរ។

## ២.៤- ផលប៉ះពាល់ នៃអំពើហិង្សាលើកុមារ

*អំពើហិង្សាលើកុមារមានផលប៉ះពាល់ជាច្រើនឥតគណនា ដែលទាមទារឱ្យមានការទប់ស្កាត់មុនពេលហិង្សាកើតមាន។ ផលប៉ះពាល់មានទាំងលើកុមារផ្ទាល់ គ្រួសារ និងសហគមន៍។*

### ២.៤.១- ផលប៉ះពាល់លើកុមារផ្ទាល់ និងគ្រួសារ

*គ្រប់អំពើហិង្សាទាំងអស់ តែងតែមានផលប៉ះពាល់ ពិសេសអំពើហិង្សាលើកុមារ។ ផលប៉ះពាល់ទាំងនោះរួមមាន៖*

- *ស្មុកស្មាំងមិនសូវមានកម្លាំងកំហែង*
- *គេងយល់សប្តិអាក្រក់ យល់សប្តិឃើញគ្រោះថ្នាក់*
- *ឧស្សាហ៍ឈឺក្បាល ឈឺពោះ*
- *គេងនោមដាក់ខោ*
- *ប្រុងប្រយ័ត្នជ្រុលចំពោះគ្រោះថ្នាក់*
- *បង្កការឈឺចាប់ដល់កុមារដទៃឬសត្វ*
- *ខឹងច្រឡោតតាមរបៀបក្មេងតូច មានអាកប្បកិរិយារឹងរូស*
- *ចូលចិត្តនៅម្នាក់ឯង ផ្តាច់ខ្លួនពីសកម្មភាពទូទៅ*
- *សេពគ្រឿងញៀនពេលកំពុងមានបញ្ហាឬក្រោយពីពេលនោះមក*

- ប៉ុនប៉ងសម្លាប់ខ្លួនឬធ្វើអាកប្បកិរិយាដែលប្រកបដោយគ្រោះថ្នាក់
- រៀនខ្សោយ
- ពិបាកក្នុងការផ្ទង់អារម្មណ៍ ឬផ្តោតអារម្មណ៍
- តែងតែគិតថាអ្វីដែលប្រឹងប្រែងធ្វើអស់លទ្ធភាពហើយនៅតែមិនទាន់បានល្អគ្រប់គ្រាន់
- ព្យាយាមយកចិត្ត ឬបំពេញនូវការទទួលខុសត្រូវរបស់មនុស្សធំ ឬឪពុកម្តាយ
- មានការព្រួយបារម្ភខ្លាំងជ្រុល។

**២.៤.២- ផលប៉ះពាល់លើសង្គម**

យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវស្តីពីបន្ទុកសេដ្ឋកិច្ចចំពោះផលវិបាកផ្នែកសុខភាព នៃអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣ បានបង្ហាញថា យ៉ាងហោចណាស់ មានការបាត់បង់ថវិកា១៦៨លានដុល្លារ ដោយសារតែផលវិបាកផ្នែកសុខភាពមួយចំនួនបង្កដោយអំពើហិង្សា និងអំពើហិង្សាកាលពីកុមារភាព បណ្តាលឱ្យខាតបង់ផលិតភាពគិតជាសាច់ប្រាក់ប្រមាណ ៨៣.៣០លានដុល្លារ ក្នុងឆ្នាំ២០១៣។ បន្ទុក សេដ្ឋកិច្ចនៃផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចនៃអំពើហិង្សាលើកុមាររួមមាន ការបន្ថែមបន្ទុកទៅលើប្រព័ន្ធថែទាំសុខភាព ដោយសារតែការប្រើប្រាស់សេវាសុខភាពដ៏លើសលប់ និងក្នុងករណីធ្ងន់ធ្ងរគឺបណ្តាលឱ្យមានពិការភាព និងមរណភាពព្រមទាំងកម្រិតនៃអំពើហិង្សា និងពិរុទ្ធភាពមានការកើនឡើង។

ដោយមានការព្រួយបារម្ភនេះ ទើបអង្គការអន្តរជាតិ រដ្ឋធម្មនុញ្ញជាតិដែលមានគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលអប់រំ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃជាប្រចាំមិនបានធ្វេសប្រហែសឡើយ។ ទន្ទឹមនិងនេះ ការបង្វែរកម្មវិធីឧបត្ថម្ភ គាំទ្រតាមរយៈមជ្ឈមណ្ឌល ត្រូវបានផ្ទេរមកជាការឧបត្ថម្ភគាំទ្រតាមគ្រួសារវិញ ។ ការធ្វើបែបនេះ ទើបដល់ដៃ ឬដល់មូលដ្ឋានកុមាររងគ្រោះដោយផ្ទាល់ ។

ឆ្លើយតបតាមខ្លឹមសារនៃមេរៀន យើងបានយល់ដឹងសព្វគ្រប់អំពីហេតុជាច្រើន ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ច្រើនដល់កុមារដែលក្នុងនោះទាក់ទងនឹងការអនុវត្តជំនឿប្រកបដោយហេតុផល និងដែនកំណត់ជាក់លាក់ប្រកបដោយវិទ្យាសាស្ត្រ។ ម្យ៉ាងទៀត យើងបានយល់អំពីស្ថានភាពរស់នៅ ប្រភេទនៃផលប៉ះពាល់របស់កុមារដែលបានកើតឡើង ព្រមទាំងបានយល់អំពីវិធីសាស្ត្រទប់ស្កាត់ ការពិចារណាអំពីសូចនាករទាំងឡាយ ដែលពាក់ព័ន្ធដល់ការមើលឃើញអំពីលក្ខណៈនៃសញ្ញាហិង្សានានា ។

## ២.៥- អំពើហិង្សាលើកុមារមិនអាចទទួលយកបានឡើយ

អំពើហិង្សាលើកុមារ គឺមិនអាចទទួលយកបានឡើយ។ ទាំងសាសនចក្រ ទាំងអាណាចក្រ តែងតែផ្តន្ទាទោសដល់បុគ្គលដែលប្រព្រឹត្តអំពើហិង្សាលើកុមារ។ បុគ្គលដែលប្រើហិង្សាលើកុមាររមែងទទួលនូវការខុសត្រូវពីរគឺ ការទទួលខុសត្រូវខាងសីលធម៌ និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

២.៥.១- ការទទួលខុសត្រូវខាងពុទ្ធវិន័យ ឬ សីលធម៌ (Moral esponsibility)

ព្រះពុទ្ធសាសនាពិពណ៌នានូវក្រមសីលធម៌ ដើម្បីធ្វើឱ្យចិត្តប្រសើរឡើង។ ក្រមសីលធម៌ត្រូវបានបែងចែងជាពីរក្រុមគឺ **បណ្ណត្តិវជ្ជៈ** និង**លោកវជ្ជៈ**។

**បណ្ណត្តិវជ្ជៈ** ស្របទៅតាមទំនោរវប្បធម៌និងសង្គមដែលមានស្រាប់ និងត្រូវបានអនុវត្តដោយផ្ទាល់សម្រាប់ភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ក្នុងការរក្សាសេចក្តីថ្លៃថ្នូរក្នុងសហគមន៍សង្ឃ។

**លោកវជ្ជៈ** ត្រូវបានអនុវត្តគ្រប់សមាជិកទាំងអស់ នៃសង្គមក្នុងការនាំជីវិតទៅរកភាពរុងរឿង។

ក្នុងន័យនេះ ទំនួលខុសត្រូវខាងសីលធម៌ គឺជាច្បាប់កម្មផលដែលប្រតិបត្តិដោយស្វ័យប្រវត្តិជំនួសឱ្យការផ្តល់រង្វាន់ និងការដាក់ទណ្ឌកម្ម។ វាផ្តល់ទណ្ឌកម្មទាំងកាយ ទាំង

ចិត្តចំពោះអ្នកប្រើប្រាស់ហិង្សា។ ទណ្ឌកម្មផ្លូវកាយ គឺជាប្រភេទទណ្ឌកម្មផ្ទាល់ ឬការបំបិទសេរីភាព។ ឯទណ្ឌកម្មផ្លូវចិត្ត គឺជាសម្ពាធផ្លូវអារម្មណ៍ និងផ្លូវចិត្ត ធ្វើការឱ្យមានការភ័យខ្លាច ក្ដីបារម្ភដោយការឃើញនូវអំពើហិង្សា ដែលបានប្រព្រឹត្តកន្លងមកហើយ។ មួយវិញទៀត ការប្រើប្រាស់ហិង្សារមែងធ្វើឱ្យបុគ្គលអ្នកប្រព្រឹត្តទទួលបាននៈ

១. ជួបប្រទះនូវពៀរវេរា

២. អាយុខ្លី

៣. រមែងមានជំងឺតម្កាត់ច្រើន

៤. សេចក្ដីភ័យខ្លាចក្នុងដំណើរការជីវិត

៥. បាត់បង់នូវសេចក្ដីសុខផ្លូវចិត្ត

៦. រមែងកើតក្នុងអបាយភូមិ ទុគតិ វិនិបាត និងអសុរកាយ។

### ២.៥.២- ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

ច្បាប់ជាតិ និងច្បាប់អន្តរជាតិហាមឃាត់នូវគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ។ ជនល្មើសទោះជាបុគ្គលណាក៏ដោយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ គឺជាការកាត់ទោសដល់ជនអ្នកប្រព្រឹត្តហិង្សា ដែលមានចែងក្នុងច្បាប់ជាធរមានហើយធាតុផ្សំនៃបទល្មើសត្រូវបានបង្ហាញដោយវិមតិសង្ស័យ។ អ្នកប្រើប្រាស់ហិង្សនឹងត្រូវផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារជាដើម។

ការផ្ដន្ទាទោសដល់អ្នកប្រើប្រាស់ហិង្សា គឺជាផលនៃការប្រព្រឹត្ត ដែលត្រូវបានប្រព្រឹត្តដោយជនជាប់ចោទដោយរដ្ឋ។ រដ្ឋក្នុងទីនេះសំដៅដល់ចៅក្រម។ ចៅក្រម

សម្រេចថា តើកាត់ទោសជនជាប់ចោទឱ្យជាប់ពន្ធនាគារ ឬក៏គ្រាន់តែពិន័យ ស្របតាមបទល្មើស។

ហេតុនេះ អ្នកប្រើប្រាស់ហិង្សាលើកុមារ មិនអាចគេចផុតពីការផ្តន្ទាទោសតាមផ្លូវច្បាប់ឡើយ។

### ២.៥.៣- យន្តការរាយការណ៍ចំពោះអំពើហិង្សា

ចំពោះមធ្យោបាយរាយការណ៍នូវពេលអធិករណ៍ ឬអំពើហិង្សាគ្រប់កម្រិតស្រាល និងធ្ងន់ណាមួយកើតឡើងចំពោះកុមារតាមបណ្តាវត្ត ពួកគេអាចរាយការណ៍ ព័ត៌មាននោះទៅតាមតួនាទីនិងភារកិច្ចរបស់ថ្នាក់ដឹកនាំសង្ឃ និងអាជ្ញាធរនៅទីនោះ អាស្រ័យតាមទិដ្ឋភាព និងកម្រិតជាក់ស្តែង។

#### ក- មន្ត្រីសង្ឃ និងមន្ត្រីធម្មការ

ជនរងគ្រោះ និងជនរងគ្រោះអាចរាយការណ៍នូវបញ្ហារបស់ខ្លួនទៅកាន់ គណៈសង្ឃ ឬមន្ត្រីសង្ឃវត្តមាន ព្រះគ្រូចៅអធិការ ព្រះគ្រូសូត្រស្តាំនិងឆ្វេង ព្រះវិន័យ-ធរ ព្រះលេខាធិការ និងការរកសង្ឃ អាស្រ័យទៅតាមរចនាសម្ព័ន្ធនៃថ្នាក់ដឹកនាំសង្ឃវត្តនីមួយៗ ដើម្បីដោះស្រាយនិងចាត់វិធានការទៅតាមពុទ្ធវិន័យ ព្រះសង្ឃប្រកាស និងបទបញ្ជាផ្ទៃក្នុងរបស់វត្តជាដើម។ ទន្ទឹមនិងនេះ បើករណីអវត្តមាន ឬមិនយល់ព្រមទៅនឹងដំណោះស្រាយរបស់មន្ត្រីសង្ឃវត្ត ជនរងគ្រោះ និង ជនរងគ្រោះនោះ អាចរាយការណ៍ទៅអាចារ្យគណៈកម្មការវត្ត ក៏អាចជួយរាយការណ៍ផ្ទាល់បន្ថែមទៀត ទៅមន្ត្រីសង្ឃសាលាអនុគណ និងមន្ត្រីធម្មការ។ ដើម្បីអង្កេត និង តាមដានបន្ថែម។ ពិសេសក្នុងករណីចាំបាច់ អាចារ្យគណៈកម្មការវត្តនោះ បន្ថែមពីលើនឹងទៅទៀត ជនរងគ្រោះ និងជនរងគ្រោះ ក៏អាចទំនាក់ទនងដោយផ្ទាល់ទៅកាន់ការិយាល័យ និងមន្ទីរធម្មការ និង

សាសនាប្រចាំស្រុកភូមិ និង រាជធានីខេត្ត របស់ខ្លួនបាន។ ក្នុងករណីដែលមិនអាចដោះស្រាយបាន ឬមិនយល់ព្រមទៅនឹងសេចក្តីសម្រេចរបស់គណៈសង្ឃវត្ត ជនរងាយរងគ្រោះ និងជនរងគ្រោះនោះ អាចរាយការណ៍នូវបញ្ហារបស់ខ្លួនជាថ្មីម្តងទៀតទៅកាន់សាលាអនុគណក្រុងស្រុកខណ្ឌរបស់ខ្លួន ដើម្បីវិផ្សាប់អធិករណ៍ឬវិវាទនោះ បើនៅតែមិនអាចដោះស្រាយបានទៀត ត្រូវបន្តទៅសាលាមេគណរាជធានីខេត្ត និងគណៈសង្ឃនាយក ចុងក្រោយជាមួយថេរសភាសង្ឃជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ដែលជាតុលាការសង្ឃជាន់ខ្ពស់ ដើម្បីសម្រេចសេចក្តី។

## ខ- អាជ្ញាធរមានសមត្ថកិច្ច

ថ្នាក់ដឹកនាំសង្ឃនៅតាមវត្តនីមួយៗមានតួនាទីដោះស្រាយ ករណីរំលោកបំពានលើកុមារទៅតាមវិន័យធម៌ និងបញ្ជូនករណីរំលោកបំពានទៅ អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់។

ជនរងាយរងគ្រោះ និងជនរងគ្រោះក៏អាចរាយការណ៍ពីស្ថានភាពបទល្មើស ជាក់ស្តែងណាមួយ ទៅអាជ្ញាធរដែនដីមានសមត្ថកិច្ច ដូចជាមន្ត្រីភូមិ មន្ត្រីឃុំសង្កាត់ ប៉ូលីសប៉ុស្តិ៍នគរបាល អធិការដ្ឋាននគរបាលក្រុង/ស្រុក/ខណ្ឌ មូលដ្ឋានកងរាជអាវុធហត្ថ និងមន្ត្រីពាក់ព័ន្ធនានា ដើម្បីចាត់វិធានតាមផ្លូវច្បាប់ទាន់ហេតុការណ៍ភ្លាមៗ។

## គ- អង្គការក្រៅរដ្ឋាភិបាលនានា

អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិនានា បាននឹងកំពុងយកចិត្តទុកដាក់ លើបញ្ហាកុមារយ៉ាងខ្លាំង។ ដូច្នេះក្នុងដំណាក់កាលចាំបាច់ណាមួយ នៅពេលពួកគេមិនទុកចិត្ត និងមិនទទួលយកនូវចំណាត់ការណាមួយពីមន្ត្រីសង្ឃ និងមន្ត្រីធម្មការ និងសាសនា រួមទាំងអាជ្ញាធរដែនដី ពួកគេក៏អាចរាយការណ៍ទៅកាន់អង្គការជាតិ និងអន្តរ

*ជាតិទាំងនោះ ដែលទទួលបន្ទុកកិច្ចការពារកុមារពីបញ្ហារបស់ពួកគេ ដើម្បីសង្កេត និង តាមដាន រួមទាំងស្វែងរកដំណោះស្រាយសមស្របចំពោះករណីអធិករណ៍នោះបាន។*

*បុគ្គលគ្រប់រូបអាចចូលរួម ទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារតាមរយៈ ការមិនប្រព្រឹត្តអំពើហិង្សាជាមួយកុមារ ការធ្វើជាគំរូអហិង្សា ចូលរួមផ្សព្វផ្សាយទប់ស្កាត់ រាយការណ៍ ពីអំពើហិង្សាដល់អាជ្ញាធរមានសមត្ថកិច្ច ។*

*កុមារទាំងអស់ មានសិទ្ធិទទួលបានការការពារពីអំពើហិង្សា។ សម្រាប់ព័ត៌មាន បន្ថែម និង យោបល់បែបកុមារមេត្រី ព្រមទាំងរក្សាការសម្ងាត់ សូមហៅមកលេខ* 1280 *ដោយឥតគិតថ្លៃ ២៤ម៉ោង របស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។*

**២.៦- សង្ខេបមេរៀន**

*អំពើហិង្សាលើកុមាររួមមាន អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។ ការដាក់ទណ្ឌកម្មលើកុមារជាអំពើខុសឆ្គង ពីព្រោះគេមិនត្រូវប្រើប្រាស់អំពើហិង្សា*

*ដើម្បីអប់រំអ្នកណាម្នាក់ឡើយ ដោយសារវាបណ្តាលឱ្យមានគ្រោះថ្នាក់។ ការដាក់ ទណ្ឌកម្មលើរាងកាយ គឺជាវិធានការដែលតាមជាក់ស្តែង«រហ័ស» បង្កតែភាពភ័យខ្លាច និងបង្រៀនកុមារឱ្យយកហិង្សាមកដោះស្រាយតែប៉ុណ្ណោះ។ ការរុកកួនជាទង្វើអាចពាក់ ព័ន្ធទៅនិងអំពើហិង្សាលើផ្លូវកាយ ឬផ្លូវចិត្តដែលប្រព្រឹត្តពីកុមារដូចគ្នាផ្សេងទៀត។*

*ប្រភេទ និងផលប៉ះពាល់នៃអំពើហិង្សាលើកុមារ មានប្រភពកើតឡើងពីអារម្មណ៍ បញ្ញា និងការយកចិត្តទុកដាក់ជាប្រចាំពីអ្នកមានឥទ្ធិពលជាបុព្វការីជាមាតា ឬអាណា ព្យាបាល ព្រមទាំងអ្នកអភិបាលសហគមន៍ និងសង្គមផងដែរ។*

*ការចាប់ផ្តើមដំបូង គឺពាក់ព័ន្ធដល់ការជឿ ឬជំនឿ។ ការជឿអាចខុស ឬត្រូវទៅតាម សទ្ធា មនោសញ្ចេតនារបស់មនុស្ស និងការយល់ដឹងរបស់មនុស្ស។ ជំនឿដែលខុស ដែល*

មិនត្រឹមត្រូវ ដែលមិនពិតអាចនាំឱ្យអ្នកប្រព្រឹត្ត និងអ្នកទទួលរងអំពើស្ទាប់ក៏ថាបាន។ ក្នុងបញ្ហាជំនឿ និងការអភិវឌ្ឍជាប្រក្រតីទាំងអស់នេះក៏បាន ចូលរួមបង្កើតឱ្យមាន ជាប្រភេទនៃហិង្សាច្រើនទៀត ដែលមានលក្ខណៈឆ្លងវប្បធម៌តៗគ្នាពីស្រទាប់មនុស្ស ពីសម័យមួយទៅសម័យមួយ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត រកទីបញ្ចប់ពុំឃើញ។

អំពើហិង្សាលើកុមារនៅកម្ពុជា បានបង្ហាញថាយ៉ាងហោចណាស់មានការបាត់បង់ថវិកា ១៦៨លានដុល្លារ ដោយសារតែផលវិបាកផ្នែកសុខភាពមួយចំនួន បង្កដោយអំពើហិង្សា និងអំពើហិង្សាកាលពីកុមារភាព បណ្តាលឱ្យខាតបង់ផលិតភាព គិតជាប្រាក់ចំនួនប្រមាណ ៨៣.៣០លានដុល្លារ ក្នុងឆ្នាំ២០១៣។ បន្ទុកសេដ្ឋកិច្ចនៃផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចនៃអំពើហិង្សាលើកុមាររួមមាន ការបន្ថែមបន្ទុកទៅលើប្រព័ន្ធថែទាំសុខភាព ដោយសារតែការប្រើប្រាស់សេវាសុខភាពដ៏លើសលប់ និងក្នុងករណីធ្ងន់ធ្ងរគឺបណ្តាលឱ្យមានពិការភាព និងមរណភាព ព្រមទាំងកម្រិតនៃអំពើហិង្សា និងពិរុទ្ធភាពមានការកើនឡើង។

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាលើកុមារ ក៏ត្រូវបានដាក់ចេញជាអន្តរជាតិ ដែលប្រទេសជាហត្ថលេខីជាច្រើនបានប្តេជ្ញាអនុវត្តចូលរួម ដើម្បីពង្រឹង និងអភិវឌ្ឍ លើការការពារចំពោះកុមារជាអន្តរជាតិ។ នៅព្រះរាជាណាចក្រកម្ពុជាមានច្បាប់រដ្ឋធម្មនុញ្ញ មានគោលនយោបាយ យុទ្ធសាស្ត្រ មានកម្មវិធីជាតិ អន្តរជាតិ អង្គការ សង្គមស៊ីវិល បានសហការចូលរួមស្ទើរគ្រប់ក្រសួង ហើយក្នុងនោះក្រសួងធម្មការ និងសាសនា ក៏បានសម្រេចនឹងទទួលយកបញ្ហានេះ ព្រមទាំងនឹងដាក់បញ្ចូលក្នុងកម្មវិធីពុទ្ធិកសិក្សាទាំងមូល ។

ការយល់ព្រម និងការឯកភាព ជាចក្ខុវិស័យដ៏ប្រសើរ ដោយរំពឹងឃើញថា កន្លងមក ក្រសួងធម្មការ និងសាសនា ធ្លាប់បានចូលរួមក្នុងការទប់ស្កាត់ច្រើនប្រកបដោយជោគជ័យ។ ក្នុងនោះមានការអនុវត្តច្បាប់ស្តីពីសិទ្ធិមនុស្ស ការពារបរិស្ថាន ការទប់ស្កាត់

ជំងឺអេដស៍ ការទប់ស្កាត់ការជក់បារី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងពេលនេះ ការទប់ស្កាត់ការរំលោភបំពាននិងហិង្សាលើកុមារទៀត។ ក្នុងកិច្ចការទប់ស្កាត់នេះ យើងផ្អែកលើប្រព័ន្ធខ្សែបណ្ដោយរបស់ក្រសួង និងខ្សែទទឹងនៃរដ្ឋអំណាច ដែលមានចាប់តាំងពីរាជធានី-ខេត្ត ដល់ជនបទ ខណ្ឌ/ស្រុក/ក្រុង ឃុំ/សង្កាត់ ភូមិ។ ក្នុងនោះ សកម្មភាពវត្តអារាម វិស័យពុទ្ធិកសិក្សា ពុទ្ធិកមជ្ឈមណ្ឌលពុទ្ធសាសនា អង្គការ សហគមន៍ពុទ្ធសាសនា សមាគមអាចារ្យ។ល។ នឹងមានសកម្មភាពចូលរួមច្រើន តាមរយៈព្រះសង្ឃ អាចារ្យ ដូនជី គ្រូបង្រៀន សាស្ត្រាចារ្យ យុវជន កុមារនៅតាមទីកន្លែងនីមួយៗទាំងអស់នោះ ។ តាមរយៈបណ្ដាញរដ្ឋបាលបច្ចេកទេស ទាំងព្រះសង្ឃ និងគ្រហស្ថ ក្នុងប្រព័ន្ធនៃក្រសួងធម្មការ និងសាសនានេះ យើងសង្ឃឹម និងជឿជាក់ថា ការទប់ស្កាត់ការរំលោភបំពាន និងការកាត់បន្ថយផលប៉ះពាល់លើអំពើហិង្សានោះ ប្រាកដជាទទួលបានការជយចុះ ដូចការអនុវត្តលើគោលនយោបាយរបស់ក្រសួងធម្មការ និងសាសនាពីមុនដែរ។

អំពើហិង្សាលើកុមារ គឺមិនអាចទទួលយកបានឡើយ ច្បាប់ជាតិ និងច្បាប់អន្តរជាតិហាមឃាត់នូវគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ។ ការចូលរួមសហការទាំងអស់គ្នា គឺជាផលប្រយោជន៍ដល់កុមារដែលជាទីសង្ឃឹមនៃអនាគត និងជោគវាសនា នៃសសរទ្រូងរបស់មាតុភូមិកម្ពុជា ។

### ២.៧- សំណួររំលឹក

១. តើមានជំនឿ និងការពិតអ្វីខ្លះដែលជាផ្នែកមួយនៃអំពើហិង្សាលើកុមារ?

២. តើអំពើហិង្សាមានទម្រង់អ្វីខ្លះ? ហើយបណ្ដាលឱ្យខាតបង់អ្វីខ្លះ?

៣. អំពើហិង្សាលើកុមារ មានសូចនាករអ្វីខ្លះ ? ចូរបង្ហាញ !

៨. តើបព្វជិត សាមណេរ ភិក្ខុ មានអ្វីខ្លះដើម្បីគាំទ្រ និងជួយអន្តរាគមន៍ដល់ការទប់ស្កាត់ហិង្សាលើកុមារតាមរយៈការឆ្លើយតបនៃទ្រឹស្តីពុទ្ធសាសនា? ចូរបង្ហាញ និង ពន្យល់!

៩. តើវិស័យពុទ្ធសាសនា មានគោលការណ៍ យុទ្ធសាស្ត្រណាខ្លះ សម្រាប់ចូលរួមវិភាគទានដល់យុទ្ធនាការទប់ស្កាត់អំពើហិង្សាលើកុមារនេះ?

## ជំពូក៣៖ ការចិញ្ចឹមកុមារ ឬកូនបែបវិជ្ជមាន

### គោលបំណង

*ក្រោយពីសិក្សានូវជំពូកនេះ សមណនិស្សិត និស្សិតនឹងទទួលបាន៖*

- *ការយល់ដឹងអំពី របៀបនៃការអភិវឌ្ឍកុមារ*
- *ការយល់ដឹងអំពី របៀបចិញ្ចឹមកូនតាមរបៀបវិជ្ជមាន*
- *ការយល់ដឹងអំពី គោលការណ៍ប្រៀនប្រដៅ និងអប់រំកុមារ*
- *ការយល់ដឹងពី សិទ្ធិ និងតម្រូវការរបស់កុមារ*

### សេចក្តីផ្តើម

*ការចិញ្ចឹម និងបីបាច់ថែរក្សាកូនជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់រូប។ មាតាបិតាចិញ្ចឹមថែរក្សាបណ្តុះបណ្តាលបុត្រធីតា ទាំងផ្លូវកាយ ស្មារតី ពុទ្ធិ ប្រកបដោយភាពវិជ្ជ-មាន។ ដើម្បីឱ្យកុមារលូតលាស់ល្អ ការបីបាច់ ការថែរក្សាកុមារ និងការអប់រំកុមារ ចាប់តាំងពីក្នុងផ្ទៃមាតាមកម្ល៉េះ។ ការបីបាច់ ការថែរក្សាកុមារ និងការអប់រំកុមារ ចាប់តាំងពីក្នុងផ្ទៃមាតា មានន័យថា ស្ត្រីជាមាតានិងជាភរិយា បុរសជាបិតានិងជាស្វាមី ត្រូវមានឥរិយាបថវិជ្ជមាន មិនប្រើហិង្សាដល់គ្នានិងគ្នា និងត្រូវមានចិត្តប្រកបដោយព្រហ្មវិហារធម៌ទាំង៤ដល់គ្នានិងគ្នា(មេត្តា ករុណា មុទិតា និងឧបេក្ខា)។*

### ៣.១- ការអភិវឌ្ឍរបស់កុមារ

*កុមារទទួលរងការឈឺចាប់ និងសប្បាយរីករាយជាមួយនិងប្រពលភាពដូចមនុស្សពេញវ័យដែរ ទោះជាកម្លាំងជំរុញមានភាពផ្សេងគ្នាទាំងស្រុងក៏ដោយ។ ការផ្លាស់ប្តូរ ខាងសរីរសាស្ត្រនិងជវ័ន ធ្វើឱ្យកុមារអភិវឌ្ឍដោយស្វ័យភាពក្នុងការទប់ទល់ នូវសម្ពាធ ខាងក្រៅនិងសកម្មភាពនានាដែលពួកគេជួបប្រទះ។ ហេតុនេះ ការអភិវឌ្ឍរបស់កុមារ គឺជាកត្តាចាំបាច់តាមបែបធម្មជាតិនិងចិត្តសាស្ត្រ[១១]។*

---

[១១] សុខ ប៊ុនធឿន : *វិធីកាត់បន្ថយស្ត្រេស* ដ.ឯ.ម. ទំព័រ ៦១-៨៨

### ៣.១.១- តើអ្វីទៅជាការអភិវឌ្ឍកុមារ?

ការអភិវឌ្ឍរបស់កុមារ សំដៅលើដំណើរការដែលកុមារមានលទ្ធភាពអាចធ្វើកិច្ចការ កាន់តែលំបាកនិងស្មុគស្មាញទៅៗ នៅពេលដែលកុមារមានអាយុកាន់តែច្រើន ឡើងៗ។ ការអភិវឌ្ឍគឺខុសប្លែកពីការលូតលាស់ ដែលការលូតលាស់សំដៅលើកុមាររីកធំធាត់ផ្នែកទំហំរាងកាយ ។

### កត្តាដែលជំរុញឱ្យមានការអភិវឌ្ឍ៖

ដើម្បីធានាឱ្យកុមារមានសុខភាពល្អ គួរមានតុល្យភាពនៃកត្តាដូចខាងក្រោម៖

- ម្តាយមានសុខភាពល្អ
- គ្រួសារ និងបរិយាកាសសង្គមដែលមានការយកចិត្តទុកដាក់ និងការចិញ្ចឹមបីបាច់
- ការផ្តល់នូវអាហារគ្រប់គ្រាន់ និងចាំបាច់សម្រាប់សុខភាព
- បរិយាកាសជុំវិញខ្លួនមានសុវត្ថិភាព
- ការគាំទ្រ និងការលើកទឹកចិត្តពីអ្នកថែទាំ ដើម្បីបំពេញតាមតម្រូវការនៃការអភិវឌ្ឍរបស់កុមារ ។

ដូច្នេះហើយ វាជាការសំខាន់ណាស់ដែលតម្រូវការរបស់កុមារត្រូវបានបំពេញ បើពួកគេអភិវឌ្ឍតាមលក្ខណៈមួយប្រកបដោយសុខភាពល្អ ។

### ៣.១.២- ដំណាក់កាលនៃការអភិវឌ្ឍកុមារ

**១-<u>ផ្នែករាងកាយ (ជំនាញផ្នែកចលនា)</u>:** ជាភាពរឹងប៉ឹងដែលកើនឡើង និង ស៊ីសង្វាក់គ្នានៃចលនាដែលកើនឡើង ហើយអាចឱ្យកុមារអង្គុយ ឈរ ដើរ រត់ រក្សាលំនឹង និងផ្លាស់ប្តូរទីតាំងជាដើម។ យើងហៅទាំងអស់នេះថា ជាជំនាញ ចលនាទូទៅ ហើយកុមារអភិវឌ្ឍចលនានេះជាបន្តបន្ទាប់ដូចជាគេចាប់ផ្តើមចេះ ក្រឡាប់ បន្ទាប់មក ចេះអង្គុយ ឈរ ដើរ រត់ លោតឡើង ឬ លោតរំលងជាដើម។ ជំនាញចលនាដែលល្អ គឺនៅពេលកុមារចេះប្រើដៃ និងជើងរបស់គេ ដោយអាចញ៉ាំ ស្លៀកពាក់ លេង សរសេរ និងធ្វើអ្វីជាច្រើន

ផ្សេងទៀតបាន។ ពួកគេអាចចាប់យករបស់របរដោយប្រើដៃទាំងមូលរបស់គេ បន្ទាប់មកគេអភិវឌ្ឍចាប់យករបស់របរដោយប្រើមេដៃ និងចង្អុលដៃហើយជាបន្ទាប់គេអាចចាប់យករបស់កាន់តែតូចល្អិត រហូតដល់គេអាចដោតអំបោះចូលក្នុងគូទម្ជុលបានជាដើម ។

<u>២-ផ្នែកយល់ដឹង (ជំនាញក្នុងការគិត)</u>: រួមទាំងការរៀន ការយល់ ការដោះស្រាយបញ្ហា ការផ្តល់ហេតុផល និងការចងចាំ។

<u>៣-ផ្នែកសង្គម(រួមទាំងភាសា)</u>: ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ទំនាក់ទំនងជាមួយគ្រួសារ មិត្តភក្តិ គ្រូ ហើយនិងការសហការជាមួយអ្នកដទៃ។ និយាយដោយប្រើភាសាកាយវិការ និងកាយវិការប្រាស្រ័យទាក់ទង ហើយយល់ពីអ្វីដែលអ្នកដទៃ និយាយ។

<u>៤-ផ្នែកអារម្មណ៍</u>: ការបង្កើតឱ្យមានការផ្សារភ្ជាប់ ការអភិវឌ្ឍសមត្ថភាព ស្គាល់ខ្លួនឯង ការដឹង ការបង្ហាញ និងការគ្រប់គ្រងអារម្មណ៍ ការឆ្លើយតបចំពោះអារម្មណ៍របស់អ្នកដទៃ ការគ្រប់គ្រងលើខ្លួនឯង និងការមានភាពឯករាជ្យ ។

## ៣.២- ការចិញ្ចឹមកូនបែបវិជ្ជមាន

កុមារអាចរៀនសូត្រតាមទង្វើរបស់មនុស្សធំ ឬឪពុកម្តាយពួកគេដែលបានធ្វើ មិនមែនធ្វើតាមតែអ្វីដែលឪពុកម្តាយគេគ្រាន់តែប្រាប់នោះទេ ។

សូមកុំមានការភាន់ច្រឡំគ្នារវាងការគោរព និងការភ័យខ្លាច។ អាកប្បកិរិយាល្អដែលសម្តែងចេញដោយសារតែការភ័យខ្លាច មានន័យថា កុមារកំពុងតែគេចចេញពីការដាក់ទណ្ឌកម្មលើរាងកាយរបស់ពួកគេ មិនមែនកំពុងបង្ហាញនូវការគោរពដោយស្មោះស្ម័គ្រទេ។ កុមារអាចរៀនសូត្រពីការគោរពដោយស្មោះស្ម័គ្រចំពោះមនុស្ស និងវត្ថុទូទៅលុះត្រាតែ ពួកគេយល់ច្បាស់ពីតម្លៃពិតប្រាកដរបស់ពួកគេ ។ នៅពេលដែល ឪពុកម្តាយវាយដំកូនចៅ ក្នុងនាមប្រដៅកុមារបានរៀនសូត្រតាម ហើយយល់ថា អំពើហិង្សាជាវិធីដែលអាចទទួលយកដើម្បីដោះស្រាយជម្លោះ ។

ដូច្នេះនៅពេលដែលឪពុកម្តាយបានបង្ហាញនូវការគោរព និងសេចក្តីថ្លៃថ្នូរ កុមារក៏នឹងរៀនបានពីការគោរពនោះ។ នៅពេលដែលឪពុកម្តាយប្រដៅកូនក្នុងន័យវិជ្ជមានតាមរបៀបអហិង្សា កុមារក៏នឹងរៀនសូត្រតាមដូច្នោះដែរ ។

*ការប្រដៅកូនបែបវិជ្ជមានត្រូវបានរៀបចំឡើង ដើម្បីជានាថាកុមារអាចរៀនគិតគូរចំពោះអ្នកដទៃ និងអំពីផលវិបាកដែលកើតចេញពីទង្វើរបស់ពួកគេ។*

## *គោលការណ៍សំខាន់ៗក្នុងការប្រៀនប្រដៅ / ការចិញ្ចឹមកូនបែបវិជ្ជមាន*

- *អហិង្សា*
- *ផ្តោតទៅលើការរកដំណោះស្រាយ*
- *ការគោរព*
- *ផ្អែកលើគោលការណ៍អភិវឌ្ឍរបស់កុមារ*
- *ផ្អែកលើអនុសញ្ញាសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស* (UNHCR)។

**មានធាតុផ្សំ២ នៃការប្រៀនប្រដៅ និងការចិញ្ចឹមកូនបែបវិជ្ជមានគឺ៖**

***ធាតុផ្សំទី១: គោលដៅយូរអង្វែង***

*តើអ្នកចង់ឱ្យកុមារ-កូនអ្នកក្លាយជាមនុស្សបែបណានៅពេលដែលគេធំឡើង?*

***ធាតុផ្សំទី២: ភាពកក់ក្តៅ-ដែនកំណត់***

*តើត្រូវផ្តល់ភាពកក់ក្តៅយ៉ាងដូចម្តេច? និងផ្តល់ដែនកំណត់យ៉ាងដូចម្តេច ដល់កុមារ?*

***ភាពកក់ក្តៅ*** *សំដៅដល់អ្វីដែលឪពុកម្តាយផ្តល់ដល់កូនដោយគ្មានលក្ខខណ្ឌ ហើយជាការស្រឡាញ់ប្រកបដោយការយកចិត្តទុកដាក់និងការថែទាំ។* ***ភាពកក់ក្តៅ រួមមាន:***

- *សុវត្ថិភាពផ្លូវចិត្ត*
- *សេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌ*
- *សេចក្តីស្រឡាញ់ថ្នាក់ថ្នមទាំងកាយ និងវាចាពីរោះ*
- *សេចក្តីគោរព*

- *ការតភ្ជាប់ទំនាក់ទំនងជាមួយនិងកូនផ្អែកលើកម្រិតនៃការអភិវឌ្ឍ (លូតលាស់)*
- *ការយកចិត្តទុកដាក់ក្នុងការឆ្លើយតបតម្រូវការរបស់កូន*

*នៅក្នុងបរិយាកាសកក់ក្តៅណាមួយ កូនតែងតែចង់យកចិត្តឪពុកម្តាយ ឬអ្នកមើលថែទាំរបស់ពួកគេ។ ភាពកក់ក្តៅជួយលើកទឹកចិត្តនៃការប្រព្រឹត្ត តាមរយៈពេលខ្លី និង បង្រៀនពីតម្លៃ សម្រាប់រយៈពេលយូរអង្វែង។* ***អ្នកមើលថែទាំ ឬឪពុកម្តាយអាចបង្ហាញភាពកក់ក្តៅដល់កូនតាមរយៈ***

- *និយាយទៅកាន់កុមារ-កូនដោយពាក្យផ្អែមល្ហែម*
- *លួងលោមកុមារ-កូន ពេលដែលកូនជួបបញ្ហា នៅពេលគេឈឺចាប់ ឬ ភ័យខ្លាច*
- *ស្ទុះស្ទា ផ្តល់ថ្នាំ បបោសអង្អែល ថ្នាក់ថ្នម ឬនាំទៅពេទ្យពេលកូនឈឺ*
- *សួរនាំ និងអនុគ្រោះពេលកុមារធ្វើខុស*
- *មិនស្តីបន្ទោស មិនបន្ទុះបង្អាប់ពេលកុមារធ្វើខុស*
- *ទទួលស្គាល់នូវភាពប្រឹងប្រែង និងជោគជ័យរបស់ពួកគេ។*
- *អោប ថើប ឬប្រឡែងលេងជាមួយពួកគេ ។ល។*

*ដែនកំណត់ជួយឱ្យកូនរៀនពីអ្វីដែលមានសារៈសំខាន់ និងជួយឱ្យពួកគេយល់អំពីកំហុសនិងធ្វើអ្វីមួយ ដែលពួកគេអាចធ្វើទៅបានដើម្បីកែកំហុសទាំងនោះ។ ដែនកំណត់ក៏បានផ្តល់ឱ្យកូនផងដែរនូវព័ត៌មានដែលគេត្រូវការ ដើម្បីទទួលបានជោគជ័យនៅពេលក្រោយទៀត។ វាក៏ជាឧបករណ៍សម្រាប់ជួយពួកគេដោះស្រាយបញ្ហា នៅពេលណាដែលមនុស្សចាស់ ដែលធ្លាប់ជួយពួកគេ មិនមានវត្តមាននៅទីនោះ ។*

***ដែនគំណត់គឺ៖***

- *បង្កើតគោលការណ៍ណែនាំច្បាស់លាស់ពីអាកប្បកិរិយា និងរបៀបប្រព្រឹត្តនានា*

- ប្រាប់ពីការរំពឹងទុក និងការបញ្ជាក់ប្រាប់ផលប៉ះពាល់នានាយ៉ាងច្បាស់លាស់
- ប្រាប់ហេតុផលនានាសម្រាប់អាកប្បកិរិយានិងការប្រព្រឹត្ត
- ផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីជួយឱ្យការសម្រេចចិត្តបានត្រឹមត្រូវ
- ប្រាប់ពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើ
- បង្ហាញនូវហេតុផលនានា
- ការចរចារ...។ល។

**អ្នកមើលថែទាំ ឬឪពុកម្តាយអាចផ្តល់នូវដែនកំណត់ដល់កូនតាមរយៈ**

- រៀបចំឱ្យពួកគេត្រៀមខ្លួនសម្រាប់ស្ថានភាពលំបាកនានា ដោយប្រាប់ពួកគេ ពីអ្វីៗដែលត្រូវរំពឹងទុក និងរបៀបដែលពួកគេអាចដោះស្រាយ
- ពន្យល់ហេតុផលនានាសម្រាប់ទម្លាប់ដែលមាន
- ពិភាក្សាច្បាប់ទម្លាប់នោះជាមួយពួកគេ និងស្តាប់ទស្សនៈនានារបស់ពួកគេ (ទៅតាមអាយុរបស់គេ)
- ជួយឱ្យរកឃើញវិធីនានាដើម្បីកែកំហុសរបស់ពួកគេ តាមរបៀបមួយ ដែលជួយពួកគេឱ្យរៀនបានពីកំហុសនោះ ។
- ប្រកាន់យកភាពយុត្តិធម៌ត្រឹមត្រូវ និងចេះបត់បែន
- គ្រប់គ្រងកំហឹង
- ពន្យល់ពីទស្សនៈរបស់ពួកគាត់ និងស្តាប់ពីទស្សនៈរបស់គាត់
- បង្រៀនពួកគេពីផលប៉ះពាល់នៃទង្វើរបស់ពួកគេចំពោះអ្នកដទៃ
- ផ្តល់ព័ត៌មាន ដែលពួកគេត្រូវការដើម្បីជួយឱ្យធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។
- ចៀសវាងការគំរាមវាយ ឈប់ផ្តល់ក្តីស្រឡាញ់ បន្ទាចថាមានសត្វចម្លែកខ្មោច ឬអ្វីៗដែលធ្វើឱ្យកុមារខ្លាច។

• ធ្វើជាគំរូល្អ និងជាអ្នកនាំផ្លូវដ៏ល្អចំពោះពួកគេ ។

<u>ចំណាំ</u> : ***ភាពកក់ក្តៅ*** គឺផ្តល់នូវការគាំទ្រ រីឯ ***ដែនកំណត់*** គឺផ្តល់នូវព័ត៌មាន ។

***ធាតុផ្សំទី៣ : យល់ដឹងពីការគិត និងអារម្មណ៍កុមារ***

*ចំណុចនេះយើងមើលទៅលើវ័យរបស់កុមារ មើលទៅលើដំណាក់កាលអភិវឌ្ឍរបស់ពួកគេ ថាតើវ័យនេះពួកគេកំពុងត្រូវការអ្វី ហើយយើងត្រូវផ្តល់អនុសាសន៍ឱ្យពួកគេបែបណា?*

***ធាតុផ្សំទី៤: ដោះស្រាយបញ្ហា***

*នៅពេលដែលយើងបានយល់អំពីបញ្ហាទាំងអស់របស់កូន ដោយការយកចិត្តទុកដាក់ផ្តល់ភាពកក់ក្តៅ យល់ពីការគិត យល់អារម្មណ៍ និងយល់ដឹងពីការវិវត្តរបស់កូនទៅតាមអាយុតាមវ័យហើយនោះ នោះយើងប្រាកដជាអាចរកឃើញដំណោះស្រាយថាតើយើងគួរធ្វើយ៉ាងណាដើម្បីបំពេញតម្រូវការកូនបាន ហើយស្របទៅតាមគោលការណ៍យូរអង្វែងរបស់យើង។*

***៣.២.១- ការដាក់វិន័យបែបវិជ្ជមាន*** **(Positive Discipline)**

*នៅពេលដែលអ្នកសួរថា តើការទះកំផ្លៀងលើកុមារមិនធ្វើឱ្យកុមារឈឺចាប់ទេ? ការពិតណាស់វានឹងធ្វើឱ្យកុមារឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត។ ជាការធ្វើឱ្យឈឺចាប់លើរាងកាយកុមារ គឺជាការរំលោភលើសិទ្ធិកុមារក្នុងការទទួលបានការការពារ គេចផុតពីការរំលោភបំពាន ហើយមនុស្សចាស់គួរកុំបង្កើនផលប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូររបស់កុមារ ព្រោះការរំលោភសិទ្ធិកុមារ ក៏មានរួមបញ្ចូលទាំងកត្តាដែលនាំឱ្យឈឺចាប់ផ្នែកផ្លូវចិត្តផងដែរ ។*

*តាមរយៈនៃការស្រាវជ្រាវដែលកំពុងត្រូវបានអនុវត្តទូទាំងពិភពលោក កុមារកំពុងចាប់ផ្តើមប្រាប់យើងពីទំហំនៃការដាក់ទណ្ឌកម្មលើរាងកាយ ដែលធ្វើឱ្យពួកគេឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត។*

នៅឆ្នាំ២០០៦ របាយការណ៍នៃការស្រាវជ្រាវមួយ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាប្រឆាំងកុមារ ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈគឺជាការសិក្សាស្រាវជ្រាវដែលមានលក្ខណៈទូលំទូលាយ និងជាសកលជាលើកដំបូងទៅលើចរិតលក្ខណៈ និងវិសាលភាពនៃបញ្ហា ។

ការសិក្សាបានបង្ហាញថាកុមារបានសម្តែងគំនិតស្របៗគ្នាពីតម្រូវការជាបន្ទាន់ក្នុងការបញ្ឈប់រាល់អំពើហិង្សាលើពួកគេ។ កុមារបានបង្ហាញនូវភ័ស្តុតាងចំពោះការឈឺចាប់ ថា មិនត្រឹមតែផ្នែករាងកាយប៉ុណ្ណោះទេ ថែមទាំងឈឺចាប់ផ្នែកផ្លូវចិត្តផងដែរខណៈដែលមនុស្សចាស់វាយធ្វើបាបពួកគេ។

ការសិក្សាជាច្រើនដែលបានបង្ហាញដូចគ្នា អំពីគ្រោះថ្នាក់ដែលកើតឡើងពីការវាយធ្វើបាបកុមារ ការវិភាគបានបង្ហាញពីភាពជាប់ទាក់ទងគ្នា រវាងការដាក់ទណ្ឌកម្ម លើរាងកាយកុមារដោយឪពុកម្តាយ និងផលប៉ះពាល់បែបអវិជ្ជមានមួយចំនួនទៀត ទៅលើកុមារដូចជា ភាពកាចសាហាវហួសហេតុ អាកប្បកិរិយាប្រឆាំងសង្គមដែលនាំឱ្យអន្តរាយដល់សង្គម ខ្វះការទទួលយកនូវតម្លៃដែលត្រឹមត្រូវតាមក្រមសីលធម៌ និងបញ្ហាសុខភាពផ្លូវចិត្តចុះខ្សោយ។

ការសិក្សាផ្សេងៗទៀតបានបង្ហាញថា យ៉ាងហោចណាស់មាន២នាក់ក្នុងចំណោមអ្នកមើលថែរក្សាកុមារចំនួន៥នាក់ បានទះកំផ្លៀងកូនរបស់ពួកគេ ដោយប្រើកម្លាំងដៃធ្ងន់ហួសកម្រិតជាងការតាំងចិត្ត (វាយជ្រុលដៃ) ។

អ្នកដែលគិតបែបនេះតែងតែវាយដំកូនខ្លួនបន្ត ដោយយល់ថាជាការប្រដៅធម្មតា ព្រោះពួកគាត់ក៏ធ្លាប់ទទួលរងបែបនេះកាលពីនៅក្មេង បើទោះជាវាយកូនហើយមានអារម្មណ៍ស្តាយក្រោយក៏ពួកគេនៅតែបន្តវាយព្រោះនេះជាវប្បធម៌ ដែលជ្រួតជ្រាប បន្តតាមសម័យកាល។

ដូច្នេះរាល់ការដាក់វិន័យចំពោះកុមារ មិនត្រូវធ្វើឱ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍផ្នែករាងកាយ ផ្លូវចិត្ត និងផ្នែកសង្គមរបស់កុមារនោះទេត្រូវចៀសវាងរាល់ការដាក់ពិន័យ បែបហិង្សាជាដាច់ខាតមានដូចជា៖

- ការធ្វើទារុណកម្មលើរាងកាយកុមារ
- ការចាក់សោបង្ខាំងឱ្យកុមារនៅតែឯង
- ការចាប់ចងកុមារ
- ការមិនឱ្យកុមារទៅរៀន
- ការបង្អត់អាហារ ឬទឹក ឬមិនអនុញ្ញាតឱ្យគេទទួលទានដំណេកជាដើម
- ការដាក់លក្ខខណ្ឌឱ្យកុមារស្លៀកពាក់ប្លែកពីធម្មតា ឬមិនសមស្រប
- ការមិនឱ្យកុមារទទួលការព្យាបាលជំងឺ
- ការប្រើឱ្យកុមារដាក់វិន័យលើកុមារដទៃទៀត
- ការគំរាមកំហែង ឬការស្តីបន្ទោសកុមារដោយប្រើពាក្យមិនសមរម្យ និងអាសគ្រាម
- ការដាក់ទណ្ឌកម្មឱ្យកុមារធ្វើការងារលើសពីកម្លាំងកាយរបស់កុមារ ដូចជាការបង្ខំឱ្យកុមារដែលនៅតូចទៅលើកវត្ថុធ្ងន់ៗជាដើម។

កុមារត្រូវទទួលបាននៅសិទ្ធិការពារ ដែលអាណាព្យាបាលទាំងអស់ត្រូវថៃទាំ យកចិត្តទុកដាក់ និងផ្តល់ឱ្យពួកគេនៅអ្វីដែលពួកគេត្រូវទទួលបាន

**ការដាក់ពិន័យកុមារបែបវិជ្ជមានរួមមាន៖**

- លើកទឹកចិត្តកុមារឱ្យមានឥរិយាបថល្អ សុភាពរាបសារ ស្លូតបូត មានសាមគ្គីភាព និងវិន័យថ្លៃថ្នូរ ។
- ការដាក់វិន័យលើកុមារអាចធ្វើទៅបាន លុះត្រាកុមារមិនគោរពតាមបទបញ្ជា ឬ វិន័យតែប៉ុណ្ណោះ ។
- មិនត្រូវវាយតម្លៃ បន្ទុះបង្អាប់កុមារអំពីអាកប្បកិរិយារបស់កុមារនៅចំពោះមុខកុមារ ឬមនុស្សផ្សេងទៀតឡើយ។
- បុគ្គលិកក៏ត្រូវគោរពតាមបទបញ្ជាឬវិន័យមណ្ឌល និងត្រូវធ្វើជាគំរូល្អចំពោះ កុមារ។

### ៣.២.២- សិទ្ធិ និងតម្រូវការ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសហត្ថលេខីចំពោះអនុសញ្ញាសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិទទួលស្គាល់ថា កុមារមានសិទ្ធិដូចដែលមានចែងក្នុងអនុសញ្ញានេះ។ នេះមានន័យថា យើងត្រូវចាត់វិធានការដើម្បីបញ្ចប់ការទទួលយកនូវអំពើហិង្សាដែលប្រឆាំងនឹងកុមារជាលក្ខណៈសង្គមក្តី និងជាលក្ខណៈផ្លូវច្បាប់ក្តី ដោយសារតែផលប៉ះពាល់អវិជ្ជមាន និងនិន្នាការនៃសង្គមបានវិវត្តន៍ឆ្ពោះទៅរកការបញ្ចប់ការទទួលយកអំពើហិង្សាប្រឆាំងនឹងស្ត្រី។ អ្នកខ្លះនិយាយថា «កាលខ្ញុំនៅក្មេងក៏ត្រូវបានគេវាយ ហើយខ្ញុំបែរជាមិនអី»។ មនុស្សខ្លះ បានទទួលរងនូវបទពិសោធន៍ហិង្សាគ្រប់បែបយ៉ាង នៅពេលពួកគេធំឡើងពួកគេក៏ «ក្លាយទៅជាមិនអី» ប៉ុន្តែគ្មានអ្នកណាម្នាក់កត់សម្គាល់ថា បទពិសោធន៍ដែលគេធ្លាប់ជួបប្រទះនោះបានបង្រៀនគេទទួលយកនូវហិង្សា ដើម្បីយកមកដោះស្រាយទប់ទល់ជាមួយបទពិសោធន៍ជូរចត់ទាំងនោះ ដែលជួយឱ្យពួកគេប្រែក្លាយជីវិតទៅជា «មិនអី ឬ គ្មានបញ្ហា» និងបន្តវដ្តនៃការប្រព្រឹត្តអំពើហិង្សាជាមួយមនុស្សជុំវិញខ្លួន ដូច្នេះមិនមែនមានន័យថាបទពិសោធន៍ជូរចត់ឬអាក្រក់ទាំងនោះមិនមានបញ្ហានោះទេ។

សង្គមបានវិវត្តន៍ប្រែប្រួលពីការមើលឃើញកុមារ ថាជាទ្រព្យសម្បត្តិកម្មសិទ្ធិ របស់ឪពុកម្តាយ ទៅជាការមើលឃើញថាមនុស្សមានសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុង ឋានៈជាមនុស្សជាតិ និងផ្អែកតាមគោលការណ៍សិទ្ធិមនុស្ស កុមារមានសិទ្ធិដូចគ្នាទៅនឹងសមាជិកទាំងអស់នៅក្នុងគ្រួសារ ដើម្បីទទួលបាននៅការការពារ គេចផុតពីការវាយដំគ្មានការរំលោភបំពានលើសិទ្ធិឯកជន និងជីវិតរស់នៅជាលក្ខណៈគ្រួសារ។

កុមារក៏ត្រូវការសេចក្តីថ្លៃថ្នូរ និងការគោរពសិទ្ធិដែរ។ រាល់រូបភាពណាមួយនៃ អំពើហិង្សាប្រឆាំងពួកគេ ដូចជាមនុស្សចាស់កំពុងរំលោភបំពាន ដាក់ទណ្ឌកម្ម លើកុមារដោយគេងចំណោញការត្រួតត្រា អំពើទាំងនេះចាត់ទុកជាការរំលោភលើសិទ្ធិស្មើភាពគ្នារបស់កុមារ និងសេចក្តីថ្លៃថ្នូររបស់កុមារក្នុងនាមជាមនុស្សជាតិហើយ។

### ៣.២.៣-ចិត្តវិទ្យាកុមារ

*តាមលក្ខណៈជីវសាស្ត្រ កុមារមានការវិវត្តទាំងផ្នែកសរីរសាស្ត្រ និងចិត្តសាស្ត្រ។ ចិត្តសាស្ត្រនិងសរីរាង្គអាស្រ័យគ្នា និងប្រែប្រួលបានគ្រប់កាលៈទេសៈនៃការវិវត្តនោះ។*

***ក- ចិត្តវិទ្យា***

*គឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីបាតុភូតចិត្ត ដែលបាតុភូតនេះបានសម្តែងតាមរយៈកាយវិការ ពាក្យសម្តី ទឹកមុខ និងអាកប្បកិរិយាជាដើម។ ជាការពិតណាស់ថា ផ្លូវចិត្ត ឬអារម្មណ៍របស់មនុស្សបង្ហាញតាមរយៈកាយវិការ ពាក្យសម្តី ទឹកមុខ និង អាកប្បកិរិយា។ រាល់ការបង្ហាញតាមរយៈកត្តាទាំងអស់នោះ មិនប្រាកដថា អាចឆ្លុះបញ្ចាំងប្រាប់ពីចិត្តរបស់មនុស្សបានត្រឹមត្រូវដូចការមើលឃើញ ស្តាប់ឮ មួយរយភាគរយបានទេ។ ព្រោះមានទឹកមុខខ្លះ ពាក្យសម្តីមួយចំនួន និងអាកប្បកិរិយា មួយផ្នែកណាមួយនោះ មិនសមស្រប ទៅនឹងចិត្តបុគ្គលនោះទេ បានន័យថា ជាការសម្តែងក្លែងក្លាយ។ ចិត្តមនុស្សគ្មានរូប គ្មានពណ៌ គ្មានក្លិន។ ចិត្តគឺជាពិភពអាថ៌កំបាំង ពិបាកយល់ មានបុគ្គលជាច្រើនស្ទើរតែមិនអាចប៉ាន់ស្មានពីចិត្តរបស់ខ្លួនបាន និងមានចំណុចខ្លះ ក្រោយពេលប្រព្រឹត្តរួចទើបដឹងថា វាជាអំពើមិនគួរគប្បី។ **ឧទាហរណ៍** ការសើចបញ្ជាក់ថា មនុស្សសប្បាយចិត្ត។ ការយំបង្ហាញពីការពិបាកចិត្ត តែក៏មានការសើចខ្លះមិនប្រាកដថាសប្បាយចិត្តទេ ហើយការយំខ្លះព្រោះតែការរំភើបចិត្ត ដូចជា ពេលបានជួបជុំបងប្អូនដែលបានបែកជាច្រើនឆ្នាំជាដើម។*

*ការសិក្សាអំពីចិត្តវិទ្យា គឺជាលំនាំនៃការសិក្សាផ្តោតលើការសម្តែងចេញរបស់អាកប្បកិរិយា និងលំនាំនៃបាតុភូតចិត្តរបស់មនុស្ស។ អាកប្បកិរិយាយើងអាចពិនិត្យមើលឃើញបាន ប៉ុន្តែលំនាំនៃផ្លូវចិត្តយើងមិនអាចមើលឃើញបានឡើយ ដែលមានដូចជា លំនាំនៃការគិត ការនឹក ឬការស្រមៃជាដើម[១២]។*

***ខ- កុមារ :***

---

[១២] *ចាន់ពៅ ត្រាយ សារ៉េត* (6th, ២០១៤). *ចិត្តវិទ្យាទូទៅ:ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន. ភ្នំពេញ: គូមិន្ទភ្នំពេញ។*

*ក្នុងចំណោមសត្វលោកទាំងអស់ដែលនៅក្មេងខ្ចីដូចគ្នា កូនង៉ែតមានសភាពទន់ខ្សោយ។ កូនង៉ែតមិនអាចធ្វើអ្វីបានទាំងអស់ ក្រៅពីស្រែកយំ។ បើឃ្លានបៅទាល់តែម្តាយលើកឱ្យបៅ។ ភាពជាកូនខ្ចី ស្ថិតស្ថេរអស់រយៈពេលជាយូរអង្វែងបំផុត បើធៀបទៅនឹងជីវិតសត្វលោកផ្សេងៗទៀត។ ជីវិតសត្វលោកផ្សេងៗទៀត សុទ្ធតែឆាប់ពេញវ័យជាង មនុស្ស។ តែទោះជាបែបនេះក្តី កូនង៉ែតត្រូវការរៀនសូត្រច្រើន និងអភិវឌ្ឍជាងសត្វឯ ទៀត។ និយាយរួម កូនង៉ែតត្រូវការរៀនសូត្រច្រើន ដើម្បីក្លាយជាមនុស្សពេញវ័យ។ ការរៀនសូត្ររបស់កូនង៉ែតមានច្រើនបំផុតនៅឆ្នាំទី១។ ពិតមែនហើយ ដំបូងទារកអាចទប់ទល់និងខ្លួនបានដើម្បីដើរ និងធ្វើចលនាបានច្រើនយ៉ាងជាបន្តបន្ទាប់។ កុមារចេះធ្វើអ្វីៗបានយ៉ាងច្រើន ដើម្បីបំពេញតម្រូវការខ្លួនឯងផ្ទាល់[១៣]។*

### ៣.២.៤- ឥរិយាបថរបស់អាណាព្យាបាល និងកុមារ

*តាមការសិក្សាស្រាវជ្រាវមួយស្តីពីការលូតលាស់រាងកាយបានបញ្ជាក់ថា កូនក្មេងតាំងពីនៅជាទារក ប្រហែលជាអាចមានផលប៉ះពាល់ដោយព្រឹត្តិការណ៍ដែលបានគំរាមកំហែងពីសុវត្ថិភាពរបស់ពួកគេ ឬពីឪពុកម្តាយ ហើយរោគសញ្ញារបស់ពួកគេ ត្រូវបានចងក្រងជាព័ត៌មានទុកផងដែរ។ ការប៉ះទង្គិចទាំងនេះអាចជា លទ្ធផលនៃអំពើហិង្សាខាងក្នុងដែលអាចជាចេតនាដែលមានដូចជា ការប៉ះពាល់លើរូបរាងកាយរបស់ក្មេង ការរំលោភបំពានផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ លទ្ធផលនៃគ្រោះធម្មជាតិ គ្រោះថ្នាក់ ឬ សង្គ្រាម។ កូនតូចៗ ក៏អាចមានបទពិសោធន៍ ការប៉ះទង្គិចពីការតានតឹងចិត្ត ដែលធ្វើឱ្យមានការឈឺចាប់ ឬក៏បាត់បង់ឪពុកម្តាយ ឬអ្នកមើលថែ។ ស្ទើរតែទាំងអស់ នៃការប៉ះទង្គិចផ្លូវចិត្ត ធម្មតាៗអាចមានផលប៉ះពាល់ដល់កូនក្មេង រួមមាន៖ គ្រោះថ្នាក់ ការប៉ះទង្គិចលើរូបរាងកាយ ការរំលោភ ការប្រមាថ និងរួមបញ្ចូល ទាំងការប្រើអំពើហិង្សាក្នុងគ្រួសារ ឬសហគមន៍ផងដែរ។*

---

[១៣] *ចិត្តវិទ្យាកុមារ, ឡាយ សុក្ខណាក់, ២០១២។*

### ក- រោគសញ្ញានិងទំនាក់ទំនងអាកប្បកិរិយា ធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្ត

ក្មេងដែលមានបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តអាចមានអាកប្បកិរិយា តាមកម្រិតផ្សេងៗធ្វើឱ្យក្មេងមួយចំនួន ពិបាកនឹងមានសមត្ថភាពក្នុងការទំនាក់ទំនង វាពិតជាមានសារៈសំខាន់ណាស់ចំពោះឪពុកម្តាយ និងវ័យជំទង់ដែលត្រូវយល់ដឹង ពីរោគសញ្ញាដែលអាចកើតមានៗ បើយោងទៅតាម National Child Traumatic Stress Network កុមារអាចប្រកាន់នូវភាពរឹងរូស និងការភ័យខ្លាចនៃស្ថានភាពថ្មីៗ បានយ៉ាងងាយស្រួល វាមានការពិបាកក្នុងការលួងលោម ឬក្នុងការឈ្លានពានហើយនិងខ្វះការគិតៗ ពួកគេក៏អាចមានបញ្ហាដំណេក ឬបទពិសោធន៍បរាជ័យក្នុងការអភិវឌ្ឍជំនាញផងដែរ(ឧទាហរណ៍ ការនិយាយ ការត្រួតពិនិត្យពោះវៀន ទឹកនោម) ព្រមទាំងការបង្ហាញនៃដំណើរថយក្រោយនៃតួនាទី និងអាកប្បកិរិយាៗ

### ខ- ការជួយដោះស្រាយកុមារ

ក្នុងការជួយកុមារដោះស្រាយបញ្ហាផ្លូវចិត្ត វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះវ័យជំទង់ ក្នុងជីវិតកាលពីអតីតកាលរបស់ពួកគេ ដែលជួបអារម្មណ៍អវិជ្ជមាន ពួកគេអាចមានអារម្មណ៍ត្រូវបានស្តីបន្ទោសៗ មានយុត្តិសាស្ត្រមួយចំនួនដូចជា៖

- បង្ហាញពីការយកចិត្តទុកដាក់ស្តាប់កូននិយាយ
- ប្រើសំឡេងទន់ភ្លន់
- ធានាថាពួកគេនិងមានសុវត្ថិភាព
- កុំសរុបសេចក្តីអារម្មណ៍របស់កូនដោយពាក្យ «កុំធ្វើដូចក្មេង កុំយំ»
- អនុញ្ញាតឱ្យកូនគ្រប់គ្រងខ្លួនគេ (ភាពឯករាជ្យ)
- ប្រសិនបើកូនចង់និយាយត្រូវស្តាប់
- អនុញ្ញាត ប្រសិនបើកូនចង់មានការផ្លាស់ប្តូរ
- ប្រសិនបើកូនប្រកាន់ភាពរឹងរូសត្រូវមានភាពអត់ធ្មត់និងរកហេតុផល
- អនុញ្ញាតឱ្យកូនបង្ហាញពីភាពភ័យខ្លាច ហើយជួយគាំទ្រ
- ជួយកូនឱ្យកូនស្គាល់អារម្មណ៍របស់ពួកគេ

ចំណុចទាំងនេះអាចជាព័ត៌មានដល់ឪពុកម្តាយ ដើម្បីជួយក្នុងការដឹងពីការប៉ះពាល់ និងអំពីរបៀបដើម្បីជួយកូនរបស់អ្នកឱ្យងើបឡើងវិញ។

គ-ផលប៉ះពាល់នៃការចិញ្ចឹមកូន ឬកុមារតាមជំនឿបុរាណ

ក្រុមអ្នកចិត្តវិទ្យារកឃើញថា ការចិញ្ចឹមកូនតាមទម្លាប់ចាស់ មានផលប៉ះពាល់ដល់រូបរាងកាយ សិទ្ធិសេរីភាព និងសតិអារម្មណ៍ ផ្លូវចិត្តកុមារ។ ក្រុមអ្នកចិត្តវិទ្យា បានជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាផ្លាស់ប្តូរឥរិយាបថចិញ្ចឹមបីបាច់កូនចៅ និងងាកមកចិញ្ចឹមថែរក្សាអប់រំកូនចៅតាមវិធីសាស្ត្រត្រជាក់(ការចិញ្ចឹមកូនបែបវិជ្ជមាន និងបែបវិទ្យាសាស្ត្រវិញ)។

**៣.៣- សារៈសំខាន់នៃការថែរក្សាកុមារតាមគ្រួសារ និងសហគមន៍**

ទោះជារាជរដ្ឋាភិបាលមានគោលនយោបាយកំណត់ថា ការដាក់កុមារតាមមណ្ឌលថែទាំគួរតែជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្ន សម្រាប់កុមារក៏ដោយ តែចំនួនកុមារដែលបាននិងកំពុងរស់នៅតាមមណ្ឌលថែទាំ កើនឡើងទ្វេដងពី**៦.២៥៤**នាក់ ក្នុងឆ្នាំ២០០៥ ដល់ **១១.៩៤៥**នាក់ ក្នុងឆ្នាំ២០១៤ និងកើនដល់១៦.៥៧៩នាក់ ក្នុងឆ្នាំ២០១៦។ តួលេខជាក់ស្តែង ត្រូវបានគេប៉ាន់ប្រមាណ ថាមានកម្រិតខ្ពស់ជាងនេះ ដោយសារតែមណ្ឌលថែទាំក្នុងប្រទេសកម្ពុជាមួយចំនួនធំ បានកំពុងដំណើរការដោយពុំបានចុះបញ្ជី ឬមានការត្រួតពិនិត្យពីអាជ្ញាធររដ្ឋាភិបាលឡើយ។

ការស្រាវជ្រាវរកប់ទសវត្សរ៍បង្ហាញថា កុមាររស់នៅតាមមណ្ឌលថែទាំអាចបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍខាងកាយសម្បទា បញ្ញា ស្មារតី និងផ្លូវចិត្តរបស់កុមារ។ ជាពិសេស កុមារដែលត្រូវបានគេយកទៅដាក់តាមមណ្ឌលថែទាំនៅវ័យកុមារតូច ត្រូវប្រឈមនិងការបាត់បង់ការអភិវឌ្ឍសំខាន់ៗខាងរាងកាយ និងផ្លូវចិត្តដែលអាចមានផលប៉ះពាល់ដល់សមត្ថភាពរៀនសូត្រ របស់ពួកគេនាពេលអនាគត។ កុមារជាច្រើននាក់ដែលរស់នៅតាមមណ្ឌលថែទាំ គឺជាកុមារមកពីគ្រួសារពុំមានលទ្ធភាពផ្តល់អាហារ សម្លៀកបំពាក់ ឬការអប់រំដល់ពួកគេបាន។ ពេលខ្លះគ្រួសារដែលមានជីវភាពក្រីក្រត្រូវបានអ្នកគ្រប់គ្រងមណ្ឌលថែទាំបង្ខំ ឬបោកឱ្យបញ្ជូនកូនរបស់ខ្លួនទៅរស់នៅមណ្ឌលក្នុង

គោលបំណងទទួលប្រាក់ចំណេញពីមណ្ឌលថែទាំ ឬតាមរយៈការជួញដូរកុមារ។ បើទោះបីជាមានបំណងល្អយ៉ាងណាក៏ដោយ អ្នកផ្តល់ជំនួយ និងអ្នកស្ម័គ្រចិត្តអន្តរជាតិបានជួយបង្កើនចំនួនមណ្ឌលថែទាំរកប្រាក់ចំណេញដោយមិនដឹងខ្លួន តាមរយៈការផ្តល់ថវិកាដល់ដំណើរការរបស់មណ្ឌលទាំងនោះ និងបង់ថ្លៃសេវាខ្ពស់ ដើម្បីអាចធ្វើសកម្មភាពស្ម័គ្រចិត្តជួយដល់កុមារតាមមណ្ឌលដែលគេហៅថា «ទេសចរណ៍តាមមណ្ឌលកុមារកំព្រា» ឬ «ទេសចរណ៍ស្ម័គ្រចិត្ត»[១៤]។

ការស្រាវជ្រាវបង្ហាញពីផលប្រយោជន៍វិជ្ជមានជាច្រើនដល់កុមារ ក្នុងការថែទាំជំនួសកុមារតាមគ្រួសារ និងសហគមន៍។ កុមារគ្រប់រូបត្រូវការសេចក្តីស្រឡាញ់ថ្នាក់ថ្នមជាប្រចាំ សេចក្តីស្រឡាញ់ធ្វើឱ្យមានការអភិវឌ្ឍដល់កុមាររួមទាំងខួរក្បាល សកម្មភាព ចលករ និងភាសា ។

## ការថែទាំជំនួស

គោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា បោះពុម្ពផ្សាយឆ្នាំ២០០៦ បានលើកឡើងនូវតម្រូវការថែទាំជំនួសដល់កុមារកំព្រា និងកុមារងាយរងគ្រោះឯទៀត ដែលមិននៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត។ ការថែទាំជំនួសមានពីរប្រភេទ គឺការថែទាំក្នុងស្ថាប័ន ឬការថែទាំក្នុងមណ្ឌលស្នាក់នៅ និងការថែទាំក្រៅមណ្ឌល ឬការថែទាំនៅតាមសហគមន៍ ។ ដោយសារការថែទាំក្នុងមណ្ឌលស្នាក់នៅ មានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ អនុក្រឹត្យនេះជំរុញឱ្យមានការថែទាំ ក្រៅមណ្ឌល ឬការថែទាំតាមសហគមន៍។ ការថែទាំក្រៅមណ្ឌលត្រូវបានរាប់បញ្ចូលៈ

- ការថែទាំដោយឪពុកម្តាយធម៌

[១៤] ឯកសារកិច្ចការពារកុមារ កម្មវិធីប្រចាំប្រទេសកម្ពុជារបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៦-២០១៨

- ការថែទាំដោយសាច់ញាតិ
- សុំកូន
- ការចិញ្ចឹមថែទាំនៅតាមទីវត្តអារាម ឬតាមទីកន្លែងជំនឿសាសនានានា
- ក្រុមគ្រួសារ ឬផ្ទះដែលមានកុមារជាមេគ្រួសារ
- ការថែទាំនៅតាមផ្ទះជាក្រុម

**ការប្រៀបធៀបរវាងការថែរក្សាកុមារតាមគ្រួសារ និង ក្នុងមណ្ឌល**

| ការថែទាំតាមគ្រួសារខុសគ្នាពីការថែទាំតាមមណ្ឌល | |
|---|---|
| គ្រួសារ | មណ្ឌល |
| • សេចក្តីស្រឡាញ់ និងការថ្នាក់ថ្នម<br>• ថែទាំជិតដល់ពីគ្រួសារ<br>• យកចិត្តទុកដាក់ច្រើនចំពោះកុមារម្នាក់ៗ<br>• ទទួលបានកិច្ចការពារជាបុគ្គល<br>• ផ្សារភ្ជាប់ជាមួយសាច់ញាតិ<br>• មានការលើកទឹកចិត្ត<br>• បន្តជំនាញពីគ្រួសារ<br>• ចំណាយថវិកាតិច | • ទទួលសេចក្តីស្រឡាញ់តិចតួច<br>• ថែទាំមិនបានជិតដល់យកចិត្តទុកដាក់តិចតួច (អ្នកថែទាំម្នាក់= កុមារពី៨-៣៥នាក់)<br>• ចាត់ជាក្រុម គ្រប់គ្រងជាក្រុម<br>• នៅដាច់ដោយឡែក និងពិបាកវិលទៅសហគមន៍វិញ<br>• ជំរុញទឹកចិត្តតាមរយៈកម្មវិធីរួម |

**ការសិក្សាអំពីឥរិយាបថការថែទាំជំនួសចំពោះកុមារតាមមណ្ឌល ក្នុងប្រទេសកម្ពុជា របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារនីតិសម្បទា ឆ្នាំ២០១១ គេបានកត់សម្គាល់ឃើញថា៖**

- កុមារភាគច្រើនមិនមែនជាកុមារកំព្រាទេ
- ភាពក្រីក្រជាមូលហេតុចម្បងក្នុងការយកកុមារដាក់ទៅក្នុងមណ្ឌល

- ភាពសកម្មនៃការជ្រើសរើសកុមារដោយបុគ្គលិកអង្គការពីគ្រួសារក្រីក្រ
- ឪពុកម្តាយ និងអាជ្ញាធរខ្វះការយល់ដឹងពីផលប៉ះពាល់ ក្នុងការទុកដាក់កុមារនៅក្នុងមណ្ឌល
- អ្នកផ្តល់ជំនួយមិនបានដឹងថា ការផ្តល់លុយរបស់ពួកគេធ្វើឱ្យកុមារបែកពីគ្រួសារដោយគ្មានភាពចាំបាច់។

គុណវិបត្តិ

- ខ្វះការគាំទ្រផ្លូវចិត្ត មានលក្ខណៈពឹងផ្អែក ឯកោពីសង្គម និងឪពុកម្តាយ
- មានហានិភ័យពីការរំលោភបំពានផ្នែករាងកាយ និងផ្លូវភេទ

ហើយបើយើងក្រឡេកទៅមើលទស្សនៈរបស់យុវវ័យកម្ពុជា ដែលរស់នៅតាមមណ្ឌលៈ

- មិនមានអារម្មណ៍ថាពួកគេអាចវិលទៅរស់នៅក្នុងសហគមន៍វិញបាន
- មានអារម្មណ៍ភ័យខ្លាចនិងព្រួយពីអនាគត
- មានអារម្មណ៍ក្រៀមក្រំ ស្រងូតស្រងាត់ថាខ្លួនត្រូវបានសង្គមផាត់ចោល
- មានអារម្មណ៍ថាខ្លួនត្រូវបានគេរើសអើងជាមួយ
- ប្រាថ្នាចង់ចម្រើនដឹងក្តីនៅក្នុងគ្រួសារផ្ទាល់របស់ពួកគេ។

ដើម្បីថែរក្សាកុមារឱ្យបានល្អយើងត្រូវមានវិធីសាស្ត្រ និងយន្តការមួយចំនួនត្រូវយកមកអនុវត្ត មានអនុសញ្ញាអន្តរជាតិស្តីពីកុមារ និងគោលនយោបាយស្តីពីការថែទាំកុមាររបស់រាជរដ្ឋាភិបាល។

### ៣.៣.១- កុមារ និងគ្រួសារ នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីកុមារ

- កុមារមានសិទ្ធិចម្រើនវ័យឡើងនៅក្នុងបរិយាកាសគ្រួសារមួយមានសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ (បុព្វកថា UNHCR)
- ឧត្តមប្រយោជន៍កុមារ គឺជាអាទិភាពរាល់ការសម្រេចចិត្តទាំងឡាយដែលពាក់ព័ន្ធ និងពួកគេ (មាត្រា៣)

- ក្រុមគ្រួសារកុមារត្រូវទទួលបាននូវការជួយជ្រោមជ្រែង កាលណាពួកគេជួបប្រទះនូវការលំបាកក្នុងការចិញ្ចឹមបីបាច់បុត្រធីតារបស់ខ្លួន (មាត្រា៧)
- រដ្ឋជាភាគីត្រូវធានាថា មិនមានកុមារណាម្នាក់ត្រូវបំបែកចេញពីឪពុកម្តាយរបស់គេទេ លើកលែងតែការបែកពីគ្រួសារជាឧត្តមប្រយោជន៍សម្រាប់កុមារតែប៉ុណ្ណោះ (មាត្រា៩)

### ៣.៣.២- គោលនយោបាយស្តីពីការថែទាំកុមាររបស់រដ្ឋាភិបាល

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញនូវគោលការណ៍មួយចំនួន ដើម្បីជានាឧត្តមប្រយោជន៍របស់កុមារ រួមមាន៖

- គោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ មាន៨ជំពូក ដោយបានណែនាំឱ្យយល់ដឹងពីទស្សនទានខ្លះៗអំពីការថែទាំជំនួស គោលនយោបាយរបស់រាជរដ្ឋាភិបាល និងផែងអំពីអន្តរាគមន៍ នៃការថែទាំជំនួសនៅក្នុងប្រទេសកម្ពុជា ទិសដៅជាក់លាក់ពាក់ព័ន្ធទៅនឹងប្រភេទផ្សេងៗនៃការថែទាំជំនួស និងភាពងាយរងគ្រោះ រួមទាំងផែងពីការកិច្ចទទួលខុសត្រូវរបស់រដ្ឋាភិបាល និងការប្តេជ្ញាចិត្តរបស់អ្នកថែទាំជំនួស។ និយមន័យ និងបញ្ហាដែលទាក់ទងនិងប្រភេទជាក់លាក់នីមួយៗ របស់កុមាររងគ្រោះ ក៏មានផែងជាលំអិតផងដែរ។
- ប្រកាសស្តីពីបទដ្ឋានអប្បបរិមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បោះពុម្ពផ្សាយឆ្នាំ ២០០៨។ បទដ្ឋាននេះត្រូវបានរៀបចំឡើង ដើម្បីកំណត់អំពីលក្ខខណ្ឌនៃការបង្កើតមណ្ឌល ការគ្រប់គ្រង និងការថែទាំកុមាររស់នៅក្នុងមណ្ឌល ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា។
- អនុក្រឹត្យលេខ១១៩ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៥។ អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងការពារឧត្តមប្រយោ-

ជន៍កុមារ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នមាន សមត្ថកិច្ចតែមួយគត់ក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងត្រួតពិនិត្យវាយតម្លៃអំពីសមត្ថភាព និងលទ្ធភាពរបស់មណ្ឌលថែទាំកុមារ។

## ៣.៤- សង្ខេបមេរៀន

កុមារមានការអភិវឌ្ឍតាមដំណាក់កាល ដែលទាមទារឱ្យមនុស្សចាស់ មានការយល់ដឹងពីដំណាក់កាលទាំងនេះ ដើម្បីអប់រំកុមារឱ្យរីកលូតលាស់ប្រកបដោយសក្តានុពលទាំងផ្នែករាងកាយ ការយល់ដឹងសង្គម និងអារម្មណ៍។

កុមាររៀនសូត្រតាមទង្វើរបស់ឪពុកម្តាយ ឬមនុស្សធំដែលធ្វើ មិនមែនធ្វើតាមតែអ្វីដែលឪពុកម្តាយ ឬមនុស្សធំប្រាប់នោះទេ។ ការអប់រំ និងចិញ្ចឹមកុមារតាមបែបវិជ្ជមាន និងអហិង្សាត្រូវធ្វើឡើងតាំងពីទារកនៅក្នុងពោះមាតា ហើយទាមទារឱ្យមានការអត់ធ្មត់ និងត្រូវការពេលវេលាដើម្បីជួយឱ្យកុមាររីកធំធាត់ក្នុងបរិយាកាសរួមទាំងទង្វើ និងការគិតបែបវិជ្ជមាន។ មានធាតុផ្សំនៃការអប់រំប្រៀនប្រដៅ និងការចិញ្ចឹមបែបវិជ្ជមាន ចំនួន៤ រួមមាន គោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់ ការយល់ដឹងពីការគិត និងអារម្មណ៍កុមារ និងការដោះស្រាយបញ្ហាជាមួយកុមារ។ អំពើហិង្សាប៉ះពាល់ដល់កុមារ ប៉ះពាល់យ៉ាងខ្លាំងដល់កុមារ រួមទាំងធ្វើឱ្យកុមារឃ្លាតចាកឆ្ងាយពីគ្រួសារ។ កុមារត្រូវការរស់នៅក្នុងសហគមន៍ និងបរិយាកាសគ្រួសាររបស់ពួកគេ។ ការដាក់កុមារនៅក្នុងមណ្ឌលគឺជាជម្រើសចុងក្រោយបំផុត។ ការដាក់កុមារនៅក្នុងមណ្ឌល មានផលប៉ះពាល់យ៉ាងច្រើន រួមមានខ្វះការគាំទ្រផ្លូវចិត្ត មានលក្ខណៈពឹងផ្អែក ឯកោពីសង្គមកុមារ និងឪពុកម្តាយ មានហានិភ័យពីការរំលោភបំពានផ្នែករាងកាយ និងផ្លូវភេទ។

## ៣.៥- សំណួរត្រិះរិះ

១ -តើអ្វីទៅជាការចិញ្ចឹមកូនបែបវិជ្ជមាន? មានគោលការណ៍ និងធាតុផ្សំអ្វីខ្លះ?

២ -អ្វីទៅជាការដាក់ពិន័យបែបវិជ្ជមាន?

៣-តើការថែទាំយ៉ាងណាដែលធ្វើឱ្យកុមាររីកធំធាត់ឡើងប្រកបដោយសក្តានុ-

ពល?

៤- ដូចម្តេចដែលហៅថា ការថែទាំជំនួសចំពោះកុមារ?

៥- តើការចិញ្ចឹមកូនក្នុងមណ្ឌល និងតាមគ្រួសារខុសគ្នាយ៉ាងណាខ្លះ ចូរប្រៀប

ធៀប?

## ជំពូក៤ ៖ ព្រះពុទ្ធសាសនាឆ្លើយតបអំពើហិង្សាលើកុមារ

### គោលបំណង

*ក្រោយពីសិក្សានូវជំពូកនេះ សមណនិស្សិត និស្សិតនឹងទទួលបាន៖*

- *ការយល់ដឹងអំពីតម្លៃនៃការអប់រំរបស់ពុទ្ធសាសនា ឆ្លើយតបអំពើហិង្សាលើកុមារ*
- *ការយល់ដឹងអំពីគោលការណ៍សំខាន់ៗរបស់ពុទ្ធសាសនាចំពោះការមើលថែកុមារ*
- *ការយល់ដឹងអំពីពុទ្ធសាសនា និង ការឱ្យតម្លៃដល់ជីវិតទូទៅ និងជីវិតមនុស្ស*
- *ការយល់ដឹងពីការឱ្យតម្លៃដល់កុមាររបស់ពុទ្ធសាសនា*
- *ការយល់ដឹងពីរបៀបទប់ស្កាត់អំពើហិង្សាលើកុមារ តាមរយៈរចនាសម្ព័ន្ធពុទ្ធ-សាសនា។*

### សេចក្ដីផ្ដើម

*បច្ចុប្បន្ន ពិភពលោកកំពុងមានការប្រែប្រួល និងអភិវឌ្ឍលើគ្រប់វិស័យ ដែលធ្វើឱ្យសង្គមមនុស្សរីកចម្រើនយ៉ាងលឿន។ ជាមួយនិងការរីកចម្រើនក៏មានចំណុចអវិជ្ជមានផងដែរ ក្នុងនោះកុមារដែលជាក្រុមទន់ខ្សោយខ្វះសេចក្ដីក្នុងការការពារខ្លួន។ បញ្ហានេះបណ្ដាលឱ្យមជ្ឈដ្ឋានអ្នកទទួលខុសត្រូវលើសិទ្ធិកុមារ ខិតខំរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីប្រតិបត្តិ ការឃ្លាំមើល ការត្រួតពិនិត្យ និងវាយតម្លៃដោយប្រុងប្រយ័ត្នជាទីបំផុត។ នៅអង្គការសហប្រជាជាតិមានកតិកាសញ្ញា និងអនុសញ្ញាស្ដីពីផលប៉ះពាល់ លើការរំលោភបំពានលើកុមារ ហើយច្បាប់ប្រទេសនីមួយៗដែលស្ថិតក្នុងសមាជិកហត្ថលេខីក៏បានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញ ហើយមានចេញជាគោលនយោបាយ យុទ្ធសាស្ត្រតូចៗតាមអង្គភាពចម្រុះតាមភាពជាក់ស្ដែងទៀត។*

*ព្រះពុទ្ធសាសនានៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លៃសីលធម៌និងធម៌អហិង្សា ក៏ដូចជាទ្រទ្រង់នូវអរិយធម៌វប្បធម៌ជាតិទាំងមូល។ ប្រជាជនកម្ពុជាមានប្រមាណជាង ៩៥%ជាពុទ្ធសាសនិក ទីណាមានពុទ្ធសាសនិក ទីនោះមានវត្ត ឬមានព្រះ*

*សង្ឃ ហើយព្រះសង្ឃតែងនៅជិតពុទ្ធបរិស័ទចំណុះជើងវត្ត។ ព្រះសង្ឃជាឧត្តមភេទដែលប្រជាជនខ្មែរស្តាប់តាម និងគោរពប្រណិប័តន៍ដែលជាការគោរពមានប្រភពពីវប្បធម៌ ប្រពៃណី បទដ្ឋានសង្គមដោយពុទ្ធសាសនិកកម្ពុជា។ ហេតុដូចនេះ ព្រះសង្ឃអាចមានសង្ឃដីកាជាមួយពុទ្ធបរិស័ទនូវបញ្ហារសើប និងជួយដោះស្រាយនូវបទដ្ឋានសង្គម និងការអនុវត្តមួយចំនួនដែលអាចបង្កឱ្យមានហានិភ័យ។ វត្ត និងព្រះសង្ឃ ផ្សារភ្ជាប់ជាមួយជីវភាពប្រចាំថ្ងៃរបស់ពុទ្ធបរិស័ទតាមរយៈការផ្តល់ឱវាទ ទេសនា សូត្រមន្ត និមន្តបិណ្ឌបាត្រចង្ហាន់តាមភូមិចំណុះជើងវត្ត ទីកន្លែងដែលកើតមាននូវអំពើហិង្សា និងបញ្ហាគ្រប់យ៉ាងដែលកើតឡើង និងក៏ជាទីកន្លែងរស់នៅរបស់កុមារ ដែលមានជនប្រព្រឹត្តហិង្សាផងដែរ។ ការចូលរួមរបស់ព្រះសង្ឃក្នុងការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ គឺជាសកម្មភាពរួមចំណែកឱ្យកាន់តែមានប្រសិទ្ធភាព និងសុក្រឹតភាពទាំងរូបភាព ខ្លឹមសារ និងទ្រឹស្តីរបស់ព្រះពុទ្ធសាសនា។*

*តើទ្រឹស្តីពុទ្ធសាសនា មានការចាប់អារម្មណ៍យ៉ាងណាខ្លះ? តើព្រះសង្ឃ ឧបាសក ឧបាសិកា ដូនជី តាជី និងអ្នកប្រាជ្ញខាងពុទ្ធសាសនាមានអ្វីខ្លះ ដើម្បីចូលរួមចំណែកក្នុងការទប់ស្កាត់ អំពើហិង្សាលើកុមារនេះ ?*

## ៤.១- ទ្រឹស្តីពុទ្ធសាសនា និងអហិង្សាធម៌

***ពុទ្ធសាសនាជាអ្វី?***

*ពុទ្ធសាសនាជាមហាសាសនាដ៏ធំមួយក្នុងចំណោមសាសនាទាំង៥ ដែលមានក្នុងពិភពលោក។ ពុទ្ធសាសនាជាសាសនារបស់មហាអ្នកប្រាជ្ញដ៏កំពូលលើលោក និងក្រៃលែងបំផុតដែលមិនមានទ្រឹស្តីណាមានលក្ខណៈជាវិទ្យាសាស្ត្របរមត្ថ និងមានតម្លៃសកលដូចច្បាប់និងទ្រឹស្តីពុទ្ធសាសនាឡើយ។ បច្ចុប្បន្ន ការប្រតិបត្តិ កម្មវិធីបុណ្យវិសាខបូជា ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីបុណ្យអន្តរជាតិរួចស្រេចទៅហើយ។*

- បើវិភាគអំពីប្រវត្តិ សកម្មភាព ពុទ្ធិ ភាវៈ សុខៈ ក្នុងទ្រឹស្តីពុទ្ធសាសនានោះ រឹតតែគោរព និងកោតស្ញប់ស្ញែងនូវលើតួអង្គព្រះពុទ្ធ និងសាសនារបស់ព្រះអង្គ។ ពាក្យ « ពុទ្ធ» សំដៅលើតួអង្គឯក ដែលរកឃើញនូវសព្វញ្ញុតញាណពោលគឺ «ពោធិ» មានន័យថាការត្រាស់ដឹង<ត+រាស់+ដឹង។ ព្រះពុទ្ធមានព្រះនាមពិសេសៗ ទៀតជាច្រើន (សូមពិនិត្យមើលក្នុងពុទ្ធគុណទាំង១០)។
- ពាក្យ «ពុទ្ធិ» សំដៅលើការបរិបូរណ៍ដោយវិជ្ជាចរណសម្បន្នោ គឺការអប់រំ ការ ទូន្មាន និងការផ្សព្វផ្សាយប្រកបដោយពុទ្ធិប្រធាន ពុទ្ធិវត្ថុ និងពុទ្ធវិចារ។
- ពាក្យ «ភាវៈ» សំដៅលើសភាព ទម្រង់ លក្ខណៈទាក់ទងនិងរចនាសម្ព័ន្ធ រូបវន្តគ្រប់គ្រង ដែលមានរូបវន្តបុគ្គល នីតិបុគ្គលជាក់លាក់ ប្រកបដោយភេទ ជាបព្វជិត និងភេទជាគ្រហស្ថដែលមានតួនាទីភារកិច្ច ដឹកនាំក្នុងក្រមច្បាប់ ក្រមសីលធម៌សង្គមជាក់លាក់។
- ពាក្យ «សុខ» សំដៅអត្ថប្រយោជន៍ចុងក្រោយ ដែលជាគោលដៅនៃការប្រតិបត្តិតាមរយៈពុទ្ធសាសនាដែលសាវ័កពុទ្ធបរិស័ទតែងប្រាថ្នាគ្រប់ៗគ្នា។ នោះគឺសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខ។

សរុបសេចក្តីមក ពុទ្ធសាសនាជាជំបូន្មាន ជាសារជាព័ត៌មាន ជាគម្ពីរ ជាប្រព័ន្ធសេវាជាឃ្នាំងច្បាប់ និងទ្រឹស្តីសម្បូរណ៍បែប ហើយដែលក្នុងគោលដៅពិសេសនោះព្រះពុទ្ធតែងលើកបញ្ហាមនុស្ស តម្លៃជីវិត តម្លៃជីវិតមនុស្ស បញ្ញាមនុស្ស ពិសេសគឺការកសាងពូជ និងពន្លក នៃមនុស្សដើម្បីបន្តវេនគ្រប់គ្រងលោកឱ្យបានល្អប្រសើរ។

## តើពុទ្ធសាសនាមានតួនាទី ជួយដោះស្រាយបញ្ហាមនុស្សដូចម្តេចខ្លះ?

ការកសាងពូជមនុស្ស ការលើកយកបញ្ហាមនុស្ស និងបញ្ហាសង្គមរបស់មនុស្ស មកជាកម្មវត្ថុសម្រាប់កុមារ គឺជាផែនការការអប់រំលើប្រព័ន្ធសង្គមវិជ្ជាមួយ ដែលមានអត្ថន័យខ្លឹមសារ ល្អិតល្អន់បំផុតសម្រាប់ពុទ្ធសាសនា។ ក្នុងនោះការប្រើហិង្សា ការបៀតបៀន ការរំលោភបំពានគ្រប់ទម្រង់លើកុមារត្រូវបានទ្រឹស្តីពុទ្ធសាសនា បំភ្លឺយ៉ាងក្បោះក្បាយ នៅក្នុងសៀវភៅ «សិង្គាលោវាទសូត្រ» ដែលមានបរិយាយអំពីតួនាទីភារកិច្ច ការទប់ស្កាត់ ការគ្រប់គ្រង ការថែទាំ ការចិញ្ចឹមបីបាច់ ថែរក្សាបុត្រធីតាតាំងពីនៅជាទារកទារិកា (កលលៈ អម្ពុទ បេសិ ឃណៈ និងបញ្ចសាខា)នៅក្នុងគម្ពីរ «អភិណ្ហប្បច្ចវេក្ខណៈ»។

ព្រះពុទ្ធសាសនាមានគម្ពីរកំពូល គឺព្រះត្រៃបិដក ដែលបានស្រាយបំភ្លឺនូវមូលដ្ឋានគ្រឹះសំខាន់ៗអំពីគោលការណ៍អប់រំធំៗទាំង៣ គឺ៖

| | |
|---|---|
| ១. សព្វបាបស្ស អករណំ | ការមិនធ្វើអំពើបាបទាំងពួង |
| ២. កុសលស្សូបសម្បទា | ការបំពេញអំពើជាកុសលទាំងពួង |
| ៣. សចិត្តបរិយោទបនំ | តាំងចិត្តបេះដូងឱ្យបរិសុទ្ធផូរផង់ល្អ។ |

នៅក្នុងប្រទេសកម្ពុជាលទ្ធិពុទ្ធសាសនា មានអាយុកាលតាំងពីបុរាណកាលមក។ កើតក្រោយពេលមានវត្តមានចរកជន ឬពនេចរមកពីឥណ្ឌា ដោយហោចណាស់ មានតាំងពីស.វ.ទី៣ មុនគ.ស.ម៉្លេះ។ កាលនោះ មានព្រះមហាថេរៈ ២ព្រះអង្គគឺ សោណត្ថេរ និងឧត្តរត្ថេរ ដែលជាបេសកជនទូត ឬជាបេសកសង្ឃ ឬក៏បេសកត្ថេរ ដែលត្រូវមោគ្គលិបុត្រតិស្សត្ថេរ ប្រធានអង្គសង្គាយនាលើកទី៣ ក្រោមការឧបត្ថម្ភគាំទ្រទំនុកបម្រុងនៃអធិរាជឥណ្ឌាព្រះនាមព្រះបាទអសោករាជ នៃមោរិយវង្សប្រទានឱ្យចុះមកដែនសុវណ្ណភូមិ។

រហូតមកដល់ពេលនេះ ជំនឿព្រះពុទ្ធសាសនាបានស្ថិតនៅក្នុងអារម្មណ៍ខ្មែរប្រមាណ៩៥%។ វត្ត មានចំនួនជាង៤ពាន់វត្ត ព្រះសង្ឃមានចំនួនជិត៦ម៉ឺនអង្គ មានមជ្ឈមណ្ឌលពុទ្ធិកអប់រំពុទ្ធិកសមាគម ពុទ្ធិកសិក្សាគ្រប់កម្រិត និងមានក្រសួងធម្មការ និងសាសនា ជាស្ថាប័នសម្របសម្រួលជាមួយសាសនាវត្ត និងសាសនាទាំងអស់។

ក្រៅពីនេះ ព្រះពុទ្ធសាសនាក៏មានតួនាទី និងសកម្មភាពយ៉ាងសំខាន់ក្នុងការអប់រំបណ្តុះបណ្តាល ក្នុងការផលិតឯកសារ និងក្នុងចលនាអប់រំតាមប្រព័ន្ធផ្សព្វផ្សាយនានា។ ប្រទេសកម្ពុជាតែងមានកម្មវិធីបុណ្យប្រពៃណី បុណ្យសាសនា និងបុណ្យអន្តរជាតិសន្ទឹកសន្ទាប់ និងជាបន្តបន្ទាប់។ ការយកតួនាទីពុទ្ធសាសនាមកឆ្លើយតបហិង្សាលើកុមារ គឺជាចក្ខុវិស័យមួយប្រកបដោយសក្តានុភាព និងមានប្រសិទ្ធភាពបំផុត។

ភាពកាន់តែងាយស្រួលសំខាន់មួយទៀត គឺការសហការជាមួយវិស័យពុទ្ធិកសិក្សា តាមរយៈក្រសួងធម្មការ និងសាសនា គឺមធ្យោបាយគន្លឹះមួយដែលមានសារៈសំខាន់ មិនអាចមើលរំលងបាន។

ព្រឹត្តិការណ៍បច្ចុប្បន្នយោងតាមការវាស់វែងភាពអវិជ្ជមានលើកុមារ និងតាមការវាយតម្លៃព្រមទាំងការព្យាករអំពីអនាគតសម្រាប់កុមារ ធ្វើឱ្យមានការព្រួយបារម្ភយ៉ាងក្រៃលេង។ ក្នុងភាពអវិជ្ជមានទាំងនោះ មានផលប៉ះពាល់ដល់ជីវិត ការរស់នៅ សុខភាព ការសិក្សា ការរៀនសូត្រ ការបាត់បង់ការងារ ការបិតក្នុងភាពអនាថា និងការប្រើប្រាស់គ្រឿងញៀនជាដើម នឹងធ្លាក់មកលើកុមារកម្ពុជា។

### ៤.១.១- អហិង្សាធម៌ក្នុងឱវាទបាតិមោក្ខ

ឱវាទបាតិមោក្ខ ជាដំបូន្មានដ៏ពិសេស ជាវិន័យកម្ម ជាឧបោសថកម្មរបស់ភិក្ខុសង្ឃ និងជាមាគ៌ាប្រតិបត្តិយ៉ាងល្អពិសិដ្ឋដែលបរិស័ទទាំងឡាយត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួន។

អត្ថន័យដ៏សំខាន់នៃឱវាទបាតិមោក្ខនោះមាន១១ប្រការគឺ

១. សព្វបាបស្ស អករណំ ការមិនធ្វើអំពើបាបទាំងពួង

២. កុសលស្សូប សម្បទា ការធ្វើអំពើកុសល

៣. សចិត្តបរិយោទបនំ ការតាំងចិត្តឱ្យបរិសុទ្ធស្អាត

៤. ខន្តិ បរមំ តបោ តីតិក្ខា សេចក្តីអត់ធន់ជាតបធម៌ដ៏ល្អ

៥. និព្វាន បរមំ វទន្តិ ពុទ្ធា ព្រះពុទ្ធតែងសម្តែងថានិព្វានជាគុណធម៌ ដ៏ឧត្តម

៦. នហិ បព្វជិតោ បរូបឃាតិ សមណោ ហោតិ បរំ វិហេឋយន្តោ បុគ្គលដែលសម្លាប់សត្វមិនឈ្មោះថាបព្វជិត បុគ្គលដែលបៀតបៀនសត្វដទៃ មិនឈ្មោះថា សមណៈឡើយ

៧. អនុបវាទោ អនុបឃាតោ ការមិនពោលតិះដៀលអ្នកដទៃ ការមិនបៀតបៀនអ្នកដទៃ

៨. បាតិមោក្ខេ ច សំវរោ ការសង្រួមក្នុងបាតិមោក្ខ គឺផ្លូវប្រតិបត្តិដើម្បីរួចចាកផុតទុក្ខ

៩. មត្តញ្ញុតា ច ភត្តស្មឹ ភាពជាអ្នកដឹងប្រមាណក្នុងភត្តាហារ

១០. បន្តញ្ច សយនាសនំ ទីដេក ទីអង្គុយដ៏ស្ងាត់

១១. អធិចិត្តេ ច អាយោគោ ការបំពេញសេចក្តីព្យាយាមក្នុងអធិចិត្ត គឺសមាធិចិត្ត ចិត្តបានសម្រេចសមាធិ។

ប្រការទាំងអស់នេះ ក៏ជាពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ ដែលមានតាំងពីបុរាណ។ ឱវាទបាតិមោក្ខនេះ ជាផ្លូវប្រតិបត្តិរបស់ពុទ្ធសាសនិកគ្រប់រូប មិនថាបព្វជិត ឬ

គ្រហស្ថទេ។ ម្ដែឆ្នាំក្រោយមកទើបព្រះពុទ្ធទ្រង់បញ្ញត្តិ និងអនុញ្ញាតបន្ថែមនូវអាណាបាតិមោក្ខទៀត ដើម្បីជាឧបករណ៍សម្រាប់ដាក់ទណ្ឌទោសដល់បព្វជិត ដែលធ្វើឱ្យកន្ទង់នូវសិក្ខាបទណាមួយ ដែលមានរហូតដល់២២៧សិក្ខាបទ។ ពិធីកម្ម នៃការអនុវត្តអាណាបាតិមោក្ខនេះ លោកហៅថា ឧបោសថកម្មរបស់ភិក្ខុ។

ទាក់ទង និងអហិង្សាក្នុងឱវាទបាតិមោក្ខនេះ ថ្វីត្បិតតែមានរូបភាពនៅក្នុងចរិតនៃពុទ្ធសាសនាសម្រាប់សង្ឃមណ្ឌល ប៉ុន្តែបើយើងសិក្សាឱ្យបានស៊ីជម្រៅយើងនឹងបានដឹងថាព្រះពុទ្ធសាសនាបានបង្ហាញ បានចាប់អារម្មណ៍ខ្លាំងលើអំពើអហិង្សាផ្សេងៗដូចជា៖

- ការហាមមិនឱ្យធ្វើអំពើបាបទាំងពួង

## តើអំពើបាបជាអ្វី?

យើងអាចយល់បានថា អំពើបាប គឺអំពើអាក្រក់ អំពើប្រកបដោយទោស អំពើគួរចៀសវាងនាំឱ្យប៉ះពាល់ដល់អត្ថប្រយោជន៍អ្នកដទៃ និងជាអំពើមិនគួរសេពគប់។ ក្នុងមង្គលសូត្រ មានបញ្ជាក់អំពីការស្វែងរកមិត្តដ៏ល្អ ដើម្បីបញ្ចៀសនូវអន្តរាយផ្សេងៗ ទ្រង់ឱ្យស្វែងរកអ្នកប្រាជ្ញ អ្នកមានគុណធម៌ទើបរីកចម្រើន និងបានសុខគ្រប់ប្រការ។ ករណីនៃអំពើបាបមានច្រើនប្រភេទ ច្រើនទម្រង់ដែលនឹងត្រូវបកស្រាយក្នុងមេរៀនខាងមុខ ទៀត។

- ការបំពេញ ឬការសន្សំនូវកុសលកម្ម គឺជាការបំពេញបន្ថែមទៅលើការហាមឃាត់មិនឱ្យធ្វើអំពើបាប។ ជាកុសលធម៌ផ្នែកមួយ ដែលញ៉ាំងឱ្យវិន័យ សិក្ខាបទ ឬពុទ្ធប្បញ្ញត្តិកាន់តែល្អប្រសើរ។ ជាសភាវធម៌ ជួយជាបច្ច័យនាំដល់ការទប់ស្កាត់ ការធ្វើអំពើបាបទាំងពួងឱ្យកាន់តែខ្ជាប់ខ្ជួន និងកាន់តែប្រសើរឡើង។

- ការធ្វើចិត្ត គឺអារម្មណ៍ឱ្យល្អផូរផង់ ឱ្យស្អាតបរិសុទ្ធជាគុណធម៌មួយទៀត ជួយដុសលាងចិត្ត បេះដូង អារម្មណ៍ឱ្យកាន់តែថ្មី ឱ្យកាន់តែស្រួច ដើម្បីឈានទៅរកមាគ៌ាបដិបត្តិឆ្ពោះទៅរកការត្រាស់ដឹងនេះឯង។
- ការព្យាយាម ការអត់ធ្មត់ ការព្យាយាមប្រព្រឹត្តតបធម៌ជាគន្លងនាំទៅកាន់ភាពជោគជ័យ។ ដើម្បីបានជោជ័យត្រូវតែមានខន្តី និងតបធម៌។
- និព្វានគឺជាត្រើយនៃសេចក្តីស្ងប់ដ៏កំពូល ជាទីគ្មានរូប គ្មានកើតស្លាប់ទៀតឡើយ។ បើគ្មានកើតស្លាប់ សុខ ទុក្ខ ក៏ពុំអាចមានដែរ។
- ការបៀតបៀន ការសម្លាប់ជីវិតមិនមែនជាធម៌នៃបណ្ឌិត ឬបព្វជិតឡើយ ព្រោះថាធម៌របស់បព្វជិត គឺមិនសាងអំពើអកុសលគ្រប់យ៉ាងដល់អ្នកដទៃ និងដល់ខ្លួន ឯង។
- បុគ្គលដែលបៀតបៀនសត្វដទៃមិនឈ្មោះថាជាសមណៈឡើយ។ មិនតែប៉ុណ្ណោះ សូម្បីការពោលតិះដៀល ការបៀតបៀនអ្នកដទៃក៏មិនគួរអ្នកបួសប្រព្រឹត្តទៀត។

ក្នុងមេរៀននេះចង់បញ្ជាក់ថា ឱវាទបាតិមោក្ខបានចូលរួមទប់ស្កាត់អំពើហិង្សាលើកុមារនូវគ្រប់ទម្រង់ទាំងផ្លូវកាយ វាចា ចិត្តទៀតផង ព្រោះហិង្សាអាចកើតបានដោយសារភាគីម្ខាងៗមិនបានយល់អត្ថនិងស៊ីជម្រៅអំពីសកម្មភាព និងលទ្ធផលនៃការប្រព្រឹត្តនោះៗ។ តែបើបានយល់ដឹងនិងបានអនុវត្តល្អហើយ អំពើហិង្សា នឹងពុំមានទៀតឡើយ។

### ៤.១.២- ទ្រឹស្តីនានាទាក់ទងនឹងអហិង្សាធម៌

#### ក- ការគិតពីមនុស្សតាមរយៈពុទ្ធសាសនា

ទ្រឹស្តីពុទ្ធសាសនា ជាទ្រឹស្តីសកលនិយម និងមនុស្សនិយមប្រកបដោយពិចារណានិយម យ៉ាងទូលំទូលាយ?

ព្រះពុទ្ធឱ្យតម្លៃជីវិតសត្វលោកដូចជា វត្ថុ បាតុភូតធម្មជាតិ សត្វទូទៅ ក្នុងលោក។ តម្លៃដែលខ្ពស់ជាងនេះ នោះគឺតម្លៃមនុស្ស។ ជាប្រភេទនៃសត្វ ដែលមានពលកម្ម ដៃជើង និង ពលកម្មខួរក្បាលគ្មានទីបញ្ចប់។ សត្វទូទៅមានតែសភាវធម៌៤គឺ ឃ្លាន យំ ផ្លូវភេទ សើច ដែលជាអំណោយរបស់ធម្មជាតិ។ ចំណែកមនុស្សមានសញ្ញាពិសេសមួយទៀតគឺ ធម្មសញ្ញាដែលមរតកបន្ថែម ដើម្បីតម្លើងតម្លៃឱ្យមនុស្សមានភាពអស្ចារ្យជាងសត្វទាំងឡាយ។

ព្រះពុទ្ធបានយកបញ្ហាមនុស្ស ដាក់ជាកម្មវត្ថុនៃការពិចារណា។ ក្នុងទ្រឹស្តីអប់រំ ព្រះពុទ្ធប្រៀនប្រដៅមនុស្ស «ឱ្យយកខ្លួនឯងជាទីពឹង» មិនឱ្យមនុស្ស «យកវត្ថុដទៃជាទីពឹងឡើយ» «អត្តាហិ អត្តនោ នាថោ កោហិ នាថោ បរោសិយា ន ហិ សុទន្តេន នាថំ លភតិ ទុល្លភំ»។ តម្លៃសំខាន់របស់មនុស្សដែលមានសារៈប្រយោជន៍នោះ គឺអាស្រ័យដោយ មានជីវិត មានរូប មានសកម្មភាព មានវិចារណញ្ញាណប្រកបដោយចលនា ជាចរន្តនៃការងារ ចំណេះដឹង សីលធម៌ និងសីលគុណ។ ការងារត្រូវតែមានជាប្រចាំ ទើបអាចរស់បាន បើមិនប្រកបការងារ នឹងត្រូវស្លាប់ហើយឥតន័យ។ ក្នុងការងារបើធ្វើល្អ នឹងទទួលផលល្អ តែបើធ្វើអាក្រក់នឹងទទួលផលអាក្រក់។ ព្រះពុទ្ធទ្រង់សម្តែងថា «ចូរអ្នកទាំង ឡាយវៀរចាកអំពើអកុសល ហើយចូរប្រព្រឹត្តអំពើកុសលវិញ ចូរធ្វើចិត្តឱ្យសង្រួមស្ងប់ទើបប្រសើរ។ ពូជណាដែលអ្នកដាំ អ្នកនឹងបានពូជនោះ «សូម្បីតែជាតិជូរដូចគ្នា» បើអ្នកដាំស្វាយ គឺមិនបានផលជាអំពិលទេ។ វាជូរដូចគ្នា តែនៅមានរស់ជាតិជូរបែបស្វាយដដែល មិនមែនជូរបែបអំពិលទេ «(ប្រៀបធៀប)បាលី យាទិសំ វប្បតេពិជំ តាទិសំ លភតេ ជលំ » ប្រែថា ការសាបព្រោះនូវពូជណា នឹងទទួលនូវពូជនោះ។

ក្រៅពីការបំពេញការងារ(កម្ម) មនុស្សគប្បីបណ្តុះវប្បធម៌ គឺវិជ្ជា (វិជ្ជាចរណសម្បន្នោ)។ វិជ្ជា ឬវប្បធម៌តំណាងអរិយជន/អារ្យជន ឬអនារិយជន/អនារ្យជន។ តម្លៃ នៃវិជ្ជា

ប្រៀបបានអាវុធមុខ២ គឺអាវុធសម្រាប់កាប់ឆ្ការព្រៃ ទប់ស្កាត់សត្វមានរូប និងជាអាវុធសម្រាប់កាប់ឆ្ការកិលេស គ្រឿងសៅហ្មងនៃចិត្តផងដែរ។ ម្យ៉ាងទៀត ចំណេះវិជ្ជាអាចនាំឱ្យមានការរីកចម្រើន និង នាំឱ្យមានការវិនាសក៏មាន។ ព្រះពុទ្ធសម្ដែងអំពីសុវិជ្ជា អំពើនៃវិជ្ជាល្អ និងទុវិជ្ជា អំពើនៃវិជ្ជាជាទោស។ ព្រមជាមួយការរៀនសូត្រអំពីចំណេះដឹង មនុស្សគប្បីធ្វើកាយ វាចា ចិត្តប្រកបដោយធម៌បានដល់បញ្ចធម៌ទាំង៥ (មេត្តាព្រហ្មវិហារ សម្មាអាជីវៈ សទារសន្តោសៈ សច្ចៈ និងអប្បមាទ) ដែលជាគូនៃបញ្ចធម៌ គឺត្រូវមានបញ្ចសីលផង (បាណា អទិន្នា កាមេ មុសា សុរា)។

## ខ- ការគិតពីកុមារតាមរយៈពុទ្ធសាសនា

### តើកុមារជានរណា?

កុមារជាមនុស្សដែលស្ថិតក្នុងបឋមវ័យ វ័យក្មេង វ័យកំពុងមានការលូតលាស់ និងរីកចម្រើន។ ក្នុងទ្រឹស្ដី កុមារស្ថិតក្នុងប្រភេទមន្ទទសកផង(វ័យផុយស្រួយ) និង វ័យខិឌ្ឌទសក (វ័យញៀននឹងល្បែងទាំងឡាយផង)។ ហេតុនេះការចាប់អារម្មណ៍លើការអប់រំចំពោះកុមារមានសារៈសំខាន់ណាស់។

កុមារជាផ្កាំងក្រដាសស ឬក្រណាត់ពណ៌ស ឬក៏ដុំពេជ្រដែលពុំទាន់យកមកច្នៃ។ចរិតសម្បទា វាចាសម្បទា ពុទ្ធិសម្បទាទាំងផ្នែកខាងក្រៅ និងខាងក្នុងនៃរាងកាយទាំងមូល។ ការបង្កើតបានជារូប និងជីវិតនៃកុមារ គឺជាព្រឹត្តិការណ៍ពោរពេញដោយ សុភមង្គលបំផុត និងជាដំណាក់កាលនៃការចាប់ផ្ដើមកំណើតថ្មី ដំណើរជីវិតថ្មីនៃគ្រួសារ និងសង្គមមួយ ប្រកបដោយការទុកចិត្ត និងជំនឿជឿជាក់ជាងពេលណាៗទាំងអស់។ វាជាតំណាងនិរន្តរភាព ស្ថិរភាពនៃតំណវង្សត្រកូលដ៏វែងឆ្ងាយនៃគ្រួសារ និងសង្គម។ ទន្ទឹមនិងការរក្សាកូន ការចិញ្ចឹមកូន បុព្វការីជន មាតាបិតា អាណាព្យាបាលត្រូវមានករណីយកិច្ចទទួលខុសត្រូវ លើជោគវាសនាអនាគតរបស់គេគ្រប់យ៉ាងពុំអាចធ្វេស

ប្រហែសបានឡើយ។ រាល់ពេលមានបុណ្យគ្រួសារលើលោក តែងមានកម្មវិធីលើកទឹកចិត្តកូន ដូចជាបុណ្យកំណើត ខួបកំណើត វិធីផ្តល់ឱកាសកម្សាន្តសប្បាយ វិធីចែករង្វាន់ឱ្យកូនដើម្បីឱ្យកូនមានភាពកក់ក្តៅ និងក្តីសង្ឃឹមក្នុងការងារ ។

កុមារប្រើឥន្ទ្រិយារម្មណ៍(មានភ្នែក ច្រមុះ ត្រចៀក អណ្តាត កាយ ចិត្ត) មើល ហិត ស្តាប់ លិឍ កាន់ ចំណាំលើអារម្មណ៍វត្ថុទាំងឡាយ (រូប ក្លិន សំឡេង រសជាតិ វត្ថុ និងការគិត លំនឹកគិតផ្សេងៗ)។

កុមារអាចទទួលនូវរាល់វិញ្ញាណដែលខ្លួនបានទទួល គេអាចចងចាំ គេអាចធ្វើ គេអាចគិត គេអាចប្រកាន់យកតាមអារម្មណ៍របស់គេ/ទម្លាប់របស់គេ។ កុមារអាចក្លាយទៅជាមនុស្សល្អ ឬមនុស្សមិនល្អអាស្រ័យលើអ្នកចិញ្ចឹមថែរក្សា អាណាព្យាបាល យន្តការអប់រំរបស់សង្គម និងបរិស្ថានរបស់សង្គម។

## គ- តើកុមារគួរមានសិទ្ធិ និងទទួលបានសិទ្ធិអ្វីខ្លះ?

ព្រះពុទ្ធបានសម្តែងអំពីសិទ្ធិមនុស្សទូទៅក៏ដូចនិងសិទ្ធិស្តីពីកុមារ ពោលគឺសិទ្ធិមានជីវិត សិទ្ធិថែទាំ ការពារ សិទ្ធិអប់រំ សិទ្ធិរស់នៅក្រោមច្បាប់សង្គមជាតិ និងអន្តរជាតិដូចគ្នាទាំងផ្លូវកាយ វាចា និងចិត្តវិញ្ញាណ។ សិទ្ធិទទួលបាននូវមរតកសង្គមគ្រួសារ ពីអ្នកបង្កើតអ្នកផ្គត់ផ្គង់ អ្នកគាំទ្រ និងយន្តការការពារគ្រប់ទម្រង់ច្បាប់ក្នុងវិស័យនានា។ កុមារមានបុព្វសិទ្ធិទទួលបានពីកម្មសិទ្ធិ សភាវគតិ ធម្មជាតិ និងធម្មសញ្ញាជាមនុស្សពេញ លក្ខណៈ និងទទួលផលគ្រប់រចនាសម្ព័ន្ធ ដែលសង្គមមនុស្សទទួលបានដូចគ្នា ដូចជា ទ្រព្យសម្បត្តិ ធម្មជាតិ គ្រួសារ និងទ្រព្យសម្បត្តិសង្គមទាំងអស់។

កុមារនឹងទទួលបានរាល់សេវា ទាំងព័ត៌មាន ការថែទាំសុខភាព ការគាំទ្រពីច្បាប់សិទ្ធិ និងតួនាទីនានា ដែលគ្រួសារ សហគមន៍ និងសង្គមមាន។ ព្រះពុទ្ធបានបង្រៀន

មនុស្សដូច្នេះថា: «អត្តានំ ឧបមំ កត្វា» ការប្រៀបធៀបនៅអ្វីដែលយើងប្រាថ្នា គេក៏ចង់បានដូចយើងដែរ សូម្បីជីវិត ទ្រព្យសម្បត្តិ គ្រួសារ និងកម្មសិទ្ធិគ្រប់យ៉ាង។

## ឃ- តើអ្វីជាការបំពានលើកុមារ?

ក្នុងច្បាប់ពុទ្ធសាសនា នៅពេលមានការប្រព្រឹត្តតាមផ្លូវអកុសលទាំងឡាយចំពោះកុមារ ចាត់ទុកថា ជាការបំពានទៅហើយៈ

### ឃ.១- ការបំពានកុមារតាមផ្លូវកាយ

រាល់ការប៉ះពាល់រាងកាយដូចជា ការពុំមានកាយសម្បទាល្អ ការពុំមានសុខភាពពេញលេញ ការបំប៉នមិនគ្រប់គ្រាន់នូវអាហារ ឬបច្ច័យទាំង៤ (សំពត់ បាយ ទីស្នាក់ ថ្នាំ...) ដោយប្រយោល និងការវាយដំច្រំជាក់ ធ្វើឱ្យមានស្លាកស្នាម និងរបួសក្លាយជាពិការដោយផ្ទាល់។

ការយករូបកាយ សោភ័ណ សម្ផស្ស អវៈយវៈផ្នែកណាមួយទៅលក់ដូរ ជាមុខជំនួញ ដើម្បីបានទទួលកម្រៃសម្រាប់បុគ្គល ឬក្រុម។

### ឃ.២- ការបំពានតាមរយៈផ្លូវវាចា

ការបញ្ឆោត ការគំរាម ការភូតកុហក ការជេរបញ្ចោរ ការណែនាំតាមវាចាដើម្បីឱ្យមានសម្រើប ក្នុងគោលបំណងឱ្យស្រេកឃ្លានតណ្ហាងាយស្រួលក្នុងការបោកខ្លួនប្រាណព្រហ្មចារីយកទៅលក់ដូរ។

### ឃ.៣- ការបំពានតាមរយៈផ្លូវចិត្ត

ការបំពានតាមរយៈផ្លូវចិត្ត ដូចជាការមើលងាយ ការរើសអើងដែលមានដូចជាៈ

- ការប្រកាន់ពូជសាសន៍ វណ្ណៈ មានក្រ បក្សពួក

- ការប្រកាន់ ផ្នែកវប្បធម៌ ទម្លាប់ ប្រពៃណី
- ការប្រកាន់ «យេនឌ័រ» លិង្គភេទ ក្នុងជីវិត/ធម្មជាតិ
- ការមិនអើពើ និងចាប់អារម្មណ៍លើសិទ្ធិសេរីភាព នៃកុមារនៅគ្រប់ទម្រង់ និងដែនកំណត់។
- ការបិទបាំងព័ត៌មាន សេវាកម្មគ្រប់ទម្រង់ និងគ្រប់វិស័យមិនឱ្យកុមារយល់ដឹង ឬចូលរួមអនុវត្តន៍បាន។

## ង-ការដាក់ទោសទណ្ឌលើអ្នកបំពាន «កុមារ» តាមរយៈបរាកវសូត្រ

**តើកុមារនឹងក្លាយជានរណា?**

ព្រះពុទ្ធតែងសម្ដែងថា «មាននេះ ទើមាននោះ តែបើគ្មាននេះ ក៏គ្មានោះដែរ» «នោះកើតឡើងពីនេះ» បានន័យថា When this is that is, when that isn't. From the arising of this, comes the arising of that. From the stopping of this, comes the stopping of that.) ។ កុមារជាផលនៃពូជគ្រួសារ ដែលមានម៉ែឪ ជាបុព្វការី និងមានការចូលរួមពីបរិយាកាសសង្គមវប្បធម៌បន្ថែមទៀត។

ប្រសិនបើបុព្វការីជនមានចំណេះដឹង មានសទ្ធា ឬជំនឿល្អ មានបញ្ចធម៌ និងបញ្ចសីល មានអធ្យាស្រ័យល្អចំពោះកុមារ មានការគិត ការចិញ្ចឹមថែរក្សាប្រកបដោយភាពវិជ្ជមាន មានការពង្រឹង កែលម្អជាប់ជានិច្ចចំពោះកុមារនោះមែន កុមារប្រាកដជា នឹងក្លាយទៅជាធនធានដ៏ល្អ ក៏ជាអ្នកបន្តវេនដ៏ល្អ សម្រាប់អនាគតដូចមានពាក្យថា «យុវជនជាសសរទ្រូង នៃប្រទេសជាតិ»។

ត្រង់ចំណុចនេះ ក្នុងទ្រឹស្តីពុទ្ធសាសនាបានបញ្ជាក់ថា «កុមារល្អនឹងក្លាយទៅជាធនធានពិសេសក្នុងការកសាងវប្បនិងវិមានស្ថានសួគ៌សម្រាប់ជំនាន់ថ្មី»។ ពាក្យធ្លាប់ប្រើ

ខំធ្វើល្អជាតិនេះ សម្រាប់ជាតិក្រោយ កន្ទង់មកជាតិក្រោយគឺនរណា គឺកុមារ ឬយុវជននេះឯង។

ឧទាហរណ៍មួយទៀត ក្នុងពុទ្ធប្បវត្តិដែលទាក់ទងដល់ការប្រគេនត្រៃចីវររបស់ព្រះនាងបជាបតិគោតមី ដែលជាពុទ្ធមាតាទី២ របស់ព្រះពុទ្ធ។ ព្រះនាងចង់យកចីវរនោះមកថ្វាយព្រះពុទ្ធ តែព្រះពុទ្ធទ្រង់ព្រះរាជានុញ្ញាតឱ្យព្រះនាងនាំទៅប្រគេនព្រះភិក្ខុក្មេងជាងគេ គឺអស្សជិតត្ថេរ ភិក្ខុថ្មីទៅវិញ។ ត្រង់នេះមានន័យសេចក្ដីថា ព្រះសិអារ្យមេត្រីយ៍ចុងក្រោយ គឺភិក្ខុអស្សជិតត្ថេរនេះឯង។ អង្គនេះហើយ ជាព្រះជំនាន់ក្រោយ។

ព្រះបន្ទូលនេះគឺជាសញ្ញាមួយបញ្ជាក់ថា ចូរពុទ្ធបរិស័ទទាំងឡាយកុំមើលស្រាលចំពោះវ័យកុមារ វ័យក្មេង ឬវ័យយុវជនឱ្យសោះ ព្រោះយើងពុំអាចមើលឃើញឧបនិស្ស័យវាសនារបស់ពួកគេបានឡើយ បានន័យថាព្រះពុទ្ធឱ្យបរិស័ទជួយគាំទ្រ និងលើកកម្ពស់ចំពោះយុវជនជានិច្ច។ ព្រះពុទ្ធតែបញ្ជាក់ថា បុព្វការីជនទាំងឡាយ គួរធ្វើអំពើល្អជាកុសល ដល់បុត្រធីតារបស់ខ្លួនគេហៅថាម៉ែឪបាន។ «សង្គហធម៌ម៉ែឪ»ធ្វើល្អ ម៉ែឪក៏នឹងក្លាយជា បុព្វការីល្អ បើបុព្វការីល្អ បុត្រធីតា ឬកុមារគេនឹងក្លាយទៅជាជនជានប្រកបដោយកតញ្ញូ និងកតវេទីផងដែរ។

ជនទាំងពីរយ៉ាងនេះគឺទាំងបុព្វការី ទាំងបុត្រធីតាកុមារ នឹង/ទទួលបាននូវការអភិវឌ្ឍប្រកបដោយភាពរុងរឿង ភាពសុខដុមរមនា សន្តិភាពជាតិយោភាព ស្ថិតស្ថេរតទៅ។ ចំណែកឯការរំលោភលើកុមារ ទោះបីជាទម្រង់បែបណាក៏ដោយ អ្នករំលោភត្រូវទទួលនូវភាពបរាជ័យក្នុងជីវិត។ ក្នុងបរាភវសូត្រ ព្រះពុទ្ធទ្រង់ប្រដៅ មនុស្សមិនឱ្យប្រព្រឹត្តនូវករណី ដែលមានដូចជា៖

- សុវិជ្ជា នោ ភវំ ហោតិ ទុវិជ្ជា នោ បរាភវោ ប្រែថា អ្នកមានវិជ្ជាល្អ មានសេចក្តីចម្រើន អ្នកមានវិជ្ជាថោកទាប មានសេចក្តីវិនាស។
- អតីតយោព្វនោ បោសោ អនេតិ តិម្ពរុត្ថនី តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ប្រែថា បុគ្គលអ្នកមាន វ័យចាស់ហួសពេក មានតម្រេក យកស្ត្រីក្មេងមកធ្វើជាភរិយា ហេតុនោះនាំមកនូវក្តីវិនាស។
- ឥត្ថី ធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ប្រែថា អ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់ នឹងធ្វើឱ្យខ្លួនធ្លាក់ក្នុងក្តីអន្តរាយ ហេតុនោះនាំឱ្យវិនាស។

ការដកស្រង់យកមកបង្ហាញប៉ុណ្ណោះ ក៏ជាសេចក្តីពិសេសមួយ ដែលចូលរួមក្នុងការបង្ការ ការរំលោភបំពានលើកុមារ ដែលអ្នកទាំងឡាយគួរចៀសវាង។

### ៤.១.៣- ការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ តាមរយៈពុទ្ធសាសនា

យោងការទប់ស្កាត់និងការឆ្លើយតបនៃអំពើហិង្សាតាមរយៈពុទ្ធសាសនាមកខាងលើនេះ យើងនឹងធ្វើការទាញចេញនូវចំណុចលេចធ្លោធំៗ មកបង្ហាញដូចខាងក្រោម៖

យើងបានដឹងហើយថា បញ្ហាហិង្សាមានច្រើនប្រភេទ ឬច្រើនទម្រង់ដូចមេរៀន មុនៗក្នុងកម្រិតបឋម មធ្យមដែលបានបង្ហាញហើយ តែយើងសូមទាញរំលឹកបន្ថែមទៀត ដើម្បីពង្រឹងចំណេះដឹង និងជំរុញឱ្យសកម្មភាពយើងកាន់តែមានប្រសិទ្ធិភាពឡើង។

ព្រះពុទ្ធសាសនាបានចូលរួមក្នុងការទប់ស្កាត់ និងការឆ្លើយតបផ្អែកលើចំណុចសំខាន់ពីរគឺ៖

១. ការទប់ស្កាត់ និងការឆ្លើយតបផ្អែកតាមរយៈទ្រឹស្ដីពុទ្ធសាសនា គឺការមិនឱ្យមានការប៉ះពាល់ហិង្សាលើកុមារ។ (ដកស្រង់យកខ្លឹមសារពីទំព័រត្រង់ចំណុច «៤.១២»)។

២. ការទប់ស្កាត់ និងការឆ្លើយតបតាមរយៈពុទ្ធសាសនាផ្អែកលើធនធាន និងយន្តការនានាដើម្បីជួយគាំទ្រថែរក្សាការពារ លើការបំពាន ការរំលោភហិង្សាលើកុមារទាំងឡាយដែលមានដូចជា៖

ក- វត្តអារាម ជាមជ្ឈមណ្ឌលពហុវិស័យ

- វត្ត មាន ព្រះសង្ឃ អាចារ្យ ពុទ្ធបរិស័ទ ក្មេងវត្ត
- វត្ត មាន គម្ពីរ ក្បួនច្បាប់ តម្រា ទ្រឹស្ដី
- វត្ត មាន សាលា ពុទ្ធិកអប់រំ និងមជ្ឈមណ្ឌលអប់រំ
- វត្ត មាន កម្មវិធីបុណ្យនានា

ខ- ប្រព័ន្ធវិស័យពុទ្ធិកអប់រំ

- កម្រិតបឋម
- កម្រិតមធ្យម (បឋមភូមិ ទុតិយភូមិ)
- កម្រិតឧត្តមសិក្សា (បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់)

គ- ប្រព័ន្ធពាក់ព័ន្ធនានា

- ពុទ្ធិកសមាគមនានា
- ប្រព័ន្ធសេវាផ្សព្វផ្សាយរបស់ក្រសួងព័ត៌មានជាតិ
- ប្រព័ន្ធសេវាផ្សព្វផ្សាយវប្បធម៌ វិចិត្រសិល្បៈ
- ក្រសួងធម្មការ និងសាសនា

- *គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា។*

**៤.២- ទស្សនាទានពុទ្ធសាសនាស្តីពីអហិង្សាធម៌**

*ក្នុងទ្រឹស្តីពុទ្ធសាសនា ពាក្យ «ហិង្សា» ផ្ទុយនឹងពាក្យ «អហិង្សា» តែន័យខ្លឹមសារមិនឃ្លៀងឃ្លាតពីគ្នា។ ភាពផ្ទុយគ្រាន់តែការប្រើពាក្យមានអក្សរ «អ» គ្មានដាក់ពីមុខពាក្យ ឬពុំមានអក្សរ «អ» = មាននៅពីមុខពាក្យប៉ុណ្ណោះ ដូចពាក្យ អកុសល ផ្ទុយពី កុសល, វិជ្ជា ផ្ទុយនឹង អវិជ្ជាជាដើម។*

*ពាក្យ ហិង្សា (ន) បានសេចក្តីថា ទង្វើបៀតបៀនផ្លូវកាយវាចាចិត្ត ស្តែងតាមសកម្មភាព ប្រកបដោយចេតនាផង និងអចេតនាផង។*

***តើពុទ្ធសាសនាមានការទប់ស្កាត់អំពើហិង្សាលើកុមារដូចម្តេច?***

*នៅក្នុងការចិញ្ចឹមជីវិតគ្រប់ទម្រង់ នៃបុគ្គល គ្រួសារ និងសង្គម ព្រះពុទ្ធតែងអប់រំមនុស្សឱ្យប្រកាន់ ការគោរព ការប្រតិបត្តិ តាមក្រមសីលធម៌យ៉ាងហោចណាស់ គឺការគោរពតាមនិច្ចសីល ដើម្បីវិសុទ្ធិសីល ជាបឋមមានការសម្តែងអំពីមេត្តាធម៌ សម្មាអាជីវៈ សទារសន្តោស សច្ចៈ និងការពុំមានការធ្វេសប្រហែស គឺអប្បមាទៈ ដែលជាប្រការនៃបញ្ចធម៌ក្នុងពុទ្ធសាសនាផង។*

*ជាមួយគ្នានេះ ព្រះពុទ្ធតម្រូវឱ្យមនុស្សប្រកាន់មុខរបររកស៊ីចិញ្ចឹមជីវិតដោយវៀរចាកអាជីវកម្ម៥យ៉ាង ដែលមានការលក់ដូរមនុស្ស គ្រឿងសព្វាវុធ សត្វ គ្រឿងស្រវឹង និងថ្នាំពិស។*

*ក្រៅពីនេះ ព្រះពុទ្ធសាសនាបានផ្តោតអារម្មណ៍ខ្លាំងលើការប្រតិបត្តិល្អ ការសិក្សាល្អ ដើម្បីទទួលបានផលល្អ និងដើម្បីទទួលបាននូវជោគជ័យសម្រាប់ជីវិត បានសេចក្តីថា មនុស្សម្នាក់ៗ កុមារម្នាក់ៗត្រូវមានសិទ្ធិទទួលបាននូវការអប់រំ ការបណ្តុះបណ្តាល ការ*

ថែទាំ គាំទ្រទាំងសុខភាពអនាម័យ ក្នុងសកម្មភាពដេកដើរឈរអង្គុយ និងរាល់ការងារ របស់មនុស្ស និងកុមារ។ មនុស្សទាំងអស់ត្រូវមានការសិក្សាបីដែលមាន(បរិយត្តិធម៌ បដិបត្តិធម៌ និងបដិវេធធម៌) និងមានតួនាទីធំបីទៀតដែលមាន (សីលសិក្ខា បញ្ញាសិក្សា និងសមាធិសិក្ខា)។

ទស្សនៈដោយឡែក ចំពោះកុមារក្នុងទ្រឹស្តីពុទ្ធសាសនាបានបង្រៀនដូចតទៅៈ

តាមរយៈមជ្ឈដ្ឋានគ្រួសារដែលម៉ែឪ ឬអាណាព្យាបាលកុមារទាំងឡាយ ត្រូវទទួលបាននូវសង្គហធម៌៤យ៉ាងពីម៉ែឪ និងអាណាព្យាបាលដែលមានការចិញ្ចឹមជីវិត ការហាមឃាត់គ្រប់អំពើអាក្រក់ ការឱ្យធ្វើអំពើល្អៗ ការផ្តល់ចំណេះដឹង និងការការពារកូននូវគ្រប់ទម្រង់ទាំងឡាយដែលអាចកើតមាន។

តាមរយៈការអប់រំ ឬប្រព័ន្ធអប់រំដែលមានលក្ខណៈជាអង្គភាព សមាគម ឬ គណៈផ្សេងៗ ដូចជានៅតាមសាលារៀន មជ្ឈមណ្ឌលអប់រំ តែងមានចែងអំពីវិន័យ សីលធម៌ បទបញ្ជា ច្បាប់ជាប្រចាំ មានវិធីសាស្រ្ត វិធានអប់រំជាក់លាក់ មានបណ្តុះបណ្តាលអំពីគ្រូប្រកបដោយគរុកោសល្យ និងជំនាញពិតប្រាកដព្រមទាំងមានការរៀបចំមេរៀនអនុវត្តសកម្មភាពបង្រៀន និងការតាមដាន វាយតម្លៃគ្រប់សកម្មភាពរបស់កុមារទៀតផង។

តាមរយៈសង្គមមានចែងមេដឹកនាំកំពូលៗ ដែលមានតួនាទី បង្កើត ប្រតិបត្តិ វិនិច្ឆ័យ ត្រួតពិនិត្យ តាមដានសកម្មភាពនូវរាល់បណ្តាញ នៃក្រសួង មន្ទីរ មូលដ្ឋានដោយអនុលោមតាមទសពិធរាជធម៌ នាយកធម៌ និងសង្គហធម៌។

ការបង្ហាញអំពីយន្តូបករណ៍ លិខិតូបករណ៍ និងទឡ្ហីករណ៍នេះ គឺចង់បញ្ជាក់បន្ថែមថា ព្រះពុទ្ធសាសនាមានវិធី ឬវិធានទ្រឹស្តីជាក់លាក់ក្នុងការទប់ស្កាត់នូវរាល់អំពើហិង្សាលើកុមារ។ នៅក្នុងន័យនេះ មានការទប់ស្កាត់អំពើហិង្សា អាចហៅម្យ៉ាងទៀតថា «

ធម៌អហិង្សា» ឬហៅថា «អហិង្សាធម៌» ក៏បាន។ ធម៌ចែងអំពីអហិង្សានេះ មាននៅក្នុងគម្ពីរផ្សេងៗដែលមានក្នុងពុទ្ធសាសនា មាននៅគ្រប់ភាគទាំងគម្ពីរព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម។ តែយើងមានការពិបាក ក្នុងការបែងចែកផែន កម្រិត ឬស្ថានភាពឱ្យបានជាក់លាក់ ព្រោះទ្រឹស្តីពុទ្ធសាសនាទូលំទូលាយណាស់ បើយើងចង់យល់ច្បាស់យើងត្រូវបន្តការសិក្សាបន្ថែមទៀត។ សេចក្តីនេះមានចែងដូចខាងក្រោម៖

១.ការបង្កើនចិត្តប្រកបដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា ក្នុងសទ្ធា (Faiths) ជំនឿ (Believes) ទាំងពួងពីសំណាក់អាណាព្យាបាលទាំងឡាយ។ សទ្ធាត្រូវតែប្រកបដោយឧត្តមប្រយោជន៍មានដែនកំណត់ មានវិចារណ៍ មានលក្ខណៈវិទ្យាសាស្ត្រ មានគណិតវិទ្យា ឬរូបវិទ្យាជាដើម។ ការឈរលើជំនឿពិតជាតម្លៃរបស់មនុស្ស ព្រោះមនុស្សពេញលក្ខណៈ ឬអ្នកជាអាណាព្យាបាលតោងជាស្ម័យម្ភូជន (Spontaneous Reasonability).

២. ការប្រើជំនឿខុស/អបិយជំនឿមិនគួរជាមនុស្សទេ បើជាមនុស្សស្ថិតក្នុងប្រភេទទី១ ទី២ និងទី៣ប៉ុណ្ណោះ ពុំមានធម្មសញ្ញាទេ។ មនុស្សគួរតែជឿ ឱ្យត្រូវតាមព្រះពុទ្ធ ព្រោះការជឿខុស/សទ្ធាខុស នាំឱ្យធ្លាក់ក្នុងមហន្តរាយខ្លួនឯង ព្រមទាំងឈានដល់ ប្តី/ប្រពន្ធ កូន ចៅ និងសង្គមទាំងមូលទៀត។ វាពុំមែនជា/ការសាង ឋានសួគ៌ ឋានសុខ ឱ្យមនុស្សទេ ផ្ទុយទៅវិញ វាជាការសាងឋាននរកឱ្យមនុស្សទៅវិញទេ។ ការប្រើប្រាស់ឱសថ/ថ្នាំ មិនត្រឹមត្រូវតាមវេជ្ជបញ្ជា ការគិតស្រមៃក្នុងការប្រើអាវុធស្នាទៗ ការធ្វើដំណើរកាត់តំបន់គ្រោះថ្នាក់ដោយផ្សងព្រេង វាប្រាកដជានឹងនាំខ្លួន និងជីវិតទៅរកការបំផ្លាញខ្លួនឯង និងបណ្តាលឱ្យស្លាប់ដល់អ្នកដែលខំដើរតាមពីក្រោយទៀត។

បញ្ហានេះ ការចិញ្ចឹមកុមារ ការការពារកុមារ ការអប់រំកុមារ ការផ្ដល់ឧត្តមប្រយោជន៍ឱ្យកុមារ ការបញ្ចៀសកុមារពីហានិភ័យទាំងឡាយ ប្រាកដជាមានប្រសិទ្ធភាពប្រសិនបើអាណាព្យាបាលម្នាក់ៗ បានប្រយ័ត្នក្នុងទម្រង់នៃការជឿខុសទាំងឡាយ។ ការជឿខុសនេះ ក៏មានច្រើនយ៉ាងជួនកាលពួគេនិយាយតៗ ជាពាក្យប្រជាប្រិយ ជាទម្លាប់ ជាប្រពៃណី ជាការធ្វើតៗគ្នា ក្នុងស្ថានភាពគ្មានវិជ្ជាជីវៈពិតប្រាកដ និងពុំមានគណនេយ្យភាពគ្រប់គ្រាន់។

ហេតុនេះរាល់ការថែរក្សា ការចិញ្ចឹម ការការពារនៃអាណាព្យាបាលទាំងឡាយប្រសិនបើគ្មានជំនាញទេនោះ ក៏អាចចាត់ទុកថា ជាការប្រើហិង្សាលើកុមារផងដែរ ដោយពុំចាំបាច់ប្រកបដោយចេតនា ឬអចេតនាផងឡើយ គេហៅថា «ម៉ែឪនាំកូនទៅស្លាប់ដោយមិនដឹងខ្លួន»។

ក្នុងការជឿខុស ធ្វើខុស គិតខុស ព្យាយាមខុស រស់នៅខុសនេះ មានបញ្ហាហានិភ័យខ្លាំងមែនទែនដល់កូនចៅ ឬកុមារដែលជាទីស្រឡាញ់របស់ខ្លួនដូចជា៖

- ការណ៍ខុសដោយចេតនា៖ ឧ. ការនិយាយ ការបញ្ជា ឬការអនុវត្តដូចជា ការប្រើវិន័យតឹងតែង ការធ្វើទារុណកម្ម វាយ បង្អត់អាហារ សម្លុតគំរាម បំភ័យ បញ្ឆោតបោកប្រាស់កូនខុសទំនងដោយគិតតែខ្លួនឯងថា ជាមធ្យោបាយអប់រំល្អ អាចធ្វើឱ្យកូនងាយស្រួលក្នុងការប្រើប្រាស់ ឬបញ្ជាទៅកាន់កូន។ ជួនកាល ការប្រើភាសាជេរ ឬសរសើរពេកនៅពេលកូនធ្វើល្អ ឬអាក្រក់ពេក នោះក៏ជាការរំលោភបំពានកុមារដែរ។
- ការប្រើទម្លាប់រើសអើង ឬប្រមាថក្នុងគ្រួសារដែលខ្លួនយល់ថា ជារឿងធម្មតាសម្រាប់ខ្លួន ប៉ុន្តែជាគំរូអាក្រក់បំផុតសម្រាប់កុមារដូចជាការជេរគ្រួសារ ជាប្ដី

ឬប្រពន្ធ និងកូនចៅ។ ពាក្យនេះកូននឹងទទួលដឹងឮ ឃើញ ក្រោយមក គេនឹងធ្វើការត្រាប់តាម។

- ការចិញ្ចឹមកូនដោយការប្រាថ្នាចង់បានផលប្រយោជន៍ពីកូន ដោយហៅថាកូននៅតូចផ្ទះស្ងាត់ គ្មានអ្នកជួយធ្វើការងារ វាពុំចាំបាច់ទៅរៀនទេ ចាំធំចាំទៅរៀន កូនគេមិនទាំងរៀនក៏មិនស្លាប់ដែរ កូនៗត្រូវតែនៅផ្ទះទើបបានជួយម៉ែឪ។ល។ អំពើនេះនឹងធ្វើឱ្យកូនរងការប្រើហិង្សា រំលោភបំពានកាន់តែច្រើនដូចជា ការមិន ចិញ្ចឹមប្រកបដោយភាពវិជ្ជមាន និងមានការប្រឈមហានិភ័យយ៉ាងខ្ពស់បំផុត។
- ការរំលោភបំពានផ្លូវភេទទាំងដោយចេតនា និងអចេតនាសុទ្ធតែត្រូវទទួលខុសត្រូវ ពីច្បាប់ព្រះធម៌ និងច្បាប់លោកទាំងអស់។ អំពើនេះមានបាបធ្ងន់ណាស់មិនអាចអត់ឱនបានទេ គេបានចាត់ចូលក្នុងប្រភេទមនុស្សវាណិជ្ជា គឺការជួញដូរផ្លូវ ភេទ។ អាណាព្យាបាល នឹងក្លាយជាឧក្រិដ្ឋជនមិនមែនជាបុព្វការីជនដ៏ល្អទេ ឋាននរកនឹងបើកទ្វារចាំបុគ្គលនោះ។

អាស្រ័យលើការពន្យល់ដោយសង្ខេបមកប៉ុណ្ណេះ អាចបញ្ជាក់ឱ្យឃើញថាការប្រើហិង្សាលើកុមារ មានអត្ថន័យច្រើនយ៉ាងណាស់ ហើយកាលណាអាណាព្យាបាល មានការប្រព្រឹត្តក្នុងអំពើជាអកុសល ឬអំពើបាបហើយមិនព្រមសន្សំនូវចំណេះដឹង ត្រឹមត្រូវមកលាងកំហុស ឬកែលម្អខ្លួនទេ នឹងត្រូវទទួលកំហុសថា ខ្លួនជាអ្នកបានប្រើហិង្សា លើកុមារដែលជាកូនចៅខ្លួនឯង។ អំពើនេះអាណាព្យាបាលត្រូវប្រុងប្រយ័ត្ន។

ប្រធានបទនេះគឺចង់បង្ហាញអំពីការប្រព្រឹត្តតាមទ្រឹស្តី និងគោលការណ៍ពុទ្ធ-សាសនាដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារមានដូចគ្នា ប៉ុន្តែដោយប្រើវិធីសាស្ត្រផ្សេងៗទៀតដែលមានក្នុងទ្រឹស្តីពុទ្ធសាសនាដូចគ្នាដូចជា៖

### ៤.២.១- អត្តសម្មាបណិធិ

ប្រធានបទនេះ ស្ថិតនៅក្នុងមង្គលសូត្រ ដែលមានចែងអំពីមង្គលមាន៣៨ប្រការ ក្នុងពុទ្ធសាសនា។ ដោយឡែក ពាក្យថា «អត្តសម្មាបណិធិ» ស្ថិតនៅក្នុងមង្គលទី៦ ក្នុងវាក្យខណ្ឌទី២ នៃមង្គលសូត្រ។

ពាក្យថា អត្តសម្មាបណិធិ មានន័យថា កិរិយាតម្កល់ខ្លួនដោយប្រពៃ ជាមង្គលដ៏ឧត្តម[១៥]។ តើកិរិយាតម្កល់ខ្លួនដោយប្រពៃមានតម្លៃជាអត្ថរូប អត្ថន័យ និងអត្ថរសយ៉ាងណា? ពិសេសការតម្កល់ខ្លួនដោយប្រពៃអាចចូលរួមក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ បានយ៉ាងដូចម្ដេច?

បើយើងនិយាយអំពីកុមារ យើងត្រូវនិយាយអំពីតួនាទីមាតាបិតា និងតួនាទីកុមារផងដែរ ព្រោះមាតាបិតា ឬអាណាព្យាបាលជាអ្នកគ្រប់គ្រងលើកុមារ ហើយកុមារជាអ្នកដែលត្រូវមាតាបិតា ឬអាណាព្យាបាលគ្រប់គ្រង។

ពាក្យថា «មាតាបិតា» មិនសំដៅត្រង់តែទៅលើម្ដាយឪពុកចំតែពីរនាក់ប៉ុណ្ណោះទេ យើងអាចសំដៅរួមទៅអ្នកដែលពាក់ព័ន្ធដល់ការទទួលខុសត្រូវចំពោះមុខកុមារឆ្លើយតបតាមតួនាទីជាអ្នកអនុវត្តច្បាប់ រហូតដល់អ្នកដឹកនាំកំពូលនៃប្រទេស និងអន្តរប្រទេសទៀតផង ព្រោះសិទ្ធិកុមារត្រូវបានចែងក្នុងអនុសញ្ញាអន្តរជាតិ។

តើក្នុងនាមនៃជនជាតិដែលស្ថិតនៅក្នុងបរិបទនៃមាតាបិតា គប្បីតម្កល់ខ្លួនឱ្យប្រពៃយ៉ាងដូចម្ដេច?

ចម្លើយទី១. ត្រូវស្គាល់ខ្លួនឯងដោយប្រពៃ

---

[១៥] មើលសៀវភៅសត្តបរិត្ត ទ្វាទសបរិត្ត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៤ ទំព័រ២៦។

ពាក្យថា «មាតាបិតា» គឺជាអ្នកផ្ដល់ពូជ ផ្ដល់ភូមិ ផ្ដល់អាហារ ផ្ដល់ការថែទាំ ផ្ដល់ការព្យាបាល ផ្ដល់ជីវជាតិ ផ្ដល់កំណើត និងផ្ដល់សុភមង្គលគ្រប់យ៉ាងដល់ បុត្រធីតារបស់ខ្លួន។

ឆ្លើយតបតាមន័យជាមាតាបិតានេះ គេគប្បីគិតតាំងពីពេលដែលខ្លួនគេបានចាប់ផ្ដើមក្នុងនាមជាដៃគូ ជាស្វាមី+ជាភរិយាដ៏ល្អ ដ៏ប្រពៃ។ តើដៃគូល្អប្រពៃត្រូវគិតធ្វើអ្វីខ្លះដើម្បីខ្លួន និងដើម្បីគ្រួសាររបស់ខ្លួន?

ក្នុងទ្រឹស្ដីពុទ្ធសាសនា បានចែងច្បាប់សង្ខេបក្នុងគម្ពីរសិង្គាលោវាទសូត្រ ស្ដីអំពីតួនាទីជាស្វាមីល្អ ជាភរិយាល្អ និងជាមាតាបិតា ឬបុព្វការីជនដ៏ល្អ និងដ៏ប្រពៃ។ មាតាបិតាគឺជាធនធានសម្រាប់បណ្ដុះបណ្ដាលអប់រំ និងផ្ដល់ដោគវាសនាឱ្យបុត្រធីតា របស់ខ្លួនជាដំបូង ឬក៏ជាសាលាទី១។ ក្នុងនោះ ព្រះពុទ្ធលោកចាត់ថាជាបុព្វការីជនទី១ ជាព្រះទី១ (ព្រះរស់) ជាបុព្វាចារ្យ ជាអាចារ្យខាងដើម។ ជាទេវាចារ្យ ជាទេវតាទី១ ជាទក្ខិណេយ្យបុគ្គលដែលគួរជាទីគោរពបូជា ជាបូជាចារ្យដែលគួរជាទីបូជា...។

ក្នុងនាមជាមាតាបិតា តាមពិតត្រូវធ្វើល្អអំពីខ្លួនឯងជាដំបូង គឺរៀបចំគ្រួសារ មិនគិតអំពីការផ្សេងៗទៀត ព្រោះតួនាទីមាតាបិតាមិនមែនគ្រាន់តែបំផើមចោល ឬបង្កើតកូនឱ្យហើយចោលនោះទេ។ បើដូច្នោះមែន អ្នកនោះក៏ពុំមានឈ្មោះ និងមាននាមជាមាតាបិតាឡើយ។ ថែមទាំងមានឈ្មោះថា ចិត្តជាអមនុស្សទៀត ព្រោះសូម្បីសត្វក៏ចេះស្រឡាញ់ និងថែរក្សាចិញ្ចឹមកូនវាដែរ។

កិច្ចតម្កល់ខ្លួនឱ្យក្លាយជាមនុស្សល្អ ឬមាតាបិតាល្អនោះ គឺក្នុងនាមជាមាតាបិតាត្រូវកសាងអំពើល្អ ការពោលពាក្យល្អ ការធ្វើឱ្យសន្ដានចិត្តល្អប្រកបដោយមេត្តា ករុណា មុទិតា ឧបេក្ខា ចាប់តាំងពីដឹងថាកូនបានស្ថិតនៅក្នុងគភ៌ម្ដេះ។ ការថែរក្សាការពារកូន ពុំ

មានដែនកំណត់ ពុំមានការគិតអំពី ថ្ងៃ ខែ ឆ្នាំ ឬពេលវេលា ឬក៏សភាវៈ ក្តៅ ត្រជាក់ រង់ារ និងរយៈពេលឆាប់យូរឡើយ។ ការចញ្ចឹមកូនមានរយៈពេលយូរអង្វែង រហូតដល់បំណង ប្រាថ្នារបស់ខ្លួន និងបំណងប្រាថ្នារបស់កូនបានសម្រេចគោលដៅ។

ដូច្នេះ ការតម្កល់ខ្លួនដោយប្រពៃ ឬ ថាជាបុគ្គលងាយស្រួល ក្នុងការប្រតិបត្តិល្អ តាមឱវាទនៃព្រះពុទ្ធជាម្ចាស់ គឺមាតាបិតាគប្បីរៀនសូត្រ ប្រតិបត្តិ និងធ្វើឱ្យបានសម្រេច ប្រកបដោយប្រសិទ្ធភាព។

ប្រសិនបើមាតាបិតាបំពេញបានគ្រប់ចំណុចនៃពុទ្ធឱវាទ កុមារនឹងរួចចាកផុតពី ការរំលោភបំពាន ការប្រើហិង្សានានាពីគ្រប់ទម្រង់គ្រប់ប្រភេទដែលអាចកើតឡើង ព្រោះ យើងប្រៀបករណីនេះដូចជាពេទ្យ ប្រសិនបើពេទ្យអនុវត្តតាមវេជ្ជបញ្ជារបស់អ្នកប្រាជ្ញ ដែលជាបិតាផលិតឱសថនោះ អ្នកជំងឺ ឬអតិថិជនទាំងឡាយដែលមកព្យាបាលនោះនឹង ជាសះស្បើយ ឬបានជាជំងឺគ្រប់ៗគ្នា។

ចំពោះជនទាំងឡាយ ដែលមានសញ្ញាសម្គាល់ថា ជាមាតាបិតា សត្វ ឬមនុស្ស ទូទៅ គប្បីធ្វើខ្លួនឱ្យទៅជាអ្នកតម្កល់ខ្លួនឱ្យប្រពៃ ពោលគឺត្រូវស្វែងរកគុណជាតិ គុណធម៌ សម្រាប់ជីវិតខ្លួនទុកជាគំរូល្អ ទុកស្នាមជើងដ៏ល្អដល់អ្នកដទៃ ធ្វើជាអ្នកកសាងឋានសួគ៌ ស្ថានសុខដល់មនុស្សជាតិដូចគ្នា ពុំគប្បីធ្វើខ្លួនឱ្យជាអ្នកមានការលំបាកមានឧបសគ្គ មាន ការប្រឈម មានហានិភ័យដល់មនុស្សជាតិ និងពុំគួរបណ្តោយឱ្យសំណាងជីវិតក្លាយជា ចៃសង្គម ក្លាយជាជនឧក្រិដ្ឋដែលគួរឱ្យស្អប់ខ្ពើមនោះទេ។

តួនាទីទាំងពីរគឺ អ្នកក្នុងនាមជាមាតាបិតានិងក្នុងនាមជាបុត្រធីតា ទាំងពីរផ្នែកនេះ គឺជាកម្លាំងកត្តាលីករដ៏មានសក្តានុពល និងមានប្រសិទ្ធភាពក្រៃលែងក្នុងកិច្ចសហការ

ចូលរួម និងទប់ស្កាត់រាល់អំពើរំលោភបំពាន និងហិង្សាលើកុមារដែលកំពុងតែប្រឈមហានិភ័យដ៏ខ្ពស់គួរឱ្យចាប់អារម្មណ៍នៅក្នុងប្រទេសយើង។

«អកោធេន ជិនេ កោធំ» សេចក្តីក្រោធ ឈ្នះដោយមិនក្រោធ «អហឹសេន ជិនេ ហឹសា» ការបៀតបៀន ឈ្នះដោយការមិនបៀតបៀន។

**៤.២.២- អដ្ឋង្គិកមគ្គ (ផ្លូវប្រកបដោយអង្គ ៨ប្រការ)**

ទ្រឹស្តីអំពីច្បាប់អដ្ឋង្គិកមគ្គ គឺជាពុទ្ធវចនៈមានតម្លៃកាត់ថ្លៃមិនបាន ជាកំណប់ វប្បធម៌ដ៏មហាសាល ជាបីតិកកណ្តៀវប្បធម៌សម្រាប់សាកល ពោលគឺជាធម៌សច្ចៈ ជាកំពូលលើលោកដែលគ្មានសច្ចៈធម៌ណាមានប្រៀបស្មើបាន។

ក្នុងលោកនេះ ពុំមានទ្រឹស្តីលោកអ្នកប្រាជ្ញណា ដែលដើរឱ្យហួសពីមាគ៌ាព្រះពុទ្ធនេះបានឡើយ។ តើមាគ៌ានេះមានតម្លៃយ៉ាងម៉េច?

អំពីអត្ថន័យ អដ្ឋង្គិកមគ្គ ជាអរិយសច្ចៈទី៤ ក្នុងបណ្តាសច្ចៈដ៏កំពូលក្នុងពុទ្ធសាសនា អដ្ឋង្គិកមគ្គ < អដ្ឋ + អង្គិក + មគ្គ បានន័យដោយសង្ខេបថា មាគ៌ាប្រកបដោយអង្គ៨។ មាគ៌ាទាំង៨ជាផ្លូវ ជាគន្លង សម្រាប់ដោះស្រាយបញ្ហាទុក្ខ ឧបសគ្គ ការប្រឈម និងហានិភ័យគ្រប់យ៉ាង។ ផ្ទុយទៅវិញ សេចក្តីទុក្ខ ឧបសគ្គ ការប្រឈម និងហានិភ័យដែលអាចមានអត្ថិភាពរស់បាន មានជីវិតបាន និងបន្តអភិវឌ្ឍបានដរាបណាពុំមានចលនា ឬ សកម្មភាពនៃការប្រតិបត្តិមាគ៌ា អដ្ឋង្គិកមគ្គប៉ុណ្ណោះ។

ក្នុងអដ្ឋង្គិកមគ្គ មានន័យសេចក្តីដូច្នេះ ៖

ក- សម្មាទិដ្ឋិ : (Right Vision) គំនិតយល់ឃើញត្រូវ

ការយល់ត្រូវគឺជាសភាវៈពិត មិនស្រពេចស្រពិលក្នុងលោកនេះ និងលោកខាងមុខ បានន័យថាឃើញល្អ ឃើញអាក្រក់ ឃើញគុណ ឃើញទោស ក្នុងសភាវៈទាំងពួង។

បើយើងវិភាគ និងផ្តោតអារម្មណ៍លើវិធាននៃការទប់ស្កាត់អំពើហិង្សាលើកុមារសម្រាប់កម្ពុជាវិញ ពាក្យសម្មាទិដ្ឋិនេះ មានតម្លៃជាទឡ្ហីករណ៍ជាកាលានុវត្តភាព និងជាសូចនាករដ៏ល្អប្រសើរ។ តើហេតុអ្វី?

- យើងត្រូវទទួលស្គាល់ការពិតថា នៅប្រទេសកម្ពុជាប្រាកដជាមានព្រឹត្តិការណ៍នេះប្រាកដមែន។
- យើងទទួលស្គាល់បាន ត្រូវប្រាកដលើការអង្កេត ការពិនិត្យ ការវាយតម្លៃ តាមសកម្មភាព ឬព័ត៌មាន និងការអនុវត្តន៍ជាក់ស្តែងបន្ថែមទៀត។
- យើងអាចមើលឃើញអំពីទិដ្ឋភាព សញ្ញាណដែលបង្ហាញតាមទម្រង់ និងប្រភេទព្រមទាំងលក្ខណៈពិសេសៗទៀត នៃហិង្សាលើកុមារ។
- យើងអាចស្គាល់ពីប្រភព ឬមូលហេតុផ្ទាល់ ឬប្រយោលបាន អាស្រ័យលើយើងសង្កេតមើលដល់អាគតដ្ឋាន ឬមូលដ្ឋាននៃដែនជាទីកើតឡើងនៃសកម្មភាពហិង្សាលើកុមារ។
- យើងអាចធ្វើការសន្និដ្ឋានរួម និងលើកគោលការណ៍ទាំងឡាយ ដោយផ្អែកលើច្បាប់នានាមានគោលនយោបាយ យុទ្ធសាស្រ្ត សកម្មភាព និងការបញ្ចូលកម្មវិធីនានា ដើម្បីទប់ស្កាត់សកម្មភាពអវិជ្ជមានទាំងឡាយ ដែលបណ្តាលឱ្យប៉ះពាល់ដល់ហិង្សាលើកុមារ។

## ២- សម្មាសង្កប្បៈ (Right Thought) ការត្រិះរិះត្រូវ

ការពិចារណាត្រូវ បានដល់ការវិភាគ ការគិត ការត្រិះរិះត្រឹមត្រូវ ឬការប្រើយន្តការក្នុងការធ្លុះ ការស្ទង់ ការត្រួតពិនិត្យ តាមរយៈប្រព័ន្ធវិភាគត្រឹមត្រូវ។ យើងមុននឹងធ្វើអ្វីៗ មុននឹងចេញអ្វីៗ លុះត្រាតែយើងបានទទួលទ្ធផលត្រូវ។ តែលទ្ធផលដែលត្រូវ វាទាមទារឱ្យយើងមានបច្ចេកវិទ្យាពិត មានវិធីពិត មានយន្តការសមហេតុសមផល វិទ្យា-សាស្ត្រប្រាកដប្រជា។ ការត្រិះរិះត្រឹមត្រូវ វាទាក់ទងដល់ចំណេះដឹង ការពិសោធ ការប្រើវិចារណញ្ញាណ ការផ្អែកលើឧបករណ៍វាយតម្លៃ និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រាន់។ បើតាមវិទ្យាសាស្ត្រមាន ការអង្កេត ការពិសោធ ការធ្វើសម្មតិកម្ម ការចងក្រងជារូបមន្ត ឬទ្រឹស្តីបទ និងជំហាននៃការប្រតិបត្តិត្រឹមត្រូវ។

ក្រមស្តីពីការត្រិះរិះត្រឹមត្រូវនេះ គឺផ្អែកទាំងស្រុងលើគំនិតបញ្ញារួម ជាមួយរូបជាតុវិទ្យា ហើយទាក់ទងពិសេសលើការប្រើឥន្ទ្រិយារម្មណ៍ និងបត្យារម្មណ៍របស់អ្នកវិភាគប្រកបដោយហេតុ និងផលស្របគ្នា។

ពាក់ព័ន្ធជាមួយការទប់ស្កាត់អំពើហិង្សាលើកុមារ សម្មាសង្កប្បៈ គឺការពិចារណាត្រឹមត្រូវ និងមានតួនាទីស្រាវជ្រាវរករកជាតុពិត ដើម្បីបង្កើតជាសក្ខីកម្មឱ្យមាន ជំនឿជឿជាក់។ ការជឿជាក់ផ្តើមចេញពីការរកឱ្យឃើញនូវហេតុបច្ច័យ និងផល ដែលទទួលបានពីសកម្មភាពបំពាននូវគ្រប់ទម្រង់លើកុមារដូចជា៖

-កុមាររងគ្រោះដោយសារអ្វី? មានកត្តាអ្វីខ្លះ?

-កុមាររងគ្រោះដោយទម្រង់ប្រភេទអ្វីខ្លះ?

-អ្វីជាមូលហេតុ ឬជាបច្ច័យនាំឱ្យមានការរងគ្រោះ តាមប្រភេទនីមួយៗ?

-តើទំហំនៃសកម្មភាពរំលោភយ៉ាងម៉េចខ្លះ? អ្វីជាការប្រឈមសម្រាប់កុមារ ?

-តើមានឱសថ និងវិធានអ្វីដើម្បីទប់ស្កាត់?

-តើត្រូវប្រើវិធីសាស្ត្រដូចម្តេច?

-ចាប់ផ្តើមនៅពេលណា? ប្រើឧបករណ៍អ្វីដើម្បីវាស់?

សំណួរទាំងអស់នេះ គឺជាមធ្យោបាយសម្រាប់ជំរុញឱ្យយើងយល់ដឹង និងគាំទ្រ កាន់តែរឹងមាំក្នុងអារម្មណ៍ដើម្បីឆ្លើយតប។ ប្រសិនបើយើង មិនប្រើឧបករណ៍វាស់វែង ដូចអ្វីដែលយើងបានរៀបរាប់ទាំងអស់នេះទេ ការពិចារណាត្រូវ និងពុំអាចប្រាកដបាន។ តែបើបានអនុវត្តតាមនិយាមទាំងអស់នេះ នោះយើងនឹងមាន សម្មាសង្កប្បៈ ពេញបរិបូរណ៍។ ពិសេសការឆ្លើយតបនៃអំពើហិង្សាលើកុមារនឹងមានហេតុផល នឹងឈានដល់ប្រសិទ្ធភាពបាន។ បានន័យថា «ការវិភាគត្រូវ នាំឱ្យមានការស្រាយត្រូវ»។

គ- សម្មាវាចា (Right Speech) សម្តីត្រូវ

ចំណុចទី៣នេះ ជាយន្តការពិសេសមួយទៀត សម្រាប់ជួយក្នុងការផ្សព្វផ្សាយព័ត៌មានពិត ដំណឹងវិទ្យាសាស្ត្រដើម្បីឱ្យសាធារណជនទាំងឡាយបានដឹង និងបានស្វែងយល់ដើម្បីជួយចូលរួមដោះស្រាយទាំងអស់គ្នា។ ក្នុងនិយាមសីលធម៌ អ្នកប្រាជ្ញខ្មែរ បានចងក្រងពាក្យច្រើនដូចមានពាក្យថា៖

- មនុស្សយកសម្តី ដំរីយកភ្លុក
- អណ្តាតជាអាទិ៍កន្ទង់ បានសុខទុក្ខផងពីព្រោះអណ្តាត
- រនាបបាក់យករនាបជួស សម្តីហួស ពុំមានអ្វីជួសឡើយ
- សម្តីជាឯក លេខជាទោ
- មុននិយាយត្រូវត្រលាស់អណ្តាតឱ្យបានមួយរយដង ជាដើម។

ពាក្យប្រើក្នុងពុទ្ធភាសិត «សច្ចំ វេ អមតា វាចា» ប្រែថា ពាក្យពិតជាពាក្យមិនស្លាប់ អាច និយាយថា «ពាក្យច្រើនកួត ច្រើនចាញ់អត្ថា» ផងដែរ។ យើងអាចយកពាក្យពេចន៍ ត្រឹមត្រូវល្អៗ មកនិយាយពាក់ព័ន្ធនិងការទប់ស្កាត់អំពើហិង្សាលើកុមារដូចជា៖

- អំពើហិង្សាលើកុមារមានហានិភ័យខ្ពស់ នេះបើតាមការវាស់វែងរបស់អ្នកស្រាវជ្រាវ
- ធ្វើតាមការវិភាគជាលទ្ធផលហេតុដែលបណ្តាលឱ្យមានអំពើហិង្សាលើកុមារមានច្រើនករណី មាន ភាពក្រីក្រ ភាពមិនអើពើ ភាពកេងប្រវ័ញ្ច ភាពពុករលួយ ភាពខ្វះការអនុវត្តច្បាប់ប្រកបដោយនីត្យានុកូលភាព ភាពយឺតយាវក្នុងការទទួលបានសេវា ភាពលាក់បាំង ឬភាពភ័យខ្លាច...។
- ការរំលោភបំពានទាំងឡាយតែងកើតឡើងតាមរយៈគ្រួសារផ្ទាល់ តាមរយៈសង្គម និងតាមរយៈជនអ្នកប្រព្រឹត្តខុសច្បាប់ ច្រើនបណ្តាលមកពីឈ្មួញ និងអ្នកមានអំណាចទៀតផង។
- វិធានការតាមដាន ការអង្កេត ការបង្ក្រាបនៅមានកម្រិតប៉ុណ្ណោះជាដើម។ អាស្រ័យហេតុនេះ រាល់សេវាប្រព័ន្ធក្រសួងមានសមត្ថកិច្ច ប្រព័ន្ធអនុវត្តសេវាច្បាប់ ប្រព័ន្ធថែរក្សា ប្រព័ន្ធការពារ គ្រប់ទម្រង់ ត្រូវសហការគ្នា និងផ្តល់ព័ត៌មានទាំងអស់គ្នា។ បើបានដឹងព័ត៌មានចេញពីប្រភពណា?

មានសកម្មភាពយ៉ាងម៉េចផ្តល់ព័ត៌មានពិតៗ និងភ្លាមៗ។ ការធ្វើបែបនេះ ការទប់ស្កាត់អំពើហិង្សាលើកុមារ នឹងទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព។

### ឃ- សម្មាកម្មន្ត (Right Actions) ការងារត្រូវ

ក្រោយពីស្តាប់ព័ត៌មាន បានជាការពិត ការអនុវត្តផែនការ និងយុទ្ធសាស្រ្តទាមទារឱ្យមានការពិតជាក់ស្តែង។ ការធ្វើគប្បីអនុវត្តតាមសូចនាករ តាមវិធីសាស្រ្ត តាមរូបមន្តវាយតម្លៃមានហេតុផលជាក់លាក់ធ្វើឱ្យការអនុវត្ត ឱ្យត្រូវតាមអ្វីដែលបង្ហាញក្នុង ចំណុច ១ ចំណុច២ និងចំណុច៣។ បានសេចក្តីថា ការងារត្រូវ ជាការងារដែលពុំមានទោស ជាការងារមិនប៉ះពាល់និងអំពើខុសឆ្គង ជាការងារប្រាសចាក អំពើបាបគ្រប់យ៉ាង។ អំពើល្អនេះ នឹងទទួលបានជោគជ័យគ្រប់យ៉ាង និងពុំមានឧបសគ្គអ្វីឡើយ។

### ង- សម្មាអាជីវៈ (Right Livelihood) ការចិញ្ចឹមជីវិតត្រូវ

ការចិញ្ចឹមជីវិតត្រឹមត្រូវ ជាគន្លងនៃមាគ៌ាប្រតិបត្តិរបស់អ្នកប្រាជ្ញ។ មនុស្សភាគច្រើនតែងយកចិត្តទុកដាក់ចំពោះការចិញ្ចឹមល្អ ដោយមានការវៀរចាក ប្រាសចាកការចិញ្ចឹមជីវិតខុស ដូចជាការបៀតបៀន ការរំលោភបំពាន ការប្រកបមុខជំនួញខុសច្បាប់ជាដើម។ តែមានជនជំពូកខ្លះទៀត សប្បាយក្អឹតក្អឺននិងរស់នៅលើញើសឈាមលើគំនរទុក្ខសោក លើគំនរទឹកភ្នែក លើការឈឺចុកចាប់នៃអ្នកដទៃ។ ចំពោះចំណុចនេះយើងក៏ត្រូវសិក្សាវែកញែកឱ្យច្បាស់តាមមាត្រាព្រះធម៌ដែលបានពន្យល់អំពីខាងដើមដូចគ្នា គឺត្រូវស្គាល់ថា ការរស់យ៉ាងម៉េចដែលស្ថិតនៅក្នុងការបំពាន ការរំលោភ និងការប្រើហិង្សាលើកុមារ? ធ្វើយ៉ាងម៉េចដើម្បីបញ្ចៀសការរំលោភបំពាន ហិង្សាលើកុមារ?

តាមអត្ថន័យនៃព្រះធម៌ ទាក់ទងនឹងការរស់នៅត្រឹមត្រូវមិនប៉ះពាល់ដល់ហិង្សា លើកុមារ គឺស្ថិតនៅត្រង់ផ្លូវព្រះធម៌បានសម្តែងអំពីមិច្ឆាជីវៈ ការរស់នៅខុសបានដល់ការប្រើឥរិយាបថក្នុងជំនឿប្រកបដោយសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ ទៅលើតួនាទីទប់ស្កាត់ហិង្សាលើកុមារ។ អ្វីដែលត្រូវអនុវត្ត និងអ្វីដែលមិនគួរធ្វើដូចជា៖

- ការបិញ្ចឹម ការការពារកូនបានល្អប្រពៃក្នុងតម្លៃកុសលធម៌ បានន័យផ្តល់សិទ្ធិ សេរីភាព គ្រប់យ៉ាងដល់កុមារតាមរយៈបច្ច័យ៤ តាមរយៈការលូតលាស់នៃ រាងកាយ (សុខភាពឈាម)។
- ការផ្តល់ចំណេះដឹង ពហុវិស័យ តាមតម្រូវការរបស់កុមារ និងតួនាទីកុមារក្នុងបទដ្ឋានច្បាប់នានាដែលច្បាប់របស់រដ្ឋ ឬអង្គការអន្តរជាតិមានចែងអំពីការចង់ចេះដឹងរបស់កុមារ។
- ការផ្តល់ឱកាសឱ្យចូលរួមក្នុងការងារណាដែលជាតម្លៃរបស់កុមារ និងជាសិទ្ធិកុមារ ដែលត្រូវមានចែងក្នុងវ័យ និងច្បាប់។
- ការទប់ស្កាត់រាល់ការប្រមាថ ការបំពាន ការរំលោភបែបអវិជ្ជមានផ្សេងៗបានដល់ការហាមឃាត់ ឬការទប់ស្កាត់រាល់មច្ឆាជីវៈ ឬក៏ការរស់នៅដែលផ្ទុយនិងសីលធម៌មនុស្ស សីលធម៌សង្គម។ ម្យ៉ាងទៀតដើម្បីបានការជំរុញ ឬការបង្ខំឱ្យកូនធ្វើអ្វីដែលមិនសមស្របនឹងកុមារ តែដើម្បីអត្តប្រយោជន៍ខ្លួនដូចជា ការបង្ខំឱ្យកូនធ្វើការហួសកម្លាំង ការជេរស្តី ការដាក់ទារុណកម្ម ឬអំពើធ្ងន់ធ្ងរ។ លើសនេះទៀតដូចជា ការឱ្យទៅស៊ីឈ្នួលគេ បម្រើសេវាកម្មអកុសលបែបអមនុស្សធម៌ហួសហេតុជាដើម។

ប) សម្មាវាយាម -Right Efforts) ការព្យាយាមត្រូវ

ការងារទាំងឡាយសម្រេចបាន អាស្រ័យដោយការព្យាយាម តែការព្យាយាម ព្រះពុទ្ធ ឱ្យជ្រើសរើសយកតែការព្យាយាមណា ដែលប្រកបដោយកុសលធម៌ ផ្លូវសុចរិត ផ្លូវប្រកបដោយសម្មាអាជីវៈ ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃ។ ការព្យាយាមមួយណាដែលប្រកបដោយអំពើទុច្ចរិត អកុសល ឬអំពើបាប ព្រះពុទ្ធទ្រង់ឱ្យចៀសវាង បើមិនដូច្នោះនឹងត្រូវមានទោស។

ចំពោះការឆ្លើយតបនិងសកម្មភាពទប់ស្កាត់ហិង្សាលើកុមារ សម្មាវាយាម មានមុខងារសំខាន់ណាស់ដើម្បីចូលរួមដែលមានដូចជា៖

- ការព្យាយាម អង្កេត តាមដាន ត្រួតពិនិត្យ វាយតម្លៃ ឬព្យាយាមអនុវត្តទប់ស្កាត់ និង ការពារគ្រប់យ៉ាងដែលកើតមាន និងអ្វីដែលត្រូវដោះស្រាយ ដើម្បីបញ្ចៀសអំពើហិង្សាលើកុមារឱ្យបាន។
- ការព្យាយាមទៅរកមូលដ្ឋានគតិយុត្ត ឬអ្នកការពារច្បាប់ ដើម្បីជួយបំភ្លឺ ឬបង្ហាញការពិតដល់សកម្មភាពរំលោភបំពានលើកុមារ។
- ការព្យាយាមបែបមនុស្សធម៌ ដើម្បីគាំទ្រលើកស្ទួយជីវភាពកុមារ សិទ្ធិកុមារ តម្រូវការរបស់កុមារ ឱ្យបានសម្រេចដល់គោលដៅ ឬក៏ព្យាយាមរកហេតុផល ដើម្បីរក្សាកុមារ ក៏ជាធម្មសាស្ត្រនៃអរិយសច្ចផងដែរ។

៨- សម្មាសតិ (Right Mindfulness) ការរលឹកត្រូវ

មនុស្សប្រសើរ តែមានសតិរឹងមាំ សតិតាំងនៅ សតិមិនវិប្បលាស បើបាត់បង់សតិហើយ ការងារគ្រប់យ៉ាងក៏ពុំមានន័យអ្វីដែរ។ មនុស្សមានសតិ ធ្វើអ្វីមួយក៏ដោយ គង់នឹងបានសម្រេច ឧទាហរណ៍ ការសិក្សា ការគិត ការងារតូចធំទាំងឡាយ។ ប្រសិនបើពុំមានសតិកើតឡើង ការសិក្សានោះ ការគិតនោះ ការងារនោះ នឹងរាយប៉ាយចែកជាអូរ ហូរជាស្ទឹងរកគោលដៅពុំឃើញឡើយ។

ទាក់ទងនឹងសកម្មភាពឆ្លើយតប ការរំលោភបំពានហិង្សាលើកុមារ ដ៏ដូចគ្នាបានន័យថា បើយើងគិតអំពីកុមារ យើងត្រូវតាំងសតិឱ្យមាំថា «យើងកំពុងផ្ដង់អារម្មណ៍លើកុមារ ហើយបញ្ហាសំខាន់ គឺការប្រើហិង្សាលើកុមារ»។ បើដូច្នេះ គ្រប់ពលកម្ម គ្រប់

សកម្មភាព ត្រូវលើកឡើងពីជំនឿត្រូវ ជំនឿពិត ការចិញ្ចឹមត្រូវ ការថែរក្សាត្រូវ ការការពារត្រឹមត្រូវ ហេតុនៃការប្រឈមត្រឹមត្រូវ និងវិធីណាអាចជួយទប់ស្កាត់ហិង្សាបាន។

ជ- សម្មាសមាធិ(Right Meditation) ការតម្កល់ចិត្តត្រូវ

សម្មាសមាធិជាមូលធម៌ជួយញ៉ាំងអារម្មណ៍ឱ្យមានភាពប្រក្រតី ការធ្វើ ឬការទប់សតិឱ្យល្អ មិនឱ្យញាប់ញ័រ ឃ្លេងឃ្លោង ផ្លាស់ប្តូរតាមឥទ្ធិពលខាងក្រៅ បានន័យថា ការតាំងចិត្តឱ្យទូលាយ តម្កល់ឱ្យមាំក្នុងភាពតែមួយ។ គោលបំណងនៃសម្មាសមាធិ គឺចង់ បណ្តាលឱ្យចិត្តមានទីតាំង មានជំហរ ស៊ុបមាំ ច្បាស់លាស់ ពុំសើរើ ពុំរាយមាយ តាមអ្វីដែលនាំឱ្យរំខានផ្លូវចិត្ត ឬផ្លូវអារម្មណ៍។

ទាក់ទងនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពានហិង្សាលើកុមារ តម្លៃសម្មាសមាធិ សង្កត់ធ្ងន់ទៅលើបញ្ហា និងកម្មវិធីអនុវត្តដើម្បីធ្វើការឆ្លើយតបឱ្យបានតាមអ្វី ដែលជាផែនការ និងជាយុទ្ធសាស្ត្រដែលបានកំណត់នឹងរំពឹងទុក។ ការតាំងអារម្មណ៍ បានន័យថា មិនខ្វល់នឹងអ្វីដទៃ ដែលក្រៅពីការចាប់អារម្មណ៍លើការរំលោភបំពាន ហិង្សាលើកុមារ។

អាស្រ័យហេតុនេះ កងធម៌អដ្ឋង្គិកមគ្គទាំង៨នេះពិតជាសច្ចធម៌ជួយអន្តរាគមន៍យ៉ាងទូលំទូលាយក្នុងការអនុវត្តកម្មវិធីឆ្លើយតបការប្រើហិង្សាលើកុមារ តាមរយៈទ្រឹស្តីពុទ្ធសាសនានេះមិនខាន។

## ៤.២.៣- អកុសលមូលទាំង៣

អកុសលមូលក្នុងទ្រឹស្តីព្រះពុទ្ធសាសនា ផ្តោតអារម្មណ៍លើការប្រព្រឹត្តប្រកបដោយអកុសលធម៌ជាមូលដ្ឋាន ឬជាឫសគល់។ ប្រធានបទនេះ លោកចាត់ចូលក្នុងសភាវៈអាក្រក់ ដែលជាធម្មជាតិបណ្តាលឱ្យកើតមានបញ្ហាឱ្យកើតជាឧបសគ្គ និងវិបត្តិផង

ទាំងពួង មិនមែនជាសភាវៈ ឬជាគុណជាតិនាំមកនូវសេចក្តីសុខ សេចក្តីចម្រើន ឬនាំទៅកាន់ឋានបរមសុខបានឡើយ។ អកុសលធម៌នេះ ជាឧបសគ្គ ធំណាស់ វាជាកិលេស ជាគ្រឿងសៅហ្មង ជាគ្រឿងធ្វើឱ្យមនុស្សជាប់ជំពាក់។ វាជាភ្លើង បណ្តាលឱ្យចិត្តក្តៅក្រហល់ក្រហាយ អន្ទះអន្ទែងគ្មានទីបញ្ចប់។ វាជាអាវុធដ៏មុតថ្លា ដែលចាក់ដោតអារម្មណ៍មនុស្សឱ្យឈឺចុកចាប់ខ្លោចផ្សារគ្មានទីបញ្ចប់។ ព្រះពុទ្ធទ្រង់សម្តែងថា វាជាសភាវៈកំណាច ជាភ្លើងអំណាច ជាអាវុធអំណាច និងជាដើមចមដ៏កំណាចដែលនាំមកនូវសេចក្តីទុក្ខទាំងឡាយទាំងពួង។ អកុសលមូលនេះ មានបញ្ជាក់នៅក្នុងអង្គទី២នៃអរិយសច្ចធម៌ គឺសមុទ័-យសច្ចនេះឯង។ ប្រភេទនៃអកុសលមូលមានតួអង្គធំៗ៣គឺ

១.លោភៈ ការប្រាថ្នាចង់បានហួសដែនកំណត់

២.ទោសៈ ការប្រទូស្តរាយណ៍គ្មានមូលហេតុ

៣.មោហៈ សេចក្តីល្ងង់វង្វេងក្នុងភាពអវិជ្ជា

ពាក្យថា «លោភៈ» គឺ «សេចក្តីប្រាថ្នា» វាតែងកើតមានគ្រប់សន្តាននៃសត្វលោក មិនមាននរណាម្នាក់គេចវេះចៀសវាងបានទេ គ្រាន់តែការប្រាថ្នាមានកម្រិតទាប ឬខ្ពស់ស្រាល ឬធ្ងន់ប៉ុណ្ណោះ។ បុគ្គលណាក្រាស់ដោយអកុសល គឺសេចក្តីលោភ បុគ្គលនោះតែងមានអារម្មណ៍ជាប់ជំពាក់ជិតដាម តាមជាប់ស្អិតមិនងាយនឹងដកចិត្តរួចបានឡើយ។ ប្រសិនជាដកចិត្តមិនបាន នឹងស្លាប់ជាអសារបង់។

ថា «ទោសៈ» គឺ «ការខឹង» ឬ «ការប្រកាន់» វាជាអកុសលមួយទៀតដែលនឹងកើតឡើងនៅពេលណាដែលលោភៈ គឺសេចក្តីប្រាថ្នានោះមិនបានសម្រេចដូចបំណង។ កាលណាបើទោសៈចាប់ផ្តើមឡើង វាធ្វើឱ្យសត្វនោះភ្លេចភ្លាំង សតិស្មារតី បាត់បង់សីលធម៌

កល្យាណធម៌ សទ្ធម្មធម៌ និងព្រហ្មវិហារធម៌អស់ ពីក្នុងសន្តាន និងកាន់តែធ្វើឱ្យចិត្ត អន្ទះអន្ទែងក្តៅក្រហល់ក្រហាយទ្វេឡើងឥតឈប់ឈរ។

ពាក្យថា «មោហៈ» គឺ «សេចក្តីវង្វេង» ក៏ជាអកុសលធម៌មួយដ៏កំណាចផងដែរ។ មោហៈ សេចក្តីវង្វេង ភាពល្ងិតល្ងង់ ភាពល្ងង់ខ្លៅ ភាពអវិជ្ជា ភាពអន្ធការ និងភាពមិនចេះដឹង វាជាឧបសគ្គនិងជាគ្រោះថ្នាក់ដ៏គួរឱ្យភ័យខ្លាចជាទីបំផុត។ គ្រោះថ្នាក់នៃភាពអវិជ្ជាមិនអាចរៀបរាប់បានទេមានច្រើនណាស់។ មនុស្សបែបនេះ ងាយនឹងប្រឈមមុខនឹងគ្រោះថ្នាក់បំផុត។

អកុសលទាំង៣នេះ មានចែងនៅក្នុងអន្ទង់ទាំង៤ គឺ កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និងអវិជ្ជោឃៈ។ ក្នុងអន្ទង់ទី១ គឺពាក្យថា «កាម» និង អន្ទង់ទី៤ ពាក្យថា «អវិជ្ជោឃៈ»។ អន្ទង់នេះមិនជាក្តីប្រាថ្នារបស់ព្រះអរិយបុគ្គលទេ។ សូម្បីបថុជ្ជនក៏ពុំមានប្រាថ្នាដែរ ព្រោះវាជាអន្ទង់ទុក្ខសោកពោកភ័យ។

ព្រះពុទ្ធទ្រង់សម្តែងថា «តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ» ប្រែថា «ការឈ្នះទុក្ខទាំងពួង (ឧបសគ្គទាំងពួង) ដោយការអស់ទៅនៃតណ្ហា»។

នៅក្នុងគាថាធម្មបទ ស្តីពីតណ្ហាវគ្គ(craving)ស្រង់ចេញពីគាថាធម្មបទខ្មែរ បារាំង អង់គ្លេស បោះពុម្ពដោយបរិស័ទ វត្តពោធិវង្ស ប្រទេសបារាំង ព.ស.២៥៥៦ គ.ស.២០១២ ទំព័រ (៣៨៩៤១២) បានចែងក្នុងគាថាទី៣៤០ថា៖

សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ តិដ្ឋតិ

តញ្ច ទិស្វា លតំ ជាតំ មូលំ បញ្ញាយ ឆិន្ទថ។

"ក្រសែ នៃតណ្ហាទាំងឡាយ រមែងជ្រួតជ្រាបចូលទៅ ក្នុងអារម្មណ៍ទាំងពួង តណ្ហាដូចជាវល្លិ៍បែកខ្នែងហើយ រមែងស្ថិតនៅ ក៏អ្នកទាំងឡាយបានឃើញនូវតណ្ហាដូចវល្លិ៍នោះកើតឡើងហើយ ចូរកាត់ផ្តាច់ឫសរបស់វាចោលដោយបញ្ញាចុះ។"

ក្នុងគាថាទី៣៤១៖

សរិតានិ សិនេហិតានិ ច សោមនស្សានិ ភវន្តិ ជន្តុនោ

តេ សាតសិតា សុខេសិនោ តេ វេ ជាតិជរូបគា នរា។

សោមនស្សទាំងឡាយដែលជ្រួតជ្រាបទៅហើយ និងសោមនស្សដែលប្រព្រឹត្តទៅជាមួយនិងតណ្ហាដូចជ័រស្អិត រមែងមានដល់សត្វទាំងនោះ អាស្រ័យសេចក្តីសុខសប្បាយទើបស្វែងរកសេចក្តីសុខ នរជនទាំងនោះ គឺជាអ្នកដែលចូលទៅកាន់ជាតិ និងជរា។

នៅក្នុងគាថាធម្មបទ(ចាប់ពី៣៤១៣៥៩) មានច្រើនទៀត ដែលបង្ហាញអំពីតណ្ហា ទោសៈ និងមោហៈ ចូរអានមើល និងសិក្សាស្វែងយល់ផងចុះតាមការគួរ។ ជនប្រកបដោយមហិច្ឆតា ក្នុងតណ្ហាទាំងឡាយ មិនដឹងអំពីទោសនៃតណ្ហាទេ ព្រោះគេកំពុងឈ្ងក់វង្វេងដោយជាតិផ្អែម ដែលគេបានដាក់នៅចុងអាវុធដ៏មុតថ្លា ប្រកបដោយពិសដ៏សា-ហាវ។ ក្រោយមក គេនឹងដល់សេចក្តីស្លាប់, ពេលនោះ ទើបគេដឹងខ្លួន, ទោះបីដឹងខ្លួន ក៏ឥតប្រយោជន៍ដែរ ។

នៅគ្រប់គាថាទាំងនោះ សុទ្ធតែមានប្រៀបធៀបការបញ្ជាក់អំពីសន្ទុះល្បឿន ការកម្រើកញាប់ញ័រ និងអំណាចនៃតណ្ហា ទោសៈ និងអវិជ្ជាដែលជាគ្រឿងរួបរិតសន្តានចិត្តមនុស្សឱ្យពុះកញ្ជ្រោលក្នុងសន្តានសំណាញ់ចិត្តពុំអាចលះ និងកាត់ផ្តាច់ ដើម្បីចាប់យកកុសលធម៌បានឡើយ។

អកុសលមូលមួយនេះហើយដែលបណ្ដាលឱ្យមនុស្សល្អ ក្លាយជាមនុស្សពាល បាន ព្រោះកាលណាបើទ្វារចិត្តបើកឱ្យអារម្មណ៍ណាមួយចូលក្នុងបសាទៈហើយ សរីរៈ វិញ្ញាណ និងមូលដ្ឋានចិត្តក៏ចាប់ផ្ដើមកគ្រើកឡើង ញាប់ញ័រឡើង ហើយបន្ទាប់មកខួរក្បាល ពោលគឺវិញ្ញាណ ក៏បញ្ជាអាការៈ ឥរិយាបថទាំងកាយវាចាចិត្តឱ្យហ៊ានប្រព្រឹត្ដដើម្បីបានសម្រេចតាមបំណងខ្លួនដោយឥតខ្មាស់អៀនៗ យ៉ាងណាមិញអំពើហិង្សា លើកុមារ ទោះបីជាកើតឡើងក្នុងទម្រង់ណាក៏ដោយ ក៏នឹងអាចកើតមានដោយពុំមានឧបសគ្គណាមកឃាំងឃាំង ឬហាមឃាត់បានឡើយៗ ការកើតឡើងបាននេះដោយហេតុថា អកុសលចិត្តមើលឃើញតែការសប្បាយ ក្នុងចំណង់ ក្នុងវត្ថុ ដែលខ្លួនពេញចិត្តប៉ុណ្ណោះៗ កាលណាគេបានសម្រេចមហិច្ឆតាណាមួយហើយអារម្មណ៍របស់គេរមែងភ្ញើតភ្ញើន ពុះកញ្ជ្រោលពោរពេញដោយបីតិ ក្នុងមច្ឆាជីវៈ ដោយគេពុំខ្វល់និងការឈឺចាប់ការរងគ្រោះ នៃអ្នកដទៃឡើយៗ

អាស្រ័យហេតុនេះ ការទប់ស្កាត់រាល់ការរំលោភបំពានលើកុមារ ត្រូវការយល់ដឹងអំពីហេតុបច្ច័យដ៏អាក្រក់ដែលបណ្ដាលមកពីអកុសលមូលនេះៗ បើយល់ដឹងអំពីហេតុបច្ច័យនៃអកុសលមូលនេះហើយ គប្បីរកវិធីលះបង់តាមរយៈការប្រព្រឹត្តបញ្ចសីល និងបញ្ចធម៌ឡើងវិញនិងធ្វើឱ្យសំវរធម៌កើតឡើងក្នុងការប្រើឥន្ទ្រិយ ឬអាយតនៈចុះបញ្ចាំងទៅលើវត្ថុ ធាតុភូតធម្មជាតិ មនុស្សសត្វទាំងឡាយប្រកបដោយភាពវិជ្ជាមានឡើងវិញផងដែរៗ ការអភិវឌ្ឍចិត្តពីអកុសលមូលមកកាន់កុសលចិត្តវិញនេះ អាចធ្វើឱ្យចិត្តមានការពិចារណាតាមគន្លងនៃសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាសតិ និងសម្មាសមាធិៗ ប្រសិនចិត្តប្រកបដោយមគ្គធម៌ទាំង៨នេះ កើតឡើងប្រាកដមែន អំពើ និងឥរិយាបថផ្នែកអកុសលមូល ពុំអាចកើតឡើងជាថ្មីទៀតឡើយៗ ពេលនោះការទប់ស្កាត់ អំពើហិង្សាលើកុមារ និងទទួលបានដោយស្វ័យប្រវត្តិៗ

ចូរអ្នកទាំងឡាយ លះបង់នូវរាល់អារម្មណ៍ដែលពាក់ព័ន្ធនិងអកុសលមូលឱ្យអស់ ហើយចាប់យកកុសលធម៌មកវិញ ពោលគឺប្រើអារម្មណ៍គិតពីអត្ថប្រយោជន៍ដ៏វែងឆ្ងាយ ពីការរំពឹងទុកដ៏យូរអង្វែង ពីការសង្ឃឹមសម្រាប់អនាគតនៃមនុស្ស នៃសង្គម នៃប្រទេសជាតិរបស់ខ្លួន ព្រោះថា កុមារគឺជាទំពាំងស្នងឫស្សី និងជាសសរទ្រូងនៃប្រទេស បើកុមារល្អ វានឹងក្លាយជាធនធានល្អសម្រាប់យើង។

### ៤.២.៤- ការឆ្លុះបញ្ចាំង និងការឆ្លើយតប

តាមរយៈនៃការបំភ្លឺអំពីគោលធម៌ទាំងឡាយ ដែលទាក់ទងនិងអត្តសម្មាបណិធិ អដ្ឋង្គិកមគ្គ និងអកុសលមូលដើម្បីឆ្លុះបញ្ចាំង និងឆ្លើយតបចំពោះការទប់ស្កាត់ ការរំលោភបំពានហិង្សាលើកុមារនេះ យើងទទួលបាននូវដំណោះស្រាយជាច្រើនដូចតទៅះ

**ដំណោះស្រាយទី១** អភិបាលជនទាំងឡាយរាប់ចាប់តាំងពីមាតាបិតា គ្រូអាចារ្យ មេការ ចៅហ្វាយនាយ រហូតដល់អ្នកដឹកនាំសង្គមគួរតាំងខ្លួន តម្កល់ខ្លួនឱ្យក្លាយទៅជាអ្នកល្អប្រពៃស្របតាមភាពនៃខ្លួនជាមនុស្ស ជាបុព្វការីជនដ៏ល្អប្រពៃក្នុងការញុំាងប្រយោជន៍ល្អៗ ប្រកបដោយវិជ្ជមានដល់បុត្រធីតាកូនចៅ ជាពិសេសចំពោះកុមារកម្ពុជា។

**ដំណោះស្រាយទី២** អភិបាលជនជាអាណាព្យាបាល ដែលទទួលខុសត្រូវលើអ្នកក្រោមឱវាទ ពិសេសកុមារភាពគួរបើកទស្សនៈឱ្យសមស្រប ក្នុងនាមជាអ្នកគ្រប់គ្រងពីលើគេ មិនគួរមើលឃើញអ្វី គិតអ្វី និយាយអ្វី ធ្វើការងារអ្វី ក្នុងផ្លូវខុស ក្នុងផ្លូវមិច្ឆាជីវៈ ថែមទាំងមិនគួរតាំងចិត្តក្នុងផ្លូវអកុសលទៀតផង។ ផ្ទុយទៅវិញ លោកគួរតែមើលឱ្យត្រូវ ពិចារណាគិតគូរឱ្យបានត្រឹមត្រូវមុននឹងអនុវត្តអ្វីនីមួយៗ និងគួរធ្វើអំពើជាគំរូដល់បច្ឆាជនជំនាន់ក្រោយ ដើម្បីទុកជាស្នាមជើងឱ្យគេដើរតាម គ្រាន់ទុកជាមាគ៌ាដ៏ល្អប្រកបដោយសេចក្ដីសុខនិងសុភមង្គលតទៅ។

***ដំណោះស្រាយទី៣*** អភិបាលជនទាំងឡាយគប្បីលះបង់នូវគំនិត គិតតែពីប្រយោជន៍អត្តទត្ថបុគ្គល ដែលជាគំនិតទុទ្ឋិដ្ឋិនិយមប្រកបដោយគ្រោះថ្នាក់សម្រាប់សង្គម និងប្រទេសខ្លួន។ អំពើនៃអ្នកអភិបាលទាំងឡាយគួរសម្លឹងមើលឃើញឱ្យបានទូលំទូលាយ និងឱ្យបានវែងឆ្ងាយជាងនេះ។ គួរលះបង់ធម៌អកុសលចេញ ព្រោះថាពល់សេចក្ដីសុខ សេចក្ដីចម្រើន ពល់សុកមង្គល និងសុខសន្តិភាព ពុំអាចប្រាថ្នាចង់បានតែម្នាក់ឯង គ្រួសារខ្លួន ឬក្រុមបក្សពួកខ្លួនតែម្ខាងបានទេ។ សុខទុក្ខតែងនៅលាយឡំគ្នាជានិច្ច បើយើងបានសុខតែម្នាក់យើង ហើយអ្នកដទៃរងគ្រោះជាងយើង ក្រីក្រជាងយើង ពុំមានលទ្ធភាពដូចយើង នៅជុំវិញយើង តើសន្តិសុខសណ្ដាប់ធ្នាប់មាន ឬអត់? វិបត្តិបញ្ចប់បាន ឬអត់? ការនៅក្បែរគ្នា បើផ្ទះក្បែរខាងឆេះ ឬមានហានិភ័យកើតឡើង យើងកុំគប្បីនៅស្ងៀមហើយគិតថាខ្លួននឹងអាចគេចផុតពីគ្រោះនោះបាន។ ចង់មិនចង់ ភ្លើង ឬហានិភ័យនោះនឹងរីករាលដាលឆ្លងបន្តមកទៀតមិនខានឡើយ។

ដូច្នេះតាមរយៈព្រះធម៌ ដូចបានរៀបរាប់មកខាងលើ អាចចូលរួមរំលែក និងជួយដល់ការទប់ស្កាត់អំពើហិង្សាលើកុមារបាន។ តែតាមរយៈទ្រឹស្ដីផ្នែកព្រះធម៌នេះ ត្រូវមានការចូលរួមសកម្មភាពពីបណ្ដាញមនុស្សដែលមានព្រះសង្ឃ អាចារ្យ ដូនជី តាជី យុវជន យុវនារី និងពុទ្ធបរិស័ទនៅតាមបណ្ដាវត្តអារាម និងតាមពុទ្ធិកមជ្ឈមណ្ឌល ប្រព័ន្ធពុទ្ធិកសិក្សា ក្រសួងធម្មការ និងសាសនា ប្រធានមន្ទីរ ការិយាល័យធម្មការ គ្រប់ស្រុកព្រមទាំងបណ្ដាញនៃក្រសួងពាក់ព័ន្ធទាំងអស់ដូចជា ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ ក្រសួងអប់រំ ។ល។ សហការផងដែរ។ និយាយរួម ពល់សកម្មភាពអប់រំក្ដី ពល់សកម្មភាពហិង្សាលើកុមារក្ដី គឺជាបញ្ហាទាំងអស់គ្នាត្រូវការចូលរួមសហការ ទាំងអស់គ្នាទើបជោគជ័យ។

សរុបសេចក្ដីមក ការប្រកាន់យកព្រះធម៌មកទប់ស្កាត់ក្ដី ការអនុវត្តច្បាប់ស្ដីពីសិទ្ធិនានារបស់មនុស្សក្ដី សិទ្ធិកុមារក្ដី ឬការអនុវត្តច្បាប់ទូទៅក្នុងសង្គមក្ដី សុទ្ធតែជាទស្សន

ទានដ៏ល្អ ផ្ដើមចេញពីថ្នាក់លើ ស្ថាប័នលើរហូតស្ថាប័នក្រោម ចូលរួមសហការជាមួយគ្នា បើមិនដូច្នោះទេចម្លើយទប់ស្កាត់ពិតលើបញ្ហាអ្វីមួយនោះពុំអាចសម្រេចបានឡើយ។

"យើងត្រូវចូលរួមទាំងអស់គ្នា ដើម្បីអានាគតប្រទេសទាំងអស់គ្នា"។

**៤.៣- ការចូលរួមរបស់សាមណេរ និងយុវជន**

ការចូលរួមរបស់សាមណេរ និងយុវជន ប្រាកដជាមានសារៈសំខាន់បំផុត ព្រោះសមាសជាតុទាំងពីរនេះ មានអន្តរកម្មទាក់ទងគ្នាទាំងក្នុងបរិបទវត្តអារាម និង បរិបទ សង្គម។ ជាតុទាំងពីរនេះ បានឆ្លងកាត់ពីវ័យកុមារភាពដូចគ្នា ហើយពួកគេ ក៏ធ្លាប់បានទទួលស្គាល់អំពីរសជាតិជីវិតពិត ដែលកើតមានក្នុងបឋមវ័យផងដែរ។ វ័យកុមារ និងវ័យយុវជននៅជិតគ្នាណាស់ ភាពចងចាំមិនអាចបំភ្លេចបានទេ ម្ល៉ោះហើយ គេនឹងបានទទួលយកបទពិសោធន៍ និងភាពចងចាំនៅថ្មីៗជាងវ័យណាៗទាំងអស់។

នៅក្នុងសង្គមខ្មែរ មជ្ឈដ្ឋានវត្តអារាម ឬមជ្ឈមណ្ឌលពុទ្ធសាសនាតែងនៅជាមួយគ្នាទាំងកាយវាចា និងចិត្ត យ៉ាងណាមិញសាមណេរក្ដី យុវជនក្ដី ថ្វីត្បិតតែមានមជ្ឈដ្ឋានខុសគ្នា តែមានចំណងជិតស្និទ្ធិគ្នាផងដែរ។ រាល់ទង្វើរបស់សាមណេរ និងយុវជន ក៏តែងមានទំនាក់ទំនងគ្នាក្នុងសង្គម។

តើសាមណេរ និងយុវជនបានចូលរួមបញ្ចប់ឥរិយាបថប្រកបដោយហានិភ័យទៅលើអំពើហិង្សាលើកុមារដូចម្ដេចខ្លះ?

***អំពើសាមណេរ៖*** សាមណេរបានចូលរួមប្រាស្រ័យក្នុងជីវភាពជាបព្វជិត ច្រើនជាង យុវជន ម្ល៉ោះហើយគេទទួលបានការអប់រំបែបសីលវិន័យធម៌ ឥរិយាបថ ច្រើនជាងយុវជន។ សាមណេរនៅវត្ត មានឥរិយាបថរស់ក្នុងការសង្រួមបែបអភិសមាចារ មានចរិតចរិយាប្រសើរក្នុងវិន័យ សិក្ខាបទតាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាតច្រើន។ ស្ថិតក្នុងវ័យភាពនៃភេទ

នេះ សាមណេរមានទិដ្ឋភាពក្នុងជីវភាព២គឺ ទិដ្ឋភាពមុនមកបួស និងទិដ្ឋភាពក្រោយពេលក្លាយជាភេទសាមណេរ។ តាមរយៈការធ្វើទិដ្ឋភាពទាំង២នេះ គេកាន់តែមានបទពិសោធន៍ច្រើន ក្នុងការបកស្រាយបង្ហាញអំពីភាពរស់នៅរបស់គេ ព្រមទាំងការស្គាល់រសជាតិជីវិតនៃកុមារច្រើនផងដែរ។ ទិដ្ឋភាពមិនភេទជាសាមណេរ លោកបានដឹងអំពីជីវិតកុមារ ក្នុងភាពកុមាររបស់ខ្លួន និងមិត្តភក្តិជាដៃគូរ កាលពីនៅកុមារដូចគ្នា។ ពេលនោះ អារម្មណ៍សាមណេរអាចមើលឃើញទិដ្ឋភាពនៃជីវិត កុមារភាគច្រើនស្ថិតនៅក្នុងភាពខុសពីភាពអ្នកបួស ដូច្នេះលទ្ធផលនោះគឺជាទុន ជាសារដ៏មានសារៈសំខាន់សម្រាប់ការចូលរួមមួយភាគធំ ក្នុងការបញ្ចប់ហានិភ័យទាំងនោះ។

***ភាពជាសាមណេរ៖*** គេនឹងទទួលបាននូវទិដ្ឋភាពថ្មីមួយទៀត ពោលគឺតាមរយៈវត្តអារាម តាមរយៈព្រះធម៌នឹងមានអ្វីកើតឡើងប្លែកពីមុន។ អ្វីដែលគេទទួលបាននោះ គឺការកែប្រែជីវិត តាមការរស់នៅបែបថ្មី ដែលមានគំរូពុទ្ធសាសនាមានតម្លៃវត្តជាតម្លៃ អ្នកបួសដែលមានក្រមសីលធម៌ក្នុងឥរិយាបថដេក ដើរ ឈរ អង្គុយមានភាពខុសគ្នាស្រឡះ។ ទិដ្ឋភាពថ្មីនេះអាចឆ្លុះបញ្ចាំងលើទិដ្ឋភាពចាស់ និងបានទទួលចម្លើយថ្មីមួយទៀត គឺខ្លួនរបស់គេ ជីវិតរបស់គេបានទទួលការអភិវឌ្ឍថ្មីល្អប្រសើរ ហើយគេបានរួចផុតពីបញ្ហានានាក្នុងសង្គម។ គេហាក់មានសិទ្ធិសេរីភាព និងមានការគោរពបូជាពីអ្នកដទៃ។ ចំពោះបញ្ហាសេដ្ឋកិច្ច ការអប់រំ ការស្នាក់នៅ និងការរងផលប៉ះពាល់ពីអំពើហិង្សានានា ហាក់ដូចជាធូរស្រាលឡើងវិញ។ ពិសេស គេមានឱកាសផ្តល់គំរូល្អៗ និងចូលរួមសេវាកម្មក្នុងពុទ្ធសាសនា និងក្នុងមហាជន ឬសង្គមបានច្រើនជាង។ ដើម្បីក្លាយជាអ្នកអប់រំបន្តដល់គេបាន សាមណេរ និងយុវជនត្រូវយល់ដឹងពីការវិវឌ្ឍ និងឥរិយាបថ របស់វ័យជំទង់ និងយុវជន។

## ៤.៣.១- ឥរិយាបថប្រកបដោយហានិភ័យរបស់វ័យជំទង់ ( Adolescence )

ច្បាប់បានកំណត់អាយុកុមារក្រោម១៨ឆ្នាំ។ ប៉ុន្តែការស្រាវជ្រាវថ្មីបានចែកក្រុមមនុស្សមួយក្រុមទៀត ហៅថា ក្រុមមនុស្សវ័យជំទង់ ដែលមានអាយុពី១០ឆ្នាំ ដល់ ១៩ ឆ្នាំ។ ការបែងចែកនេះ ដោយសារវ័យនេះ ជាវ័យទីពីរនៃជីវិតមនុស្ស ដែលជាវ័យមានការប្រែប្រួលយ៉ាងខ្លាំងរបស់កុមារ ជាវ័យស្ពានឆ្លងពីវ័យកុមារទៅជាមនុស្សពេញវ័យ។ ក្នុងវ័យនេះ មានការប្រែប្រួលរាងកាយ ការវិវឌ្ឍចនាសម្ព័ន្ធខួរក្បាល ការគិតជាដើម។ វ័យជំទង់ពោរពេញទៅដោយការប្រែប្រួល និងជួបប្រទះបញ្ហាប្រឈមជាច្រើន ប៉ុន្តែក៏មានការអភិវឌ្ឍ និងឱកាសផងដែរ។ ក្នុងវ័យនេះ ពួកគេងាយទទួលរងឥរិយាបថ ដែលមានហានិភ័យខ្ពស់។ ក្រុមយុវជន (អាយុពី១៥ ដល់ ២៤ឆ្នាំ) ក៏ជាក្រុមដែលការចាប់ផ្ដើមឈានចូលប្រឡូកក្នុងសង្គម ដែលមិនមានបទពិសោធន៍ជីវិត។ ឪពុកម្ដាយ និងមនុស្សពេញវ័យពាក់ព័ន្ធផ្សេងទៀត ចាំបាច់ត្រូវដឹងពីឥរិយាបថ និងកត្តាហានិភ័យទាំងនេះ។

យើងដឹងហើយយុវជនក៏ជាវ័យមួយ ដែលបានឆ្លងកាត់ដូចសាមណេរ កាលដែលមិនទាន់បានមកបួសជាសាមណេរដែរ។ គេបានទទួលនូវរសជាតិប្រៃល្វីងជូរចត់ ល្អអាក្រក់ដូចសាមណេរដែរ តែនៅពេលគេបានឈានចូលមកដល់វ័យជំទង់ និងយុវវ័យវិញ គេក៏បានទទួលនូវការប្រែប្រួលផ្នែកកាយសម្បទា គំនិតប្រាជ្ញា ចំណេះដឹង ឥរិយាបថ ការប្រាថ្នា ចំណង់ចំណូលចិត្តបែបថ្មីដូចគ្នា។ ពេលនេះ វ័យយុវជនមានព្រឹត្តិការណ៍ថ្មីៗជាច្រើនកើតឡើង ដែលខុសប្លែកពីវ័យកុមារ។ សញ្ញាណដែលគួរឱ្យគត់សម្គាល់នោះគឺ ចំណង់ថ្មី ភាពក្លាហានថ្មីៗ ភាពចង់ដឹងអ្វីៗដែលមិនទាន់បានជួបប្រទះ ភាពម្ចាស់ការ ភាពចង់ទទួលខុសត្រូវដោយខ្លួនឯង ភាពមានៈ ទិដ្ឋិ ក៏កើតឡើងទៀត ផង។ ទន្ទឹមនឹងវ័យយុវភាព គេក៏ត្រូវមានការប្រឈមនឹងបញ្ហាច្រើនជាងមុន ព្រោះវ័យគេចង់គិត ចង់ធ្វើ ចង់ដឹង នូវអ្វីដែលគេចង់ធ្វើ ម៉្លោះហើយអាចជួបនឹងការប្រឈម និងគ្រោះសារ ទំនៀមទម្លាប់ ឈានដល់ហ៊ានជំទាស់ជាមួយច្បាប់នៅពេលណាដែលគេហៅថា ការប្រឈមទាំងនោះ មិនបម្រើឱ្យផលប្រយោជន៍របស់គេ។ ហេតុនេះហើយបានជាគេតែងនិយាយថា វ័យយុវ

ជនប្រៀបដូចជា "ដំរីចុះប្រេង" "វ័យឈាមពរ" ឬ "វ័យមិនខ្លាចស្លាប់"...។ ការនិយាយ បែបនេះមិនសំដៅទៅលើយុវជនគ្រប់រូបទេ។ មានយុវជនភាគច្រើន ដែលទទួលបានពីការអប់រំល្អរបស់ម៉ែឪ អំពីសាលា អំពីអង្គភាព សហគមន៍ ឬសង្គមល្អ ពួកគេក៏មានគុណសម្បត្តិល្អៗរហូតក្លាយទៅជាសសរទ្រូងរបស់ប្រទេស ចេះស្នេហាជាតិ ហ៊ានលះបង់ជីវិតបម្រើមាតុប្រទេសជាតិ។ យុវជនបច្ចុប្បន្ន ក្រោយពីបានសិក្សារៀនសូត្រ គេបានស្គាល់ពីផ្លូវជីវិតល្អៗ គេចេះទាញគោលដៅជីវិត គេបានតម្រង់ឧត្តមគតិរបស់គេគិតពីខ្លួនគេ គ្រួសារគេ និងឈានដល់លះបង់ពេលវេលា ពលកម្ម អាយុជីវិតដើម្បីបុព្វហេតុជាតិទៀតផង។

ចំពោះឥរិយាបថប្រកបដោយហានិភ័យ គឺជាឥរិយាបថដែលមានផលប៉ះពាល់ជាអវិជ្ជមានមកលើការអភិវឌ្ឍ និងសុខុមាលភាពជារួមរបស់យុវជន ឬដែលអាចរារាំងពួកគេមិនឱ្យសម្រេចបានជោគជ័យ និងការអភិវឌ្ឍនាពេលអនាគត។ ឥរិយាបថទាំងនេះរួមមាន ឥរិយាបថដែលអាចនាំឱ្យមានការរងរបួសស្នាមភ្លាមៗ (ឧ. ការវាយតប់គ្នា) និងឥរិយាបថដែលមានផលប៉ះពាល់អវិជ្ជមានកើនឡើងបន្តិចម្តងៗ (ឧ. ការប្រើសារធាតុញៀនជាដើម)។ ឥរិយាបថប្រកបដោយហានិភ័យ ក៏អាចមានផលប៉ះពាល់ដល់ក្មេងជំទង់តាមបែបផ្សេងផងដែរដូចជា បន្ថយបង្អាក់ការអភិវឌ្ឍធម្មតារបស់ពួកគេ ឬរារាំងពួកគេមិនឱ្យទទួលបានបទពិសោធន៍ធម្មតា សម្រាប់ក្រុមអាយុរបស់ពួកគេ។ ឧទាហរណ៍ក្មេងជំទង់ដែលមានផ្ទៃពោះ អាចមិនបានចូលរួមក្នុងព្រឹត្តិការណ៍ធម្មតាៗសម្រាប់ក្មេងជំទង់ដូចជាការបញ្ចប់ការសិក្សាពីសាលារៀន ឬមិនអាចមានមិត្តជិតស្និទ្ធ ជាដើម។

ការបង្ហាញខាងលើនេះ យើងអាចទាញភាពជាសាមណេរ និងភាពជាយុវជន មកចូលរួមគ្នាដើម្បីបញ្ចប់ភាពហានិភ័យដែលកើតឡើងពីការរំលោភបំពាន និងហិង្សា លើកុមារប្រកបដោយប្រសិទ្ធភាពជាកិច្ចការ។ ពិសេសការសន្ទនារវាងសាមណេរ និងយុវជន ឬការផ្តោតអារម្មណ៍លើការចូលរួមពីសាមណេរ និងយុវជនពិតជាគំហើញថ្មីដែលមិនអាចមើលរំលងបាន។

### ៤.៣.២- ផលប៉ះពាល់នៃអំពើហិង្សាលើសុខភាព

យោងលើការស្រាវជ្រាវអំពីផលវិបាកផ្នែកសុខភាព នៃអំពើហិង្សាលើកុមារ ឆ្នាំ ២០១៣[16] បានបង្ហាញឱ្យឃើញថា៖

**អំពើហិង្សាផ្លូវកាយលើកុមារកាលពីកុមារភាព**

- **ចំពោះកុមារា៖** មាន ២៤.១ ភាគរយ បានជក់បារី, ១៣.៦ ភាគរយ បានទទួលទានគ្រឿងស្រវឹងនិងបង្កបញ្ហា, និង ៤៩.៧ ភាគរយមានរបួសស្នាមក្នុងកម្រិតមធ្យម ក្រោយពេលកើតមានអំពើហិង្សាអន្តរបុគ្គល ដែលទាំងនេះគឺបណ្តា-លមកពីអំពើហិង្សាផ្លូវកាយកាលពីកុមារភាព។
- **ចំពោះកុមារី៖** មាន ៣៧ ភាគរយបានបង្កគ្រោះថ្នាក់ដល់ខ្លួនឯង, ៣២.៩ភាគរយបានឆ្លងជំងឺកាមរោគ, ១១.៧ភាគរយមានវិបត្តិផ្លូវចិត្ត, ១០.៤ភាគរយបានទទួលទានគ្រឿងស្រវឹងនិងបង្កបញ្ហា, ៣៣.៧ភាគរយបានប្រព្រឹត្តអំពើហិង្សារវាងដៃគូរស្និទ្ធស្នាល, និង ៤៨.២ភាគរយមានរបួសស្នាមកម្រិតមធ្យម ក្រោយពេលបង្កហិង្សាអន្តរបុគ្គល ដែលទាំងនេះបណ្តាលមកពីអំពើហិង្សាផ្លូវកាយកាលពីកុមារភាព។

**អំពើហិង្សាផ្លូវចិត្តលើកុមារកាលពីកុមារភាព**

- អំពើហិង្សាផ្លូវចិត្តកាលពីកុមារបានរួមចំណែក ៣២.៦ភាគរយនៃការបង្កគ្រោះថ្នាក់ដល់ខ្លួនឯងចំពោះកុមារី និង ១៣.៦ភាគរយចំពោះកុមារ។
- ការឆ្លងជំងឺកាមរោគ១២.៣ភាគរយ គឺបណ្តាលមកពីអំពើផ្លូវចិត្ត កាលពីកុមារភាពចំពោះស្ត្រី។
- វិបត្តិផ្លូវចិត្ត ១២.៧ ភាគរយ គឺបណ្តាលមកពីអំពើហិង្សាផ្លូវចិត្តកាលពីកុមារភាពចំពោះស្ត្រី ដោយឡែកចំពោះបុរសវាមានរហូតដល់ ២៦.៤ ភាគរយ ។

---

[16] ក្រសួងកិច្ចការនារី៖ បន្ទុកសេដ្ឋកិច្ចចំពោះផលវិបាកផ្នែកសុខភាពនៃអំពើហិង្សាលើកុមារ ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥

- ការប្រព្រឹត្តហិង្សារវាងដៃគូស្និទ្ធស្នាលមាន ១៤.៤ភាគរយ ចំពោះស្ត្រី និងមាន ២១.៥ភាគរយ ចំពោះបុរសគឺបណ្តាលមកពីអំពើហិង្សាផ្លូវចិត្តកាលពីកុមារភាព។
- ស្ត្រី ២៩.៣ ភាគរយ និងបុរស ២៦.៦ភាគរយ បានទទួលរងរបួសស្នាមកម្រិតមធ្យម ក្រោយពេលប្រព្រឹត្តហិង្សាអន្តរបុគ្គល គឺបណ្តាលមកពីអំពើហិង្សាផ្លូវចិត្តកាលពីកុមារភាព។

**អំពើហិង្សាផ្លូវភេទលើកុមារកាលពីកុមារភាព**

- ចំពោះស្ត្រីអំពើរំលោភបំពានផ្លូវភេទ កាលពីកុមារភាព បានរួមចំណែក ៥.០ ភាគរយនៃការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ១.៦ ភាគរយនៃការឆ្លងជំងឺកាមរោគ ១.៥ ភាគរយនៃវិបត្តិផ្លូវចិត្ត និង១១.៥ ភាគរយនៃការប្រព្រឹត្តអំពើហិង្សារវាងដៃគូស្និទ្ធស្នាល។
- ចំពោះបុរស អំពើហិង្សាបំពានផ្លូវភេទកាលពីកុមារភាព បានរួមចំណែក ៨.២ ភាគរយចំពោះការបង្កឱ្យមានគ្រោះថ្នាក់ដល់ខ្លួន និង ៩.៥ភាគរយ ចំពោះការឆ្លងជំងឺកាមរោគ។

**៤.៣.៣- ឥរិយាបថប្រកបដោយហានិភ័យ**

ការប្រឈមមុខប្រកបដោយហានិភ័យ ទាក់ទងដល់ឥរិយាបថផ្សេងៗរបស់កុមារ គឺជាមហាភ័យមួយ ដែលសង្គមទាំងមូល មនុស្សទាំងឡាយក្នុងសង្គម គប្បីចូលរួមព្រួយ និងមានវិធានការណ៍ទប់ស្កាត់ទាំងអស់គ្នា។ យើងទាំងអស់គ្នាត្រូវទទួលស្គាល់ថា ផលទាំងឡាយមានហេតុជាបច្ច័យកើតឡើង ហើយបច្ច័យដែលនាំឱ្យមានគ្រោះថ្នាក់ទាំងនោះមានច្រើនយ៉ាង ហេតុខ្លះកើតឡើងដោយចៃដន្យ ហេតុខ្លះកើតឡើងដោយធម្មជាតិ ហេតុខ្លះកើតឡើងដោយមនុស្ស និងសង្គមវប្បធម៌របស់មនុស្ស ហើយជាពិសេស គឺកត្តាខ្លួនឯងតែម្តងក៏មាន។ ឥរិយាបថប្រកបដោយហានិភ័យជាច្រើន ដែលអ្នកជំនាញមានការចាប់អារម្មណ៍ ជាពិសេស នៅពេលដែលឥរិយាបថទាំងនេះ កើតមានឡើងក្នុងកម្រិតមួយខ្ពស់ក្នុងចំណោមក្មេងជំទង់ និងយុវជន។ ឥរិយាបថជាច្រើន ក្នុងចំណោមឥរិយាបថទាំងនេះ នាំឱ្យក្មេងជំទង់ជាច្រើននាក់ស្លាប់ និងរងរបួស និងមានផលប៉ះពាល់ជា

អវិជ្ជមានមកលើសង្គមទាំងមូល។  តាមការស្រាវជ្រាវពីឥរិយាបថប្រកបដោយហានិភ័យ ជាងគេរបស់ក្រុមមនុស្សវ័យក្មេង គេកត់សំគាល់លើឥរិយាបថ៣គឺ៖

- ឥរិយាបថ ពាក់ព័ន្ធនិងការប្រើប្រាស់ជាតិស្រវឹង
- ឥរិយាបថ ពាក់ព័ន្ធនិងការប្រើប្រាស់គ្រឿងញៀន
- ឥរិយាបថផ្លូវភេទ

## ក- ឥរិយាបថពាក់ព័ន្ធនឹងការប្រើប្រាស់ជាតិស្រវឹង

ក្មេងស្រីជំទង់ ៧០% និងក្មេងប្រុសជំទង់ ៩១% ប្រើជាតិស្រវឹង។ មូលហេតុចម្បងមាន៖

- ការជួបជុំមិត្តភក្តិក្នុងកម្មវិធីនានា
- ការហូបដើម្បីបំបាត់ភាពតានតឹង ឬស្មុគស្មាញក្នុងការងារ
- ការហូបចុកអាចធ្វើឱ្យគេមានអំនួត និងមានមោទនភាព
- ការប្រើជាតិស្រវឹងក្នុងក្របខ័ណ្ឌការងារ សាលា ទំនាក់ទំនងនានា
- ការប្រើថ្នាំខ្មែរ ឱសថបុរាណប្រើដោយសុរាច្រើនពេក។

## ខ- ឥរិយាបថពាក់ព័ន្ធនិងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

មានក្មេងស្រីជំទង់  ៣.៥%  និងក្មេងប្រុសជំទង់  ១៥.២%  ធ្លាប់ប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ មូលហេតុចម្បងមាន៖

- សម្ពាធមិត្តភក្តិ
- លក្ខខណ្ឌការងារលំបាក
- ការបម្រើចំណង់ដើម្បីសប្បាយ និងដោះស្រាយភាពតានតឹង
- ការដោះស្រាយការលំបាកជាមួយគ្រួសារ សង្គម ដោយកំហុសផ្សេងៗ

មានផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនដូចជា ការខូចសរសៃខួរក្បាល សរីរាង្គ ការបង្កទំនាស់តាមរយៈឥរិយាបថខុសឆ្គង ការបង្កនាំឱ្យមានភាពងាយស្រួល បម្រើសេវាផ្លូវភេទ រួមទាំងធ្វើឱ្យមានភាពអនាធិបតេយ្យ អសន្តិសុខសង្គម។

គ- ឥរិយាបថផ្លូវភេទ

ការស្រាវជ្រាវថ្នាក់ជាតិអំពីប្រេវ៉ាឡង់ នៃអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ ២០១៣[17] បានបង្ហាញឱ្យឃើញថា៖

- អ្នកមានអាយុ ១៥ ដល់ ២៤ឆ្នាំ មានស្រីវ័យក្មេង១នាក់ ក្នុងចំណោម១០នាក់ និង បុរសវ័យក្មេងជិត២នាក់ ក្នុងចំណោម១០នាក់ ពុំបានប្រើស្រោមអនាម័យ។
- ប្រេវ៉ាឡង់ ការមានដៃគូរួមភេទច្រើននាក់ ក្នុងរយៈពេល១២ខែចុងក្រោយ មានកម្រិតខ្ពស់ ក្នុងចំណោមក្មេងយុវវ័យអាយុពី១៩ ដល់ ២៤ឆ្នាំ ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ កាលនៅកុមារ(១៥.៤%) បើធៀបជាមួយបុរសវ័យក្មេង ដែលរាយការណ៍ថា មិនធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ មុនអាយុ១៨ឆ្នាំ (៣.០%)។
- បុរសវ័យក្មេងកម្ពុជាអាយុ ១៨ ដល់២៤ឆ្នាំ ដែលបានរាយការណ៍ថា មិនធ្លាប់ធ្វើតេស្តរកមេរោគអេដស៍ឡើយ មានភាគរយច្រើន (៧៨.២%) ជាស្ត្រីវ័យក្មេង (៦២.៦%)។

### ៤.៣.៤- តើសាមណេរ និងក្មេងជំទង់អាចធ្វើអ្វីខ្លះ?

សាមណេរ និងក្មេងជំទង់អាចចូលរួមចំណែកជាច្រើនដើម្បីកាត់បន្ថយអំពើហិង្សា និងឥរិយាបថប្រកបដោយហានិភ័យរបស់វ័យជំទង់ទាំងឡាយ។ មេរៀននេះ មានធ្វើការបកស្រាយនៅដើមជំពូកក្នុងមេរៀនរួចហើយ តែដើម្បីឈានដល់ឱកាសដែលសាមណេរ

[17] ក្រសួងកិច្ចការនារី៖ របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាឆ្នាំ២០១៣

និងយុវជនអាចចូលរួមដើម្បីកាត់បន្ថយអំពើហិង្សាកាន់តែមានប្រសិទ្ធភាពចំណុចខាងក្រោមនឹងបំភ្លឺបន្ថែមទៀត៖

- ការអប់រំកុមារ និងដឹកនាំយុវជនឱ្យយល់ពីផលលំបាក និងផលប៉ះពាល់នៃអំពើហិង្សា និងឥរិយាបថប្រកបដោយហានិភ័យ តាមរយៈសកម្មភាពការការពារ និងការទប់ស្កាត់គ្រប់ទម្រង់លើកុមារ។
- អប់រំគេក្នុងវ័យកុមារឱ្យមានការស្រឡាញ់ ក្នុងការធ្វើជាគំរូល្អ សិស្សល្អ កូនល្អ មិត្តល្អ និងប្រជាពលរដ្ឋដ៏ល្អ។
- ការផ្តល់ឱ្យពួកគេជួយចូលរួមក្នុងសកម្មភាពនានាតាមរយៈផ្តល់ព័ត៌មាន ឬធ្វើរបាយការណ៍បញ្ជូនដល់ក្រសួងភ្នាក់ងារមានសមត្ថកិច្ចដូចជា អាជ្ញាធរដែនដីមានភូមិ ឃុំ ឬអង្គការនានា។
- ព្រះសង្ឃ សាមណេរអាចមានឱកាសច្រើន ដើម្បីចូលរួមក្នុងការអប់រំ ដើម្បីបញ្ឈប់ការរើសអើង ការប្រកាន់បងធំអាចជួយឱ្យពួកកុមារ ឬអាណាព្យាបាល នាំគ្នាធ្វើអំពើកុសលធម៌ ការបំពេញតួនាទីបែបវិជ្ជមានដើម្បីបញ្ចប់ការបំភ័យ ការបន្ទាច ការគំរាម ការធ្វើទារុណកម្ម ការជេរ ការប្រមាថគ្រប់បែបយ៉ាង នាំឱ្យខាតប្រយោជន៍ដល់កុមារ ពិសេសជួយញ៉ាំងចិត្តកុមារឱ្យចេះស្រឡាញ់គ្នា ហ៊ានប្រព្រឹត្តតាមសីល៥/ បញ្ចសីលយ៉ាងហោចណាស់។

**៤.៤- សង្ខេបមេរៀន**

ពុទ្ធសាសនាជាសាសនាធំមួយ ក្នុងចំណោមបណ្តាសាសនាទាំង៥ក្នុងលោក។ ពុទ្ធសាសនាជាពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញដ៏ឆ្នើមក្នុងលោក ដែលមានគតិបណ្ឌិត និងមនសិការជ្រាលជ្រៅ និងមានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយនីត្យានុកូលភាព ព្រមទាំងមានច្បាប់គ្រប់គ្រាន់ មានតួនាទីគ្រប់គ្រងក្នុងការគ្រប់គ្រងពុទ្ធមណ្ឌលរបស់ ខ្លួន។ ព្រះពុទ្ធសាសនាមានទ្រឹស្តីអប់រំទាក់ទងនឹងកុមារ ឬមនុស្សជាច្រើនព្រោះ ព្រះពុទ្ធ

សាសនា ឱ្យតម្លៃមនុស្ស ជីវិតមនុស្ស ច្រើនជាងជំនឿលើការឱ្យតម្លៃក្រៅពីមនុស្សដូចជា ទេវៈ អាទិទេព ឬទេវតាជាដើម។

ដោយការគោរពស្រឡាញ់ និងការឱ្យតម្លៃមនុស្ស ព្រះពុទ្ធបានឱ្យអាណាព្យាបាល (បុព្វការី) ចិញ្ចឹមថែរក្សា និងការពារកូនប្រកបដោយសង្គហធម៌ ទសពិធរាជធម៌ ឬព្រហ្មវិហារធម៌។ នៅគ្រប់ទម្រង់នៃការជឿខុស ហើយមកប្រព្រឹត្តលើកុមារ ឬមនុស្ស ចាត់ទុកថាជាការរំលោភបំពានលើកុមារ ឬមនុស្ស ទោះដោយចេតនាក្តី អចេតនាក្តី។

អាណាព្យាបាលទាំងឡាយគួរធ្វើខ្លួនឱ្យបានល្អ កុំធ្វើខុស និយាយខុស ព្យាយាមខុសតទៅទៀត បើមិនដូច្នោះអាណាព្យាបាល នឹងប្រឈមចំពោះអនាគតកូន និងចំពោះមុខច្បាប់នានាដោយខ្លួនឯង។

**៤.៥- សំណួរត្រិះរិះ**

១. តើអ្នកបានយល់អ្វីខ្លះ អំពីពាក្យថា "ពុទ្ធសាសនា"?

២. តើការឆ្លើយតបតាមរយៈពុទ្ធសាសនា ចំពោះអំពើហិង្សាលើកុមារមានអ្វីខ្លះ? ចូរបង្ហាញ។

៣. ដើម្បីក្លាយជាអ្នកអប់រំបន្តដល់វ័យជំទង់ និងយុវជន តើសាមណេរ ត្រូវយល់ដឹងអ្វីខ្លះពីវ័យជំទង់ និងយុវជន? ចូររៀបរាប់។

៤. តើសាមណេរ និងយុវជនអាចចូលរួមបញ្ចប់ឥរិយាបថប្រកបដោយហានិភ័យទៅលើអំពើហិង្សាលើកុមារដូចម្តេចខ្លះ?

# ជំពូក៥៖ វិធីសាស្ត្រផ្សព្វផ្សាយ

## គោលបំណង

*ក្រោយពីសិក្សាជំពូកនេះ សមណនិស្សិត និស្សិតនឹងទទួលបាន៖*

- *ការយល់ដឹងអំពីវិធីសាស្ត្រ នៃការផ្សព្វផ្សាយទប់ស្កាត់អំពើហិង្សាលើកុមារ*
- *ការយល់ដឹងពីសារៈសំខាន់របស់វត្តអារាម ចំពោះការចូលរួមចំណែកទប់ស្កាត់អំពើហិង្សាលើកុមារ*

## សេចក្តីផ្តើម

*ផ្នែកនេះបង្ហាញពីវិធីនានាដែលព្រះពុទ្ធសាសនា និងព្រះសង្ឃអាចទាញយក ឱកាសពីតួនាទី និងមុខងារមានស្រាប់របស់ព្រះអង្គ ដើម្បីចូលរួមចំណែកយ៉ាងច្រើន ដល់ការទប់ស្កាត់ និងឆ្លើយតបទៅអំពើហិង្សាលើកុមារ និងផលប៉ះពាល់នៃការរក្សាកុមារ ក្នុងមណ្ឌល។ កិច្ចពិភាក្សានឹងលើកឡើងពីវិធានការមួយចំនួន ដែលព្រះសង្ឃអាចធ្វើបាន នៅតាមសហគមន៍ចំណុះជើងវត្ត។ ការធ្វើជាគំរូ ឬការចាប់ផ្តើមពីព្រះសង្ឃអង្គឯង ផ្ទាល់ ការយល់ពីការវិវឌ្ឍរបស់កុមារ និងផលប៉ះពាល់នានាលើការអភិវឌ្ឍរបស់កុមារ ជាចំណុចនៃការចាំផ្តើម ដើម្បីឈានទៅរកការអប់រំកែប្រែឥរិយាបថសង្គមដែល បណ្តាលឱ្យមានអំពើហិង្សាលើកុមារ។*

## ៥.១- វិធីសាស្ត្រផ្សព្វផ្សាយ

*ការអភិវឌ្ឍមានវិធីសាស្ត្រជាច្រើនដែលសមណនិស្សិត និស្សិត អាចចូលរួម តាមបែបសាមញ្ញ និងជាប្រចាំផងដែរ តាមរយៈសកម្មភាពប្រចាំថ្ងៃ។ ការបញ្ជ្រាបគំនិត ឬមនោគមវិជ្ជាអ្វីមួយ សំខាន់គឺត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មហាជនទូទៅ ដើម្បីបានយល់ និងត្រូវភ្ជាប់មកជាមួយដោយខានពុំបាននូវអត្ថប្រយោជន៍អ្នកដែលទទួលព័ត៌មាននិងមនុស្សដែលពាក់ព័ន្ធត្រូវទទួលបាន។ ដោយសៀវភៅនេះ សម្រាប់សមណនិស្សិត និស្សិត ដូច្នេះអ្នកដែលពាក់ព័ន្ធសំខាន់បំផុតក្នុងការផ្សព្វផ្សាយគឺសមណនិស្សិត និស្សិត ខ្លួនឯងត្រូវសិក្សាស្វែងយល់អំពីទ្រឹស្តីទាំងនេះ និងស្រាវជ្រាវពលឯកសារដែលទាក់ទងនឹងអំពើហិង្សាលើកុមារដទៃទៀត ដើម្បីសិក្សាឱ្យកាន់តែយល់*

ច្បាស់ថែមទៀត។ ជាមួយគ្នានេះ ការសិក្សាស្វែងយល់ពីមេរៀនខាងដើម និងចិត្តសាស្ត្រកុមារ ដែលមានចែងនៅក្នុងជំពូក ៣ (ចំណុច ៣.២.៣- ចិត្តវិទ្យាកុមារ) នឹងជួយឱ្យការចូលរួមរបស់ព្រះសង្ឃកាន់តែមានប្រសិទ្ធភាព។

**តើព្រះសង្ឃ និងវត្តអាចចូលរួមធ្វើអ្វីបានខ្លះ?**

### ៩.១.១- ការលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារ

ឪពុកម្តាយគ្រប់រូបអាចចិញ្ចឹមកូនរបស់ពួកគាត់បាន ប៉ុន្តែមានពេលខ្លះគាត់ត្រូវពុះពារខ្លាំងណាស់ ពីព្រោះតែខ្វះចំណេះដឹង ខ្វះធនធាន ឬតានតឹងក្នុងអារម្មណ៍ ការចិញ្ចឹមកូនមិនមែនជាការងាយស្រួលនោះទេ។ ឋានៈទាបរបស់កុមារ និងជំនឿដែលថាឪពុកម្តាយគឺជាម្ចាស់នៃកូនរបស់គេ និងគេមានសិទ្ធិធ្វើអ្វីៗលើពួកគេ ឱ្យតែគេជឿថាល្អ គឺកាន់តែបង្កើននូវអំពើហិង្សា។ ត្រូវលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិដែលកុមារមាន។

### ៩.១.២- ធម្មទេសនា ពីទម្រង់នៃអហិង្សាធម៌ក្នុងការប្រៀនប្រដៅ និងអប់រំកុមារ

ឪពុកម្តាយនិងគ្រួសារ មានការលំបាកក្នុងការផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់ ប្រសិនបើទម្លាប់ និងអាកប្បកិរិយាដែលមាននៅក្នុងសហគមន៍របស់គេ នៅតែមិនផ្លាស់ប្តូរ។ ព្រះសង្ឃគឺជាឧត្តមភេទដែលទទួលបានការគោរពយ៉ាងល្អ នៅក្នុងសហគមន៍របស់គេ ព្រះសង្ឃមានលទ្ធភាពក្នុងការជះឥទ្ធិពលកែប្រែអាកប្បកិរិយារបស់មនុស្សម្នាក់ៗ និងទម្លាប់សង្គម រួមបញ្ចូលទាំងកែប្រែទម្លាប់ និងអាកប្បកិរិយាដើម្បីថ្កោលទោសចំពោះអំពើហិង្សាលើកុមារ។

អ្នកស្តាប់ធម្មទេសនា គឺមានការយកចិត្តទុកដាក់ស្តាប់ជាងការស្តាប់អ្វីផ្សេងៗ បើទោះជាអ្នកស្តាប់ទាំងនោះភាគច្រើនមិនមែនជាយុវវ័យក៏ដោយ ក៏មនុស្សចាស់ជាអ្នកធ្វើជាគំរូអហិង្សា និងមានឥទ្ធិពលក្នុងការផ្តល់ឱវាទបន្តដល់យុវវ័យ។ នេះក៏ជាមធ្យោបាយមួយដ៏ប្រសើរ ព្រះសង្ឃអ្នកសម្តែងត្រូវជ្រើសរើសគោលធម៌ ឬទ្រឹស្តីអហិង្សារបស់ព្រះពុទ្ធសាសនា និងគោលគំនិតអ្នកប្រាជ្ញ ឬក៏លទ្ធផលនៃការស្រាវជ្រាវដែលមានប្រយោជន៍ដល់សង្គម តាមរយៈធម្មទេសនានេះ។ ជាពិសេស គោលគំនិតឆ្លើយតបការចិញ្ចឹម និង

បង្រៀនកុមារតាមបែបវិជ្ជមាន ដើម្បីឱ្យអ្នកស្តាប់ដែលបានស្តាប់បាន ជាគំនិតផ្សព្វផ្សាយបន្ត។

ប្រើប្រាស់អត្ថបទព្រះត្រៃបិដក ឬពុទ្ធោវាទ ឬ ព្រះធម៌ និងឯកសារផ្សេងៗដើម្បីអប់រំពីផលប៉ះពាល់នៃការដាក់កុមារនៅតាមមណ្ឌល និងបញ្ឈប់ឪពុកម្តាយពីការប្រើអំពើហិង្សាលើកុមារគឺជារឿងសំខាន់ណាស់។ បង្រៀនពីរបៀបក្នុងការប្រាស្រ័យទាក់ទង និងការដោះស្រាយ ទំនាស់ដោយមិនប្រើអំពើហិង្សា និងប្រើរបៀបគ្រប់គ្រងកំហឹង (ការអប់រំបែបវិជ្ជមាន)។

### ផ្សព្វផ្សាយបង្កើនការយល់ដឹង

- អំពីផលប៉ះពាល់នៃរាល់ទម្រង់ នៃអំពើហិង្សាលើកុមារ និងផលប៉ះពាល់នៃការដាក់កុមារនៅតាមមណ្ឌល។
- ជំរុញអោយមានការពិភាក្សាអំពីទម្លាប់ និងវប្បធម៌ ដែលត្រូវបានគេប្រើដើម្បីជាហេតុផល ក្នុងការប្រើហិង្សាលើកុមារ ។
- ធ្វើការយ៉ាងសកម្មដើម្បីផ្លាស់ប្តូរឥរិយាបថរបៀបនេះ ដែលត្រូវថ្កោលទោស ដល់ការប្រើអំពើហិង្សា រួមបញ្ចូលទាំងជំនឿដែលថា ការប្រើទណ្ឌកម្មផ្លូវកាយ ឬ ទម្រង់អាក្រក់ផ្សេងៗទៀតគឺជាមធ្យោបាយចាំបាច់ក្នុងការប្រៀនប្រដៅកុមារ។
- ផ្សព្វផ្សាយដោយប្រើប្រាស់សៀវភៅរឿងសាមណេសុខា ដែលផលិតដោយក្រសួងធម្មការ និងសាសនា ដែលជារឿងខ្លីមួយនិយាយអំពីកុមារម្នាក់ រស់រងនូវអំពើហិង្សាក្នុងគ្រួសារ ហើយវត្ត និងព្រះសង្ឃបានជួយកែប្រែជីវិតកុមារ និងគ្រួសារកុមារឱ្យជួបសុភមង្គល។ រឿងនេះបានបង្ហាញការចូលរួមរបស់ពុទ្ធសាសនាក្នុងការកសាងសហគមន៍មួយប្រកបដោយធម៌អហិង្សា។
- ផ្សព្វផ្សាយសាររបស់មេដឹកនាំព្រះពុទ្ធសាសនា

សារមេដឹកនាំព្រះពុទ្ធសាសនាក្នុងទិវាសកម្មភាពសាសនាដើម្បីកុមារឆ្នាំ២០១៤ និង ២០១៥

- ព្រះពុទ្ធសាសនានៅកម្ពុជា សូមបញ្ចេញនូវសុចន្ទៈ និងពាំនាំនូវពុទ្ធោវាទ ដែលបានសម្តែងក្នុងគម្ពីរព្រះត្រៃបិដកមកផ្សព្វផ្សាយជាទូទៅ ដល់បរិស័ទ លើសកលលោក ក៏ដូចជានៅព្រះរាជាណាចក្រកម្ពុជា ឱ្យយកចិត្តទុកដាក់ ចូលរួមប្រតិបត្តិធម៌អហិង្សា ទប់ស្កាត់ និងឆ្លើយតបរាល់អំពើហិង្សាលើកុមារ ដោយប្រតិបត្តិតាមពុទ្ធោវាទ របស់ព្រះសម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើងដោយយកព្រហ្មវិហារធម៌ មេត្តា ករុណា សង្គហធម៌ចំពោះបុត្រាបុត្រីជាទីស្រឡាញ់ របស់យើងគ្រប់ៗគ្នា។
- សូមឱ្យមាតាបិតាជាពុទ្ធសាសនិកទាំងអស់ រៀបចំតម្លៃជាវិជ្ជមាន នៃអាកប្បកិរិយាអហិង្សាក្នុងគ្រួសារ ដើម្បីធ្វើជាគំរូល្អដល់កុមារា កុមារីទាំងឡាយ (កុមារឃើញ កុមារធ្វើតាម) អាកប្បកិរិយារបស់មាតាបិតាត្រូវបានប៉ះពាល់ដល់កុមារ នូវអ្វីដែលមាតាបិតារបស់ខ្លួនធ្វើច្រើនជាងមាតាបិតានិយាយ។ ដូច្នេះការធ្វើជាគំរូល្អ គឺជាឧបករណ៍អប់រំរបស់មាតាបិតា ដ៏មានប្រសិទ្ធភាពខ្ពស់បំផុត។
- មាតាបិតា នៃពុទ្ធសាសនិកទាំងឡាយត្រូវចិញ្ចឹមបីបាច់បុត្រាបុត្រីរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ គ្មានអំពើហិង្សា។ ការភ្ជាប់ទំនាក់ទំនងផ្លូវកាយ ផ្លូវចិត្តរវាងឪពុកម្តាយ និងកូនៗ យ៉ាងណានោះនឹងមានឥទ្ធិពល លើអាកប្បកិរិយាមារយាទរបស់កូនបែបនោះ។ ដើម្បីប្រៀនប្រដៅកូន មាតាបិតាគួរបង្កើតបរិយាកាស អហិង្សា ស្តាប់កូនដោយយកចិត្តទុកដាក់ ហើយពន្យល់កូនដោយពាក្យផ្អែមល្ហែម មានហេតុផលច្បាស់លាស់ដើម្បីស្វែងយល់ថា ហេតុអ្វីបានជាគាត់មានអាកប្បកិរិយាមិនល្អបែបនេះ។ តើវិធីសាស្ត្របែបណា នឹងជួយមាតាបិតា ព្រមទាំងកូនឱ្យចេះគិតរិះរកផលវិជ្ជមានចែករំលែក និងទទួលព័ត៌មានធ្វើឱ្យទំនាក់ទំនងរវាងមាតាបិតា និងកូនធ្វើឱ្យល្អប្រសើរឡើង។
- ព្រះសង្ឃគ្រប់អង្គ ចូលរួមផ្សព្វផ្សាយធម៌អហិង្សាដល់មាតាបិតា លោកគ្រូអ្នកគ្រូសហគមន៍ ដើម្បីរួមគ្នាអប់រំ និងប្រតិបត្តិព្រះធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ ដោយ

យកព្រហ្មវិហារធម៌ និងសង្គហធម៌ ជាធម៌នៃការអប់រំចិត្តចៀសផុតអំពើហិង្សា លើកុមារទាំងឡាយ។

- ទន្ទឹមចំណុចទាំងបីខាងលើនេះ សូមប្តេជ្ញាថា វត្តអារាម សាលារៀនរបស់ពុទ្ធសាសនាទាំងឡាយ សូមបើកទ្វារចំហទទួលកុមារគ្រប់រូបឱ្យចូលសិក្សារៀនសូត្រ គោរពប្រតិបត្តិព្រះធម៌ ដោយសេចក្តីស្រឡាញ់ នៅគ្រប់សហគមន៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

### ៥.១.៣- ការជំរុញ ឬបង្កើតឱ្យមានបរិយាកាសសុវត្ថិភាព

ជានាថាវត្តអារាម និងសហគមន៍ចំណុះជើងវត្តគឺជាកន្លែង ឬបរិស្ថានដែលមានសុវត្ថិភាព និងគាំទ្រសម្រាប់កុមារ។

### ៥.១.៤- ការចលនាសហគមន៍ ឱ្យហ៊ាននិយាយ និងធ្វើសកម្មភាព

- គ្រឹះដ៏សំខាន់មួយ ក្នុងចំណោមគ្រឹះដ៏សំខាន់ផ្សេងទៀតនៃការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ត្រូវតែបំបែកភាពស្ងៀមស្ងាត់ ដែលក្នុងនោះកុមារច្រើនបំផុតទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ។ ជំនឿដែលថា ផ្ទះគឺជាមជ្ឈដ្ឋាន "ឯកជន" ធ្វើឱ្យអ្នកជិតខាង អាជ្ញាធរ និងសមាជិកសហគមន៍ រួញរា មិនហ៊ាននិយាយ នៅពេលដែលពួកគេដឹងថា កុមារកំពុងរងគ្រោះ។
- ការផ្តោតផ្តួលតែលើមណ្ឌល ឬប្រានកុមារចេញពីសហគមន៍ ជាបញ្ហាដែលកើតមានជាញឹកញាប់។ ត្រូវចាំថាមានផលប៉ះពាល់ជាច្រើនក្នុងការបំបែកកុមារចេញពីគ្រួសារ និងសហគមន៍របស់គាត់ដែលមិនចាំបាច់ ដោយយកទៅដាក់នៅក្នុងមណ្ឌល។ ការជំរុញឱ្យមាតាបិតា សាច់ញាតិ អាជ្ញាធររួមគ្នា ផ្តល់កិច្ចការពារកុមារនៅតាមសហគមន៍ ជាជាងបញ្ជូនកុមារទៅដាក់ក្នុងមណ្ឌលដែលមិនចាំបាច់។
- វ័យជំទង់ ជាដំណាក់កាលផ្លាស់ប្តូរវ័យ ពីកុមារទៅជាមនុស្សពេញវ័យ។ អាកប្បកិរិយាងាយរងគ្រោះជាច្រើនដែលវ័យនេះជួបប្រទះ។ ការជួយអប់រំក្រុមមនុស្សវ័យជំទង់ និងយុវជនឱ្យយល់ពីអាកប្បកិរិយាប្រកបដោយគ្រោះ

ថ្នាក់ និងចៀសវាងអាកប្បកិរិយាទាំងនោះ និងរួមចំណែកកាត់បន្ថយគ្រោះថ្នាក់នានារបស់ពួកគាត់ ក៏ដូចជាកាត់បន្ថយអំពើហិង្សាផងដែរ។

## ៩.១.៥- ការពន្យល់ពីទង្វើបែបហិង្សាលើកុមារមួយចំនួនដែលគួរចៀសវាង

- បើគ្រាន់តែទះមួយដៃ វាមិនមែនជាអំពើហិង្សាទេ (ហិង្សាបង្រៀនពីតិចទៅច្រើន កើតពីតិចទៅច្រើន)
- ខ្ញុំត្រូវបានគេវាយកាលពីក្មេង ហើយវាគ្មានធ្វើអោយខ្ញុំគ្រោះថ្នាក់ផង (អ្នកអាចនឹងមានសក្តានុពលជាងនេះ បើអ្នកត្រូវបានចិញ្ចឹមបែបវិជ្ជមាន)
- ឪពុកម្តាយត្រូវតែវាយកូន ដើម្បីអប់រំពួកគេ (ការអប់រំកូនបែបវិជ្ជមាន ជាការចាប់ផ្តើមបង្រៀនធម៌អហិង្សាដល់កូន ឱ្យកូនក្លាយជាមនុស្សមានហេតុផល)
- កូនៗនឹងមិនស្តាប់យើងឡើយ ប្រសិនបើយើងប្រើតែពាក្យពីរោះ (អ្នកត្រូវយល់ពីការលូតលាស់ និងចិត្តសាស្ត្ររបស់កុមារ កុមារទាមទារឱ្យមានការអត់ធ្មត់ ប្រាប់ និងក្រើនរំលឹកច្រើនដង)
- កុមារឃើញកុមារធ្វើតាម ឬការបង្រៀនកុមារដោយមិនដឹងខ្លួន

  -បើអ្នកទះកូនមួយដៃដោយសារតែអ្នកមួម៉ៅ មានន័យថា "អ្នកកំពុងបង្រៀនកូន ឱ្យប្រើហិង្សាដើម្បីទប់កំហឹង"

  -បើកូនអ្នកធ្វើអ្វីមួយដែលមិនត្រូវចិត្តអ្នក អ្នកវាយកូន មានន័យថា "អ្នកកំពុងបង្រៀនកូនឱ្យប្រើហិង្សាដើម្បីដោះស្រាយបញ្ហា"

  -បើមានអ្នកមកសួររកអ្នកនៅផ្ទះ តែអ្នកប្រាប់កូនថា ឱ្យទៅប្រាប់គេថា អ្នកមិននៅផ្ទះទេ នោះមានន័យថា " អ្នកបង្រៀនកូនឱ្យចេះកុហក "

  -បើអ្នកលក់អាប់លុយលើស កូនអ្នកឃើញថា អ្នកទទួលយកហើយដើរចេញ មានន័យថា " អ្នកកំពុងបង្រៀនកូនឱ្យលួច "

-បើអ្នកកំពុងបើកឡាន ហើយអ្នកដេរអ្នកបើកឡានម្នាក់ទៀត ដែលបើកបរកាត់មុខឡានអ្នកទាំងទទឹងទិស មានន័យថា " អ្នកកំពុងបង្រៀនកូនឱ្យជេរគេដើម្បីសម្រាលកំហឹង "

-សូមគិត មុននឹងធ្វើអ្វីមួយចំពោះមុខ ឬជាមួយកុមារ។ អ្នកជាគ្រូឯកជន តែមួយគត់របស់កូនក្មួយអ្នក។

### ៤.១.៦- ភាពជាគំរូ

ការធ្វើខ្លួនឱ្យជាគំរូជារឿងសំខាន់បំផុត ព្រោះថាក្នុងសង្គមខ្មែរយើង គេឱ្យតម្លៃអ្នកនិយាយល្អ តាមរយៈអ្នកនោះធ្វើល្អឱ្យគេមើលឃើញបានផង។ ដូច្នេះតាមរយៈ ការបង្រៀន ឬនិយាយ ត្រូវតែរក្សាក្រមសីលធម៌ និងចេះប្រើពាក្យពេចន៍ឱ្យបានត្រឹមត្រូវ។ ម្យ៉ាងទៀត ភាពជាគំរូ តាមរយៈការបំពេញការងាររបស់ខ្លួនយ៉ាងម៉ត់ចត់ និងធ្វើអ្វីមួយដើម្បីបង្កើតភាពជាគំរូដល់បុគ្គលដទៃទៀត។

ម្យ៉ាងទៀតភាពជាគំរូ ចាំបាច់ត្រូវបង្ហាញពី សុជីវធម៌ សីលធម៌ និងគុណធម៌ របស់មនុស្ស ជាជាងបង្ហាញពីការប្រើប្រាស់អំណាចហិង្សា សម្ភារៈនិយម បក្សពួកនិយម។ ក្រៅពីបង្ហាញពីគំរូទាំងនេះដល់កុមារ មនុស្សធំ ឬអាណាព្យាបាល ត្រូវតែធ្វើជាគំរូល្អ ឱ្យពួកគេបានឃើញផងដែរ។

### ៤.១.៧- មិត្តអប់រំមិត្ត

ក្នុងចំណោមមនុស្សដែលនៅក្បែរយើងរួមមាន មាតាបិតា សាច់ញាតិ អ្នករស់នៅក្បែរខាង និងមិត្តភក្តិ អ្នកដែលមានឥទ្ធិពលជាងគេ គឺមិត្តភក្តិនេះឯង។ ចំពោះកុមារ និងមនុស្សវ័យជំទង់ គេនឹងអាចស្តាប់មិត្តភក្តិរបស់ពួកគេជាងអ្នកណាៗទាំងអស់។ ការបញ្ជ្រាបការអប់រំដល់មនុស្ស ដែលមានវ័យជំទង់ឱ្យយល់ដឹងអំពីមនោគមវិជ្ជាអហិង្សា គឺជាពិធីមួយដ៏ល្អនៅក្នុងសង្គមជាតិយើង។ ប្រសិនបើពួកគេបានយល់ដឹងកាន់តែច្រើន ការរីកសាយភាយគំនិតទាំងនេះ នឹងបានជាប្រយោជន៍សម្រាប់ជាតិ។

ម្យ៉ាងទៀត មិត្តអប់រំមិត្ត មិនសំដៅទៅលើកុមារ ឬមនុស្សវ័យជំទង់នោះទេ វាក៏អាចមានន័យសម្រាប់មនុស្សធំជាអាណាព្យាបាលទាំងឡាយណាដែលបានយល់ដឹងទ្រឹស្តីអំពីការអប់រំកុមារនេះ យកទៅចែកចាយដល់មនុស្សធំដែលត្រូវជាមិត្តភក្តិ ដើម្បីបានយល់ដឹងបន្តទៀត។

**៥.១.៨- វត្តអារាម និងសហគមន៍**

វត្តក៏ជាជម្រកសម្រាប់សិស្ស និស្សិតជាច្រើនមកពីជនបទចុងកាត់មាត់ញក ដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកលុយដើម្បីជួលផ្ទះ បានចូលទៅសុំស្នាក់អាស្រ័យដើម្បីបន្តការសិក្សារបស់ពួកគេ។ តាំងពីដើមរហូតមក វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលយុវជនខ្មែរ ឱ្យក្លាយជាធនធានមនុស្សដ៏សំខាន់សម្រាប់សង្គម។ អ្នកប្រាជ្ញអក្សរសាស្ត្រ កវីនិពន្ធនៅសម័យមុនៗ ភាគច្រើនសុទ្ធតែធ្លាប់បានបួសរៀន និងស្នាក់នៅនិងវត្តអារាម។

ប្រហាក់ប្រហែលគ្នានេះដែរ ពេលបច្ចុប្បន្នវត្តអារាមនៅតែមានតួនាទីយ៉ាងសំខាន់សម្រាប់យុវជនក្រីក្ររាប់រយនាក់ ដែលមកពីតំបន់ដាច់ស្រយាលស្នាក់នៅរៀនសូត្របន្តនាទីក្រុងភ្នំពេញ។ សិស្ស និងនិស្សិតជាច្រើនដែលទទួលអាហារូបករណ៍រដ្ឋ ហើយពួកគេមកបន្តការសិក្សានាទីក្រុងភ្នំពេញ ភាគច្រើនមិនមានលទ្ធភាពគ្រប់គ្រាន់រកលុយបង់ថ្លៃផ្ទះនោះឡើយ ដោយសារឪពុកម្តាយក្រីក្រ។ ដូច្នេះពួកគេទាំងនោះភាគច្រើនមានតែមកសុំស្នាក់អាស្រ័យនិងវត្តអារាមជាមួយព្រះសង្ឃ។

ម្យ៉ាងទៀតវត្តអារាមមានតួនាទីសំខាន់ណាស់ចំពោះប្រជាជនកម្ពុជាដូចជា៖

- ជាកន្លែងសម្រាប់ឱ្យព្រះសង្ឃ អប់រំសីលធម៌ ផ្សព្វផ្សាយពុទ្ធវចនៈ ដល់ពុទ្ធបរិស័ទ។
- ជាកន្លែងសម្រាប់ឱ្យប្រជាជនបានផ្សារភ្ជាប់ជីវិតរបស់គេទៅនឹងព្រះពុទ្ធសាសនា។
- ជាទីតាំងនៃព្រះពុទ្ធសាសនា សម្រាប់ឱ្យពុទ្ធសាសនិកទុកជាទីពឹងពាក់ ជាបង្អែកខាងផ្លូវចិត្ត។

- ជាកន្លែងអប់រំកាយ ចិត្ត និងជាទីសក្ការៈ។
- ជាកន្លែងសម្រាប់ ឱ្យប្រជាជនកម្ពុជានិយមធ្វើពិធីបុណ្យផ្សេងៗ ដែលជាប្រពៃណីពុទ្ធសាសនា តាមទំនៀមទម្លាប់របស់ប្រជាជនកម្ពុជាដូចជា បុណ្យកឋិន ភ្ជុំបិណ្ឌ មាឃបូជា វិសាខបូជា ចូលវស្សា ចេញវស្សា បុណ្យចូលឆ្នាំជាដើម។
- ជាកន្លែងសម្រាប់ដុសខាត់ចិត្តឱ្យកកើតសេចក្តីប្រាថ្នា ជ្រះថ្លា ឱ្យមានអារម្មណ៍ស្ងប់។
- ជាកន្លែងទីពំនាក់អាស្រ័យរបស់សិស្សានុសិស្សដែលជាកូនចៅប្រជាជនក្រីក្រ។
- ជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺចិត្ត។
- ជាកន្លែងសម្រាប់ប្រជុំរបស់ប្រជាជនគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ គ្រប់វ័យដោយគ្មានរើសអើង ពណ៌សម្បុរ សញ្ជាតិ ឋានៈ នាទី សង្គម ដោយឥតប្រកាន់មានក្រ ឬមានជំនឿផ្សេងៗ។
- ជាកន្លែងសម្រាប់ក្នុងការជួយកសាងសង្គម ដូចជា ស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ ស្រះទឹក អណ្តូង និង ដាំដើមឈើមានតម្លៃ ឈើហូបផ្លែ ឈើសម្រាប់ធ្វើជាឱសថជាដើម។
- ជាឃ្លាំងចំណេះដឹង ជាបណ្ណាល័យ ជាសារមន្ទីរនៃវប្បធម៌ និងអរិយធម៌ជាដើម ដោយឥតប្រកាន់អ្នកមានជំនឿផ្សេងៗឡើយ។
- កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្តីសង្គ្រោះអំពីបព្វជិតពុទ្ធសាសនិកក្នុងឆ្នាំនីមួយៗ បានច្រើនអ្នកណាស់ ដូចយ៉ាងវត្តធំៗ មានកុមារចំនួន៣០០ ឬ ៤០០ នាក់។ ចំនួនពួកកុមារទាំងនោះ បើជារាជរដ្ឋាភិបាលទទួលយកទៅចិញ្ចឹមវិញអស់ថវិកាជាតិមិនតិចទេ។ កុមារទាំងនេះឈ្មោះថា រស់នៅដោយអាស្រ័យនិងម្លប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមម្លប់ទង់ព្រះពុទ្ធសាសនា ខំប្រឹងប្រែងសិក្សាទាល់តែបានទទួលលទ្ធផល នៃការសិក្សារបស់ខ្លួន។ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកអភិវឌ្ឍដល់ប្រទេសជាតិ។ វត្តនៃព្រះពុទ្ធសាសនាទុកដូចជាកន្លែងឧបត្ថម្ភអាហារូបករណ៍មួយដ៏ប្រសើរ

ដល់កុមារនិងអ្នកក្រីក្រ អាចចិញ្ចឹមមនុស្សទ័លក្រដែលមិនមានលំនៅជ្រកកោន និងអាហារបរិភោគ។ ដូចនេះ ការដែលព្រះសង្ឃ ធ្វើជាគំរូនៃការប្រព្រឹត្តអហិង្សា ក្នុងការអប់រំ ការធ្វើឱ្យវត្តក្លាយជាកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ និងមានប្រព័ន្ធគាំទ្រ និងឆ្លើយតបទៅរាល់ការរំលោភបំពានណាមួយ ក៏ដូចជាជួយអប់រំដល់ឧបាសក ឧបាសិកាទាំងអស់នោះទើបជាការចូលរួមដ៏ពិតប្រាកដក្នុងការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ។ វត្តរបស់ព្រះពុទ្ធសាសនា ឈ្មោះថាបានជួយសម្រាលភារៈនៃរាជរដ្ឋាភិបាលឱ្យធូរស្រាលបានច្រើន។

ដូចនេះ វត្តអារាមពុទ្ធសាសនា មានសារៈសំខាន់ណាស់ ក្នុងការជួយសម្រាលបន្ទុកសេដ្ឋកិច្ចរដ្ឋមួយកម្រិត និងជួយដោះស្រាយបញ្ហានានា ក្នុងសង្គមមួយចំណែកទៀតផង[១៨]។

## ៥.១.៩- ការប្រជុំជាមួយមាតាបិតាសិស្ស

ចំពោះវត្តដែលមានបើកសាលា ការប្រជុំជាមួយមាតាបិតាសិស្សឱ្យបាន ក៏ជាវិធីសាស្ត្រមួយដ៏ល្អសម្រាប់ការបញ្ជ្រាបគំនិត ព្រោះការប្រជុំនេះ ព្រះសង្ឃអាចមានពេលវេលាគ្រប់គ្រាន់ មានសង្ឃដីការអប់រំដោយផ្ទាល់ដល់មាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស។ ព្រះសង្ឃ ឬសមណនិស្សិតអាចសហការជាមួយសាលា ផ្តល់ការអប់រំដល់អាណាព្យាបាលគ្រប់រូបដែលបានចូលរួមស្តាប់។ ម្យ៉ាងទៀតការប្រជុំអាចនឹងនាំមកនូវការផ្លាស់ប្តូរទម្លាប់អាក្រក់ នៃការចិញ្ចឹមបីបាច់កូន តាមរយៈការឆ្លុះបញ្ចាំងបទពិសោធន៍របស់អ្នកចូលរួម ដែលជាអាណាព្យាបាលនោះផងដែរ។

## ៥.១.១០- សកម្មភាពផ្សេងៗទៀត អំពីការចូលរួមរបស់ព្រះសង្ឃ

### ក- តស៊ូមតិ និងសកម្មភាពរួម

[18] http://answer.seuksa.com/?p=87

ព្រះសង្ឃអាចក្លាយជាអ្នកតស៊ូមតិគាំទ្រកុមារដ៏មានឥទ្ធិពល។ ព្រះសង្ឃអាចបង្កើនការយល់ដឹងពីផលប៉ះពាល់នៃអំពើហិង្សាលើកុមារ និងផ្តោតលើការទប់ស្កាត់អំពើហិង្សាលើកុមារ ដោយអនុវត្តគុណតម្លៃរួមនៃសេចក្តីមេត្តា សេចក្តីស្រឡាញ់អហិង្សា និងយុត្តិធម៌។

ខណៈដែលព្រះសង្ឃអាចចូលរួមយ៉ាងមានប្រសិទ្ធភាព ក្នុងការតស៊ូមតិផ្លូវការ ពាក់ព័ន្ធនិងកំណែទម្រង់ច្បាប់ គោលនយោបាយសម្រាប់កិច្ចការពារកុមារ តួនាទីដ៏មានឥទ្ធិពលបំផុតរបស់ព្រះសង្ឃ អាចជាការសម្របសម្រួលកិច្ចសន្ទនា ការឆ្លុះបញ្ចាំង និងសកម្មភាពពាក់ព័ន្ធនិងអំពើហិង្សា និងការរំលោភសិទ្ធិក្នុងបរិបទវប្បធម៌ និងព្រះធម៌។ នេះជាការពិត អំពើហិង្សាលើកុមារមានបង្កប់ក្នុងនិយាមសង្គម និងទំនៀមទម្លាប់ក្នុងមូលដ្ឋាន។ តាមរយៈការរៀបចំ និងជំរុញឱ្យសហគមន៍ចូលរួមពិនិត្យលើការបង្កអំពើហិង្សា និងតាមរយៈការជំរុញទស្សនវិស័យរួមនៃឧត្តមគំនិត និងជម្រើសនានាការផ្លាស់ ប្តូរក្នុងសង្គមនឹងបង្កើតជាការប្តេជ្ញាចិត្ត និងអាកប្បកិរិយា ដែលស៊ីសង្វាក់គ្នានិងបទដ្ឋានសិទ្ធិមនុស្ស។

### សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា

- តើទម្រង់អំពើហិង្សាណាខ្លះដែលមានបង្កប់ក្នុងប្រពៃណីសាសនា និង/ឬ វប្បធម៌? តើមានការយល់ដឹងដូចម្តេច ពីសកម្មភាពទាំងនេះពាក់ព័ន្ធនិងការចិញ្ចឹមកូន?
- តើមានទ្រឹស្តីរបស់ព្រះសម្មាសម្ពុទ្ធអ្វីខ្លះ សម្រាប់យកមកប្រើការពារកុមារពីអំពើហិង្សា និងកាត់បន្ថយការដាក់កុមារនៅតាមមណ្ឌល?
- តើកុមារទទួលបានការទទួលស្គាល់ និងការគោរពក្នុងនាមជាមនុស្ស និងជាអ្នកមានសិទ្ធិមនុស្សក្នុងសហគមន៍ និងសង្គមទាំងមូលដោយរបៀបណា?
- តើត្រូវមានវិធានការអ្វីខ្លះ សម្រាប់ផ្តល់ការការពារដល់កុមារពីគ្រប់ទម្រង់ នៃអំពើហិង្សានៅថ្នាក់ជាតិ? ថ្នាក់មូលដ្ឋាន? ក្នុងសហគមន៍សាសនា?

- តើកម្ពុជាមានច្បាប់អ្វីខ្លះដែលចែងពីអំពើហិង្សាលើកុមារ? តើទ្រឹស្តី និង គោលការណ៍ព្រះពុទ្ធសាសនាស៊ីសង្វាក់គ្នា និងផ្ទុយនិងក្របខ័ណ្ឌផ្លូវច្បាប់ដូចម្តេច?
- តើអ្វីជាគុណតម្លៃបន្ថែម និងការគាំទ្រជាក់ស្តែង ដែលផ្តល់ដោយចក្ខុវិស័យសាសនាក្នុងកិច្ចខិតខំប្រឹងប្រែងលុបបំបាត់អំពើហិង្សាលើកុមារ?

*វិធានការ*

- ជំរុញកិច្ចពិភាក្សាក្នុងសហគមន៍សាសនាស្តីពីសិទ្ធិកុមារ បទពិសោធន៍អំពើហិង្សាក្នុង ឬជុំវិញសហគមន៍ តម្រូវការការពារ និងរបៀបដែលសហគមន៍អាចផ្តោតលើការបំពេញតម្រូវការទាំងនោះ។
- ធានាថា កុមារមានលទ្ធភាពទទួលបានព័ត៌មាន និងធនធានស្តីពីសិទ្ធិរបស់ខ្លួនក្នុងនាមជាមនុស្សក្នុងទម្រង់ដែលយកចិត្តទុកដាក់លើកុមារ និងសមស្របតាម អាយុ។
- ធានាថា ព័ត៌មានទាំងនេះមានផ្តល់ឱ្យកុមារដែលមានសាវតារចម្រុះ (ដូចជា ភេទ ពិការភាព ជាតិពន្ធុ ឬភាសា)។
- ផ្សព្វផ្សាយ និងគាំទ្រយុទ្ធនាការនានាដើម្បីផ្តល់ឱកាសស្មើភាពក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព និងពេលវេលាលំហែកាយ និងលេងកម្សាន្តដល់កុមារដែលរងការកេងប្រវ័ញ្ចតាមរយៈពលកម្មកុមារ និង/ឬ ប្រឈម និង ទម្រង់ផ្សេងទៀតនៃអំពើហិង្សា។
- ស្នើគាំទ្រ និងអនុវត្តគំនិតផ្តួចផ្តើម ដើម្បីបង្កើតប្រព័ន្ធគាំទ្រសម្រាប់កុមារងាយរងគ្រោះ និងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សា ការជួញដូរ និងការរំលោភបំពាន ដូចជាការបង្កើតនីតិវិធីរាយការណ៍អំពើហិង្សាទៅអាជ្ញាធរ និងខ្សែទូរស័ព្ទជំនួយ ឬយន្តការផ្សេងទៀតសម្រាប់កុមារដែលត្រូវការការពារ។
- គូសបញ្ជាក់ពីភាពចាំបាច់ នៃការពង្រីកសេវាតាមសហគមន៍សម្រាប់កុមារ។
- រៀបចំកិច្ចប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន និងតួអង្គសំខាន់ៗផ្សេងទៀត ដើម្បីពិភាក្សាពីសិទ្ធិមនុស្សរបស់កុមារ យេនឌ័រ និងទម្រង់ផ្សេងទៀតនៃការ

លើសអើង និងការការពារមានស្រាប់ពីគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ ក្នុងសេវាមូលដ្ឋាន សាលារៀន អង្គការសាសនា និងស្ថាប័ននានា។

- សហការជាមួយក្រុមសិទ្ធិមនុស្ស និងក្រុមអ្នកច្បាប់ដើម្បីធ្វើឱ្យមានកំណែទម្រង់ផ្លូវច្បាប់ សំដៅទប់ស្កាត់អំពើហិង្សាលើកុមារ និងជួយដល់កុមាររងគ្រោះ។
- ផ្តួចផ្តើមយុទ្ធនាការ ឬគាំទ្រកិច្ចខិតខំប្រឹងប្រែងមានស្រាប់ ដើម្បីឱ្យមានកំណែទម្រង់ច្បាប់។ នេះជាបញ្ហាបន្ទាន់ក្នុងបណ្តាប្រទេសនានា ដែលអំពើហិង្សាក្នុងគ្រួសារមិនត្រូវបានហាមឃាត់ដោយច្បាប់។ ការផ្តល់ការណែនាំស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានមានសារប្រយោជន៍បំផុត ទោះបីជាវាអាចនឹងមិនទាន់គ្រប់គ្រាន់ក៏ដោយ។ គេអាចសម្រេចបានការការពារកុមារទាំងអស់បាន ពេញលេញពីអំពើហិង្សាក្នុងគ្រួសារ លុះត្រាតែកុមារទទួលបានសិទ្ធិជាមូលដ្ឋាន នៃការការពារក្រោមផ្លូវច្បាប់។
- ធ្វើយុទ្ធនាការឱ្យមានការដាក់បញ្ចូលសិទ្ធិកុមារ និងការលុបបំបាត់អំពើហិង្សាលើកុមារក្នុងកម្មវិធីសិក្សាតាមសាលារៀន។

**២- ព្រះសង្ឃជាអ្នកជំរុញពុទ្ធសាសនិក និងធ្វើជាគំរូ**

ក្នុងនាមព្រះអង្គជាអ្នកណែនាំ និងអ្នកគ្រប់គ្រង ព្រះសង្ឃមានតួនាទីពិសេសក្នុងការជំរុញឱ្យគេយកចិត្តទុកដាក់ និងចាត់ទុកជាអាទិភាពស្នូលនៃចំណាត់ការទប់ស្កាត់ និងលុបបំបាត់បញ្ហានេះ។

សាសនាជាច្រើនបានផ្សព្វផ្សាយដល់ប្រជាជនដ៏ច្រើន ដែលមិនទទួលបានសេវា ពីក្រុមផ្សេងទៀត មានរចនាសម្ព័ន្ធដែលផ្តល់ជំនួយជាក់ស្តែង និងការគាំទ្រ និងផ្តល់ការណែនាំផ្នែកស្មារតី។ ព្រះសង្ឃមានសមត្ថភាព និងការទទួលខុសត្រូវលើការធានាថាកុមារក្នុងអង្គការ និងសហគមន៍របស់ព្រះអង្គទទួលបានការការពារពីអំពើហិង្សាគ្រប់ទម្រង់។ តាមរយៈការបង្កើតគំរូអាកប្បកិរិយាដែលសមស្រប និងគោរពចំពោះកុមារ ព្រះសង្ឃអាចផ្តល់ការណែនាំដល់សមាជិកសហគមន៍។

### សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា

- តើកុមារមានស្ថានភាពដូចម្តេចក្នុងអង្គការ និងសហគមន៍សាសនា?
- តើមានជំនឿ ឬការអនុវត្តក្នុងប្រពៃណីសាសនាដែលអាចផ្ទុយគ្នានិងបទដ្ឋានសិទ្ធិកុមារ ឬទេ?
- តើមានជំនឿ ឬការអនុវត្តអ្វីខ្លះក្នុងប្រពៃណីសាសនា និងសហគមន៍ ដែលការពារកុមារពីអំពើហិង្សា?
- តើត្រូវមានវិធានការអ្វីខ្លះ ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារក្នុងសហគមន៍សាសនា? តើអ្នកដឹកនាំមានតួនាទីអ្វីខ្លះ ក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែងទាំងនេះ?
- តើអ្វីខ្លះជាតួនាទីសមស្របរបស់អ្នកដឹកនាំសហគមន៍សាសនា ក្នុងការជះឥទ្ធិពលលើការជជែកដេញដោលពីគោលនយោបាយសាធារណៈ ដូចជាច្បាប់ពាក់ព័ន្ធនិងកុមារ អំពើហិង្សា និងសិទ្ធិកុមារ?

### វិធានការ

- ចាត់តាំងជនបង្គោលទទួលខុសត្រូវ លើបញ្ហារបស់កុមារក្នុងសហគមន៍សាសនា និងគាំទ្រអំណាចរបស់មន្ត្រីនោះក្នុងការបង្កើត និងអនុវត្តវិធានការសមស្រប។
- ជំរុញឱ្យមានកិច្ចពិភាក្សាដោយបើកចំហរ និងស្មោះត្រង់ស្តីពីរបៀបដែលវប្បធម៌ និងប្រពៃណីអាចត្រូវបានប្រើប្រាស់ ដើម្បីសំអាងហេតុផលលើអំពើហិង្សាលើកុមារ និងរបៀបដែលព្រះសង្ឃអាចក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរ ដើម្បីឱ្យវត្ត និងសហគមន៍ចំណុះជើងវត្តក្លាយជាកន្លែង ដែលមិនមានការអត់អោនចំពោះអំពើហិង្សាលើកុមារ។
- ធានាថាវត្តអារាម និងសហគមន៍ គឺជាទីកន្លែងសុវត្ថិភាព និងផ្តល់ជំនួយដល់កុមារ (វត្តកុមារមេត្រី)។ រៀបចំការអង្កេតពីគោលនយោបាយ និងនីតិវិធីការពារកុមារ ដើម្បីធានាថា កុមារទទួលបានការការពារពេញលេញពីអំពើហិង្សា។ ប្រសិនបើ

មិនមានគោលនយោបាយទេនោះ ត្រូវផ្តោតអាទិភាពលើការបង្កើតគោលនយោបាយនេះ ដោយមានការចូលរួមប្រកបដោយអត្ថន័យពីកុមារ។

- បង្កើតវិធីដែលអាចឱ្យកុមារប្រើប្រាស់បាន ក្នុងការរាយការណ៍ពីករណីអំពើហិង្សាក្នុងអង្គការសាសនា។
- ជានាថា មានចំណុចទំនាក់ទំនងជាសម្ងាត់ សម្រាប់ឱ្យកុមារស្វែងរកការណែនាំជំនួយ និងការថែទាំអាជីពដែលមានគុណភាពខ្ពស់បំផុត។
- ជានាថា គោលនយោបាយ និងការអនុវត្តក្នុងអង្គការសាសនាឆ្លុះបញ្ចាំងពីការគោរពកុមារ ជំរុញសមភាព និងបង្កើនស្ថានភាពរបស់កុមារា និងកុមារី ដោយលើកកម្ពស់សិទ្ធិលូតលាស់របស់កុមារដោយមិនប្រឈមនឹងអំពើហិង្សា និងការប្រមាថ។
- ផ្តល់ការបណ្តុះបណ្តាល និងការណែនាំស្តីពីការការពារកុមារដល់មនុស្សទាំងអស់ដែលធ្វើការក្នុងអង្គការសាសនា និងបង្កើតគោលការណ៍ គណនេយ្យភាព និង វិធីសាស្ត្រវាយតម្លៃច្បាស់លាស់ ដើម្បីផ្តល់ទំនុកចិត្តដល់កុមារ។
- ជំរុញគោលការណ៍វិន័យបែបវិជ្ជមានក្នុងសហគមន៍ពុទ្ធសាសនា និងបង្កើតការ បណ្តុះបណ្តាលសម្រាប់បុគ្គលិក និងគ្រូបង្រៀន។
- ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ជាមួយភាគីផ្សេងទៀត ក្នុងការជះឥទ្ធិពលលើគោលនយោបាយសាធារណៈស្តីពីបញ្ហាសិទ្ធិកុមារសំខាន់ៗ និងការរក្សាជំនឿ និងអាទិភាពរបស់សហគមន៍ពុទ្ធសាសនា។

**គ- អ្នកជំនាញផ្នែកសាសនា និងអ្នកអប់រំ**

ក្នុងការបង្រៀន និងការអនុវត្តន៍ ព្រះសង្ឃអាចផ្តោតសំខាន់លើសារៈសំខាន់នៃសិទ្ធិរបស់កុមារក្នុងការលូតលាស់ និងអភិវឌ្ឍដោយមិនប្រឈមនឹងអំពើហិង្សា។ ប្រពៃណីសាសនានីមួយៗមានធនធានជាច្រើនក្នុងអត្ថបទស័ក្តិសិទ្ធិ និងការបង្រៀនដើម្បីគាំទ្រឱ្យមានអហិង្សា និងជំរុញការគោរពកុមារ។ ការបណ្តុះបណ្តាលផ្នែកសាសនាផ្តល់ឱកាសច្រើនបន្ថែមទៀតដល់ការស្រាវជ្រាវ និងការសិក្សាពីគម្ពីរសាសនា និងលទ្ធិសាសនា ដែល

អាចប្រើប្រាស់សម្រាប់ប្រយុទ្ធប្រឆាំងនិងអំពើហិង្សាលើកុមារ។ ក្រៅពីនេះ អ្នកសិក្សាស្រាវជ្រាវសាសនាអាចទទួលខុសត្រូវលើការអប់រំសាសនា ដូចជា ការបង្រៀន និងការប្រឹក្សាយោបល់តាមសាលារៀន។ ទាំងនេះសុទ្ធតែជាតួនាទីសំខាន់ៗ ដែលផ្តល់ ឱកាសដល់ការសហការជាមួយភាគីផ្សេងទៀត ក្នុងការលុបបំបាត់អំពើហិង្សាលើកុមារ។

ម្យ៉ាងទៀត ព្រះសង្ឃមានតួនាទីសំខាន់ក្នុងការបង្កើតឧបករណ៍ និងធនធានសម្រាប់ដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ និងបង្រៀនកុមារ និងមនុស្សពេញវ័យ ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា

- តើពុទ្ធោវាទ ដែលបានសម្តែងក្នុងគម្ពីរព្រះត្រៃបិដក អាចត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់សិទ្ធិមនុស្សមូលដ្ឋានរបស់កុមារ ដើម្បីឱ្យពួកគេលូតលាស់ ដោយមិនប្រឈមនិងអំពើហិង្សាដោយរបៀបណា?
- តើមានជំនឿ និងការអនុវត្តដែលជំរុញឱ្យមានអំពើហិង្សាលើកុមារ ឬទេ?
- តើមានជំនឿនិងការអនុវត្តដែលជំរុញឱ្យមានការការពារកុមារពីអំពើហិង្សាឬទេ?
- តើទេសនា ឬការបង្រៀនពីធម៌ និងការអប់រំបង្ហាញពីបទដ្ឋានបច្ចុប្បន្ន នៃសិទ្ធិកុមារឬទេ?
- តើវិធីសាស្ត្រអប់រំ និងបង្រៀនអ្វីខ្លះ ដែលអាចជានាការគោរពសិទ្ធិកុមារ?

## វិធានការ

- ប្រើប្រាស់ព័ត៌មានក្នុងការសិក្សាពីអំពើហិង្សា ដើម្បីអប់រំប្រជាជនអំពីឥទ្ធិពលដ៏អាក្រក់នៃអំពើហិង្សាលើការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ និង លើកឡើងពីបញ្ហាប្រឈមនានាក្នុងសហគមន៍ផ្ទាល់។

- កំណត់រកការបង្រៀនក្នុងអត្ថបទគម្ពីរព្រះត្រៃបិដក និងធម៌វិន័យ ដែលជំរុញអហិង្សា ការមិនរើសអើង និងការគោរពកុមារ។ បញ្ចូលចំណុចទាំងនេះ ក្នុងពិធីថ្វាយបង្គំព្រះ ពិធីសាសនាបួងសួង និងការសិក្សាពីសាសនា។
- បញ្ជាក់ពីការបកស្រាយខុសនៃអត្ថបទសាសនា ដែលត្រូវបានប្រើប្រាស់សម្រាប់ជំរុញការប្រព្រឹត្តអំពើហិង្សាលើកុមារ និង/ឬ វិសមភាពរវាងកុមារា និងកុមារី។
- បង្រៀនពីវិធីទំនាក់ទំនង និងដោះស្រាយជម្លោះដោយអហិង្សា។
- បង្កើតឯកសារ/សម្ភារៈបណ្តុះបណ្តាលដើម្បីជំរុញឱ្យមានការឆ្លុះបញ្ចាំងពីសាសនា និងបញ្ជាក់ពីការបកស្រាយគម្ពីរសាសនា ដើម្បីបញ្ឈប់ការសំអាងហេតុផល ផ្អែកតាមជំនឿសាសនាស្តីពីអំពើហិង្សាលើកុមារ។
- ប្រឈមនិងបុគ្គលដែលប្រើប្រាស់សាសនា វប្បធម៌ ឬប្រពៃណីរបស់ខ្លួន ដើម្បីសំអាងហេតុផលស្តីពី អំពើហិង្សាលើកុមារ។

**ឃ- អ្នកផ្តល់ឱវាទ ឬទេសនា**

ព្រះសង្ឃ ដើរតួនាទីសំខាន់ក្នុងបទពិសោធន៍ជាលក្ខណៈបុគ្គល និងជារួមក្នុងសហគមន៍ចំណុះជើងវត្ត។ ម្យ៉ាងវិញទៀត ព្រះសង្ឃអប់រំតាមពុទ្ធឱវាទ សម្របសម្រួល និងកិច្ចសន្ទនា ព្រមទាំងការឆ្លុះបញ្ចាំងពីបញ្ហាសាសនា និងបញ្ហាសង្គម។ អ្វីដែលសំខាន់ផងដែរនោះគឺ តួនាទីរបស់ព្រះសង្ឃក្នុងការអប់រំផ្លូវចិត្តរបស់ពុទ្ធសាសនិក ជាពិសេសពេលពួកគេជួបការលំបាកនានា និងបញ្ជ្រាបការអប់រំតាមកម្មវិធីបុណ្យ ឬ ពិធីពុទ្ធសាសនា។

ព្រះសង្ឃមានតួនាទីសំខាន់ក្នុងការផ្តល់ការគាំទ្រ និងការណែនាំផ្នែកសីលធម៌ និងស្មារតីដល់ឪពុកម្តាយ និងការជំរុញទំនាក់ទំនងអហិង្សាក្នុងចំណោមសមាជិកគ្រួសារ និងបុគ្គលដែលរងផលប៉ះពាល់ពីអំពើហិង្សា តាមរយៈការសម្តែងធម៌ទេសនា ផ្តល់ឱវាទ និងការអប់រំផ្នែកស្មារតី។

ព្រះសង្ឃមានឱកាសលើកឡើងពីការថែទាំកុមារ នៅពេលដែលព្រះអង្គធ្វើជាប្រធានក្នុងពិធីបុណ្យសំខាន់ៗ រួមទាំងពិធីអាពាហ៍ពិពាហ៍ ពិធីបង្កក់សិរីសួស្តីកូនជាដើម។

ព្រះសង្ឃព្រះពុទ្ធសាសនាតែងតែត្រូវបានគេនិមន្តឱ្យផ្តល់ឱវាទ និងការប្រឹក្សា យោបល់ នៅដំណាក់កាលផ្សេងៗនៃជីវិតគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាមួយ ដែលតែងតែក្លាយជាចំណុចផ្តោតសំខាន់របស់សហគមន៍សាសនា។

**សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា**

- បច្ចុប្បន្នតើមានកម្មវិធី និងពិធីបែបសាសនា និងប្រពៃណីអ្វីខ្លះដែលអាចបញ្ជ្រាបទ្រឹស្តីពុទ្ធសាសនា ឬរឿងក្នុងព្រះត្រៃបិដក សិទ្ធិមនុស្ស និងការអប់រំពីផលប៉ះពាល់នៃការដាក់កុមារតាមមណ្ឌលឬទេ? តើត្រូវបញ្ជ្រាបយ៉ាងដូចម្តេច?
- តើឥរិយាបថនៃការរៀបចំពិធីបែបសាសនា និងពិធីបុណ្យនានាបង្ហាញពីការគោរពកុមារឬទេ?

**វិធានការ**

- រៀបចំសេវា និងព្រឹត្តិការណ៍សាសនាដែលផ្តោតលើកុមារ និងអហិង្សា។ ជំរុញឱ្យកុមារចូលរួមក្នុងដំណើរការរៀបចំផែនការ និងការផ្តល់សេវា ឬការដំណើរការព្រឹត្តិការណ៍។
- ក្នុងអំឡុងពេលពិធីបុណ្យ និងព្រឹត្តិការណ៍សាសនា ប្រើប្រាស់ការសូត្រធម៌ ជាពិសេស អំណាន និងអត្ថបទគម្ពីរព្រះត្រៃបិដក ដែលជំរុញឱ្យមានការគោរព សេចក្តីថ្លៃថ្នូរផ្នែករូបរាងកាយ ស្មារតី និងផ្លូវចិត្តរបស់កុមារ។
- ប្រើប្រាស់ឱកាសក្នុងពិធីបុណ្យសាសនាសម្រាប់កុមារ ដើម្បីផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ការអប់រំ អាហារូបត្ថម្ភ និងការចិញ្ចឹមកូនបែបអហិង្សា និងវិជ្ជមានដល់ឪពុកម្តាយ។
- ផ្តល់ជំនួយដល់ឪពុកម្តាយ ឬជីដូនជីតាថ្មីដូចជា ការគាំទ្រ និង កិច្ចពិភាក្សាក្រុមស្តីពីវិន័យបែបវិជ្ជមាន និងការចិញ្ចឹមកូនបែបអហិង្សា ក្នុងចំណោមបញ្ហាសុខភាព និងសុខុមាលភាពផ្សេងៗ។
- រៀបចំឱ្យមានពិធីសូត្រធម៌ ឬទេសនាជាសាធារណៈដើម្បីរំលឹកពីកុមារ និងអហិង្សា និងចងចាំកុមារដែលរងគ្រោះពីអំពើហិង្សា។

- ជានាថា ការប្រើប្រាស់អត្ថបទសាសនាជំរុញឱ្យមានវិន័យអហិង្សាបែបវិជ្ជមាន និង មិនបណ្តោតបណ្តោយឱ្យមានអំពើហិង្សាលើកុមារ។ ជំរុញឱ្យមានកិច្ចពិភាក្សាបើកចំហលើអត្ថបទដែលអាចត្រូវបានប្រើប្រាស់ ដើម្បីសំអាងហេតុផលលើអំពើហិង្សា និងសម្របសម្រួលការឆ្លុះបញ្ចាំង និងកិច្ចសន្ទនា ស្តីពីគំនិតវិវឌ្ឍស្តីពីសិទ្ធិកុមារ និងការសិក្សាពីសាសនា។
- ជំរុញឱ្យមានការឆ្លុះបញ្ចាំងពីសាសនា និងការស្រាវជ្រាវពិធីបួងសួង និងពិធីបុណ្យពិសេសៗដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាបច្ចុប្បន្នដែលពាក់ព័ន្ធនិងអំពើហិង្សា។
- សរសេរពីពិធីថ្វាយបង្គំព្រះ និងអំណានដែលជំរុញឱ្យមានសេចក្តីមេត្តា ចំពោះកុមារ និងអហិង្សា។
- រួមបញ្ចូលការចូលរួមចំណែករបស់កុមារពាក់ព័ន្ធនិងតម្រូវការរបស់ពួកគេ ក្នុងអំឡុងដំណើរការជ្រើសរើសអ្នកដឹកនាំសាសនា។

**ង- ការផ្តល់ការណែនាំ និងការគាំទ្រដល់សហគមន៍**

ព្រះសង្ឃ តែងតែត្រូវបានគេនិមន្តឱ្យផ្តល់ឱវាទ និងការប្រឹក្សាយោបល់នៅដំណាក់កាលផ្សេងៗនៃជីវិតគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាមួយ ដែលតែងតែក្លាយជាចំណុចផ្តោតសំខាន់របស់សហគមន៍សាសនា។ វិធានការនានាដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនិងអំពើហិង្សាក្នុងគ្រួសារ ត្រូវរួមបញ្ចូលការការពារកុមារក្នុងមជ្ឈដ្ឋានគ្រួសារ ជានិច្ច។

ព្រះសង្ឃមានតួនាទីសំខាន់ក្នុងការផ្តល់ការគាំទ្រ និងការណែនាំផ្នែកសីលធម៌ និងស្មារតីដល់ឪពុកម្តាយ និងការជំរុញទំនាក់ទំនងអហិង្សាក្នុងចំណោមសមាជិកគ្រួសារ និងបុគ្គលដែលរងផលប៉ះពាល់ពីអំពើហិង្សា។

*សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា*

- *តើគ្រួសារបានប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះកុមារា កុមារី? តើការបង្រៀនតាម អត្ថបទពុទ្ធោវាទ ជួយជំរុញបទដ្ឋាននៃការប្រព្រឹត្តចំពោះកុមារទាំងនេះ ដោយរបៀបណា?*
- *តើអ្វីខ្លះជាការទទួលខុសត្រូវផ្នែកសីលធម៌ និងស្មារតីចំពោះកុមារក្នុងសហគមន៍?*
- *តើមានការគាំទ្រ និងធនធានស្ដីពី ការចិញ្ចឹមកូនបែបវិជ្ជមានអ្វីខ្លះសម្រាប់ឪពុកម្ដាយ?*

*វិធានការ*

- *សហការជាមួយអ្នកមានគុណវុឌ្ឍិដើម្បីផ្ដល់បទដ្ឋានខ្ពស់បំផុតនៃការគាំទ្រ និងការណែនាំផ្នែកស្មារតី និងចិត្តសាស្ត្រសម្រាប់កុមារ ដែលរងគ្រោះពីអំពើហិង្សា។*
- *បង្កើតក្រុមគាំទ្រសម្រាប់ឪពុកម្ដាយ ជាក្រុមដែលពួកគេអាចចែករំលែកពីបញ្ហាប្រឈម និងសមិទ្ធផលនានា និងជួយគ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហាដោយអហិង្សា។*
- *ជំរុញឱ្យមានទម្រង់នៃការចិញ្ចឹមកូនបែបអហិង្សា និងវិជ្ជមាន និងការអប់រំពីដំណោះស្រាយជម្លោះសម្រាប់អ្នកដែលនឹងក្លាយជាឪពុកម្ដាយ។*
- *ចូលរួមក្នុងអន្តរសាសនា និងកិច្ចខិតខំប្រឹងប្រែងផ្សេងទៀត របស់សហគមន៍ទូទៅក្នុងការរៀបចំព្រឹត្តិការណ៍ពិសេសៗ ដូចជា ទិវាសកម្មភាពសាសនាដើម្បីកុមារដើម្បីជាការគោរពដល់ជនរងគ្រោះនៃអំពើហិង្សា។*

*៥.១.១១- អ្នកកៀរគរសហគមន៍*

*ព្រះសង្ឃតែងតែមានករណីកិច្ចពលរដ្ឋ និងការទទួលខុសត្រូវលើការដឹកនាំក្នុងសហគមន៍ ដែលធ្វើឱ្យព្រះអង្គមានឥទ្ធិពល និងអាចសហការជាមួយអង្គការសិទ្ធិមនុស្ស និងបុគ្គលផ្សេងទៀតដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ។ ក្រៅពីនេះ ព្រះសង្ឃអាចចូលរួមក្នុងការទប់ស្កាត់អំពើហិង្សាតាមរយៈការតស៊ូមតិឱ្យមានការកែប្រែគោល*

នយោបាយ សង្គម និងច្បាប់ និងសហការជាមួយសហគមន៍ និង គ្រួសារដើម្បីប្រឈមនឹងឥរិយាបថ និងអាកប្បកិរិយាគ្មានការការពារចំពោះកុមារ និងជំរុញឱ្យមានការគោរពសិទ្ធិកុមារ។ លើសពីនេះ ព្រះសង្ឃជាច្រើនបានផ្តល់សេវាដោយផ្ទាល់ដល់កុមារ និងគ្រួសារដែលមានតម្រូវការ ដោយសហការជាមួយទីភ្នាក់ងារផ្តល់សេវារដ្ឋាភិបាល។

## សំណួរសម្រាប់ការឆ្លុះបញ្ចាំង និងពិភាក្សា

- តើមានការយល់ដឹងអ្វីខ្លះស្តីពីលក្ខណៈ និងវិសាលភាពនៃអំពើហិង្សាលើកុមារក្នុងសហគមន៍?
- តើច្បាប់ក្នុងប្រទេស ទំនៀមទម្លាប់ គុណតម្លៃសាសនា និងប្រពៃណីជះឥទ្ធិពលលើការការពារកុមារក្នុងគ្រប់មជ្ឈដ្ឋានសហគមន៍ទាំងអស់ដោយរបៀបណា?
- កុមារពិការងាយរងគ្រោះខ្លាំងទៅនិងអំពើហិង្សា។ តើសហគមន៍មានឥរិយាបថ និងគុណតម្លៃអ្វីខ្លះចំពោះកុមារពិការ? តើព្រះសង្ឃអាចចូលរួមអ្វីខ្លះ ដើម្បីជួយដល់កុមារទាំងនោះ ដើម្បីចៀសផុតពីការរើសអើង និងការទុកឱ្យនៅដាច់ដោយឡែកមិនរវល់ ឬដាក់ចោលតាមមណ្ឌលនានា?
- តើអ្វីខ្លះជាតម្រូវការអាទិភាពមួយចំនួនរបស់កុមារក្នុងសហគមន៍ និងអ្នកដែលកំពុងព្យាយាមដោះស្រាយតម្រូវការទាំងនោះ?

## វិធានការ

- បង្កើនការយល់ដឹងពីអំពើហិង្សាលើកុមារ ដោយអប់រំសហគមន៍ស្តីពីទម្រង់នៃអំពើហិង្សា ផលវិបាកនៃអំពើហិង្សាលើកុមារ និងសិទ្ធិដែលកុមារមាន។
- បង្កើតទំនាក់ទំនងជាមួយសហគមន៍តាមរយៈបណ្តាញមានស្រាប់ អង្គការ និងក្រុមសាសនា។ បង្កើត ឬចូលរួមក្នុងក្រុមសកម្មភាពដើម្បីកំណត់រក និងលើកឡើងពីហានិភ័យចំពោះកុមារក្នុងសហគមន៍មូលដ្ឋាន និងបង្កើតផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហានោះ។

- *ចុះតាមអង្គការសហគមន៍ និងលើកឡើងពីការសិក្សាពីអំពើហិង្សា និងវិធានការចាំបាច់ដើម្បីឆ្លើយតប និងទប់ស្កាត់អំពើហិង្សាលើកុមារ។ ពន្យល់ពីវិធីនានា ដែលអាចឱ្យប្រជាជនគ្រប់រូបចូលរួមចំណែកបាន។*
- *គ្រោងព្រឹត្តិការណ៍សហគមន៍ ដើម្បីប្រមូលផ្តុំប្រជាជន និងបង្កើតភាពជាដៃគូសម្រាប់កិច្ចសហការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើហិង្សាលើកុមារ។ ផ្អែកលើលក្ខណៈនៃព្រឹត្តិការណ៍ គេអាចប្រារព្ធព្រឹត្តិការណ៍នេះ នៅកន្លែងប្រតិបត្តិសាសនា ឬទីកន្លែងធម្មតាមួយ។ ជំរុញឱ្យកុមារ និងក្មេងជំទង់ចូលរួមក្នុងសកម្មភាពទាំងនេះ។*

**៥.២- សន្ទេបមេរៀន**

*ដើម្បីឆ្លើយតបនិងបញ្ហាសង្គម ជាពិសេសការប្រើប្រាស់អំពើហិង្សាលើកុមារ ដែលកំពុងតែកើតមានក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ត្រូវដើរតួនាទីសំខាន់ណាស់ ក្នុងការស្វែងយល់ សិក្សា អង្កេតពិនិត្យឱ្យបានស៊ីជម្រៅ ពល់ទ្រឹស្តីទាំងក្នុងពុទ្ធសាសនា ក៏ដូចជាលទ្ធផលនៃការស្រាវជ្រាវជាក់លាក់នានា ហើយរៀបចំផែនការដើម្បីជួយសង្គមជាតិយើង ជាពិសេសតាមសហគមន៍ ដែលជាចំណុះជើងវត្តនីមួយៗ មិនថាទីប្រជុំជន និងតាមទីជនបទនានានោះឡើយ។ ដោយសារបញ្ហាអំពើហិង្សាជារឿងសង្គមជំទូលាយ ត្រូវទាមទារឱ្យមានកិច្ចសហការពីក្រសួងសំខាន់ៗដូចជា មានក្រសួងធម្មការ និងសាសនា និងក្រសួងពាក់ព័ន្ធ នានាដទៃទៀត។ ក្រៅពីក្រសួងក៏នៅមានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការយូនីសេហ្វជាដើម។*

*ការអប់រំព្រះសង្ឃពុទ្ធសាសនិកឱ្យយល់ដឹងអំពីទ្រឹស្តី នៃអំពើហិង្សាលើកុមារគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ សំខាន់គឺត្រូវបង្កើតប្រព័ន្ធអប់រំផ្សព្វផ្សាយឱ្យទ្រឹស្តីទាំងនេះចូលទៅដល់សហគមន៍តាមរយៈកត្តាមួយចំនួនដូចជា ភាពជាគំរូ កម្មវិធីមិត្តអប់រំមិត្ត វត្តអារាម និងសហគមន៍ សិក្ខាសាលា និងកម្មវិធីធម្មទេសនាតាមកម្មវិធី បុណ្យសាសនា ឬក៏អប់រំផ្សព្វផ្សាយតាមវិទ្យុជាដើម។*

ម្យ៉ាងវិញទៀត ដើម្បីសម្របសម្រួលឱ្យការផ្សព្វផ្សាយអប់រំ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិយើង អ្នកអប់រំផ្សព្វផ្សាយ ឬក៏អាណាព្យាបាលត្រូវទទួលបានការអប់រំអំពីចិត្តវិទ្យាកុមារ ពោលគឺត្រូវសិក្សាអំពីតម្រូវការកុមារតាមភេទ និងវ័យរបស់កុមារ។ ជាងនេះទៅទៀត វាការសំខាន់ ដែលត្រូវស្វែងយល់អំពីជំនឿមិនមានហេតុផល ឬទម្លាប់មិនល្អមួយចំនួនរបស់អាណាព្យាបាលតាមសហគមន៍ ចំណុះជើងវត្តដែលធ្លាប់តែប្រើប្រាស់នូវជំនឿ និងទម្លាប់មិនល្អទាំងនោះក្នុងការចិញ្ចឹមបីបាច់ថែរក្សាកុមារ ដើម្បីកុំអោយប្រការទាំងនោះក្លាយជាទម្លាប់នៃការប្រើប្រាស់អំពើហិង្សាលើកុមារទាំងមិនដឹងខ្លួន។ តាមការស្រាវជ្រាវរបស់ក្រុមអ្នកចិត្តវិទ្យា ការចិញ្ចឹមកូនតាមបែបជំនឿមិនមានហេតុផល ឬតាមទម្លាប់បុរាណ នាំមកនូវគុណវិបត្តិជាច្រើនដល់កុមារដូចជា ពោគសញ្ញា និងទំនាក់ទំនងអាកប្បកិរិយាមិនល្អ និងនាំឱ្យមានការប៉ះទង្គិចផ្លូវចិត្តដល់កុមារទៀតផង។

ការប៉ះទង្គិចដល់ផ្លូវចិត្តរបស់កុមារ គឺជាកត្តាមួយមិនល្អឡើយ ព្រោះបើកុមារកាន់តែរស់នៅក្នុងសភាពបែបនេះ វានឹងក្លាយជាបច្ច័យមិនល្អសម្រាប់អនាគតរបស់ពួកគេ។

**៥.៣- សំណួររំឭក**

១. តើពិធីសាស្ត្រអ្វីខ្លះដើម្បីផ្សព្វផ្សាយអប់រំឱ្យមានប្រសិទ្ធភាព សម្រាប់ការកាត់បន្ថយ អំពើហិង្សាលើកុមារ ក្នុងសហគមន៍ចំណុះជើងវត្តរបស់ព្រះសង្ឃ?

២. សូមឱ្យឧទាហរណ៍ពីទង្វើបែបហិង្សាលើកុមារមួយចំនួនដែលគួចៀសវាង។

៣. តើវត្តអារាម និងសហគមន៍ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

៤. ហេតុអ្វីបានជាវត្តដែលមានបើកសាលាគួររៀបចំប្រជុំជាមួយមាតាបិតាសិស្សឱ្យបានទៀងទាត់?

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
៣. ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងអំពី ធ្វើអាជីវកម្មផ្លូវភេទ
៤. ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាស្តីពីយុត្តិធម៌អនីតិជន
៥. ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា
៦. ក្រសួងយុត្តិធម៌ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១៖ គន្ថីទី១-ទី៣ (២០០៩)
៧. ឆយ អូន, ឥន យឿន, ង៉ួន យ៉ាណា, អ៊ិត មល្លិកា ៧ និង សៀន វិសាល សទ្ទានុក្រមពាក្យច្បាប់ International Standard Books (២០១២)
៨. ក្រសួងអប់រំយុវជន និង កីឡា, ចិត្តវិទ្យា ,១៩៩៨
៩. ងិន ភេន, គាថាធម្មបទ បីភាសា ខ្មែរ អង់គ្លេស បារាំង ,២៥៥៦២០១២/
១០. ជួន ណាត, វចនានុក្រម, ពុទ្ធសាសនបណ្ឌិត្យ
១១. សូរ-ហាយ,ពុទ្ធសាសនា២៥០០ (ពុទ្ធសាសនបណ្ឌិត្យ)
១២. សុត្តន្តបិដកលេខ៤១, កាលាមសូត្រ, ទំព័រ២១៨
១៣. អង្គការអាដហុក,ស្ថានភាពអំពើហិង្សាលើស្ត្រី និងកុមារ ឆ្នាំ២០១១, បោះពុម្ព២០១២
១៤. អៀប សឺង,សមគ្គបញ្ញា, ពុទ្ធសាសនបណ្ឌិត្យ ២៥៤៦/ ២០០៣
១៥. ក្រសួងធម្មការ និងសាសនា, វគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ដល់ក្រុមការងារអភិវឌ្ឍន៍មេរៀនសម្រាប់ពុទ្ធិកសិក្សា, ថ្ងៃទីដល់ ៧ ខែសីហា ឆ្នាំ ២០១៥
១៦. ឡាយ សុក្ខណាក់, ចិត្តវិទ្យាកុមារ, ២០១២

១៧ . ក្រុមប្រឹក្សាជាតិកម្ពុជាដេម្បីកុមារ និង យូនីសេហ្វ, កម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនិងការការពារកុមារ, ២០១២

១៨. ក្រសួងកិច្ចការនារី និងក្រសួងនានា, របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារ ក្នុងប្រទេសកម្ពុជា ឆ្នាំ ២០១៣, ខែតុលា ឆ្នាំ ២០១៤

១៩. ក្រសួងកិច្ចការនារី និងក្រសួងនានា, បន្ទុកសេដ្ឋកិច្ច ចំពោះផលវិបាកផ្នែកសុខភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា, ខែតុលា ឆ្នាំ២០១៥

២០. Erlanger A Turner, Early Childhood Trauma: How Parents Can Help, September 11, 2015

២១. UNICEF New York, Partnering with religious communities for children, 2012

២២. Dr. Sri Dhammananda, The Buddhist Way ISBN Buddhist Missionary Society Malaysia, st January, .1989

២៣. Bukkyo Dendokyokai, The Teaching of Buddha, Printed by Kosaido Printing Co,. ltd. Tokyo, Japan.

២៤. :២ប្រភពពីអាំងទែណែត https://www.psychologytoday.com/blog/the-race-good-health//201309early-childhood-trauma-how-parents-can-help



អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ